ឯកសារព័ត៌មាន

ផ្សាយនៅលើគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម

របស់អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
APSARA

ឆ្នាំ ២០២២ ប្រចាំឆមាសទី២



ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
០៦៣ ៧៦៥ ៥៧៧ ០៦៣ ៧៦៥ ៥៧៦
info@apsaraauthority.gov.kh apsaraautorite
www.apsaraauthority.gov.kh apsara authority

មាតិកា

ប្រចាំខែកក្កដា

- អាជ្ញាធរជាតិអប្សរាកំពុងជួសជុលព្រះវិហារនៅវត្តប្រាសាទលលៃ ១
- អាជ្ញាធរជាតិអប្សរាគ្រោងបញ្ចប់ការជួសជុលព្រះពុទ្ធបដិមានៅរូតបាកាណឆាប់ៗនេះ ២
- ឆមាសទី១ ឆ្នាំ២០២២ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន៦៨៣សំណើ ៣
- សូមរីករាយថ្ងៃចុងសប្ដាហ៍ ទេសភាពនៃប្រាសាទបាគង ៤
- នាព្រឹកថ្ងៃទី ២ ខែកក្កដា ឆ្នាំ២០២២ ម៉ោង១១ព្រឹក ភ្នាក់ងារទេសចរណ៍ ភ្នាក់ងារសណ្ដាប់ធ្នាប់ នគរបាលការពារបេតិកភណ្ឌ បានប្រគល់កាបូបលុយ ជូនទៅភ្ញៀវទេសចរវិញបន្ទាប់ពីបានរកឃើញនៅប្រាសាទបាយ័ន ៥
- ពេលរសៀលថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២២ ភ្នាក់ងារទេសចរណ៍ ភ្នាក់ងារសណ្ដាប់ធ្នាប់ រួមជាមួយនគរបាលការពារបេតិកភណ្ឌ បានប្រគល់កាបូបលុយ និងទូរសព្ទចំនួនពីរគ្រឿង ជូនម្ចាស់ដែលបានភ្លេចនៅប្រាសាទក្នុងពេលដែលពួកគាត់មកទស្សនារមណីយដ្ឋានអង្គរ ៦
- អរុណសួស្ដី ថ្ងៃអាទិត្យសូមអញ្ជើញទស្សនាទិដ្ឋភាពថ្ងៃរះនៅប្រាសាទអង្គរវត្ត ៧
- គម្រោងជួសជុលកំពង់ទឹករបស់ស្ពានហាលនៃប្រាសាទអង្គរវត្តសម្រេចបានប្រមាណ៧៥ភាគរយហើយ ៨
- សេចក្ដីជូនដំណឹង ស្ដីពីការកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ ៩
- អាជ្ញាធរជាតិអប្សរាធ្វើការជួសជុលប៉មឥដ្ឋទី១៥ ប្រាសាទប្រែរូប ១០
- កូនឈើចម្រុះចំនួន៦,៣៥០ដើមទៀតត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយដល់សាធារណជន ១១
- ព្រះពុទ្ធបាទពីថ្មភក់ចំនួន១ និងពុទ្ធបដិមាសម័យកណ្ដាលចំនួន៦ កំពុងតាំងបង្ហាញនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ក្រោយពីជួសជុលរួចរាល់ ១២
- សាររំលែកទុក្ខ ១៣
- កុដិឈើពីរខ្នងវ័យចំណាស់នៅវត្តព្រះព្រហ្មរ័ត្នប្រែប្រួលសោភ័ណភាពដ៏ស្រស់ត្រកាលក្រោយបញ្ចប់ការជួសជុល ១៤
- អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់ចំនួន៣ដើមនៅខ្លោងទ្វារជ័យ ១៥
- កំពង់ទឹករបស់ស្ពានហាលនៃស្រះស្រង់បានបញ្ចប់ការជួសជុល ១៦
- អគ្គនាយកអាជ្ញាធរជាតិអប្សរា ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តម ស៊ីនហ្សូ អាបេ នៅស្ថានកុងស៊ុលជប៉ុនប្រចាំខេត្តសៀមរាប ១៧
- កូនឈើចម្រុះចំនួន៨,០០០ដើមទៀតត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយដល់សាធារណជន ១៨
- គម្រោងជួសជុលច្រាំងកសិន្ធុអង្គរវត្តខាងលិច ប៉ែកខាងត្បូងនៃស្ពានហាលជំហានទី២គ្រោងបញ្ចប់ឆាប់ៗនេះ ១៩
- អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន ជូនប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរចំនួន១៥២២គ្រួសារ ២០
- អាជ្ញាធរជាតិអប្សរាបញ្ចប់ការជួសជុលខ្លោងទ្វារខាងលិចប្រាសាទចៅស្រីវិបុល ២១
- សូមអញ្ជើញទស្សនាទេសភាពប្រាសាទព្រះខ័ន ២២
- អាជ្ញាធរជាតិអប្សរា មានសេចក្ដីសោមនស្សរីករាយ សូមគោរពអញ្ជើញឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី បុគ្គលិកគ្រប់ស្ថាប័ន អ្នកស្រាវជ្រាវ សិស្សានុសិស្ស ព្រមទាំងសាធារណជនទាំងអស់ ចូលរួមសិក្សា ស្ដាប់បាឋកថាស្ដីពី«ព្រះពុទ្ធសាសនា និងវិស័យវេជ្ជសាស្ត្របុរាណ» ដើម្បីស្វែងរកប្រយោជន៍ក្នុងការបង្កើនចំណេះដឹងដោយមេត្រីភាព ២៣
- អាជ្ញាធរជាតិអប្សរាចាប់ផ្ដើមជួសជុលសាលាឆាន់បុរាណ(ផ្នែកតួអគារ)នៅវត្តរាជបូណ៌ ២៤

- លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរាចូលរួមប្រជុំស្តីពីការបូកសរុបការងារ និងទិសដៅការងាររបស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ នៅទីក្រុងប៉ារីស ២៥
- សកម្មភាពក្រុមការងារសម្អាតស្មៅនិងកូនរុក្ខជាតិតូចៗនៅប្រាសាទព្រះខ័ន ២៦
- លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា ចូលរួមវេទិកាថ្ងៃនៃបណ្តាញក្រុមប្រឹក្សាផ្នែកកិច្ចសហប្រតិបត្តិការនិងសកម្មភាពវប្បធម៌........ ២៧
- សកម្មភាពក្រុមការងារផ្នែកអនាម័យ នៃអាជ្ញាធរជាតិអប្សរាសម្អាតបរិស្ថានតាមដងផ្លូវ និងប្រាសាទក្នុងរមណីយដ្ឋានអង្គ........ ២៨
- ក្រុមការងារផ្នែកអនាម័យ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរាបន្តការងារប្រចាំថ្ងៃ ដើម្បីសម្រស់ឧទ្យានអង្គរ ២៩
- កូនឈើចម្រុះចំនួនជិត៧ពាន់ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយដល់សាធារណជន........ ៣០
- អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការG.A.C.Pប្រទេសអាល្លឺម៉ង់ ធ្វើការជួសជុលក្បាច់ចម្លាក់កំបោរបាយអរ និងថ្មភក់តាមជញ្ជាំងតួប៉មផដ្ឋទី៨របស់ប្រាសាទបាគងដែលកំពុងទទួលរងការខូចខាត........ ៣១
- រាជរដ្ឋាភិបាលចេញសេចក្តីសម្រេចស្តីពី ការតែងតាំងសមាសភាពក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ក្រោមការដឹកនាំដោយ ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងមានសមាសភាពចូលរួមមកពី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរជាតិអប្សរា........ ៣២
- សវនករស្ម័គ្រចិត្តជានាគុណភាពជប៉ុនធ្វើសវនកម្មផ្ទៃក្រៅ តាមជានការងារបរិស្ថាន-អង្គរ........ ៣៣
- ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការសាងសង់សំណង់នៅក្នុងរមណីយដ្ឋានអង្គរ........ ៣៤
- រីករាយថ្ងៃចុងសប្តាហ៍សូមអញ្ជើញទស្សនាសម្រស់ប្រាសាទបន្ទាយក្តី........ ៣៥
- ក្រុមភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរា បានជួយសង្គ្រោះបឋមដល់ភ្ញៀវជនជាតិអូស្ត្រាលីម្នាក់ មានអាការហត់ដោយជំងឺប្រចាំកាយ ៣៦
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរានាំយកអំណោយប្រគល់ជូន លោក ង៉ិន គឹមឡេង ភ្នាក់ងារព័ត៌មានទូរទស្សន៍ BTV ដែលមានជំងឺប្រចាំកាយ........ ៣៧
- សកម្មភាពក្រុមការងារផ្នែកអនាម័យ នៃអាជ្ញាធរជាតិអប្សរា សម្អាតបរិស្ថានតាមដងផ្លូវ និងប្រាសាទក្នុងរមណីយដ្ឋានអង្គរ........ ៣៨

ប្រចាំខែសីហា

- គម្រោងជួសជុលប្រាំងកសិន្ទខាងជើង មុខប្រាសាទអង្គរវត្ត ប្រវែងចំនួន២០ម៉ែត្រ បន្ថែមទៀត គ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២២ខាងមុខ........ ៤១
- ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា សូមសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹង ចំពោះការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ មាត្រា១៩ថ្មី (មួយ) មាត្រា៨៩ថ្មី មាត្រា១២០ថ្មី មាត្រា១១៩ថ្មី(មួយ) មាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៤ថ្មី នៃច្បាប់រដ្ឋធម្មនុញ្ញបន្ថែម ដែលរដ្ឋសភាជាតិ បានអនុម័តកាលពីព្រឹកថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២........ ៤២
- អាជ្ញាធរជាតិអប្សរារៀបចំសិក្ខាសាលាស្តីពីការគ្រប់គ្រងដីតំបន់១ និងតំបន់២ ពង្រឹងចំណេះដឹងដល់មន្ត្រី និងបុគ្គលិក........ ៤៣
- អាជ្ញាធរជាតិអប្សរាផ្ញើសារជូនពរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នាឱកាសខួបកំណើតគម្រប់៧០ឆ្នាំ ឈានចូល៧១ឆ្នាំ ៤៤
- រដ្ឋមន្ត្រីការបរទេសឥណ្ឌាទស្សនាប្រាសាទតាព្រហ្ម ៤៥
- អាជ្ញាធរជាតិអប្សរា កំពុងមមាញឹកក្នុងការងារដាំស្មៅនៅបរិវេណខាងមុខ ឆៀងត្បូងប្រាសាទអង្គរវត្ត........ ៤៦

- ដំណើរទស្សនកិច្ចរដ្ឋមន្ត្រីការបរទេសឥណ្ឌានៅរមណីយដ្ឋានអង្គរ ៤៧
- ខែកក្កដា ឆ្នាំ២០២២ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា
បានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន១៨៩សំណើ ៤៨
- ភរិយា និងស្វាមី គណៈប្រតិភូ នៃបណ្តារដ្ឋមន្ត្រីការបរទេសអាស៊ានបានទស្សនាតំបន់រមណីយដ្ឋានអង្គរ ៤៩
- ទេសភាពស្រស់បំព្រងនៃប្រាសាទបាលិលេយ្យនារដូវវស្សា ៥០
- សម្រស់ប្រាសាទតាព្រហ្មក្រោយពេលភ្លៀងធ្លាក់ ៥១
- សេចក្តីជូនដំណឹង ស្តីពីការដកហូតដើមឈើមានហានិភ័យខ្ពស់
នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ ៥២
- អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន
ជូនប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរចំនួន៨៦០គ្រួសារ ៥៣
- កូនឈើចម្រុះចំនួន៩,៥២០ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយដល់សាធារណជន ៥៤
- អាជ្ញាធរជាតិអប្សរា និងប្រទេសញ៉ូវហ្ស៊ីលែនកំពុងសិក្សាបន្តគម្រោងសហប្រតិបត្តិការដំណាក់កាលថ្មីបន្ត ៥៥
- រីករាយថ្ងៃចុងសប្តាហ៍ ប្រាសាទព្រះគោ ៖ សំណង់ឥដ្ឋដ៏ប្រណីតដើមសម័យអង្គរ ៥៦
- ប្រាសាទចៅសាយទេវតាបូជនីយដ្ឋានតូចច្រឡឹង ដែលមានចម្លាក់ក្បូរក្បាច់ល្អវិចិត្ត ៥៧
- ក្រុមការងារតម្រង់ទិស ប្រកាសបើកយុទ្ធនាការចុះវាស់វែង កំណត់និយាមកាក្បាលដី
និងអត្តសញ្ញាណអ្នកកាន់កាប់ក្បាលដី និងសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ
និងតំបន់ដទៃទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ៥៨
- សេចក្តីប្រកាសព័ត៌មាន ស្តីពីខ្លឹមសារនៃការបើកយុទ្ធនាការចុះវាស់វែង កំណត់និយាមកាក្បាលដី
និងអត្តសញ្ញាណអ្នកកាន់កាប់ក្បាលដី និងសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត
ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ៥៩
- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា ដឹកនាំក្រុមការងារចុះពិនិត្យមើលការវាស់វែង
និងកំណត់អត្តសញ្ញាណដីធ្លីក្នុងរមណីយដ្ឋានអង្គរ ៦០
- សកម្មភាព ក្រុមការងារចុះវាស់វែងនិងកំណត់អត្តសញ្ញាណដីធ្លីក្នុងសង្កាត់ទឹកវិល ក្រុងសៀមរាប ៦១
- ក្រុមការងារបច្ចេកទេសរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់
កំពុងបន្តចុះពិនិត្យ វាស់វែង កំណត់និយាមកានិងអត្តសញ្ញាណកម្មក្បាលដី ៦២
- រីករាយចុងសប្តាហ៍ ប្រាសាទមេបុណ្យខាងកើតអតីតអារាមហិណ្ឌូសាសនាសង់ក្នុងបារាយណ៍ដ៏ធំ
នៅសតវត្សរ៍ទី១០ .... ៦៣
- សម្រស់ប្រាសាទបាយ័នក្រោមដំណក់ទឹកភ្លៀង ៦៤
- សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងរៀបចំដែនដី នគរូបណីយកម្ម និងសំណង់ស្តីពី លទ្ធផលនៃយុទ្ធនាការ
ចុះវាស់វែង កំណត់និយាមកាក្បាលដី និងអត្តសញ្ញាណអ្នកកាន់កាប់ក្បាលដី និងសំណង់ខុសច្បាប់ក្នុង
តំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៣ សីហា ឆ្នាំ២០២២ .... ៦៥
- ការងារសម្អាតតាមដងផ្លូវនៅក្នុងរមណីយដ្ឋានអង្គរ ៦៦
- ប្រាសាទនាគព័ន្ធ សាងសង់ក្នុងបារាយណ៍ដ៏ធំនៅចុងសតវត្សរ៍ទី១២ .... ៦៧
- សេចក្តីជូនដំណឹង ស្តីពីការដកហូតដើមឈើ និងកាត់ក្រីមែកឈើ មានហានិភ័យខ្ពស់
នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ ៦៨

ប្រចាំខែកញ្ញា

- ក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា បើកកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពនៃការដោះស្រាយផលប៉ះពាល់ដីធ្លី និងសំណង់នៅក្នុងតំបន់ឧទ្យានអង្គរ......៧១
- រីករាយថ្ងៃចុងសប្តាហ៍ទេសភាពស្រស់ត្រកាលប្រាសាទភ្នំបូក ដែលភ្ញៀវទេសចរមិនគួរមើលរំលង......៧២
- ប្រាសាទបាក្ងួនសំណង់ប្រាសាទដ៏អស្ចារ្យ កសាងនៅដើមសតវត្សរ៍ទី១១ ក្នុងក្រុងអង្គរធំ......៧៣
- លិខិតរំលែកមរណទុក្ខ របស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករទាំងអស់នៃអាជ្ញាធរជាតិអប្សរា គោរពជូនលោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាព មហាឧបាសិកា ញឹម តេង ដែលបានទទួលមរណភាពកាលពីថ្ងៃអាទិត្យ ៩កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ១៣:៤០ នាទី ក្នុងជន្មាយុ ៩៤ ឆ្នាំ ដោយរោគាពាធ......៧៤
- ក្រុមការងារព្រៃឈើ បានកាត់ក្រើសម្អាតមែកដើមចាន់ដែលបាក់នៅចំនុចរោងទងខាងត្បូង ប្រាសាទតាព្រហ្ម......៧៥
- លោកជំទាវបណ្ឌិតសភាចារ្យ គឿង សកុណា អញ្ជើញចូលរួមពិធីប្រកាសតែងតាំងប្រធាន និងអនុប្រធាននាយកដ្ឋាននៃអាជ្ញាធរជាតិអប្សរា......៧៦
- លោកជំទាវបណ្ឌិតសភាចារ្យ គឿង សកុណាអញ្ជើញចុះពិនិត្យការងាររៀបចំដីឡូត៍ នៅភូមិធម្មជាតិរុនតាឯក......៧៧
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំកម្មវិធីពិសាអាហារពេលល្ងាចក្នុងឱកាសសន្និសីទអន្តរជាតិស្តីពី ការការពារនិងការទប់ស្កាត់ការចរាចរជួញដូរសម្បត្តិវប្បធម៌ខុសច្បាប់ «ទស្សនៈពីអាស៊ាន»......៧៨
- អាជ្ញាធរជាតិអប្សរា ពិភាក្សាការងារជាមួយភាគីអាមេរិកដើម្បីបង្កើនកិច្ចសហប្រតិបត្តិការបន្ថែមទៀតនាថ្ងៃអនាគត......៧៩
- ព្រះវិហារបុរាណនៅវត្តប្រាសាទលលៃប្រែប្រួលសោភ័ណភាពដ៏ស្រស់ត្រកាលក្រោយបញ្ចប់ការជួសជុល......៨០
- ប្រាសាទបក្សីចាំក្រុង កសាងនៅពាក់កណ្ដាលសតវត្សរ៍ទី១០កន្លែងសម្រាប់ទេសចរដែលត្រូវការភាពស្ងប់ស្ងាត់......៨១
- អនុមោទនាពិធីបុណ្យភ្ជុំបិណ្ឌ-បិណ្ឌ១ ទេសភាពស្រស់បំព្រង នៃប្រាសាទលលៃ សំណង់ឥដ្ឋសាងសង់នៅចុងសតវត្សរ៍ទី៩......៨២
- ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាអមដំណើរ ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ចុះពិនិត្យមើលសកម្មភាពពលរដ្ឋភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ចាប់ឆ្នោតក្បាលដីឡូត៍នៅភូមិធម្មជាតិរុនតាឯក ដែលពិធីនេះធ្វើឡើងនៅបរិវេណរដ្ឋបាលខេត្តសៀមរាប នាព្រឹកថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២......៨៣
- ប្រជាពលរដ្ឋរស់នៅភូមិធម្មជាតិរុនតាឯកមានជីវភាពធូរជារ......៨៤
- អាជ្ញាធរជាតិអប្សរា និងស្ថានទូតបារាំងពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ......៨៥
- រដ្ឋមន្ត្រីពាណិជ្ជកម្ម និងនីហារណែនៃប្រទេសញ៉ូវហ្សីលែន បំពេញទស្សនកិច្ចលើគម្រោងសហប្រតិបត្តិការក្នុងតំបន់អង្គរ......៨៦
- រីករាយថ្ងៃចុងសប្តាហ៍ ប្រាសាទបី កសាងនៅសតវត្សរ៍ទី១០ ស្ថិតក្បែរកសិន្ធុក្រុងអង្គរធំផ្នែកខាងត្បូង ដែលទេសចរមិនសូវបានស្គាល់......៨៧
- ប្រាសាទក្រវ៉ាន់ សង់នៅដើមសតវត្សរ៍ទី១០ដែលមានចម្លាក់លើជញ្ជាំងឥដ្ឋដ៏ល្អវិចិត្រ......៨៨
- អាជ្ញាធរជាតិអប្សរារៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយវិស័យឯកជននិងស្ថាប័នពាក់ព័ន្ធ ស្តីពីការដាក់ឱ្យដំណើរការខ្សែទស្សនាចរណ៍ក្នុងបារាយណ៍ជយតដាកដោយជិះទូក និងកង់......៨៩
- ភ្នាក់ងារទេសចរណ៍បានចូលរួមសហការជាមួយកម្លាំងនគរបាលទេសចរណ៍ និងភ្នាក់ងារសណ្ដាប់ធ្នាប់ ប្រគល់សម្ភារជូនភ្ញៀវទេសចរ ដែលភ្លេចឬជ្រុះនៅរមណីយដ្ឋានអង្គរ......៩០

- តើបោះបាយបិណ្ឌកិច្ចពិធីសំខាន់ឬយ៉ាងណា?តើខ្មែរអាចធ្វើកិច្ចនេះនៅពេលណាខ្លះ?....................................៩២
- ព្រឹត្តិការណ៍សមរាត្រី Autumnal Equinox នឹងឈានមកដល់នៅថ្ងៃស្អែក ទី២២ ខែកញ្ញាឆ្នាំ២០២២.................៩៤
- លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ នាំយកទេយ្យទានប្រគេន
ព្រះមហាវិមលធម្ម ពិន សែម សិរីសុវណ្ណោ ព្រះរាជាគណៈថ្នាក់ទោ គណៈមហានិកាយ
ព្រះឧត្តមទីប្រឹក្សាគណៈសង្ឃនាយក សមាជិកថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា
និងជាព្រះគ្រូចៅអធិការវត្តរាជបូណ៌ ក្រុងសៀមរាប...៩៥
- អបអរសាទរ ទិវាទេសចរណ៍ពិភពលោក លើកទី៤២ក្រោមប្រធានបទ "ការគិតគូរឡើងវិញពីវិស័យទេសចរណ៍" ...៩៦
- អាជ្ញាធរជាតិអប្សរា ធ្វើកំណាយខឿនតម្កល់លិង្គនៅលើភ្នំបូក
ដើម្បីឈានទៅរកការជួសជុលសំណង់បុរាណនោះឡើងវិញ ៩៧
- អគ្គនាយកអាជ្ញាធរជាតិអប្សរា និងមន្ត្រីជំនាញ បានចុះពិនិត្យស្ថានភាពដី
និងរចនាសម្ព័ន្ធនៅប្រាសាទអង្គរវត្តក្រោយពេលមានភ្លៀងធ្លាក់ខ្លាំង...៩៨
- មន្ត្រីជាន់ខ្ពស់របស់អង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់
បំពេញទស្សនៈកិច្ចនៅក្នុងរមណីយដ្ឋានអង្គរ...៩៩
- សូមអញ្ជើញទស្សនាទិដ្ឋភាពស្រស់ត្រកាល នៃប្រាសាទបេងមាលាក្រោយពេលភ្លៀងធ្លាក់ ១០០
- ទិដ្ឋភាពថ្ងៃរៀបលិចដ៏ស្រស់ស្អាតអមដោយទេសភាពផ្ទៃដីព្រៃលិចទឹកជាច់កន្ទុយភ្នែក
នៃបឹងទន្លេសាបនៅភ្នំក្រោម ១០១
- បុណ្យភ្ជុំបិណ្ឌមានទេសចរជាង៤៣ពាន់នាក់ចូលទស្សនាសួនរុក្ខជាតិអង្គរ ១០២
- ក្រុមការងារអាជ្ញាធរជាតិអប្សរាកំពុងរំដោះទឹកចេញពីប្រាសាទដើម្បីបញ្ចៀសពីការជន់លិច ១០៣
- ដីជ្រោយ ភ្លៀងខ្យល់ខ្លាំង ដើមឈើដួលរលំ សូមមានការប្រុងប្រយ័ត្នខ្ពស់ ១០៤

ប្រចាំខែតុលា

- ប្រាសាទភិមានអាកាស កសាងនៅពាក់កណ្ដាលសតវត្សរ៍ទី១០
ដែលត្រូវចាត់ទុកថាជាទីបូជា នៃព្រះរាជវាំង ក្នុងក្រុងអង្គរធំ...១០៧
- ក្រុមប្រាសាទព្រះពិធូរ មានប្រាសាទផ្សេងៗគ្នាចំនួន៥ ដែលមានប្រាសាទមួយសម្រាប់ព្រះពុទ្ធសាសនា
និងប្រាសាទ៤ផ្សេងទៀតសម្រាប់ព្រហ្មញ្ញសាសនាស្ថិតក្នុងបរិវេណក្រុងអង្គរធំ ១០៨
- ទិដ្ឋភាពដ៏អស្ចារ្យនៅប្រាសាទអង្គរវត្ត នាព្រឹកព្រលឹម ០៣ តុលា ២០២២ ....១០៩
- ក្រុមការងារអាជ្ញាធរជាតិអប្សរា តាមដានជាប្រចាំនៅតាមទ្វារទឹកសំខាន់ៗក្នុងតំបន់រមណីយដ្ឋានអង្គរ...............១១០
- ប្រទះឃើញបំណែកចម្លាក់ក្បាលនាគក្នុងរចនាបថបាយ័ន កប់ក្នុងដីចំនួន១...១១១
- ក្រុមការងារសម្អាតបរិស្ថានបន្តការងារជាប្រចាំដើម្បីសោភ័ណភាពបរិស្ថានក្នុងរមណីយដ្ឋានអង្គរ ១១២
- ក្រុមការងារសណ្ដាប់ធ្នាប់ បន្តការងារយ៉ាងសកម្មដើម្បីរៀបចំ និងសម្រួលការចតយានយន្តរបស់ភ្ញៀវទេសចរ......១១៣
- ខ្លោងទ្វារតាការ នឹងក្លាយទៅជាគោលដៅទេសចរណ៍ថ្មីមួយទៀតបន្ទាប់ពីការជួសជុលរួចរាល់ ១១៤
- សកម្មភាពក្រុមភ្នាក់ងារទេសចរណ៍នៅប្រាសាទអង្គរវត្ត
ចូលរួមជួយបោសសម្អាតដើម្បីអនាម័យល្អនៅកំពូលរួតបាកាណ ១១៦
- ប្រាសាទតាកែវ ស្ថាបត្យកម្មសំណង់បុរាណដ៏ធំ
សាងសង់នៅចុងសតវត្សទី១០ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ ....១១៧
- ប្រាសាទតានៃ បុរាណដ្ឋានកសាងនាចុងស.វ.ទី១២
សម្រាប់ទេសចរ ដែលចូលចិត្តធម្មជាតិ និងដំណើរកម្សាន្តបែបផ្សងព្រេង ១១៨
- អាជ្ញាធរជាតិអប្សរាកំពុងជួសជុលប្រាសាទខ្ទារផ្ទោលស្ថិតនៅក្នុងឃុំស្រែណូយស្រុកវ៉ារិន ខេត្តសៀមរាប.............១១៩
សកម្មភាពក្រុមការងារសម្អាតបរិស្ថានបន្តការងារជាប្រចាំដើម្បីសោភ័ណភាពបរិស្ថានក្នុងរមណីយដ្ឋានអង្គរ........១២០

- ក្រុមភ្នាក់ងារសណ្តាប់ធ្នាប់ នៃនាយកដ្ឋានសណ្តាប់ធ្នាប់ ចូលរួមដីករណ្តៅដើម្បីដាំកូនឈើឡើងវិញ
នៅបរិវេណខាងមុខប្រាសាទភ្នំបាខែង ១២១
- អាជ្ញាធរជាតិអប្សរាគ្រោងបិទផ្ទៃមុខអប្សរាដែលរបេះឡើងវិញពេលអាកាសធាតុអំណោយផល ១២២
- លិខិតអបអរសាទរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលទទួលបានយុត្តិធម៌ និងភាពស្អាតស្អំ
ពីតុលាការយុត្តិធម៌ ទីក្រុងប៉ារីស ប្រទេសបារាំង ក្នុងសំណុំរឿងបរិហាកេរ្តិ៍ ប្តឹងជនជាប់ចោទ សម រង្ស៊ី ១២៣
- ភ្ញៀវទេសចរបង្ហាញអារម្មណ៍សប្បាយរីករាយក្រោយពេលបានឆ្លងកាត់ស្ពានថ្មី
ចូលទស្សនាប្រាសាទនាគព័ន្ធ ១២៥
- អាជ្ញាធរជាតិអប្សរាស្តារកំណកដី សម្អាតស្មៅនៅតាមប្រព័ន្ធរំដោះទឹកនៅមុខបរិវេណប្រាសាទសួរព្រ័ត្រ ១២៦
- អាជ្ញាធរជាតិអប្សរា បន្តស្តារកំណកដី សម្អាតប្រព័ន្ធលូរំដោះទឹកក្នុងបរិវេណប្រាសាទអង្គរវត្ត ១២៧
- ខ្លោងទ្វារខាងកើតនៃអគារព្រះឥសូរក្នុងប្រាសាទព្រះខ័ន
- គ្រោងនឹងបើកឱ្យភ្ញៀវទេសចរឆ្លងកាត់ឡើងវិញក្រោយបញ្ចប់ការងារជួសជុល ១២៨
ទិដ្ឋភាពថ្ងៃរៀបលិចនៅស្រះស្រង់ ទីកន្លែងមួយផ្សេងទៀតក្នុងរមណីយដ្ឋានអង្គរ
ដែលទេសចរអាចផ្តិតយករូបភាពថ្ងៃលិចដ៏ស្រស់ស្អាត ១២៩
- ក្រុមការងារសម្អាតបរិស្ថានយកចិត្តទុកដាក់សម្អាតបរិស្ថានក្នុងរមណីយដ្ឋានអង្គរ ១៣០
- ផ្ទៃមុខអប្សរាដែលរបេះត្រូវបានយកបិទភ្ជាប់ឡើងវិញ ១៣១
- សូមថ្វាយមហាព្រះរាជកុសល ខួបគម្រប់១០ឆ្នាំ នៃការយាងសោយព្រះទិវង្គតរបស់ព្រះករុណា សម្តេចព្រះនរោត្តម
សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ ១៣២
- អាជ្ញាធរជាតិអប្សរាចូលរួមគោរពព្រះវិញ្ញាណក្ខន្ធថ្វាយព្រះរាជកុសលព្រះបរមរតនកោដ្ឋ
គម្រប់ខួបសោយទិវង្គត១០ព្រះវស្សា ១៣៣
- សកម្មភាពក្រុមការងារសម្អាតស្មៅ និងកូនរុក្ខជាតិតូចៗនៅប្រាសាទព្រះខ័ន ១៣៤
- រីករាយចុងសប្តាហ៍ទិដ្ឋភាពដ៏ស្រស់ស្អាតនៅខ្លោងទ្វារដីឆ្នាំង(ខាងជើង)នៃក្រុងអង្គរធំ ១៣៥
- ភ្ញៀវទេសចរបង្ហាញអារម្មណ៍សប្បាយរីករាយក្រោយពេលបានឆ្លងកាត់ស្ពានថ្មី
ចូលទស្សនាប្រាសាទនាគព័ន្ធ ១៣៦
- ក្រុមការងារទប់ស្កាត់ហានិភ័យ នៃអាជ្ញាធរជាតិអប្សរា
កំពុងជួយសង្គ្រោះបន្ទាន់ផ្នែកខ្លះនៃថែវនៅរួតទី១របស់ប្រាសាទអង្គរវត្ត ១៣៨
- សេចក្តីជូនដំណឹង ស្តីពីការផ្អាកការចូលគោរពបូជា
នៅទីសក្ការៈព្រះអង្គចេក និងព្រះអង្គចម នៅខេត្តសៀមរាប ១៣៩
- គម្រោងជួសជុលខ្លោងទ្វារខាងកើតប្រាសាទតាព្រហ្មសម្រេចបាន៣៥ភាគរយហើយ ១៤០
- លិខិតថ្កោលទោស របស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំនៃអាជ្ញាធរជាតិអប្សរា
សូមថ្កោលទោសដាច់អហង្ការ និងប្រឆាំងជាដាច់ខាត ចំពោះសេចក្តីថ្លែងការណ៍របស់ ទណ្ឌិត សម រង្ស៊ី
មេក្រុមឧទ្ទាមក្បត់ជាតិ៣ជំនាន់ ១៤១
- អាជ្ញាធរជាតិអប្សរាជួបពិភាក្សាជាមួយតំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)
ពាក់ព័ន្ធការសិក្សាលទ្ធភាពគម្រោងជួសជុលខឿនរួតបាកាណនៃប្រាសាទអង្គរវត្ត ១៤២
- ភ្ញៀវទេសចរ ចូលមកទស្សនារមណីយដ្ឋានអង្គរចាប់ផ្តើមមានកំណើនឡើងវិញជាបន្តបន្ទាប់ ១៤៣
- ដំណឹងជ្រើសរើសបុគ្គលិក ១៤៤
- ប្រទះឃើញបំណែកព្រះកេសអសុរាមួយ នៅប៉ែកខាងកើតខ្លោងទ្វារទន្លេអុំ ១៤៥
- សិស្សានុសិស្សចំនួន១៨២នាក់ នៃសាលាបឋមសិក្សាក្របីរៀលបានមកទស្សនកិច្ចសិក្សានៅប្រាសាទអង្គរវត្ត ១៤៦
- ផ្ទាំងទស្សនីយភាពដ៏ស្រស់ស្អាត នៃប្រាសាទព្រះខ័ននារដូវបែតងនេះ ១៤៧
- ប្រាសាទបន្ទាយស្រី សំណង់ថ្មភក់ពណ៌ផ្កាឈូកដ៏វិចិត្រដែលទេសចរ
កម្រមើលរំលងការទស្សនាក្នុងបុរាណដ្ឋានមួយនេះ ១៤៨

- ពលរដ្ឋខ្មែរ រស់នៅប្រទេសកាណាដាបរិច្ចាគថវិកាជួយជួសជុលចម្លាក់ទេវតាទាញព្រ័ត្រតួទី៨ នៅខ្លោងទ្វារតាការ..១៤៩
- អាជ្ញាធរជាតិអប្សរា ចាប់ផ្តើមជួសជុលច្រាំងកសិន្ធុអង្គរវត្តប៉ែកខាងត្បូងប្រវែង២៥ម៉ែត្របន្ថែមទៀត..................១៥០
- ញត្តិថ្កោលទោស របស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងផ្ទាំនៃអាជ្ញាធរជាតិអប្សរា សូមធ្វើការ ថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទង្វើរបស់ ទណ្ឌិត សម រង្ស៊ី មេក្រុមឧទ្ទាមក្បត់ជាតិ៣ជំនាន់ ដែលបាន ប្រមាថយ៉ាងធ្ងន់ធ្ងរបំផុតចំពោះអង្គព្រះមហាក្សត្រ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជាជនខ្មែរ ១៥១
- សូមថ្វាយព្រះពរព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដ៏មហាមង្គលថ្ងៃថ្លៃនៃព្រះរាជពិធីបុណ្យខួបលើកទី១៨ នៃការយាងគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះករុណាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត........១៥២
- ភ្នាក់ងារទេសចរណ៍ សហការជាមួយកម្លាំងនគរបាលទេសចរណ៍និងនគរបាលការពារបេតិកភណ្ឌ ប្រគល់ទូរស័ព្ទមួយគ្រឿងម៉ាក Iphone XR ពណ៌ខ្មៅ ដែលភ្ញៀវទេសចរជ្រុះនៅក្នុងរមណីយដ្ឋានអង្គរ ១៥៣
- ច្រាំងកសិន្ធុផ្នែកខាងជើងស្ពានហាល របស់ប្រាសាទអង្គរវត្តប្រវែង២០ម៉ែត្រទៀត នឹងបញ្ចប់ការជួសជុលនៅខែវិច្ឆិកា ឆ្នាំ២០២២ ....១៥៤
- ចម្លាក់តោចំនួន២ នឹងយកទៅដាក់នៅកំពង់ទឹកផ្នែកខាងជើងស្ពានហាល មុខប្រាសាទអង្គរវត្តឡើងវិញ ក្រោយពេលបញ្ចប់ការជួសជុល ១៥៥
- អាជ្ញាធរជាតិអប្សរាទទួលជួបសំណេះសំណាលការងារជាមួយលោកនាយកសាលាបារាំងចុងបូព៌ា (EFEO) នៅទីក្រុងប៉ារីស ប្រទេសបារាំង..១៥៦
- ទិដ្ឋភាពដ៏ស្រស់ស្អាត នៃប្រាសាទតាសោមអមជាមួយធម្មជាតិស្រស់បំព្រង កំពុងរង់ចាំស្វាគមន៍ទេសចរមកកម្សាន្ត..១៥៧
- សកម្មភាពក្រុមភ្នាក់ងារទេសចរណ៍ បន្តចូលរួមជួយសម្អាតកូនរុក្ខជាតិតូចៗដើម្បីបរិស្ថានល្អនៅប្រាសាទបាយ័ន..១៥៨
- ប្រាសាទធម្មនន្ទ បូជនីយដ្ឋានតូចច្រឡឹង កសាងនៅដើមសតវត្សរ៍ទី១២..១៥៩

ប្រចាំខែវិច្ឆិកា

- បន្ទាប់ពីការជួសជុល តួប៉មចំនួន៩ក្នុងចំណោមតួប៉មចំនួន១២នៃប្រាសាទមេបុណ្យខាងលិច បានបង្ហាញខ្លួនជាថ្មី ១៦៣
- ភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទតាព្រហ្ម សហការជាមួយក្រុមការងារវេណ្ឌា ជួសជុលជណ្តើរឈើនៅចំណុចរោងទងទី៣នៃប្រាសាទតាព្រហ្ម..១៦៤
- អ្នកសម្អាតបរិស្ថានស្នើឱ្យភ្ញៀវទេសចរចូលរួមទុកដាក់សំរាមឱ្យបានត្រឹមត្រូវពេលមកលេងប្រាសាទ ១៦៥
- អាជ្ញាធរជាតិអប្សរាទទួលជួបសំណេះសំណាលការងារជាមួយ ឯកអគ្គរដ្ឋទូតអ៊ីស្រាអែល ប្រចាំប្រទេសកម្ពុជា ១៦៦
- សិស្សសាលាបឋមសិក្សាក្របីរៀលចំនួន១៨២នាក់ចុះទស្សនកិច្ចសិក្សានៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ.....១៦៧
- សេចក្តីប្រកាសព័ត៌មាន ១៦៨
- អញ្ជើញទស្សនាទេសភាពស្អាតៗនៅប្រាសាទតាព្រហ្ម នារដូវរំហើយនេះ...១៦៩
- ប្រាសាទបាយ័ន ជាបេះដូងនៃរាជធានីអង្គរធំ ១៧០
- ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ អញ្ជើញមកទស្សនាប្រាសាទអង្គរវត្តថ្ងៃនេះ.......................................១៧១
- ទិដ្ឋភាពភ្ញៀវទេសចរ អញ្ជើញមកទស្សនាប្រាសាទនាគព័ន្ធ... ១៧២
- អបអរសាទរ ខួបលើកទី៦៩ នៃថ្ងៃបុណ្យឯករាជ្យជាតិ ១៧៣
- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា និងឯកឧត្តម លី ខឺឈាង នាយករដ្ឋមន្ត្រីចិន អញ្ជើញជាអធិបតីក្នុងពិធី សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនិងប្រគល់ទទួលគម្រោងជួសជុលប្រាសាទតាកែវ ១៧៤
- សេចក្តីជូនដំណឹង ស្តីពីការកាត់ដកហូតដើមឈើ និងកាត់ក្រមែកឈើមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗក្នុងរមណីយដ្ឋានអង្គរ ១៧៦
- អគ្គនាយកអាជ្ញាធរជាតិអប្សរាទទួលជួបពិភាក្សាការងារជាមួយអគ្គនាយក CACH.. ១៧៧

- ការងារសម្អាតបរិស្ថានក្នុងរមណីយដ្ឋានអង្គរ ១៧៨
- ខ្លោងទ្វារជ័យ ប្រើសម្រាប់ចេញចូលក្រុងអង្គរធំ ដោយព្រះមហាក្សត្រ និងកងទ័ពបន្ទាប់ពីបានទទួលនូវជោគជ័យលើខ្មាំងសត្រូវ ១៧៩
- ប្រាសាទវត្តអធ្វា ទីសក្ការៈបូជា សាងសង់នៅចុងសតវត្សរ៍ទី១២ ក្នុងរចនាបថអង្គរវត្ត ១៨០
- ឯកឧត្តមអនុប្រធានាធិបតីនៃសាធារណៈរដ្ឋឥណ្ឌា និងលោកជំទាវបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អញ្ជើញសម្ពោធសាលរបាំប្រាសាទតាព្រហ្មក្រោយពីបញ្ចប់ការជួសជុល ១៨១
- អាជ្ញាធរជាតិអប្សរា បិតបំពេញបាយអរនៅតាមជង្ហុកនិងចន្លោះថ្មភក់កម្រាលស្ពានហាលមុខប្រាសាទអង្គរវត្ត ១៨២
- អាជ្ញាធរជាតិអប្សរាទទួលជួបសម្តែងការគួរសមជាមួយសាកលវិទ្យាល័យសូហ្វីយ៉ា និងអ្នកជំនាញផ្នែកបេតិកភណ្ឌពីបណ្តាប្រទេសក្នុងតំបន់អាស៊ាន ១៨៣
- អាជ្ញាធរជាតិអប្សរាបិទវគ្គបណ្តុះបណ្តាលស្តីពីការអប់រំបេតិកភណ្ឌ ដល់សិស្សានុសិស្សសាលាបឋមសិក្សាក្របីរៀល ១៨៤
- ព្រះលានស្តេចគម្លង់ ព្រះពន្លាសាងសង់នៅចុងសតវត្សទី១២ ដែលទេសចរអាចមកទស្សនាចម្លាក់ក្បូរក្បាច់ ដ៏អស្ចារ្យជាច្រើន ១៨៥
- ស្រះស្រង់ កន្លែងទេសចរនិយមមកកម្សាន្តស្រូបយកខ្យល់អាកាសបរិសុទ្ធ អមដោយទេសភាពស្រស់បំព្រង ១៨៦
- បាយអ គឺជាសារជាតុសំខាន់មួយ សម្រាប់ការពារមិនឱ្យទឹកជ្រាបចូលគ្រឹះប្រាសាទ និងខូចខាតរចនាសម្ពន្ធសំណង់បុរាណ ១៨៧
- គណៈសង្ឃនាយកនៃព្រះរាណាណាចក្រកម្ពុជា និមន្តមកទស្សនកិច្ចវត្តអារាមព្រះពុទ្ធសាសនានៅក្នុងបរិវេណរមណីយដ្ឋានអង្គរ ១៨៨
- បាយអ គឺជាសារជាតុសំខាន់មួយ សម្រាប់ការពារមិនឱ្យទឹកជ្រាបចូលគ្រឹះប្រាសាទ និងខូចខាតរចនាសម្ពន្ធសំណង់បុរាណ ១៨៩
- ប្រាសាទ ព្រះឥន្ទ្រកោសីយ៍ សំណង់ឥដ្ឋ កសាងនៅចុងសតវត្សរ៍ទី១០ ដែលលាក់ខ្លួនក្នុងទីអារាមយ៉ាងស្ងប់ស្ងាត់ ១៩០
- ប្រាសាទប្រី កសាងនៅចុងសតវត្សទី១២ ដែលទេសចរមិនសូវបានស្គាល់ ១៩១
- សាលាឆាន់បុរាណនៅវត្តរាជបូណ៌បញ្ចប់ការជួសជុលជាស្ថាពរ ១៩២
- អាជ្ញាធរជាតិអប្សរាទទួលជួបសម្តែងការគួរសមជាមួយប្រធានទីភ្នាក់ងារបារាំង សម្រាប់ការអភិវឌ្ឍ ប្រចាំប្រទេសកម្ពុជា ១៩៣
- អាជ្ញាធរជាតិអប្សរាចែកអំណោយសប្បុរសធម៌ដែលជាជំនួយរបស់មូលនិធិចិន សម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ (CFCHC) ជូនសិស្សានុសិស្សក្នុងតំបន់រមណីយដ្ឋានអង្គរ ១៩៤
- អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលស្តីពី ការកសាងសមត្ថភាពភ្នាក់ងារសណ្តាប់ធ្នាប់និងអភិរក្សព្រៃឈើ ក្នុងការប្រើប្រាស់កម្មវិធី Carry Map ១៩៥

ប្រចាំខែធ្នូ

- ខ្លោងទ្វារទន្លេអុំ ជាទីទាក់ទាញអ្នកទេសចរគ្រប់រូប ដែលមិនអាចរំលងបាន ១៩៩
- អាជ្ញាធរជាតិអប្សរាបិទបញ្ចប់កម្មវិធីចែកអំណោយសប្បុរសធម៌ ដែលជាជំនួយរបស់មូលនិធិចិន សម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ (CFCHC) ជូនសិស្សានុសិស្សក្នុងតំបន់រមណីយដ្ឋានអង្គរ ២០០
- អាជ្ញាធរជាតិអប្សរា ធ្វើពិធីបួងសួង ប្រុងពលី បើកការដ្ឋានជួសជុលចម្លាក់សត្វមករ ២០១
- សេចក្តីជូនដំណឹង ស្តីពីការរៀបចំព្រឹត្តិការណ៍ រត់ពាក់កណ្តាលម៉ារ៉ាតុនអន្តរជាតិនៅបរិវេណមុខប្រាសាទអង្គរវត្ត. ២០២
- ទិដ្ឋភាពថ្ងៃបាក់រសៀល នៅប្រាសាទអង្គរវត្តជាទស្សនីយភាពដ៏អស្ចារ្យមួយផ្សេងទៀតនាឧទ្យានអង្គរ........ ២០៣
- ទិដ្ឋភាពខ្លោងទ្វារទន្លេអុំ ច្រកចេញចូលសំខាន់នៃក្រុងអង្គរធំដែលទាក់ចិត្តទេសចរគ្រប់រូប........ ២០៤

- ព្រឹត្តិការណ៍រត់ពាក់កណ្តាលម៉ារ៉ាតុងអន្តរជាតិឆ្នាំ២០២២ លើកទី២៧ប្រព្រឹត្តទៅនៅរមណីយដ្ឋានអង្គរ.............២០៥
- សូមកុំបោះចោលសំរាមនៅតាមដងផ្លូវក្នុងតំបន់រមណីយដ្ឋានអង្គរ ២០៦
- សេចក្តីជូនដំណឹង ស្តីពីការកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើមានហានិភ័យខ្ពស់
  នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ ២០៧
- ព្រឹត្តិការណ៍រំលឹកគុណអង្គររយៈពេល៣ថ្ងៃនឹងចាប់ផ្តើមពីថ្ងៃទី១៤ រហូតដល់ថ្ងៃទី១៦ ក្នុងខែធ្នូ ឆ្នាំ២០២២ ....២០៨
- អាយស៊ីស៊ី-អង្គរ នឹងបើកកិច្ចប្រជុំបច្ចេកទេសលើក៣៦ និងកិច្ចប្រជុំពេញអង្គលើកទី២៩
  នៅពាក់កណ្តាលខែធ្នូខាងមុខនេះ ២០៩
- ក្រុមអ្នកជំនាញការអាដហុក នៃអាយស៊ីស៊ី-អង្គរ
  ចុះពិនិត្យតាមការដ្ឋានជួសជុលប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ...២១០
- ក្រុមអ្នកជំនាញអាដហុក នៃអាយស៊ីស៊ី-អង្គរបន្តចុះពិនិត្យការងារអភិរក្សប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ២១១
- ប្រាសាទបន្ទាយធំ កសាងនៅចុងសតវត្សរ៍ទី១២ ដែលនៅមិនឆ្ងាយពីក្រុងអង្គរធំ ២១២
- ក្រុមអ្នកជំនាញអាដហុក នៃអាយស៊ីស៊ី-អង្គរ បន្តសកម្មភាពចុះពិនិត្យការងារអភិរក្សប្រាសាទ
  ក្នុងរមណីយដ្ឋានអង្គរ ២១៣
- ប្រាសាទទ សំណង់ថ្មបាយក្រៀម សាងសង់នៅចុងសតវត្សរ៍១២ដែលពុំសូវប្រទះឃើញមាននៅក្នុងឧទ្យានអង្គរ ..២១៤
- អ្នកជំនាញការចំពោះកិច្ច នៃអាយស៊ីស៊ី-អង្គរចុះពិនិត្យការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច..................២១៥
- អ្នកជំនាញការចំពោះកិច្ច នៃអាយស៊ីស៊ី-អង្គរចុះពិនិត្យទីតាំងដែលពលរដ្ឋស្ម័គ្រចិត្តផ្លាស់ប្តូរទៅភូមិរុនតាឯក
  និងអភិវឌ្ឍន៍ពាក់ស្នែង ២១៦
- ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ខាងមុខនេះ ជាថ្ងៃបើកព្រឹត្តការណ៍រំលឹកគុណអង្គរ... ២១៧
- អាជ្ញាធរជាតិអប្សរា និងសិស្សានុសិស្ស ចំនួនជិត១ពាន់នាក់ធ្វើព្យុះហយាត្រាដង្ហែក្បួនមុនព្រឹត្តិការណ៍
  រំលឹកគុណអង្គរ ២១៨
- អាជ្ញាធរជាតិអប្សរា បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា
  ជាមួយសាកលវិទ្យាល័យឯកជនចំនួន២ កិច្ចការអភិរក្សសំណង់បុរាណ ២១៩
- អាជ្ញាធរជាតិអប្សរា ប្រារព្ធពិធីបើកព្រឹត្តិការណ៍«រំលឹកគុណអង្គរ».. ២២០
- ថ្ងៃទី២ នៃព្រឹត្តិការណ៍រំលឹកគុណអង្គរ នឹងមានពិព័រណ៍ស្តីពីសមិទ្ធផលការងារ
  របស់អាជ្ញាធរជាតិអប្សរា ការចាក់បញ្ចាំងសិល្បៈនិងការសម្តែងសិល្បៈអាយ៉ៃឆ្លើយឆ្លងជូនទស្សនា ២២១
- លិខិតគោរពជូនពររបស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករនិងឆ្មាំនៃអាជ្ញាធរជាតិអប្សរា
  គោរពជូនសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា
  ក្នុងឱកាសដ៏សែនមហានក្ខត្តឫក្សចម្រើនជន្មាយុគម្រប់ ៦៨ឆ្នាំ ឈានចូល ៦៩ឆ្នាំ...២២២
- គណៈកម្មាធិការសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ
  បើកធ្វើកិច្ចប្រជុំបច្ចេកទេសលើកទី៣៦ នៅខេត្តសៀមរាប...២២៣
- អាជ្ញាធរជាតិអប្សរា រៀបចំស្តង់ពិព័រណ៍សមិទ្ធផលការងារ ក្នុងព្រឹត្តិការណ៍ដឹងគុណអង្គរឆ្នាំ២០២២................. ២២៤
- គណៈកម្មាធិការសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ
  បើកកិច្ចប្រជុំពេញអង្គ លើកទី២៩ នៅខេត្តសៀមរាប ២២៥
- អាជ្ញាធរជាតិអប្សរា ធ្វើពិធីបួងសួងលើប្រាសាទភ្នំបាខែង ២២៦
- អាជ្ញាធរជាតិអប្សរាចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាចំនួន២
  ជាមួយបារាំង និងជប៉ុន ២២៧
- ពលរដ្ឋជាច្រើនបង្ហាញអារម្មណ៍រីករាយពេលបានទស្សនាការរៀបចំព្រឹត្តិការណ៍រំលឹកគុណអង្គរ...................... ២២៨
- ប្រាសាទបន្ទាយសំរ៉ែ ទីសក្ការៈបូជា សាងសង់នៅពាក់កណ្តាលសតវត្សរ៍ទី១២ក្នុងរចនាប័ទ្មអង្គរវត្ត ២២៩
- ប្រាសាទសួរព្រ័ត ឬខ្លះហៅថាប្រាសាទនាង១២ ជាសំណង់ថ្មបាយក្រៀម
  សាងសង់នៅចុងសតវត្សរ៍ទី១២ ក្នុងក្រុងអង្គរធំ ២៣០

- លិខិតជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរាក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៣ .... ២៣១
- លិខិតជូនពរ លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៣.............. ២៣២
- សារលិខិតជូនពរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៣.. ២៣៣
- សារលិខិតថ្វាយព្រះពរ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៣ .... ២៣៤
- ប្រាសាទភ្នំបាខែង កសាងនៅចុងសតវត្សរ៍ទី៩ ជាគោលដៅទស្សនាថ្ងៃលិចដ៏ទាក់ទាញនៅក្នុងរមណីយដ្ឋានអង្គរ ២៣៥
- ថ្ងៃចុងក្រោយនៃឆ្នាំ២០២២ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនាប្រាសាទអង្គរវត្តយ៉ាងច្រើនកុះករ ២៣៦

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែកក្កដា

អាជ្ញាធរជាតិអប្សរាកំពុងជួសជុលព្រះវិហារ នៅវត្តប្រាសាទលលៃ

ផ្សាយនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២

ព្រះវិហារដែលមានចំណាស់ខិតជិត១០០ឆ្នាំ ស្ថិតនៅជ្រុងខាងកើតឆៀងខាងត្បូង នៃតួប្រាសាទលលៃមានទំហំបណ្តោយ២៧,៥ម ទទឹង១១,២ម និងកម្ពស់១៥,៥ម ដែលបានបង្កើតជារូបឯក នៃបុរាណដ្ឋានរវាងប្រាសាទ និងទេសភាពជនបទដ៏ស្រស់ស្អាត ដែលកំពុងឈានដល់វ័យចាស់ទ្រុឌទ្រោម ដោយសារអាយុកាលគុណភាពនៃសំណង់ និងមានការបំផ្លាញដោយសត្វល្អិត ត្រូវបានអ្នកបច្ចេកទេសនៃអាជ្ញាធរជាតិអប្សរា ធ្វើការជួសជុល និងអភិរក្សឡើងវិញ ដោយប្រើប្រាស់បច្ចេកទេសនិងសម្ភារដូចដើមទាំងស្រុង។

អាជ្ញាធរជាតិអប្សរា ចាប់ផ្តើមជួសជុលព្រះវិហារនៅប្រាសាទលលៃ គឺចាប់ផ្តើមនៅខែមិថុនា រហូតដល់ខែធ្នូ ចុងឆ្នាំ២០២២។ គោលបំណងនៃការជួសជុល និងអភិរក្សព្រះវិហារនេះ គឺដើម្បីថែរក្សាមរតកវប្បធម៌ខ្មែរលើវិស័យព្រះពុទ្ធសាសនាដ៏រស់រវើក ឱ្យនៅឋិតថេរបន្តទៅមុខទៀត។ ម្យ៉ាង បម្រើប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ និងការសិក្សារៀនសូត្រ បង្កើតភាពសោមនស្សដល់អារម្មណ៍ភ្ញៀវទេសចរដែលមកទស្សនាទឹកដីបុរាណដ្ឋានមួយនេះ។

សូមបញ្ជាក់ថា ព្រះវិហារនៅវត្តប្រាសាទលលៃ ស្ថិតក្នុងភូមិលលៃ ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប បានចាប់ផ្តើមការជួសជុល និងអភិរក្ស ក្រោមការឧបត្ថម្ភថវិកា និងបច្ចេកទេសពីអាជ្ញាធរជាតិអប្សរា៕

អាជ្ញាធរជាតិអប្សរា
គ្រោងបញ្ចប់ការជួសជុលព្រះពុទ្ធបដិមានៅរូតបាកាណឆាប់ៗនេះ

ផ្សាយនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា គ្រោងបញ្ចប់ការជួសជុលព្រះពុទ្ធបដិមានៅរូតបាកាណឆាប់ៗនេះ អាជ្ញាធរជាតិអប្សរា គ្រោងនឹងបញ្ចប់ការជួសជុលព្រះពុទ្ធបដិមា នៅរូតបាកាណប្រាសាទអង្គរវត្ត ក្នុងពេលឆាប់ៗខាងមុខនេះ។

លោក សយ សុភារិទ្ធ បុរាណវិទូនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកដឹកនាំគម្រោងជួសជុលព្រះពុទ្ធបដិមាចំនួន៣អង្គនៅជាន់បាកាណ មានប្រសាសន៍ថា គម្រោងជួសជុលនេះគ្រោងនឹងបញ្ចប់ឆាប់ៗខាងមុខនេះ ខណៈបច្ចុប្បន្នក្រុមការងារជួសជុលកំពុងលាបម្រ័ក្សណ៍លើរូបដែលជាការងារចុងក្រោយ។

លោក សុភារិទ្ធ បានរំឭកពីស្ថានភាពដើមឡើយនៃព្រះពុទ្ធបដិមា គឺមានស្ថានភាពខូចខាតច្រើន ដែលត្រូវជួសជុល និងអភិរក្សជាបន្ទាន់។ លោកពន្យល់ថា លើរូបបដិមាមានស្នឹមខ្មៅ ក្តាំងធូលី ក្តាំងអំបិល កំណកអាចម៍ប្រចៀវ និងទឹកនោមប្រចៀវជាដើម ដែលដក់លើរូប។ លោកបន្តថា ការសម្អាតចែកជាពីរ គឺសម្អាតស្ងួតដោយយកធូលីដែលកកក្តាំងលើផ្ទៃព្រះកាយបដិមាចេញសិន ដោយប្រើជក់ស្តើងទន់ៗបោសចេញឱ្យបានស្អាត។ បន្ទាប់មកត្រូវសម្អាតសើម មុនដំបូងត្រូវយកទឹកមកសម្អាតសិន ដោយយកសំឡីរុំនឹងឈើតូចៗ ហើយជ្រលក់នឹងទឹកដែលគ្មានជាតិរ៉ែ មកជូតកន្លែងដែលស្នឹមខ្មៅ ក្តាំងធូលី ក្តាំងអំបិល កំណកអាចម៍ប្រចៀវ និងទឹកនោមប្រចៀវ ហើយវានឹងជាច់កំណកនោះមក ប៉ុន្តែពណ៌ដើមនៅរក្សាដដែល។

បច្ចុប្បន្នការងារសម្រេចបានប្រមាណ៩០ភាគរយហើយ បន្ទាប់ពីចាប់ផ្តើមជួសជុលឡើងវិញនៅពាក់កណ្តាលខែមករា ឆ្នាំ២០២២។ ក្នុងឆ្នាំ២០២១ អាជ្ញាធរជាតិអប្សរាបានជួសជុលព្រះពុទ្ធបដិមា១អង្គ នៅទិសខាងត្បូង។ ហើយនៅឆ្នាំ២០២២នេះ ក៏បានជួសជុលព្រះពុទ្ធបដិមាចំនួន៣បន្ថែមទៀត នៅទិសខាងជើង ខាងលិច និងខាងកើត ព្រមទាំងព្រះពុទ្ធចូលនិព្វានចំនួន២អង្គ នៅទិសខាងកើត និងខាងជើង។ ក្នុងនោះក៏បានជួសជុលពង្រឹងចម្រឹងបង្អួច និងរចនាសម្ពន្ធមួយចំនួនទៀតនៅជុំវិញបដិមានោះផងដែរ។ គម្រោងជួសជុលនេះ ទទួលបានការឧបត្ថម្ភថវិកាពីលោកជំទាវឧកញ៉ា នាងវិសាខាអគ្គមហាឧបាសិកា ពុទ្ធសាសនូបត្ថម្ភក៍ កិត្តិបណ្ឌិត សៀង ចាន់ហេង អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍៕

ឆមាសទី១ ឆ្នាំ២០២២ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន៦៨៣សំណើ

ផ្សាយនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២

លទ្ធផលការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា នៅឆមាសទី១ ក្នុងឆ្នាំ២០២២ បានចុះផ្សព្វផ្សាយអប់រំ និងពិនិត្យការស្នើសុំជួសជុលផ្ទះ រួមទាំងសាងសង់តូចតាចទាំង៥ស្រុក/ក្រុង ក្នុងតំបន់រមណីយដ្ឋានអង្គរ បានចំនួន៩២៧សំណើ ដែលក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋចំនួន៦៨៣សំណើ។

ក្នុងករណីអនុញ្ញាតជូនប្រជាពលរដ្ឋខាងលើ រួមមាននៅស្រុកប្រាសាទបាគងបានចំនួន៩៧សំណើ ស្រុកអង្គរធំបានចំនួន៤៣សំណើ ស្រុកពួកបានចំនួន១៥២សំណើ និងក្រុងសៀមរាបបានចំនួន២៦៩សំណើ ស្រុកបន្ទាយស្រី ១១៩សំណើ និងក្រៅតំបន់រមណីយដ្ឋានអង្គរបានចំនួន០៣សំណើ សរុបចំនួន៦៨៣សំណើ។

ជាក់ស្តែង មានបញ្ហាប្រឈមមួយចំនួនដូចជា ការជួសជុលឬសាងសង់មុនការចុះពិនិត្យរបស់ក្រុមការងារ។ ការប្រកាសលក់ដីក្នុងតំបន់ការពារតាមរយៈបណ្តាញទំនាក់ទំនងសង្គមហ្វេកប៊ុក និងការដាក់ស្លាក (លក់ដី) ផ្ទាល់ក្នុងតំបន់ការពារនៅតែមាន។

ជាគោលដៅបន្ត ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរានឹងបន្តផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី ភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងរមណីយដ្ឋានអង្គរឱ្យកាន់តែមានប្រសិទ្ធិភាពទាន់ពេលវេលា។

សូមរីករាយថ្ងៃចុងសប្តាហ៍ ទេសភាពនៃប្រាសាទបាគង

ផ្សាយនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២

នាព្រឹកថ្ងៃទី ២ ខែកក្កដា ឆ្នាំ២០២២ ម៉ោង១១ព្រឹក ឆ្មាំក់ខារទេសចរណ៍ ឆ្នាំក់ខារសណ្តាប់ធ្នាប់ នគរបាលការពារបេតិកភណ្ឌ បានប្រគល់កាបូបលុយ ជូនទៅភ្ញៀវទេសចរវិញបន្ទាប់ពីបានរកឃើញនៅប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២

ពេលរសៀលថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២២ ភ្នាក់ងារទេសចរណ៍ ភ្នាក់ងារសណ្តាប់ធ្នាប់ រួមជាមួយនគរបាលការពារបេតិកភណ្ឌ បានប្រគល់កាបូបលុយ និងទូរសព្ទចំនួនពីរគ្រឿង ជូនម្ចាស់ដែលបានភ្លេចនៅប្រាសាទក្នុងពេលដែលពួកគាត់មកទស្សនារមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២

អរុណសួស្តី ថ្ងៃអាទិត្យ សូមអញ្ជើញទស្សនាទិដ្ឋភាពថ្ងៃរះនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២



គម្រោងជួសជុលកំពង់ទឹករបស់ស្ពានហាលនៃប្រាសាទអង្គរវត្ត សម្រេចបានប្រមាណ៧៥ភាគរយហើយ

ផ្សាយនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២

គម្រោងជួសជុលកំពង់ទឹករបស់ស្ពានហាលនៃប្រាសាទអង្គរវត្ត ក្រោមកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរានិងសាកលវិទ្យាល័យសូហ្វីយ៉ារបស់ប្រទេសជប៉ុន បានឈានដល់ដំណាក់កាលសម្រេចប្រមាណ៧៥ភាគរយហើយរហូតមកដល់ពេលនេះ ។

លោក អន សុភាព បុរាណវិទូ និងជាប្រធានក្រុមការងារជួសជុលស្ពានហាលអង្គរវត្ត ឱ្យដឹងថា គម្រោងជួសជុលកំពង់ទឹករបស់ស្ពានហាលនៃប្រាសាទអង្គរវត្ត ដែលចាប់ផ្តើមរយៈពេលជាង៦ខែមកនេះ បានធ្វើការងារជាច្រើនដូចជារៀបជញ្ជាំង ចាក់បេតុង បុកបង្ហាប់ដីនៅគ្រឹះរបស់កំពង់ទឹកឡើងវិញជាដើមនោះ គឺបានឈានទៅដល់ជិតរួចរាល់។ អ្នកជំនាញរូបនេះបន្តថា ការងារជួសជុលកំពង់ទឹកនេះគឺដំណាក់កាលដំបូងត្រូវសិក្សាស្រាវជ្រាវ វាយតម្លៃលើការខូចខាត និងវិធីសាស្រ្តជួសជុលតាំងពីឆ្នាំ២០២១មក ចំណែកឯសកម្មភាពជួសជុលបានចាប់ផ្តើមកាលពីដើមឆ្នាំ ២០២២ ហើយកំពុងបន្តរហូតមកដល់សព្វថ្ងៃនេះ។

អ្នកជំនាញនៃការងារជួសជុលរូបនេះ បន្តឱ្យដឹងថា កំពង់ទឹករបស់ស្ពានហាលនៃប្រាសាទអង្គរវត្ត មានការខូចខាតជាខ្លាំងជាពិសេសរចនាសម្ពន្ធរបស់កំពង់ទឹកផ្នែកខាងជើង។ ចំណែកគ្រឹះផ្នែកត្រង់របស់ស្ពានហាល និងកំពង់ទឹកវិញ គឺថ្មបាយក្រៀមមានសភាពពុកផុយខ្លាំង តាំងពីកាំថ្មទី១ ដល់កាំទី៤។ ជញ្ជាំងផ្នែកខាងជើងរបស់ស្ពានហាលទ្រុឌទ្រោមខ្លាំង បានរលុះធ្លាក់ចូលទៅក្នុងកសិន្ទស្ទើរតែទាំងស្រុង។ ជញ្ជាំងផ្នែកខាងលិច និងខាងកើតក៏មានសភាពហែកចេញពីគ្នាដែរ។ ក្នុងការងារជួសជុលកំពង់ទឹករបស់ស្ពានហាលនៃប្រាសាទអង្គរវត្តឡើងវិញនេះ គឺតម្រូវឱ្យរុះរើជញ្ជាំងផ្នែកខ្លះដែលពុកផុយខ្លាំង ហើយចាក់បេតុងផ្នែកខាងក្នុងដើម្បីពង្រឹងគុណភាពជញ្ជាំងឡើងវិញ។ រីឯផ្នែកខាងត្បូងដែលខិតជិតមកផ្នែកត្រង់របស់ស្ពានហាល គឺជញ្ជាំងនៅមានស្ថានភាពល្អ និងបានរក្សាទុកដដែល ដោយគោរពទៅតាមគោលការណ៍ របស់គណៈកម្មាធិការអន្តរជាតិ ដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្រ្តអង្គរ ហៅកាត់ថាអាយស៊ីស៊ីអង្គរ។

លោក អន សុភាព ឱ្យដឹងទៀតថា កំពង់ទឹករបស់ស្ពានហាលនៃប្រាសាទអង្គរវត្ត មានទំហំ១២ម៉ែត្របួនជ្រុង និងមានសណ្ឋានដូចគ្នាទៅនឹងកំពង់ទឹកផ្នែកខាងត្បូងដែរ ហើយក្រុមការងារនឹងខិតខំប្រឹងប្រែងជួសជុល ដើម្បីឈានទៅបញ្ចប់នៅបំណាច់ឆ្នាំ២០២២ខាងមុខ ៕

សេចក្តីជូនដំណឹង ស្តីពីការកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខៈ ៤៤៤ / របៈ សជណ
២២

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ
មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជា ដើម្បីលើកកម្ពស់សោភ័ណភាព នៅតាមដងផ្លូវ និងតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ នៅតាមទីតាំងនានាដូចខាងក្រោម៖

-កាត់ក្រីមែកឈើចំនួន ១៣ដើម (ឈើទាល០៧ដើម ពង្រ០២ដើម ស្លែង០១ដើម ចំបក់០១ដើម អំពិលបារាំង ០១ដើម និងស្រឡៅ០១ដើម) ដែលមានហានិភ័យ ស្ថិតនៅបរិវេណចំណតខាងកើតប្រាសាទបាយ័ន។
-កាត់ដកហូតដើមឈើចំនួន ០៣ដើម (ឈើទាល០១ដើម និងស្លែង០២ដើម) និងកាត់ក្រីមែកឈើចំនួន ០៨ដើម (ឈើទាល០២ដើម ចាន់០៣ដើម និងស្លែង០៣ដើម) ដែលមានហានិភ័យ ស្ថិតនៅបរិវេណប្រាសាទតុបខាងកើត និងខ្លោងទ្វារជ័យ។
-កាត់ដកហូតដើមឈើចំនួន ០៦ដើម (រលួស០២ដើម គគីរ០១ដើម ស្លែងគង់០១ដើម អង្គាញ់០២ដើម) ដែលប៉ះពាល់ដល់ការសាងសង់ស្ពានផ្លូវកង់ នៅស្ពានអង្គរ។
-កាត់ដកហូតដើមឈើចំនួន០៤ដើម (ក្តម្ព០២ដើម ឈើទាល០១ដើម និងសិរមាន់០១ដើម) និងកាត់ក្រីមែក ចំនួន ០៨ដើម (ស្តង់០១ដើម ស្រឡៅ០១ដើម ស្លែង០២ដើម ឈើទាល០២ដើម និងខ្នុរព្រៃ០១ដើម) ដែលមានហានិភ័យ ស្ថិតនៅបរិវេណវត្ត និងប្រាសាទវិហារ៧ល្វែង។
-កាត់ដកហូតដើមឈើចំនួន ០៥ដើម (ស្តង់០១ដើម ត្រាង០១ដើម ដូនកាយ០២ដើម និងឈើទាល០១ដើម) និងកាត់ក្រីមែកឈើចំនួន ៣៣ដើម (សង្កែ០១ដើម អង្គោល០១ដើម អំពិលបារាំង០២ដើម ពង្រ០៤ដើម ស្លែង០៣ដើម ឈើទាល១០ដើម ត្រាង០១ដើម ល្វៅ០១ដើម ខ្នុរ០១ដើម ចាន់០១ដើម និងស្រឡៅ០៥ដើម) ដែលមានហានិភ័យ ស្ថិតនៅបរិវេណប្រាសាទតាទួត និងប្រាសាទជម។
-កាត់ក្រីមែកឈើចំនួន ១៣ដើម (ឈើទាល០៧ដើម ពង្រ០២ដើម ស្លែង០១ដើម ចំបក់០១ដើម អំពិលបារាំង ០១ដើម និងស្រឡៅ០១ដើម ដែលមានហានិភ័យ ស្ថិតនៅបរិវេណចំណតខាងកើតប្រាសាទបាយ័ន។
-កាត់ដកហូតដើមឈើចំនួន ០៤ដើម (សង្កែ០៣ដើម និងអំពិលបារាំង០១ដើម) និងកាត់ក្រីមែកឈើចំនួន ៥៣ដើម (ត្នោត៣៧ដើម អំពិលបារាំង១១ដើម ស្តៅ០១ដើម សង្កែ០៣ដើម អង្គោល០១ដើម) ដែលមានហានិភ័យ ស្ថិតនៅក្នុងបរិវេណប្រាសាទអង្គរវត្ត។
-កាត់ដកហូតដើមឈើទាល ០១ដើម និងកាត់ក្រីមែកឈើទាលចំនួន ១១ដើម ដែលមានហានិភ័យ ស្ថិតនៅបរិវេណការដ្ឋានជួសជុលប្រាសាទបាយ័នរបស់អង្គភាពJASA។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារខាងលើចាប់ពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ តទៅរហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ៦ កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ពស២៥៦៦
សៀមរាប ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

អាជ្ញាធរជាតិអប្សរា ធ្វើការជួសជុលប៉មឥដ្ឋទី១៥ ប្រាសាទប្រែរូប

ផ្សាយនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២

ក្រុមអ្នកបច្ចេកទេសអាជ្ញាធរជាតិអប្សរា ធ្វើការជួសជុលតួប៉មឥដ្ឋទី១៥ ស្ថិតនៅជាន់ទី២ផ្នែកពាយ័ព្យនៃប្រាសាទប្រែរូប ដែលមានសភាពទ្រុឌទ្រោមកំពុងប្រឈមនឹងគ្រោះថ្នាក់ខ្លាំង ។

ការជួសជុលដែលបានចាប់ផ្តើម ពីខែមីនាឆ្នាំ២០២២ មកនោះ ក្រុមអ្នកបច្ចេកទេសបានអនុវត្តការងារសំខាន់ចំនួនពីរ គឺជួសជុលពង្រឹងឡើងវិញតួប៉មឥដ្ឋដែលមានសភាពពុកផុយ និងជួសជុលពង្រឹងរចនាសម្ពន្ធថ្មបាយក្រៀមផ្នែកខាងក្រោម។ ការងារជួសជុលនេះត្រូវប្រើពេល១ឆ្នាំ ដោយគ្រោងនឹងបញ្ចប់នាដើមឆ្នាំ២០២៣ខាងមុខ។



កូនឈើចម្រុះចំនួន៦,៣៥០ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយដល់សាធារណជន

ផ្សាយនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២២

- ប្រគេនកូនឈើជូនព្រះសទ្ធម្មប្បកាសនី តាត មហាទី ព្រះចៅអធិការវត្តព្រះឥន្ទកោសា ចំនួន១,០០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន ស្ថិតនៅភូមិចក ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប។កូនឈើទាំងនោះរួមមានគ្រញូង៣០០ដើម ធ្នង់២០០ដើម បេង៣០០ដើម និងប្រេស២០០ដើម។
- ប្រគេនកូនឈើជូនព្រះតេជគុណ ថូ ធូរស់ ព្រះចៅអធិការវត្តប្រាសាទរាជាសំរោង និងជាព្រះវិន័យធរគណខេត្តឧត្តរមានជ័យ ចំនួន២,៥០០ដើម ដើម្បីយកទៅដាំក្នុងពិធីរុក្ខទិវានៅព្រៃសង្ឃសហគមន៍រុក្ខាវ័ន ស្ថិតក្នុងភូមិឈូកមាស សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ កូនឈើទាំងនោះរួមមាន គ្រញូង៥០០ដើម ធ្នង់៣០០ដើម បេង២០០ដើម ប្រេស២០០ដើម គគីរ៣០០ដើម ឈើទាល៣០០ដើម ត្រយឹង១០០ដើម ពពេល១០០ដើម ស្លង់១៥០ដើម សំរោង១៥០ដើម និងរំដួល២០០ដើម។
- ប្រគេនកូនឈើជូនព្រះធម្មបាលោ សាន សប្បាយ ព្រះចៅអធិការវត្តវិសុទ្ធិមគ្គ ហៅភិនវិទ្ធារាម ចំនួន១,៥០០ដើម ដើម្បីយកទៅដាំលើដីទំនេរក្នុងបរិវេណវត្តនេះ ត្រូវនឹងថ្ងៃបុណ្យផ្កាប្រាក់សាងសង់សាលាលោកកុត្តរធម៌ ស្ថិតក្នុងភូមិបំពេញរាជ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូង២០០ដើម ធ្នង់២០០ដើម បេង២០០ដើម គគីរ២០០ដើម ឈើទាល២០០ដើម ផ្ចៀក២០០ដើម សំរោង៥០ដើម ត្រសេក៥០ដើម និងរំដួល២០០ដើម។
- ផ្តល់កូនឈើជូនតំណាងនាយកដ្ឋានសណ្តាប់ធ្នាប់ និងផ្នែកផ្សេងៗនៃអាជ្ញាធរជាតិអប្សរា ចំនួន៥០០ដើម ដើម្បីយកទៅដាំនៅលំអតាមផ្លូវក្បែរខ្លោងទ្វារតាការ និងក្នុងបរិវេណទីលានបដិសណ្ឋារកិច្ចមុខប្រាសាទអង្គរវត្ត។ កូនឈើទាំងនោះរួមមាន ធ្នង់ គគីរ និងក្ញោកធំ។
- ផ្តល់កូនឈើជូនកញ្ញា ឃឿម ស៊ីន ប្រធានគម្រោងអប់រំនៃក្រុមយុវជនកម្ពុជា ខេត្តសៀមរាប ចំនួន៥០០ដើម ដើម្បីយកទៅដាំលំអក្នុងបរិវេណវិទ្យាល័យក្រឡាញ់ ស្ថិតនៅភូមិក្រឡាញ់ ឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ឥន្ទនេល និងឈើទាល។
- ផ្តល់កូនឈើជូនលោក យិន វាសនា ជានិពន្ធនាយកគេហទំព័រសារព័ត៌មានអរគុណសន្តិភាព ចំនួន២០០ដើម ដើម្បីយកទៅដាំនៅដីតំបន់ទេសចរណ៍ថ្មរូង ស្ថិតក្នុងភូមិព្រៃប្រសិទ្ធ ឃុំអូរបាក់រទេះ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ។ កូនឈើទាំងនោះរួមមាន គ្រញូង ធ្នង់ បេង គគីរ ឈើទាល និងរំដួល ។
- ផ្តល់កូនឈើជូនលោក យឿន គឹមយុក ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន១៥០ដើម ដើម្បីយកទៅដាំនៅដីផ្ទាល់ខ្លួន ស្ថិតក្នុងភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន អង្កាញ់ និងរំដួល។

ព្រះពុទ្ធបាទពីថ្មភក់ចំនួន១ និងពុទ្ធបដិមាសម័យកណ្តាលចំនួន៦ កំពុងតាំងបង្ហាញនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ក្រោយពីជួសជុលរួចរាល់

ផ្សាយនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២២

សារមន្ទីរព្រះនរោត្តមសីហនុអង្គរ កំពុងដាក់តាំងពិព័រណ៍ពុទ្ធបដិមាបុរាណដែលកសាងឡើងអំពីឈើចំនួន៦ និងព្រះពុទ្ធបាទធ្វើពីថ្មភក់ចំនួន១ដើម្បីបង្ហាញសាធារណជនឱ្យស្វែងយល់ពីវត្ថុសិល្បៈខ្មែរដ៏សម្បូរបែប បន្ទាប់ពីក្រុមអ្នកជំនាញបានជួសជុលវត្ថុបុរាណទាំងនោះឱ្យមានលក្ខណៈល្អស្អាតឡើងវិញរួចមក។ ពុទ្ធបដិមាបុរាណដែលកសាងឡើងអំពីឈើចំនួន៦ និងព្រះពុទ្ធបាទធ្វើពីថ្មភក់ចំនួន១នោះគឺក្រុមអ្នកអភិរក្ស បានយកចេញពីរូតព្រះពាន់នៃប្រាសាទអង្គរវត្ត ទៅរក្សាទុក ហើយជួសជុល ព្រមទាំងថែរក្សានៅកន្លែងអភិរក្សអង្គរ ជាយូរមកហើយ។

នាយកស្តីទីនៃសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ លោក ប៉ែន ចំរ៉ុងឱ្យដឹងថា កាលដើមឡើយពុទ្ធបដិមាចំនួន៦អង្គ និងព្រះពុទ្ធបាទធ្វើពីថ្មភក់ចំនួន១នេះ ត្រូវបានរក្សាទុក និងជួសជុលដោយក្រុមអភិរក្សអង្គរ។ ក្រោយមក រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា លោកជំទាវ ភឿង សកុណា បានទៅទស្សនានៅអភិរក្សអង្គរ ឃើញថា ពុទ្ធបដិមាទាំង៦ និងព្រះពុទ្ធបាទនេះបានជួសជុលរួចរាល់ហើយ លោកជំទាវក៏បានណែនាំឱ្យយកវត្ថុទាំងនេះទៅដាក់តាំងបង្ហាញដល់សាធារណជនបានទស្សនា និងសិក្សាស្វែងយល់ពីវត្ថុសិល្បៈខ្មែរ ពិសេសពុទ្ធបដិមាសម័យក្រោយអង្គរ។ ដោយមានការយល់ស្របទៅតាមអនុសាសន៍របស់លោកជំទាវរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សារមន្ទីរនរោត្តមសីហនុអង្គរ ក៏បានសហការជាមួយអភិរក្សអង្គរ ធ្វើការរៀបចំតាំងពិព័រណ៍ពុទ្ធបដិមាចំនួន៦អង្គ និងព្រះពុទ្ធបាទធ្វើពីថ្មភក់ចំនួន១នេះ ចាប់តាំងតែពីអំឡុងខែឧសភា ឆ្នាំ២០២២រហូតមកដល់ពេលនេះ។ នេះជាលើកទី១ហើយដែលសារមន្ទីរព្រះនរោត្តមសីហនុអង្គរ ទទួលបានបដិមាពីអភិរក្សអង្គរមក ធ្វើការតាំងពិពរណ៍នៅសារមន្ទីរ។

ពុទ្ធបដិមាចំនួន៦នេះ ធ្វើឡើងពីឈើគគីរ ក្នុងទម្រង់កាយវិការ អភ័យមុទ្រៈ មានលាបម្រ័ក្សណ៍ និងបិទមាស នៅព្រះហស្តមានដាំត្បូងរាងមូលដូចកងចក្រ ប្រស្រីភ្នែកនិងថ្ងាសមានដាំសំបកគ្រុំធ្វើជាគ្រឿងលម្អជាដើម។
ពុទ្ធបដិមាទាំងអស់នេះ បានកសាងនៅសម័យក្រោយអង្គរ ចន្លោះពីសតវត្សរ៍ទី១៤ដល់ទី១៨នៃគ.ស ហើយពុទ្ធបដិមាភាគច្រើនមានលក្ខណៈស្រដៀងទៅនឹងរចនាបទបាយ័ន។ ដោយឡែក ព្រះពុទ្ធបាទចំនួន១ ជាព្រះពុទ្ធបាទខាងស្តាំ មានកម្ពស់១៣សង់ទីម៉ែត្រ បណ្តោយ២១០សង់ទីម៉ែត្រ ទទឹង១១៥ សង់ទីម៉ែត្រ នៅចំកណ្តាលពុទ្ធបាទមានកងចក្រ និងឆ្លាក់ចម្លាក់ផ្សេងៗ ចំនួន១០៨ ដែលគេយល់ថាជាសិរីមង្គល និងមានលាបម្រ័ក្សណ៍ព្រមទាំងទឹបទឹកមាសដែរ។

សាររំលែកទុក្ខ

ផ្សាយនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២

កុដិឈើពីរខ្នងវ័យចំណាស់នៅវត្តព្រះព្រហ្មរ័ត្ន ប្រែប្រួលសោភ័ណភាពដ៏ស្រស់ត្រកាលក្រោយបញ្ចប់ការជួសជុល

ផ្សាយនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២

គម្រោងជួសជុល និងអភិរក្សកុដិឈើបុរាណនៅវត្តព្រះព្រហ្មរ័ត្ន ដែលទទួលបានថវិកា និងបច្ចេកទេសទាំងស្រុងពីអាជ្ញាធរជាតិអប្សរា បានបញ្ចប់ជាស្ថាពរហើយ នៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០២២។

ក្រោមកិច្ចខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ពីសំណាក់មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា គឺបានជួសជុលកុដិឈើពីរខ្នង ដែលមានសភាពចាស់ទ្រុឌទ្រោម ពុកផុយ ធ្លុះធ្លាយ និងធ្លាក់បាក់ឱ្យល្អឡើងវិញ ព្រមទាំងជួសជុលពង្រឹងកែលម្អនៅតាមកន្លែងជាច្រើនទៀត ដូចជា ការជួសជុលជញ្ជាំង ជើងជញ្ជាំង ដំបូលជាដើម និងផ្នែកសំខាន់នៃគ្រឿងបង្គុំសំណង់មួយចំនួនទៀតឱ្យរួចផុតពីហានិភ័យ និងរក្សាបាននូវភាពរឹងមាំឡើងវិញ។

សូមបញ្ជាក់ថា កុដិឈើចាស់នៅវត្តព្រហ្មរ័ត្ននេះ មានទទឹង ១៣.៦៥ម៉ែត្រ បណ្តោយ ១៤.៧៨ម៉ែត្រ និងកម្ពស់ ៧.៧៧ម៉ែត្រ។ គោលបំណងនៃការងារជួសជុល និងអភិរក្សខាងលើ គឺដើម្បីឱ្យសំណង់កុដិឈើនេះអាចបំពេញតួនាទីរបស់ខ្លួនបន្តទៅទៀត ដើម្បីជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ និងការសិក្សារៀនសូត្រ ជាពិសេស រក្សានូវមរតកពីបុរាណ ព្រមទាំងអាចទាក់ទាញចំណាប់អារម្មណ៍របស់ទេសចរមកទស្សនាស្វែងយល់បន្ថែម ក្រៅពីសំណង់ប្រាសាទបុរាណរបស់យើងផងដែរ៕

អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់ ចំនួន៣ដើមនៅខ្លោងទ្វារជ័យ

ផ្សាយនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២

ក្រុមជំនាញផ្នែកព្រៃឈើនៃនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធនៃអាជ្ញាធរជាតិអប្សរា រួមជាមួយផ្នែកពាក់ព័ន្ធបានចុះពិនិត្យ និងកំពុងអនុវត្តវិធានការបន្ទាន់ចំពោះដើមឈើដែលកំពុងបង្កហានិភ័យខ្ពស់មកលើរចនាសម្ព័ន្ធខ្លោងទ្វារជ័យនៃអតីតក្រុងអង្គរធំ។ កិច្ចការងារនេះ ដើម្បីធានាសុវត្ថិភាពអ្នកដំណើរដែលឆ្លងកាត់ទីនោះ ជៀសវាងគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិត និងជួយសម្រាលតួដើម បង្ការកុំឲ្យដួលរលំប៉ះពាល់ដល់បង្កាន់ដៃនាគ និងរចនាសម្ពន្ធខ្លោងទ្វារ។

ដើមឈើដែលបាន និងកំពុងកាត់ក្រីមែកមានចំនួន២ដើម រួមមាន ស្រឡៅ១ដើម និងស្លង់១ដើម។ ចំណែកឯដើមឈើកំពុងដកហូតមាន ឈើទាល១ដើម ដែលស្ថានភាពដើមឈើនេះដុះទ្រេតខ្លាំងមកលើបង្កាន់ដៃនាគ ប្រព័ន្ធឫសចាក់ចូលក្នុងដីសើម ជ្រាយខ្លាំង ស្ថិតនៅជាប់មាត់កសិណខាងក្រៅកំពែង៕

កំពង់ទឹករបស់ស្ពានហាលនៃស្រះស្រង់បានបញ្ចប់ការជួសជុល

ផ្សាយនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២

គម្រោងជួសជុលកំពង់ទឹក របស់ស្ពានហាលស្រះស្រង់ ផ្នែកខាងត្បូង ទទួលបន្ទុកដោយនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា ដែលបានចាប់ផ្ដើមតាំងពីខែមករា ដើមឆ្នាំ២០២២ ប្រើរយៈពេល៧ខែ បានបញ្ចប់រួចរាល់ជាស្ថាពរនៅខែកក្កដា ឆ្នាំ២០២២នេះ។

លោក ក្រឹម គ្រួន អ្នកគ្រប់គ្រងការដ្ឋានជួសជុលមានប្រសាសន៍ថា ការងារជួសជុលស្ពានហាលរបស់កំពង់ទឹកនេះ គឺដើម្បីពង្រឹងរចនាសម្ពន្ធរបស់កំពង់ទឹកស្ពានហាលឱ្យមានរូបរាងដើម និងរឹងមាំឡើងវិញ។ លោក ក្រឹម គ្រួន បានបញ្ជាក់ពីមូលហេតុ ដែលធ្វើឱ្យរចនាសម្ពន្ធសំណង់កំពង់ទឹករបស់ស្ពានហាលនៃស្រះស្រង់ ផ្នែកខាងត្បូងរងនូវការខូចខាត ដោយសារអាយុកាលនៃសំណង់ ការពុកផុយនៃស្រទាប់ថ្មបាយក្រៀមខាងក្រោម ឫសឈើចាក់ជ្រែកទៅក្នុងថ្មធ្វើឱ្យថ្មរំកិលខុសពីទីតាំងដើម។

លោក ក្រឹម គ្រួន បន្តទៀតថា ការងារជំហានដំបូងក្រុមការងារធ្វើសម្រង់ប្លង់ និងការរើថ្ម លាងសម្អាត ចុះបញ្ជីថ្ម និងជួសជុលថ្ម ព្រមទាំងធ្វើកំណាយបុរាណវិទ្យាដើម្បីសិក្សាពីស្ថានភាពគ្រឹះ។ ក្រោយពីពង្រឹងគ្រឹះដោយប្រើវិធីសាស្ត្របុរាណឡើងវិញរួចរាល់ អ្នកជំនាញបានរៀបចំផ្ដុំថ្មបាយក្រៀម និងថ្មភក់ទៅតាមលំនាំដើម ដោយបន្ថែមថ្មថ្មីក្នុងចំនួនតិចបំផុត ហើយក្រុមការងារបានបិទភ្ជិតមុខដំណរថ្មដើម្បីការពារជម្រាបទឹក ជៀសវាងការខូចខាតគ្រឹះបន្តទៀត។ លោក ក្រឹម គ្រួន បញ្ជាក់ថា កំពង់ទឹកនេះ ធ្លាប់បានជួសជុលកាលពីសម័យបារាំងរួចម្ដងមកហើយ ដោយការរៀបថ្ម ចាក់បេតុង ចាក់ល្បាយដីពង្រឹងគ្រឹះឡើងវិញ ប៉ុន្តែដោយកត្តាអាយុកាល និ ងធម្មជាតិ ទឹកភ្លៀងបានហូរច្រោះគ្រឹះបណ្ដាលបាក់ស្រុតតាមកន្លែងផ្សេងៗជាអន្លើរ។

ក្រោយពីអាជ្ញាធរជាតិអប្សរា បញ្ចប់ការជួសជុលកំពង់ទឹកផ្នែកខាងត្បូងនេះរួចរាល់ រក្សាបាននូវភាពរឹងមាំស្ថិតនៅគង់វង្សយូរអង្វែង បានដល់កូនចៅខ្មែរជំនាន់ក្រោយជាបន្តទៀត និងលើកកម្ពស់សោភ័ណភាពរបស់ស្ពានហាលនេះកាន់តែមានភាពស្រស់ស្អាតទ្វេឡើង៕

អគ្គនាយកអាជ្ញាធរជាតិអប្សរា ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តម ស៊ីនហ្សូ អាបេ នៅស្ថានកុងស៊ុលជប៉ុនប្រចាំខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២

ឯកឧត្តម ហង់ ពៅ អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា និងសហការី អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ **ឯកឧត្តម ស៊ីនហ្សូ អាបេ** អតីតនាយករដ្ឋមន្ត្រីជប៉ុន នៅស្ថានកុងស៊ុលជប៉ុន ប្រចាំខេត្តសៀមរាប នារសៀលថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២។

ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** ក៏បានសម្តែងនូវការគោរពដឹងគុណ និងសោកស្តាយបំផុតចំពោះការបាត់បង់ **ឯកឧត្តម ស៊ីនហ្សូ អាបេ** ជាមួយគ្រួសារសព ប្រជាជនជប៉ុន ក៏ដូចជា រាជរដ្ឋាភិបាលជប៉ុន ដែលកន្លងមកបានចូលរួមចំណែកយ៉ាងច្រើនក្នុងកិច្ចការអភិរក្ស អភិវឌ្ឍន៍ ប្រកបដោយចីរភាពក្នុងតំបន់រមណីយដ្ឋានអង្គរ តាមរយៈជំនួយផ្សេងៗ ក្នុងការជួសជុលប្រាសាទនានា។

ក្នុងឱកាសដ៏ក្រៀមក្រំនេះ ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា និងសហការី សូមឧទ្ទិសកុសលផលបុណ្យដែលបានសាង និងបួងសួងសូមឱ្យវិញ្ញាណក្ខន្ធរបស់ **ឯកឧត្តម ស៊ីនហ្សូ អាបេ** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ៕

កូនឈើចម្រុះចំនួន៨,០០០ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយដល់សាធារណជន

ផ្សាយនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២

- ប្រគេនកូនឈើជូនព្រះឥន្ទសី. បឿត សុម៉ៅសុវណ្ណារ៉ា ព្រះគ្រូចៅអធិការវត្តវេឡុវ័ន ដោកពោយគោកក្រោល ចំនួន១,៣៥០ដើម ដើម្បីយកទៅដាំបន្ថែមលម្អក្នុងបរិវេណវត្ត ស្ថិតក្នុងភូមិឫស្សីសាញ់ ឃុំជ្រោយនាងនួន ស្រុកស្រីស្នំ ខេត្តសៀមរាប។

- ប្រគេនកូនឈើជូនព្រះភិក្ខុ មនាបសីលោ ម៉យ ម៉ានុត ព្រះគ្រូចៅអធិការវត្តគោកដូងសំរោងក្លាង ហៅវត្តសំរោង ចំនួន៦០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្តនេះ ស្ថិក្នុងភូមិសំរោង ឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។

- ប្រគេនកូនគ្រញូងជូនព្រះអង្គ ម៉ែន សាម៉ន ព្រះគ្រូចៅអធិការវត្តសសរស្តម្ភ ចំនួន៣០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណទីធ្លាវត្ត ស្ថិតក្នុងឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប។

- ផ្តល់កូនឈើជូនលោកឧត្តមសេនីយ៍ទោ សុខ ធារ៉ា តំណាងទីបញ្ជាការកងពលធំអន្តរាគមន៍លេខ២ ចំនួន ៤,០០០ដើម ដើម្បីយកទៅដាំជួស និងដាំបន្ថែមក្នុងបរិវេណទីបញ្ជាការ ស្ថិតនៅភូមិស្រះខ្វាវ ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប និងយកទៅដាំនៅទីបញ្ជាការចំនួន៣ផ្សេងទៀតនៅខេត្តឧត្តរមានជ័យ។

- ផ្តល់កូនឈើជូនតំណាងរដ្ឋបាលឃុំប៉ោយចារ ចំនួន ៨០០ដើម ដើម្បីយកទៅដាំនៅតាមទំនប់រមណីយដ្ឋានអាងទឹកត្រពាំងថ្ម សាលារៀន និងមណ្ឌលសុខភាព ក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ - ផ្តល់កូនឈើជូនលោក មាន លុជ្ស ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៣៥០ដើម ដើម្បីយកទៅដាំលើដីទំនេរផ្ទាល់ខ្លួន ស្ថិតនៅភូមិបុស្សតាត្រាវ ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប។

- ផ្តល់កូនឈើជូនលោក ងួន វុទ្ធី ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន២០០ដើម ដើម្បីយកទៅដាំនៅដីផ្ទាល់ខ្លួន ស្ថិតក្នុងភូមិទឹកថ្លា សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន។

- ផ្តល់កូនគ្រញូងជូនលោក ចែត រុងរឿង ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៣០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណសាលាបឋមសិក្សាចំបក់ស ស្ថិតនៅភូមិតាទក ឃុំពួក ស្រុកពួក ខេត្តសៀមរាប។

- ផ្តល់កូនឈើជូនអ្នកស្រី អែម សុខាន នាយិកាសាលាបឋមសិក្សាដូនឱ ចំនួន១០០ដើម ដើម្បីយកទៅដាំលម្អក្នុងបរិវេណទីធ្លាសាលារៀន ស្ថិតនៅភូមិដូនឱ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។

គម្រោងជួសជុលច្រាំងកសិន្ធុអង្គរវត្តខាងលិច ប៉ែកខាងត្បូងនៃស្ពានហាល ជំហានទី២គ្រោងបញ្ចប់ឆាប់ៗនេះ

ផ្សាយនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរាតាមរយៈនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ កំពុងបង្ហើយការងារនៅការដ្ឋានជួសជុលច្រាំងកសិន្ធុអង្គរវត្តខាងលិច ប៉ែកខាងត្បូងនៃស្ពានហាលជំហានទី២ ដែលនឹងបញ្ចប់នាពេលឆាប់ៗនេះ។

លោក សន ចាន់ថន បុរាណវិទូ បានឱ្យដឹងថា គម្រោងជួសជុលជំហានទី២នេះសម្រេចបានជាង៩០ភាគរយហើយ ដោយគ្រោងនឹងបញ្ចប់នៅក្នុងសប្តាហ៍នេះ។លោកបន្តថា ជំហានទី២នេះមានប្រវែងសរុប ៦០ម៉ែត្រ ខណៈជំហានទី១ មានប្រវែង ៨០ម៉ែត្រ ដែលសរុប ១៤០ម៉ែត្រ។

តាមការបញ្ជាក់ពីលោក សន ចាន់ថន ការជួសជុលជំហានទី២នេះ ផ្នែកខ្លះមានការបាក់បែកច្រើនដោយត្រូវជួសជុល និងពង្រឹងជើងច្រាំងកសិន្ធុកុំឱ្យស្រុតធ្លាក់បន្តទៀត។ ការជួសជុលនេះ បានចាប់ផ្តើមពីខែ មីនាមក ដោយការដ្ឋានមិនបានធ្វើទំនប់ស្ទាក់ទឹកដូចការជួសជុលជំហានទី១ទេ ដោយសារជើងច្រាំងកសិន្ធុនៅទីនេះ នៅល្អប្រសើរ ហើយកន្លែងដែលរលុះខ្លាំង ក្រុមការងារជួសជុលបានដាក់ដីទប់ជើងច្រាំងដោយមានក្រាលគ្រឹះថ្មពីក្រោមផង។

ជាមួយគ្នានេះ លោក សន ចាន់ថន បានលើកឡើងថា ក្រោយបញ្ចប់ការងារនេះរួច ក៏មានគម្រោងសម្រាប់ជួសជុលបន្តទៀតដែរ តែត្រូវរង់ចាំការសម្រេចពីថ្នាក់លើ និងថវិកាសម្រាប់ការងារនេះសិន៕

អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន ជូនប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរចំនួន១៥២២គ្រួសារ

ផ្សាយនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២

នាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ នៃអាជ្ញាធរជាតិអប្សរាឱ្យដឹងថា ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០២២ ក្រុមការងារបានចុះពិនិត្យ និងជួយសម្រួលលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន និងសំណង់ឧបសម្ពន្ធផ្សេងៗទៀតដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ និងក្រៅតំបន់រមណីយដ្ឋានអង្គរបានចំនួន១៥២២គ្រួសារ។

ចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរចំនួន១៤៩២គ្រួសារ ក្រុងសៀមរាប ៣៧៧គ្រួសារ ស្រុកប្រាសាទបាគង ៣៤៩គ្រួសារ ស្រុកបន្ទាយស្រី ២៥៥គ្រួសារ ស្រុកពួក ៣៣៧គ្រួសារ និងស្រុកអង្គរធំ ១៧៤គ្រួសារ។ ចំណែកប្រជាពលរដ្ឋរស់នៅក្រៅតំបន់រមណីយដ្ឋានអង្គរចំនួន៣០គ្រួសារ ស្រុកស្វាយលើ ២៤គ្រួសារ ស្រុកសូទ្រនិគម ០៦គ្រួសារ។

សូមបញ្ជាក់ថា រាល់ការអនុញ្ញាត និងដាក់ពាក្យសាងសង់ស្នើសុំ គឺមិនតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ៕

អាជ្ញាធរជាតិអប្សរា
បញ្ចប់ការជួសជុលខ្លោងទ្វារខាងលិចប្រាសាទចៅស្រីវិបុល

ផ្សាយនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២

ការងារជួសជុលខ្លោងទ្វារខាងលិចប្រាសាទចៅស្រីវិបុល មានសភាពទ្រុឌទ្រោមខ្លាំង ដោយការបាក់ស្រុត និងបានដួលរលំអស់មួយផ្នែកធំ ដែលបានចាប់ផ្តើមពីឆ្នាំ២០២០ បានបញ្ចប់រួចរាល់ហើយនាដើមឆ្នាំ២០២២នេះ។

ដោយផ្អែកលើស្ថានភាពខូចខាតនៃតួខ្លោងទ្វារទាំងមូល ក្នុងរយៈពេលជិត២ឆ្នាំនៃដំណើរការជួសជុល ក្រុមអ្នកបច្ចេកទេស បានអនុវត្តតាមវិធីសាស្ត្រអាណាស្ទីឡូស (Anastylosis) ដោយធ្វើការរុះរើតួខ្លោងទ្វារចេញទាំងស្រុង ដើម្បីធ្វើការជួសជុលពង្រឹងរចនាសម្ពន្ធគ្រឹះ ជួសជុលថ្ម ដែលបែកបាក់,ពុកផុយ និងរៀបផ្គុំតួខ្លោងទ្វារប្រាសាទឡើងវិញទៅតាមទម្រង់ដើម។



សូមអញ្ជើញទស្សនាទេសភាព
ប្រាសាទព្រះខ័ន

ផ្សាយនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២២



អាជ្ញាធរជាតិអប្សរា មានសេចក្ដីសោមនស្សរីករាយ សូមគោរពអញ្ជើញឯកឧត្ដម លោកជំទាវ លោក លោកស្រី មន្ត្រី បុគ្គលិកគ្រប់ស្ថាប័ន អ្នកស្រាវជ្រាវ សិស្សានុសិស្ស ព្រមទាំងសាធារណជនទាំងអស់ ចូលរួមសិក្សា ស្ដាប់បាឋកថាស្ដីពី «ព្រះពុទ្ធសាសនា និងវិស័យវេជ្ជសាស្ត្របុរាណ» ដើម្បីស្វែងរកប្រយោជន៍ក្នុងការបង្កើនចំណេះដឹងដោយមេត្រីភាព

ផ្សាយនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២



លិខិតអញ្ជើញ

មជ្ឈមណ្ឌលបណ្ដុះបណ្ដាលអង្គរ មានកិត្តិយសសូមគោរពអញ្ជើញ ឯកឧត្ដម លោកជំទាវ លោក លោកស្រី មន្ត្រី-បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាអញ្ជើញចូលរួម សិក្ខាសាលាផ្សព្វផ្សាយ អំពីលទ្ធផលនៃការស្រាវជ្រាវ

ក្រោមប្រធានបទ	៖ **ព្រះពុទ្ធសាសនា និងវិស័យវេជ្ជសាស្ត្របុរាណ**
បទបង្ហាញដោយ	៖ ក្រុមអ្នកជំនាញអន្តរជាតិ ដែលមកពីអង់គ្លេស អាមេរិក និងអាស៊ី
វាគ្មិន និងសម្របសម្រួលដោយ	៖ លោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋាន អភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ

នាថ្ងៃពុធ ទី២០ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ២:០០នាទី រសៀល
នៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលអង្គរ នៃអាជ្ញាធរជាតិអប្សរា
សិក្ខាសាលាជាភាសាអង់គ្លេស
(បន្ទប់ធំទូលាយ ហើយកំណត់សាធារណជនចូលរួមស្ដាប់ត្រឹមតែចំនួន ៥០រូប ប៉ុណ្ណោះដោយអនុវត្តនូវគោលការណ៍ណែនាំស្ដីពីការបង្ការការរីករាលដាលនៃជំងឺឆ្លង Covid 19)

កំណត់សម្គាល់ ៖ ដើម្បីសម្រួលដល់ការរៀបចំ សូមមន្ត្រី-បុគ្គលិក អាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាផ្ដល់ដំណឹងអំពីការចូលរួម តាមលេខទូរស័ព្ទ/តេឡេក្រាម៖ ០១២ ៧៣៤ ៥២០ ឲ្យបាន០១ថ្ងៃមុន

អាជ្ញាធរជាតិអប្សរា
ចាប់ផ្តើមជួសជុលសាលាឆាន់បុរាណ(ផ្នែកតួអគារ)នៅវត្តរាជបូណ៌

ផ្សាយនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២

សាលាឆាន់បុរាណ (ផ្នែកតួអគារ) នៅវត្តរាជបូណ៌ក្នុងទីរួមខេត្តសៀមរាប បានទទួលការជួសជុលដំណាក់ទី២ ក្រោមការជួយជ្រោមជ្រែងផ្នែកបច្ចេកទេសនិងឧបត្ថម្ភថវិកាពីអាជ្ញាធរជាតិអប្សរា។

ការជួសជុលដំណាក់កាលទី២នេះ គឺផ្តោតលើការជួសជុលផ្នែកតួអគារ រួមមាន ជួសជុលជញ្ជាំង កាំជណ្តើរ ក្បាច់តាមខឿនជើងជញ្ជាំង និងសម្អាតការ៉ូបាត សសរ ពិដាន។ល។ សាលាឆាន់នេះ មានសភាពទ្រុឌទ្រោមខ្លាំង ពុកផុយ និងខ្លះបានធ្លាក់បាក់។ អាជ្ញាធរជាតិអប្សរា បានជួសជុលពង្រឹងផ្នែកដែលពុកផុយ ធ្លុះធ្លាយឡើងវិញ និងដោយមានការកែលម្អនៅកន្លែងជាច្រើន។

អាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមគម្រោងអភិរក្ស និងជួសជុលសាលាឆាន់ (ផ្នែកតួអគារ) វត្តរាជបូណ៌ដំណាក់កាលទី២ ដោយចាប់ផ្តើមតាំងពីដើមខែកក្កដា ឆ្នាំ២០២២ ហើយគ្រោងនឹងបញ្ចប់ចុងខែតុលា ឆ្នាំ២០២២ខាងមុខ។ ដើម្បីរួមចំណែកថែរក្សាមរតកវប្បធម៌ខ្មែរក្នុងវិស័យព្រះពុទ្ធសាសនានេះឱ្យបានគង់វង្ស ព្រមទាំងអភិរក្ស និងលើកតម្លៃវប្បធម៌នៃសិល្បៈរបស់ខ្មែរពីបុរាណកាលដ៏រស់រវើកឱ្យនៅឋិតថេរបន្តទៅមុខទៀត។

សូមបញ្ជាក់ថា ដំណាក់កាលទី១ គឺជួសជុលផ្នែកដំបូល មានដូចជា គ្រឿងបង្គំដំបូល ហោជាង ក្បឿងស្រការលិញ ក្បាច់រងស្បូវ ព្រំដំបូល បែរកា នាគបែង នាគដងក្តារ ព្រំខ្នងដំបូល និងជហ្វាជាដើម៕

លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរាចូលរួមប្រជុំស្ដីពីការបូកសរុបការងារ និងទិសដៅការងាររបស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ នៅទីក្រុងប៉ារីស

ផ្សាយនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២

នៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០២២ **លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរាបានដឹកនាំសហការី ចូលរួមកិច្ចប្រជុំបូកសរុបការងាររយៈពេល៣០ឆ្នាំ និងការពិភាក្សាទស្សនវិស័យរយៈពេល១០ឆ្នាំខាងមុខទៀតរបស់អាយស៊ីស៊ីអង្គរ(២០២៣-២០៣៣) នៅទីស្នាក់ការក្រសួងអឺរ៉ុប និងកិច្ចការអន្តរជាតិ នៅទីក្រុងប៉ារីស ប្រទេសបារាំង។

អង្គប្រជុំដ៏មានសារសំខាន់នោះ មានការអញ្ជើញចូលរួមពី **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា **ឯកឧត្តម បុង សុវត្ថិ** ឯកអគ្គរាជទូត ប្រតិភូអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការយូណេស្កូ និងភាគីពាក់ព័ន្ធសំខាន់មួយចំនួនទៀតដូចជា ភាគីបារាំងដឹកនាំដោយលោក Matthieu PEYRAUD ក្រសួងការបរទេសបារាំង លោក Bruno FAVEL លោកស្រី Francine d´ORGEVAL តំណាងក្រសួងវប្បធម៌បារាំង ភាគីជប៉ុនដឹកនាំដោយ លោក MIZUTANI Toshihiko លេខាទីមួយ ប្រតិភូអចិន្ត្រៃយ៍នៃប្រទេសជប៉ុនប្រចាំអង្គការយូណេស្កូ លោកស្រី Nao HAYASHI តំណាងអង្គការយូណេស្កូទីក្រុងប៉ារីស។ រីឯតំណាងគណៈកម្មាធិការអាយស៊ីស៊ី-អង្គរមានការអញ្ជើញចូលរួមដោយ លោកសាស្ត្រាចារ្យ Azedine BESCHAOUCH លេខាធិការវិទ្យាសាស្ត្រអចិន្ត្រៃយ៍នៃ គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ និងលោកសាស្ត្រាចារ្យ Mounir BOUCHENAKI អ្នកជំនាញចំពោះកិច្ចសម្រាប់ការអភិរក្សនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ។

គួរបញ្ជាក់ថា នៅក្នុងសម័យប្រជុំពេញអង្គលើកទី២៨នៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ នាទីស្នាក់ការអាជ្ញាធរជាតិអប្សរា នៅខេត្តសៀមរាប សហប្រធាននៃគណៈកម្មាធិការនេះគឺប្រទេសបារាំងនិងជប៉ុន បានប្រកាសយ៉ាងឱឡារិកអំពីការបន្តបេសកកម្មជ្រោមជ្រែង ចំនួន១០ឆ្នាំបន្ថែមទៀតដល់កម្ពុជា ក្នុងកិច្ចការអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ៕

សកម្មភាពក្រុមការងារសម្អាតស្មៅ និងកូនរុក្ខជាតិតូចៗនៅប្រាសាទព្រះខ័ន

ផ្សាយនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា ចូលរួមវេទិកាថ្ងៃនៃបណ្តាញក្រុមប្រឹក្សាផ្នែកកិច្ចសហប្រតិបត្តិការនិងសកម្មភាពវប្បធម៌

ផ្សាយនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២

នាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ ក្នុងឱកាសដ៏មមាញឹកបំពេញភារកិច្ចនាទីក្រុងប៉ារីស ប្រទេសបារាំង ពាក់ព័ន្ធនឹងកិច្ចការងាររៀបចំផែនការនិងទិសដៅ១០ឆ្នាំបន្ថែមទៀតរបស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា ត្រូវបានអញ្ជើញចូលរួមជាកិត្តិយសក្នុងវេទិកាថ្ងៃនៃបណ្តាញក្រុមប្រឹក្សាផ្នែកកិច្ចសហប្រតិបត្តិការនិងសកម្មភាពវប្បធម៌(Journées du réseau des conseillers de coopération et d´actions culturelles) នៅក្រសួងអឺរ៉ុបនិងការបរទេសបារាំង។

ជាការផ្តល់នូវកិត្តិយសដ៏ខ្ពង់ខ្ពស់និងតម្លៃមិនអាចកាត់ថ្លៃបាននៃការចូលរួមរបស់កម្ពុជាក្នុងសកម្មភាពកិច្ចសហប្រតិបត្តិការនិងវប្បធម៌ លោកជំទាវ Catherine COLONNA រដ្ឋមន្ត្រីក្រសួងអឺរ៉ុបនិងការបរទេសបារាំង បានថ្លែងនូវកិច្ចស្វាគមន៍ យ៉ាងរាក់ទាក់ជាទីបំផុត នូវវត្តមានរបស់ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** និងប្រតិភូកម្ពុជាទាំងអស់នាពេលនោះព្រមទាំងសម្តែងនូវការអរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលមានឆន្ទៈដ៏មោះមុតបំផុតក្នុងការសម្រេចបាននូវជោគជ័យដ៏ត្រចះត្រចង់លើការងារអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ៕

សកម្មភាពក្រុមការងារផ្នែកអនាម័យ នៃអាជ្ញាធរជាតិអប្សរា សម្អាតបរិស្ថានតាមដងផ្លូវ និងប្រាសាទក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២

ក្រុមការងារផ្នែកអនាម័យ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា បន្តការងារប្រចាំថ្ងៃ ដើម្បីសម្រស់ឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២

កូនឈើចម្រុះចំនួនជិត៧ពាន់ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរា ចែកចាយដល់សាធារណជន

ផ្សាយនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២

កូនឈើចម្រុះសរុប៦,៧៣០ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរាបន្តចែកចាយដល់ព្រះសង្ឃ និងសាធារណជននានា ចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ ដើម្បីយកទៅដាំតាមដីទំនេរ ឬដីចម្ការតាមបណ្តាខេត្តនានា។

កូនឈើដែលបានចែកចាយទាំងនោះរួមមាន៖

- ប្រគេនកូនឈើជូនព្រះញាណទេវោ សាំង អួយ ព្រះអនុគណស្រុកចុងកាល់ គង់នៅវត្តពុទ្ធិជោតមហាវ័ន្តតារៈបាត់ថ្មៅ ចំនួន៣,០០០ដើម ដើម្បីយកទៅដាំក្នុងពិធីធម្មយាត្រាដាំកូនឈើនៅព្រៃសង្ឃសហគមន៍ ស្ថិតនៅឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។ កូនឈើទាំងនោះរួមមាន គ្រញូង៥០០ដើម ធ្នង់៥០០ដើម បេង៣០០ដើម រំដួល២០០ដើម ក្រោកធំ២០០ដើម ពុល៣០០ដើម ឈើទាល៥០០ដើម និងគគីរ៥០០ដើម។

- ប្រគេនកូនគ្រញូងជូនព្រះវារិន្ទមុនី ទី ថា ព្រះគ្រូអនុគណស្រុកវ៉ារិន ចំនួន៣៨០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្តសុវណ្ណបុទុម ស្ថិតក្នុងភូមិរំដួល ឃុំវ៉ារិន ស្រុកវ៉ារិន ខេត្តសៀមរាប។

- ផ្តល់កូនឈើជូនតំណាងលោក ឃឹម ហ្វីណង់ អភិបាលនៃគណៈអភិបាលស្រុកបន្ទាយស្រី ចំនួន២,០០០ដើម ដើម្បីយកទៅដាំលម្អនៅតាមដងផ្លូវសាធារណៈ ក្នុងភូមិសាស្រ្ត ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ក្រោកតូច១,០០០ដើម ក្រោកធំ៥០០ដើម និងឥន្ទនេល៥០០ដើម។

- ផ្តល់កូនគ្រញូងជូនលោក រ័ត្ន ភារម្យ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៥០ដើម ដើម្បីយកទៅដាំនៅដីផ្ទាល់ខ្លួន ស្ថិតនៅស្រុកស្ទោង ខេត្តកំពង់ធំ។

- ផ្តល់កូនឈើជូនតំណាងនាយកដ្ឋានសណ្តាប់ធ្នាប់ និងផ្នែកផ្សេងៗនៃអាជ្ញាធរជាតិអប្សរា ចំនួន១,១៥០ដើម ដើម្បីយកទៅដាំលម្អនៅខាងកើតប្រាសាទអង្គរវត្ត ដីបុរីវប្បធម៌ និងសណ្ឋាគារ និងនៅខាងកើតប្រាសាទប្រែ។ កូនឈើទាំងនោះរួមមាន ធ្នង់៦០០ដើម ប្រេស៥០ដើម ឈើទាល២០០ដើម គគីរ១០០ដើម កកោះ៥០ដើម រំដួល១០០ដើម និងឥន្ទនេល៥០ដើម។

- ផ្តល់កូនឈើជូនលោក វង្ស គៀង ប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញ ចំនួន១៥០ដើម ដើម្បីយកទៅដាំនៅដីផ្ទាល់ខ្លួន ស្ថិតស្រុកទឹកផុស នៅខេត្តកំពង់ឆ្នាំង។ កូនឈើទាំងនោះរួមមាន គ្រញូង៣០ដើម ធ្នង់៣០ដើម បេង៦០ដើម និងប្រេស៣០ដើម។

អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការG.A.C.Pប្រទេសអាល្លឺម៉ង់ ធ្វើការជួសជុលក្បាច់ចម្លាក់កំបោរបាយអរ និងថ្មភក់តាមជញ្ជាំងតួប៉មឥដ្ឋទី៨ របស់ប្រាសាទបាគងដែលកំពុងទទួលរងការខូចខាត

ផ្សាយនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២

ក្រុមអ្នកបច្ចេកទេសអាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការ(G.A.C.P) កំពុងដំណើរការជួសជុលក្បាច់ចម្លាក់នានានៅតួប៉មឥដ្ឋទី៨របស់ប្រាសាទបាគង ដែលកំពុងទទួលរងនូវការខូចខាត ប្រឈមនឹងគ្រោះថ្នាក់ខ្លាំងដោយថ្មភក់និងកំបោរបាយអរមានការពុកផុយ របេះធ្លាក់បន្តិចម្តងៗ។

ការជួសជុលដែលចាប់ដំណើរការពីដើមឆ្នាំ២០២២មកនេះ បានផ្តោតសំខាន់ទៅលើការងារពង្រឹងក្បាច់ចម្លាក់ មួយចំនួន ដែលនៅសេសសល់តាមជញ្ជាំងប្រាសាទ កុំឱ្យខូចខាតបន្តទៀត។ ដោយប្រើប្រភេទការពិសេសម្យ៉ាងឈ្មោះ Ethyl silicate បញ្ជ្រាបចូលក្នុងសាច់ថ្មដែលពុកផុយ និងបិទភ្ជិតតាមស្នាមប្រេះនានា ដើម្បីឱ្យចម្លាក់មានភាពរឹងមាំឡើងវិញ ។

គម្រោងនេះត្រូវប្រើពេលយ៉ាងតិចក៏២ឆ្នាំដែរ ដោយគ្រោងនឹងបញ្ចប់នាដំណាច់ឆ្នាំ២០២៣ខាងមុខ។

រាជរដ្ឋាភិបាលចេញសេចក្តីសម្រេចស្តីពី ការតែងតាំងសមាសភាពក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ក្រោមការដឹកនាំដោយ ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងមានសមាសភាពចូលរួមមក ពី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២០ សសរ

ក្រសួង ដ.ន.ស.
ចូល លេខ 3525
ចុះថ្ងៃ 22.7.22

សេចក្តីសម្រេច
ស្តីពី
ការតែងតាំងសមាសភាពក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ០០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/៣១៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្ទេរអាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងក្រុមប្រឹក្សាដែលស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២០៣ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតអាជ្ញាធរជាតិអប្សរាជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

១/៣

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ៥០ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានអាជ្ញាធរជាតិអប្សរា
- យោងសេចក្តីសម្រេចលេខ២៦ សសរ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លី ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ ១.-

ត្រូវបានតែងតាំងសមាសភាពក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដែលមានរាយនាមដូចខាងក្រោម÷

១. ឯកឧត្តម **ជា សុផារ៉ា**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	ប្រធាន
២. លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា**	រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	អនុប្រធាន
៣. ឯកឧត្តម **ទៀ សីហា**	អភិបាលនៃគណៈអភិបាលខេត្តសៀមរាប	អនុប្រធាន
៤. ឯកឧត្តម **ស៊ឺ ម៉ាច**	រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	អនុប្រធានអចិន្ត្រៃយ៍
៥. ឯកឧត្តម **ឡោ ជាវុធ**	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៦. ឯកឧត្តម **លី ស្មើ**	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៧. ឯកឧត្តម **ឈន សុភាព**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៨. ឯកឧត្តម **ហ៊ី តាំងអេង**	រដ្ឋលេខាធិការក្រសួងផែនការ	សមាជិក
៩. ឯកឧត្តម **ហាច្យ សុគតសំណរ**	អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
១០. ឯកឧត្តម **ហង់ ពៅ**	អគ្គនាយកអាជ្ញាធរជាតិអប្សរា	សមាជិក
១១. ឯកឧត្តម **មេងហុង សុជាតិខេមរ៉ូ**	អគ្គនាយក នៃអគ្គនាយកដ្ឋានលំនៅឋាន	សមាជិក
១២. ឯកឧត្តម **ឃឹត ចាន់ជារដ្ឋ**	អគ្គនាយករងអាជ្ញាធរជាតិអប្សរា	សមាជិក
១៣. ឯកឧត្តម **ញ៉ុង កុសល**	អគ្គនាយករងអាជ្ញាធរជាតិអប្សរា	សមាជិក។

២/៣

ប្រការ ២.-

ក្រុមការងារនេះ មានតួនាទីនិងភារកិច្ចស្របតាមសេចក្តីសម្រេចលេខ២៦ សសរ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ ស្តីពីការបង្កើតក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា។

ប្រការ ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០២២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

៣/៣

សវនករស្ថាប័នធានាគុណភាពជប៉ុន ធ្វើសវនកម្មផ្ទៃក្រៅ តាមដានការងារបរិស្ថាន-អង្គរ

ផ្សាយនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២

នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ បានបើកសវនកម្មផ្ទៃក្រៅ ប្រព័ន្ធគ្រប់គ្រងបរិស្ថាន ISO14001: 2015 ដោយស្ថាប័នធានាគុណភាពជប៉ុន Japan Quality Assurance ហៅកាត់ថា(JQA)។ គោលបំណងនៃសវនកម្មតាមដានគឺដើម្បីបញ្ជាក់ថាអង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ បន្តកិច្ចការអនុលោមស្របតាមតម្រូវការស្តង់ដារ ISO14001 ដែរឬទេ។

តំណាងស្ថាប័ន JQA និងជាសវនករលោក ម៉ាម៉ូរុ យ៉ាម៉ាដា (Mamoru YAMADA) បានលើកឡើងតាមរយៈវីដេអូ Zoomថា ចំណុចដែលត្រូវយកមកពិនិត្យនៅក្នុងសវនកម្មផ្ទៃក្រៅនាពេលនេះ មានដូចតទៅ៖ ទី១ ពិនិត្យលើសវនកម្មផ្ទៃក្នុង និងត្រួតពិនិត្យការគ្រប់គ្រង ទី២ ពិនិត្យសវនកម្មលើកមុនដែលមិនមានភាពមិនអនុលោម ទី៣ ឆ្លើយតបរបស់អាជ្ញាធរជាតិអប្សរាទៅនឹងការតវ៉ាផ្សេងៗពីមជ្ឈដ្ឋានខាងក្រៅ បើសិនមានការតវ៉ាកើតឡើងនៅឆ្នាំមុន ទី៤ ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាន ទៅលើការសម្រេចគោលបំណង ទី៥ ស្ថានភាពរីកចម្រើនទៅមុខសម្រាប់សកម្មភាពកែលម្អជាបន្តបន្ទាប់ ទី៦ ការគ្រប់គ្រងប្រតិបត្តិការជាប្រចាំដែលបានចារនៅក្នុងសៀវភៅគ្រប់គ្រងបរិស្ថាន ទី៧ ការផ្លាស់ប្តូរផ្សេងៗនៅក្នុងប្រព័ន្ធគ្រប់គ្រង ទី៨ ភាពសមស្របនៃការប្រើប្រាស់ស្លាកសញ្ញាចុះបញ្ជី និងការបោះពុម្ពផ្សាយ ព័ត៌មានដែលបានចុះបញ្ជី។

សូមជម្រាបថា សវនកម្មនេះធ្វើឡើងរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៨ខែកក្កដា ឆ្នាំ២០២២ ដោយពិនិត្យវាយតម្លៃ នៅតាមនាយកដ្ឋានអង្គភាពចំណុះឱ្យអាជ្ញាធរជាតិអប្សរា និងនៅតាមរណីយដ្ឋានអង្គរដោយផ្ទាល់៕

ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការសាងសង់សំណង់ នៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២

យោងតាមសេចក្តីសម្រេចលេខ៧០ សសរ ស្តីពីការកំណត់បទដ្ឋាននៃការប្រើប្រាស់ដីធ្លីនៅតំបន់១ និងតំបន់២ ក្នុងតំបន់រមណីយដ្ឋានសៀមរាប-អង្គរ បានកំណត់ថា ប្រជាពលរដ្ឋដែលមានលំនៅឋាន និងរស់នៅយូរលង់ណាស់មកហើយ អាចបន្តរស់នៅតទៅទៀត ដោយមិនតម្រូវឱ្យចាកចេញពីភូមិដ្ឋានឡើយ។ អ្នកភូមិទាំងនោះ អាចរុះរើជួសជុលផ្ទះចាស់ ទ្រុឌទ្រោម ដើម្បីសាងសង់ផ្ទះថ្មី ជំនួសផ្ទះចាស់បាន ដោយមានការអនុញ្ញាតពីអាជ្ញាធរអប្សរា។ ក៏ប៉ុន្តែ រាល់ការសាងសង់ផ្ទះថ្មី ត្រូវហាមឃាត់ជាដាច់ខាត។

លោកឡូយ អ៊ិត អាយុ៦២ឆ្នាំ រស់នៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាបបានឱ្យដឹងថា លោករស់នៅក្នុងមូលដ្ឋាននេះជាច្រើនឆ្នាំមកហើយ ពោលគឺនៅមុនឆ្នាំ១៩៩៣ ដោយទទួលបានកេរ្តិ៍មរតកជាដីធ្លីទាំងនេះពីដូនតាមក។ លោកបន្តថា ដើមឡើយលំនៅឋានរបស់លោកមានសភាពចាស់ទ្រុឌទ្រោមយ៉ាងខ្លាំង តែលោកមិនហ៊ានដាក់ពាក្យស្នើសុំជួសជុលឡើយ ព្រោះយល់ថាអាជ្ញាធរជាតិអប្សរាមិនអនុញ្ញាត។ តែក្រោយមកលោកក៏ទទួលបានព័ត៌មានតាមការផ្សព្វផ្សាយពីក្រុមការងារសហគមន៍ ថាប្រជាពលរដ្ឋដែលរស់នៅយូរលង់ណាស់មកហើយ អាចស្នើសុំជួសជុលផ្ទះចាស់ទ្រុឌទ្រោមបាន ទើបលោកសម្រេចចិត្តដាក់ពាក្យស្នើសុំជាបន្តបន្ទាប់ រហូតអាចជួសជុលលំនៅឋានរបស់លោក បានល្អប្រសើដូចសព្វថ្ងៃ។

លោក នង សុវណ្ណារិទ្ធ អនុប្រធានលេខាធិការដ្ឋាន សហគមន៍បានឱ្យដឹងថា ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អង្គរជាយូរលង់ណាស់មកហើយ អាជ្ញាធរជាតិអប្សរា មិនបានហាមឃាត់ការជួសជុលផ្ទះសម្បែង បន្ទប់ទឹក ចង្ក្រានបាយ ឬរោងចិញ្ចឹមសត្វរបស់ពួកគាត់ឡើយ តែនៅពេលត្រូវការសាងសង់ឬជួសជួលលំនៅស្ថានរបស់ខ្លួន ពួកគាត់ត្រូវតែដាក់ពាក្យស្នើសុំមកអាជ្ញាធរជាតិអប្សរា តាមរយៈអាជ្ញាធរភូមិ ឃុំដែលនៅជិតបំផុត។ លោកបន្តថា រាល់ការដាក់ពាក្យស្នើសុំរបស់ប្រជាពលរដ្ឋមិនតម្រូវឱ្យបង់ប្រាក់ឡើយ តែពួកគាត់ត្រូវភ្ជាប់មកជាមួយនូវ ៖ អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ លិខិតបញ្ជាក់កម្មសិទ្ធិដីធ្លីដែលមានការបញ្ជាក់ពីអាជ្ញាធរក្នុងតំបន់។

សូមបញ្ជាក់ថា៖ ៦ខែដើមឆ្នាំ២០២២នេះ ក្រុមការងារលេខាធិការដ្ឋានសហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យការស្នើសុំជួសជុល និងសាងសង់តូចតាច ចំនួន៩២៧សំណើ ក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋបានចំនួន៦៨៣សំណើ។

រីករាយថ្ងៃចុងសប្ដាហ៍
សូមអញ្ជើញទស្សនាសម្រស់ប្រាសាទបន្ទាយក្ដី

ផ្សាយនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២

ក្រុមភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរា បានជួយសង្គ្រោះបឋមដល់ភ្ញៀវជនជាតិអូស្ត្រាលីម្នាក់ មានអាការហត់ដោយជំងឺប្រចាំកាយ

ផ្សាយនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២

ព្រឹកថ្ងៃទី៣០ខែកក្កដា ឆ្នាំ ២០២២ វេលាម៉ោង១១:១៤នាទី នៅចំណុចរូតព្រះពាន់នៃប្រាសាទអង្គរវត្ត ក្រុមភ្នាក់ងារទេសចណ៍នៃអាជ្ញាធរជាតិអប្សរា បានជួយសង្គ្រោះបឋមដល់ភ្ញៀវជនជាតិអូស្ត្រាលីម្នាក់ ឈ្មោះ Phul Ogarman អាយុ៨៧ឆ្នាំដោយមូលហេតុគាត់អស់កំលាំង និងមានអាការហត់ខ្លាំង (ដោយជំងឺហឺតប្រចាំខ្លួន)។ ក្រោយពីបានជួយសម្រួល និងមានអាការធូរស្បើយ ក្រុមការងារភ្នាក់ងារទេសចរណ៍បានជួយរក ម៉ូតូកង់បី មកយកគាត់ទៅកន្លែងស្នាក់នៅដោយសុវត្ថិភាព។

សូមបញ្ជាក់ថា ក្រុមភ្នាក់ងារទេសចរណ៍របស់អាជ្ញាធរជាតិអប្សរាតែងតែយកចិត្តទុកដាក់ជួយសង្គ្រោះបានទាន់ពេលវេលា ដល់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិដែលគ្រោះថ្នាក់ដោយករណីផ្សេងៗពេលទស្សនាក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលនេះជាកាតបព្វកិច្ច និងតួនាទីរបស់អាជ្ញាធរជាតិអប្សរាមានចំពោះភ្ញៀវទេសចរជាតិ និងអន្តរជាតិ គ្រប់ជាតិសាសន៍៕

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរានាំយកអំណោយប្រគល់ជូន លោក ចិន គឹមឡេង ភ្នាក់ងារព័ត៌មានទូរទស្សន៍ BTV ដែលមានជំងឺប្រចាំកាយ

ផ្សាយនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២

នៅព្រឹថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២នេះ **ឯកឧត្តម ឡុង កុសល** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បាននាំយកអំណោយជាគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួនមកប្រគល់ជូន លោក ង៉ិន គឹមឡេង ជាភ្នាក់ងារព័ត៌មានទូរទស្សន៍ BTV ប្រចាំខេត្តសៀមរាប ដែលកំពុងមានជំងឺប្រចាំកាយ (ស្លាប់មួយចំហៀងខ្លួន) នឹងកំពុងសម្រាកព្យាបាលនៅផ្ទះ ដោយបច្ចុប្បន្នកំពុងជួបការខ្វះខាតក្នុងជីវភាពប្រចាំថ្ងៃ។

ក្នុងឱកាសនោះ **ឯកឧត្តម ឡុង កុសល** ក៏បានធ្វើការសួរសុខទុក្ខ និងលើកទឹកចិត្តដល់លោ ក ង៉ិន គឹមឡេង ត្រូវខិតខំមើលថែជំងឺទៅតាមលទ្ធភាព ដោយមិនត្រូវអស់សង្ឃឹមឡើយ។ ចំពោះអំណោយ និងថវិកាដែលបាននាំយកមកជូននាពេលនេះ ត្បិតតែមិនអាចយកទៅប្រើប្រាស់លើកិច្ចការធំៗបានក្តី តែក៏ជាការរួបចំណែកជួយសម្រួលដល់ការលំបាកបានមួយគ្រាៗ។

ជាមួយគ្នានោះដែរ ក្រុមគ្រួសារលោក ង៉ិន គឹមឡេង បានសម្តែងនូវក្តីត្រេកអរ លាយឡំជាមួយភាពទុក្ខព្រួយដោយសារស្វាមី បានធ្លាក់ខ្លួនឈឺជម្ងឺលើសសំពាធឈាម និយាយមិនចេញ និងដើរមិនរួច ខណៈគ្រួសារគ្មានអ្វីជាទីពឹងនោះទេ។

សូមជម្រាបថា អំណោយដែលបាននាំយកមកប្រគល់ជូននាឱកាសនោះ រួមមាន៖ អង្ករ១០០គីឡូក្រាម ថវិកាចំនួន ៤០ម៉ឺនរៀល ត្រីខ២យួរ ទឹកសុទ្ធ៣កេស ត្រីងៀត ១គីឡូក្រាម សាច់ក្រក១គីឡូក្រាម នឹងចាក់ថ្នូម៉ិច០១ឡាន នៅមុខផ្ទះគិតជាថវិកា២០ម៉ឺនរៀល ដាក់គ្រែ១ តុបាយ១ បន្ថែមទៀត៕

សកម្មភាពក្រុមការងារផ្នែកអនាម័យ នៃអាជ្ញាធរជាតិអប្សរា សម្អាតបរិស្ថានតាមដងផ្លូវ និងប្រាសាទក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២



ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែសីហា

គម្រោងជួសជុលប្រាំងកសិន្ធុខាងជើង មុខប្រាសាទអង្គរវត្ត ប្រវែងចំនួន២០ម៉ែត្រ បន្ថែមទៀត គ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២២ខាងមុខ

ផ្សាយនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២

គម្រោងជួសជុលប្រាំងកសិន្ធុខាងជើងមុខប្រាសាទអង្គរវត្ត ដំណាក់កាលទី៧ ប្រវែងចំនួន២០ម៉ែត្រជាបន្តទៀត លើការងារជួសជុលពង្រឹងគ្រឹះ និងរៀបកាំជណ្តើរពីថ្មបាយក្រៀម ព្រមទាំងត្រៀមរៀបកាំជណ្តើរធ្វើពីថ្មភក់បុរាណតាមលំនាំដើមឡើងវិញផងនោះ សម្រេចបានប្រមាណ៤០ភាគរយហើយ។

បុរាណវិទូ នៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ ជាប្រធានការដ្ឋានជួសជុលប្រាំងកសិន្ធុអង្គរវត្ត ជ្រុងខាងជើង អ្នកស្រី នង ប៉ូរ៉ាវី បានឱ្យដឹងថា មកដល់ពេលនេះ ដំណើរការជួសជុល សម្រេចបានប្រមាណ៤០ភាគរយហើយ លើការងារជួសជុលពង្រឹងគ្រឹះនៃបាតប្រាំងកសិន្ធុ រៀបកាំជណ្តើរពីថ្មបាយក្រៀមថ្មីជំនួសថ្មបាយក្រៀមចាស់ពុកផុយខូចខាតទាំងអស់ឡើងវិញបាន ៧កាំ ព្រមទាំងបានរក្សាទម្រង់ដើមរបស់លូបុរាណ ដោយប្រើថ្មបាយក្រៀមថ្មី ជំនួសថ្មបាយក្រៀមចាស់ដែលពុកផុយនៅផ្នែកខាងមុខជាប់នឹងមាត់ប្រាំងកសិន្ធុ ហើយត្រៀមនឹងរៀបកាំជណ្តើរធ្វើពីថ្មភក់ចំនួន៤កាំជាបន្តទៀត។

អ្នកស្រី នង ប៉ូរ៉ាវី បញ្ជាក់ទៀតថា ជំហានដំបូងក្រុមការងារបានធ្វើកំណាយស្រាវជ្រាវ ប្រទះឃើញលូបង្ហូរទឹកបុរាណដែលមានទំនាក់ទំនងពីកសិន្ធុទឹកប្រាសាទអង្គរវត្តទៅនឹងត្រពាំងសេសនៅមានស្ថានភាពល្អ។ ជាមួយគ្នានោះ ក្រុមការងារក៏បានបិទទំនប់ទឹកដើម្បីសម្រួលដល់ការងារជួសជុលគ្រឹះប្រាំងកសិន្ធុ ធ្វើសម្រង់ប្លង់ថ្ម ដែលជ្រុះធ្លាក់ចូលទៅក្នុងប្រាំង ព្រមទាំងរុះរើថ្មដោយប្រើកៅឡាក់អូសចេញពីប្រាំងខាងក្រោមឡើងទៅប្រាំងខាងលើ លាងសម្អាត ចុះបញ្ជីថ្ម និងជួសជុល មុននឹងយកមករៀបនៅទីតាំងដើមវិញផង។

ប្រាំងកសិន្ធុផ្នែកខាងជើងស្ពានហាលខាងលិចនៃប្រាសាទអង្គរវត្ត ក៏ជាទីតាំងដែលភ្ញៀវទេសចរជាតិ និងអន្តរជាតិនិយមមកផ្តិតយករូបភាព ប្រាសាទអង្គរកំពូលប្រាំដ៏ស្រស់ស្អាត។ នៅពេលការជួសជុលរួចរាល់ជាស្ថាពរ នឹងលើកសោភ័ណប្រាំងកសិន្ធុ ស្រស់ស្អាតទ្វេឡើង ហើយរក្សាបាននូវស្នាដៃដូនតាបានអង្វែងជាច្រើនជំនាន់ទៅមុខទៀតផង។

សូមជម្រាបថា ចាប់តាំងពីឆ្នាំ២០១៣ រហូតមកដល់ឆ្នាំ ២០២២ អាជ្ញាធរជាតិអប្សរាជួសជុលប្រាំងកសិន្ធុអង្គរវត្ត ជ្រុងខាងជើង សរុបបានប្រវែង១៤៣ម៉ែត្រ៕

ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា សូមសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹង ចំពោះការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ មាត្រា១៩ថ្មី (មួយ) មាត្រា៨៩ថ្មី មាត្រា១២០ថ្មី មាត្រា១១៩ថ្មី(មួយ) មាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៤ថ្មី នៃច្បាប់រដ្ឋធម្មនុញ្ញបន្ថែម ដែលរដ្ឋសភាជាតិ បានអនុម័តកាលពីព្រឹកថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២

ផ្សាយនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

ញត្តិគាំទ្រ
ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា សូមសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹង ចំពោះការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ មាត្រា១៩ថ្មី (មួយ) មាត្រា៨៩ថ្មី មាត្រា១២០ថ្មី មាត្រា១១៩ថ្មី (មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ថ្មី មាត្រា៤ថ្មី នៃច្បាប់រដ្ឋធម្មនុញ្ញបន្ថែម ដែលរដ្ឋសភាបានអនុម័តកាលពីព្រឹកថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ គឺបានធ្វើឡើងយ៉ាងត្រឹមត្រូវតាមគោលការណ៍ និងនីតិវិធីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ក្នុងនោះសំដៅធានាឱ្យបាននូវនិរន្តរភាពជាតិ និងសុខសន្តិភាពជូនដល់ប្រជាជនកម្ពុជាទាំងមូល។

ការធ្វើវិសោធនកម្មលើកទី១០នៃរដ្ឋធម្មនុញ្ញនាពេលនេះ ធ្វើឡើងដើម្បីការពារឧត្តមប្រយោជន៍ជាតិ អនុវត្តនូវរបបប្រជាធិបតេយ្យ សេរីពហុបក្ស និងធានាឱ្យស្ថាប័នរបស់រដ្ឋមានកិច្ចដំណើរការប្រព្រឹត្តទៅដោយរលូន មិនជាប់គាំង មានស្ថិរភាពនយោបាយ ការពារ ថែរក្សានូវសុខសន្តិភាព និងមានការអភិវឌ្ឍឱ្យកាន់តែរីកចម្រើនលើគ្រប់វិស័យដែលជាតម្រូវការរបស់ជាតិ និងប្រជាជនកម្ពុជាគ្រប់រូប។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នា សូមគាំទ្រយ៉ាងឱឡារិកចំពោះការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី ១០ និងប្តេជ្ញាចូលរួមអនុវត្តតាមការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលបម្រើឱ្យបូរណភាពទឹកដី សុខសន្តិភាព ស្ថិរភាពសង្គម ការលើកកម្ពស់កិត្យានុភាពជាតិ និងការអភិវឌ្ឍជាតិឱ្យកាន់តែមានភាពរីកចម្រើនលើគ្រប់វិស័យ។

ថ្ងៃចន្ទ ៤កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សៀមរាប ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២
អាជ្ញាធរជាតិអប្សរា

ភ្នំពេញ៖
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh
សៀមរាប៖

1/1

អាជ្ញាធរជាតិអប្សរារៀបចំសិក្ខាសាលាស្តីពីការគ្រប់គ្រងដីតំបន់១ និងតំបន់២ ពង្រឹងចំណេះដឹងដល់មន្ត្រី និងបុគ្គលិក

ផ្សាយនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០២២ បាន រៀបចំសិក្ខាសាលាស្តីពី ការគ្រប់គ្រងដីធ្លីនៅតំបន់១ និង តំបន់២ ក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលធ្វើឡើងនៅ មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ នៃអាជ្ញាធរជាតិអប្សរា។ សិក្ខាសាលានេះ មានការចូលរួមពីជាវាគ្មិនដោយ **លោកជំទាវ ជា សុភន្ធន** និង **ឯកឧត្តម ស៊ន់ សុជាតិ** ទីប្រឹក្សាក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងជា មេធាវីរបស់អាជ្ញាធរជាតិអប្សរា។ ក្នុងនោះ ក៏មានការចូលរួម ពីលោក ស៊ឹម ប៊ុនធឿន អនុប្រធាននាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរផងដែរ។

សិក្ខាសាលានេះ ធ្វើឡើងក្នុងបំណងពង្រឹងសមត្ថភាព និង ផ្តល់ចំណេះដឹងបន្ថែម ដល់មន្ត្រី បុគ្គលិក នៃនាយកដ្ឋាន រៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ ឱ្យបាន ជ្រាបកាន់តែច្បាស់លើចំណេះដឹងផ្នែកច្បាប់ និងនីតិវិធី ក្នុងការចុះសម្របសម្រួលការងារ បានកាន់តែប្រសើរ ស្របតាមទិសដៅរបស់អាជ្ញាធរជាតិអប្សរា ក្នុងការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរប្រកបដោយចីរ ភាព។សិក្ខាសាលានេះមានអ្នកចូលរួមប្រមាណ៦០នាក់។

មេធាវីអាជ្ញាធរជាតិអប្សរា **លោកជំទាវ ជា សុភន្ធន** បានចាប់ផ្តើមលើកឡើងពីច្បាប់ និងលិខិតគតិយុត្ត មួយចំនួនក្នុងការងារគ្រប់គ្រងដីតំបន់១និងតំបន់២ដែលជា ដីទ្រព្យសម្បត្តិសាធារណរបស់រដ្ឋ គ្រប់គ្រងដោយអាជ្ញាធរ ជាតិអប្សរា ក្នុងការគ្រប់គ្រង ថែរក្សា និងអភិវឌ្ឍន៍ប្រកប ដោយចីរភាព។ ដូច្នេះដើម្បីអនុវត្តន៍តាមលក្ខខណ្ឌ ក្នុងការចុះបញ្ជីបញ្ចូលរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌ ពិភពលោករបស់អង្គការយូណេស្កូ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតច្បាប់ បទបញ្ជា និងបទដ្ឋានគតិយុត្តនានា ជាបន្តបន្ទាប់ ដើម្បីកំណត់ និងចាត់ចែងគ្រប់គ្រងតំបន់ រមណីយដ្ឋានអង្គរ។

មេធាវី ស៊ន់ សុជាតិ បានលើកឡើងដែរថា ការប្រើប្រាស់ ដីធ្លីក្នុងតំបន់១ និងតំបន់២ គឺអនុញ្ញាតឱ្យប្រជាពលរដ្ឋ ដែលមានលំនៅដ្ឋាន និងរស់នៅយូរលង់មកហើយ អាច បន្តរស់នៅបាន តែពុំមានសិទ្ធិលក់ដូរទេ។ ករណីផ្ទះ សម្បែងទ្រុឌទ្រោម អាចស្នើសុំជួសជុល រុះរើ ឬសាងសង់ ថ្មីបាន ហើយក៏មានករណីចាំបាច់ដោះស្រាយជីវភាព ពួកគេក៏អាចលក់ដូរឱ្យអ្នកភូមិផងជាមួយគ្នាបានដែរ តែ ហាមសម្រាប់ការលក់ឱ្យអ្នកចំណូលថ្មី៕

អាជ្ញាធរជាតិអប្សរាផ្ញើសារជូនពរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នាឱកាសខួបកំណើតគម្រប់៧០ឆ្នាំ ឈានចូល៧១ឆ្នាំ

ផ្សាយនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ៤១៥/អរ.លជ៣/២២

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងឱកាសដ៏សែនមហានក្ខត្តឫក្សថ្លៃថ្លា នៃថ្ងៃចម្រើនជន្មាយុគម្រប់៧០ឆ្នាំ ឈានចូល៧១ឆ្នាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២ខាងមុខនេះ តាងនាមមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ យើងខ្ញុំសូមសម្តែងនូវមនោសញ្ចេតនារីករាយឥតឧបមា និងសេចក្តីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត ព្រមទាំងសូមគោរពជូនពរ បវរមហាប្រសើរជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ សូមមានជន្មាយុយឺនយូរ សុខមាលភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា ដើម្បីដឹកនាំរាជរដ្ឋាភិបាល និងប្រទេសជាតិទទួលបានជោគជ័យដ៏ត្រចះត្រចង់ថ្មីៗបន្ថែមទៀត ជាពិសេសវឌ្ឍនភាព និងកិត្យានុភាពល្បីរន្ទឺលើឆាកអន្តរជាតិ។

យើងខ្ញុំទាំងអស់គ្នាសូមកោតសរសើរយ៉ាងស្មោះអស់ពីដួងចិត្ត ចំពោះគំរូវីរភាពដ៏អង់អាចក្លាហាន ការលះបង់ និងពលិកម្មគ្រប់បែបយ៉ាង យកអស់កម្លាំងកាយចិត្តដឹកនាំនាវាកម្ពុជាប្រកបដោយគតិបណ្ឌិត និងដោយពុំចេះនឿយហត់ក្នុងការបំពេញនូវបេសកកម្មជាប្រវត្តិសាស្ត្រ ដើម្បីជាតិមាតុភូមិ និងប្រជាជន ជាពិសេសការផ្សះផ្សាបង្រួបបង្រួមជាតិ នាំមកនូវឯកភាពជាតិ ស្ថិរភាពនយោបាយ និងការអភិវឌ្ឍលើគ្រប់វិស័យ។

ជាថ្មីម្តងទៀត តាងនាមមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ យើងខ្ញុំសូមសម្តែងនូវកតញ្ញុតាធម៌ សូមលំឱនកាយបួងសួង ដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតារក្សាព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សា អភិបាលប្រោះព្រំ សព្ទសាធុការពរ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ព្រមទាំងក្រុមគ្រួសារ សូមបានប្រកបដោយពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជាមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ។

ថ្ងៃអង្គារ ៥កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សៀមរាប ថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២២
អគ្គនាយក

ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបន្ទាយ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារបេតិកភណ្ឌ និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune, Prasat Bakong District, Siem Reap Province

រដ្ឋមន្ត្រីការបរទេសឥណ្ឌាទស្សនាប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២

នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២នេះ **ឯកឧត្តម Subrahmanyam Jaishankar** រដ្ឋមន្ត្រីការបរទេសឥណ្ឌា និងគណប្រតិភូ បានអញ្ជើញមកដល់ខេត្តសៀមរាបហើយ។

ក្នុងទស្សនកិច្ចរយៈពេលខ្លីក្នុងខេត្តសៀមរាប លោករដ្ឋមន្ត្រីការបរទេសឥណ្ឌា បានអញ្ជើញទៅទស្សនាប្រាសាទតាព្រហ្ម ពិសេសចូលទស្សនាសាលរបាំ ដែលទើបនឹងជួសជុលរួច ដែលគម្រោងនេះ ជាកិច្ចសហប្រតិបត្តិការរវាងស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា (ASI) និងអាជ្ញាធរជាតិអប្សរា។

ក្រៅពីនេះ ឯកឧត្តមក៏នឹងទៅទស្សនាប្រាសាទអង្គរវត្ត និងសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ីផងដែរ មុននឹងចាកចេញទៅរាជធានីភ្នំពេញ ដើម្បីចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥៕

អាជ្ញាធរជាតិអប្សរា កំពុងមមាញឹកក្នុងការងារដាំស្មៅ នៅបរិវេណខាងមុខ ឆៀងត្បូងប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២

ដើម្បីចូលរួមចំណែកលើកកម្ពស់របៀបរៀបរយ សោភ័ណភាព បរិស្ថាន និងទេសភាពបៃតងស្រស់ស្អាតគ្រប់រដូវកាលនៅក្នុងរមណីយដ្ឋានអង្គរឱ្យស័ក្តិសមជាតំបន់បេតិកភណ្ឌពិភពលោក ព្រមទាំងទាក់ទាញភ្ញៀវទេសចរឲ្យកាន់តែច្រើនមកកម្សាន្តផងនោះ អាជ្ញាធរជាតិអប្សរា កំពុងមមាញឹកក្នុងការងារដាំស្មៅ នាបរិវេណខាងមុខប្រាសាទអង្គរវត្ត (អតីតអង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំតំបន់អង្គរ)។

លោកស្រីអាំង សុចិន្តា មន្ត្រីនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត ជ្រុងខាងត្បូងនេះ ក្រុមហ៊ុនកំពុងដាំស្មៅ ចំណែកនៅតាមព្រំ មានដាំលម្អរទៅដោយដើមឈើ និងផ្កាព្រៃចម្រុះមួយចំនួន ក្រោមទំហំផ្ទៃដីចំនួន២៤,០០០ម៉ែត្រការ៉េ។ រហូតមកដល់ដើមខែសីហានេះ ការងារសម្រេចបានប្រមាណ៣០ភាគរយហើយ ដោយចាប់ផ្តើមដំណើរការតាំងពីអំឡុងដើមខែកក្កដាមក គ្រោងចំណាយពេលវេលាចំនួន៤ខែទើបរួចរាល់។

លោកស្រីបន្តទៀតថា ក្រោយការងារដាំដុះស្មៅនៅបរិវេណនេះរួចរាល់ ទីនេះនឹងពោពេញទៅដោយវាលស្មៅស្រស់បំព្រង ហើយភ្ញៀវទេសចរអាចចូលមកថតរូបកម្សាន្តបាន ដោយអាចបញ្ចៀសការកកស្ទះ ចំនួនភ្ញៀវចូលទស្សនាប្រាង្គប្រាសាទបានមួយចំនួន ជាពិសេសទីតាំងខាងលើអាចរៀបចំប្រារព្ធពិធីផ្សេងៗ ជំនួសឱ្យទីតាំងចំពីខាងមុខប្រាសាទអង្គរវត្ត។

សូមជម្រាបផងដែរថា វាលស្មៅខៀវខ្ចីទាំងនៅជុំវិញបរិវេណប្រាសាទអង្គរវត្ត ឬខាងក្រៅប្រាសាទ ត្រូវទទួលការថែទាំជាប្រចាំដោយអាជ្ញាធរជាតិអប្សរា ទាំងការស្រោចស្រព ថែទាំ និងកាត់សម្អាតជាប្រចាំ ធ្វើយ៉ាងណាឱ្យតំបន់រមណីយដ្ឋានអង្គរមានភាពបៃតងស្រស់ស្អាតទាំងខ្យបប្រាំង និងវស្សា៕

ដំណើរទស្សនកិច្ចរដ្ឋមន្ត្រីការបរទេសឥណ្ឌា នៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២

នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២នេះ ឯកឧត្តម Subrahmanyam Jaishankar រដ្ឋមន្ត្រីការបរទេសឥណ្ឌា និងគណប្រតិភូចំនួន១១នាក់ទៀត បានមកធ្វើទស្សកិច្ច នៅរមណីយដ្ឋានអង្គរ។

នៅក្នុងដំណើរទស្សនកិច្ចនេះផងដែរ គណប្រតិភូក៏បានទៅទស្សនា ប្រាសាទអង្គរវត្ត ប្រាសាទតាព្រហ្ម និងសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី ក្នុងនោះក៏មានការចូលរួមអមដំណើរដោយ **ឯកឧត្តម បណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អគ្គនាយករង និងមន្ត្រីជំនាញមួយចំនួនទៀតផងដែរ៕

ខែកក្កដា ឆ្នាំ២០២២ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន១៨៩សំណើ

ផ្សាយនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២

លទ្ធផលការងារសហគមន៍ របស់អាជ្ញាធរជាតិអប្សរា ប្រចាំខែកក្កដា ក្នុងឆ្នាំ២០២២ បានចុះផ្សព្វផ្សាយអប់រំ និងពិនិត្យការស្នើសុំជួសជុលផ្ទះ រួមទាំងសាងសង់តូចតាច ទាំង៥ស្រុក/ក្រុង ក្នុងតំបន់រមណីយដ្ឋានអង្គរ បានចំនួន ២៤៥សំណើ ដែលក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋ ចំនួន១៨៩សំណើ។

ក្នុងករណីអនុញ្ញាតជូនប្រជាពលរដ្ឋខាងលើ រួមមាននៅស្រុកប្រាសាទបាគងបានចំនួន១៨សំណើ ស្រុកអង្គរធំបានចំនួន០៣សំណើ ស្រុកពួកបានចំនួន១៨សំណើ និងក្រុងសៀមរាបបានចំនួន៧៥សំណើ ស្រុកបន្ទាយស្រី៧៥សំណើ សរុបចំនួន១៨៩សំណើ។

ក្រុមការងារសហគមន៍ជួបនូវបញ្ហាប្រឈមមួយចំនួនដូចជា ការប្រកាសលក់ដីក្នុងតំបន់ការពារតាមរយៈបណ្តាញទំនាក់ទំនងសង្គមហ្វេកប៊ុក និងដាក់ស្លាក (លក់ដី) ផ្ទាល់ក្នុងតំបន់បេតិកភណ្ឌនៅតែមាន។

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា មានគោលដៅផ្សព្វផ្សាយ អប់រំដល់ប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី ភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់បេតិកភណ្ឌនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរឱ្យកាន់តែមានប្រសិទ្ធិភាពទាន់ពេលវេលា។

ភរិយា និងស្វាមី គណៈប្រតិភូ នៃបណ្តារដ្ឋមន្ត្រីការបរទេសអាស៊ាន បានទស្សនាតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២

នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២ **លោកជំទាវ ខេង សំវ៉ាដា ភរិយាឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជាបាន ដឹកនាំគណៈប្រតិភូជា ភរិយា និងស្វាមី នៃបណ្តារដ្ឋមន្ត្រីការបរទេសអាស៊ាន អញ្ជើញទស្សនាតំបន់រមណីយដ្ឋានអង្គរ។

ទេសភាពស្រស់បំព្រងនៃប្រាសាទបាលិលេយ្យនារដូវវស្សា

ផ្សាយនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២

សម្រស់ប្រាសាទតាព្រហ្មក្រោយពេលភ្លៀងធ្លាក់

ផ្សាយនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២២

សេចក្ដីជូនដំណឹង ស្ដីពីការដកហូតដើមឈើមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា

A P S A R A

លេខ: ៥១៩/២២ អប.សង៧

សេចក្ដីជូនដំណឹង

ស្ដីពី

ការកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ

មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាព នៅតាមដងផ្លូវ និងតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ នៅតាមទីតាំងនានាដូចខាងក្រោម៖

- កាត់ដកហូតដើមចំបក់០១ដើម ដែលមានហានិភ័យស្ថិតនៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប
- កាត់ដកហូតដើមឈើទាលចំនួន០២ដើម ដែលមានហានិភ័យស្ថិតនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប
- កាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើចំនួន៤៩ដើម (កាត់ដកហូតអង្កោល០១ដើម កាត់ក្រី៤៨ដើម រួមមានស្រឡៅ០៥ដើម ឈើទាល១៨ដើម ចាមរី១០ដើម អង្កោល០៤ដើម ស្វាយ០៤ដើម ពង្រ០៣ដើម ស្ទួល១ដើម ចំបក់០២ដើម និងខ្វាស់០១ដើម) ដែលមានហានិភ័យស្ថិតនៅបរិវេណចំណតប្រាសាទបាខែង
- កាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើចំនួន៤៧ដើម (ដកហូតស្រឡៅ០២ដើម កាត់ក្រី៤៥ដើម រួមមានឈើទាល៣៥ដើម សង្កែ០២ដើម រាំងភ្នំ០១ដើម ចាមរី០១ដើម ស្រឡៅ០៥ដើម ពង្រ០១ដើម ស្ថិតនៅបរិវេណខាងលិចប្រាសាទបាយ័ន (ព្រះអង្គគោកធ្លក)
- កាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើចំនួន១០ដើម (ដកហូតដើមឈើ០៥ដើមរួមមាន ឈើទាល០៤ដើម អំពិល០១ដើម កាត់ក្រីចំនួន០៥ដើមរួមមាន ចំបក់០១ដើម សិរមាន់០១ដើម កន្ទ្រក០១ដើម ស្វាយ០២ដើម ដែលមានហានិភ័យស្ថិតនៅបរិវេណប្រាសាទព្រះខ័ន និងចំណតច្រកចូលខាងលិច
- កាត់ដកហូតដើមឈើទាលចំនួន០៣ដើម ដែលមានហានិភ័យស្ថិតនៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប
- កាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ១៥ដើម (កាត់ដកហូត០២ដើមរួមមាន ពង្រ០១ដើម ឈើទាល១ដើម កាត់ក្រី១៣ដើមរួមមាន ដើមព្រីង០២ដើម ឈើទាល០១ដើម ស្រឡៅ០៥ដើម បេង០២ដើម និងចំបក់០៣ដើម) ដែលមានហានិភ័យស្ថិតនៅបរិវេណប្រាសាទតាព្រហ្ម
- កាត់ដកហូតដើមឈើ០៧ដើម (ឈើទាល០៣ដើម សំរោង០៤ដើម) ដែលមានហានិភ័យស្ថិតនៅវិទ្យាល័យស្រីវិបុលកេរ្តិ៍ ភូមិក្រាច ឃុំបល្ល័ង្គ ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្ដើមអនុវត្តការងារខាងលើចាប់ពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ តទៅរហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។៚

ថ្ងៃសុក្រ ៨កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

សៀមរាប ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារតំបន់រមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋានជូនប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរចំនួន៨៦០គ្រួសារ

ផ្សាយនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២

នាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ នៃអាជ្ញាធរជាតិអប្សរាឱ្យដឹងថា ក្នុងអំឡុងខែកក្កដា ឆ្នាំ២០២២ ក្រុមការងារបានចុះពិនិត្យ និងជួយសម្រួលលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន និងសំណង់ឧបសម្ពន្ធផ្សេងៗទៀតដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ និងក្រៅតំបន់រមណីយដ្ឋានអង្គរ បានចំនួន៨៦០គ្រួសារ។

ចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ចំនួន៨៣៩គ្រួសារ ក្រុងសៀមរាប២៤៧គ្រួសារ ស្រុកប្រាសាទបាគង១៧៨គ្រួសារស្រុកបន្ទាយស្រី១៧៣គ្រួសារ ស្រុកពួក១៨៤គ្រួសារ និងស្រុកអង្គរធំ៥៧គ្រួសារ។ ចំណែកប្រជាពលរដ្ឋរស់នៅក្រៅតំបន់រមណីយដ្ឋានអង្គរចំនួន២១គ្រួសារ ស្រុកស្វាយលើ១៨គ្រួសារ ស្រុកសូទ្រនិគម០៣គ្រួសារ។

សូមបញ្ជាក់ថា រាល់ការអនុញ្ញាត និងដាក់ពាក្យសាងសង់ស្នើសុំ គឺមិនតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ៕

កូនឈើចម្រុះចំនួន៩,៥២០ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយដល់សាធារណជន

ផ្សាយនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២

កូនឈើចម្រុះសរុបចំនួន ៩,៥២០ដើមទៀត ត្រូវបាននាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា ចែកចាយដល់សាធារណជន ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២។ - ប្រគេនកូនឈើជូនព្រះវារិន្ទមុនី ទី ថា ព្រះគ្រូអនុគណស្រុកវ៉ារិន ចំនួន៤២០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្តសុវណ្ណបុទុម ស្ថិតក្នុងភូមិរំដួល ឃុំវ៉ារិន ស្រុកវ៉ារិន ខេត្តសៀមរាប។

- ប្រគេនកូនឈើជូនព្រះសទ្ធម្មប្បកាសនី តាត មហាទី ព្រះគ្រូចៅអធិការវត្តព្រះឥន្ទកោសាចំនួន ៣,០០០ដើម ដើម្បីយកទៅដាំ និងចែកជូនតាមឃុំទាំង៩ ក្នុងស្រុកប្រាសាទបាគង ខេត្តសៀមរាប រួមទាំងចូលរួមដាំព្រៃឈើឡើងវិញនៅរមណីយដ្ឋានភ្នំតាម៉ៅផង។
- ផ្តល់កូនឈើជូនតំណាងឯកឧត្តម ឧត្តមសេនីយ៍ឯក សេង សារី មេបញ្ជាការទិសយោធភូមិភាគទី៤ នៃកងទ័ពជើងគោក ចំនួន៥០០ដើម ដើម្បីយកទៅដាំនៅបរិវេណទីបញ្ជាការ ស្ថិតនៅភូមិខ្នារផ្អោល ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប។
- ផ្តល់កូនឈើចម្រុះជូនអ្នកស្រី យឹម សុភ័ក្រ នាយិការរងសាលាបឋមសិក្សាប្រាសាទគោកចក ចំនួន២៧០ដើម ដើម្បីយកទៅដាំលម្អក្នុងបរិវេណសាលារៀន ស្ថិតក្នុងភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។
- ផ្តល់កូនឈើ ជូនតំណាងនាយកដ្ឋានសណ្តាប់ធ្នាប់នៃអាជ្ញាធរជាតិអប្សរា ចំនួន២០០ដើម ដើម្បីយកទៅដាំនៅបរិវេណចំណតប្រាសាទនាគព័ន្ធ។
- ផ្តល់កូនឈើជូនលោក គី ឡាយ មេឃុំសសរស្តម្ភ ចំនួន៩៥០ដើម ដើម្បីយកទៅដាំលម្អតាមដងផ្លូវ ស្ថិតក្នុងឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប។
- ផ្តល់កូនឈើជូនលោក សាប៉ាត់ សាប៉ាក់ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៥០ដើម ដើម្បីយកទៅដាំនៅបរិវេណដីសហគមន៍ ស្ថិតក្នុងភូមិគំរូ ឃុំស្រណាល ស្រុកក្រឡាញ់ ខេត្តសៀមរាប។
- ផ្តល់កូនឈើជូនអ្នកស្រី មូល សុធីរា ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៣០០ដើម ដើម្បីយកទៅដាំនៅបរិវេណវត្តសំរិទ្ធិជយារាម ស្ថិតក្នុងភូមិចុងកោះ ឃុំកោះអណ្តែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។
- ផ្តល់កូនឈើជូនកញ្ញា យឿម ស៊ីន ប្រធានគ្រប់គ្រងនៃក្រុមយុវជនកម្ពុជា ខេត្តសៀមរាប ចំនួន២,៤០០ដើម ដើម្បីយកទៅចូលរួមជាមួយអង្គការ អាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលស្រុកក្រឡាញ់ ដាំលំអតាមគេហដ្ឋាន សាលារៀន និងតាមដងផ្លូវចាប់ពីភូមិសន្លុន ដល់ភូមិសំបួរ ឃុំសំបួរ ស្រុកក្រឡាញ់ ខេត្តសៀមរាប។
- ផ្តល់កូនឈើជូនតំណាងលោក ឡាយ សំអៀន នាយកធនាគារជាតិនៃកម្ពុជា សាខាខេត្តសៀមរាប ចំនួន ១,៣០០ដើម ដើម្បីយកទៅដាំបន្ថែមនៅដីទំនេរ ស្ថិតនៅស្រុកសន្ទុក ខេត្តកំពង់ធំ។
- ផ្តល់កូនឈើជូនលោក សំ សុភាព ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន១៣០ដើម ដើម្បីយកទៅដាំនៅដីផ្ទាល់ខ្លួន ស្ថិតនៅភូមិប្រម៉ា សង្កាត់ក្របីរៀល ក្រុងសៀមរាប ខេត្តសៀមរាប។

អាជ្ញាធរជាតិអប្សរា និងប្រទេសញ៉ូវហ្សេឡែន កំពុងសិក្សាបន្តគម្រោងសហប្រតិបត្តិការដំណាក់កាលថ្មីបន្ត

ផ្សាយនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២

ចាប់ពីថ្ងៃទី០៤ ដល់ទី១១ ខែសីហា ឆ្នាំ២០២២ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំសហការីជួបពិភាក្សាការងារ និងចុះបង្ហាញពីការគ្រប់គ្រងធនធានធម្មជាតិ និងសហគមន៍នៅក្នុងតំបន់អង្គរ ជាមួយគណៈប្រតិភូក្រសួងការបរទេស និងពាណិជ្ជកម្ម មន្ត្រីទូត និងអ្នកជំនាញមកពីប្រទេសញ៉ូវហ្សេឡែន ដើម្បីបន្តកិច្ចសហការលើគម្រោងដំណាក់ថ្មីក្រោយវិបត្តិកូវីត១៩។ គម្រោងនេះមានសារៈប្រយោជន៍ខ្លាំងណាស់សម្រាប់ជួយឱ្យការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រសម័យបុរាណ កាន់តែមានប្រសិទ្ធិភាពដើម្បីបញ្ចៀសទឹកជំនន់ក្នុងតំបន់សៀមរាប អង្គរ ការទាញអត្ថប្រយោជន៍ពីធនធានធម្មជាតិដើម្បីអភិវឌ្ឍន៍សហគមន៍ និងការកសាងសមត្ថភាពនិងធនធានមនុស្សជាដើម។

សូមរំលឹកផងដែរថា ប្រទេសញ៉ូវហ្សេឡែនបានមកសិក្សារួមគ្នាជាមួយអាជ្ញាធរជាតិអប្សរា លើគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍន៍សហគមន៍នៅក្នុងតំបន់អង្គរ រហូតឈានដល់ការគាំទ្រក្នុងការអនុវត្តគម្រោងជាបន្តបន្ទាប់ ដោយបានបែងចែកជាបីដំណាក់កាល៖

- ដំណាក់កាលទី១ (២០០៩ - ២០១០)៖ ជាគម្រោងសាកល្បងដែលមានឈ្មោះថា "កម្មវិធីគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់អង្គរ ដោយមានការចូលរួមពីសហគមន៍" ដែលហៅកាត់ថា APNRM&L (Angkor Participatory Natural Resource Management & Livelihoods) ។

- ដំណាក់កាលទី២ (២០១១ - ២០១៣)៖ គម្រោង "កម្មវិធីគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់អង្គរ ដោយមានការចូលរួមពីសហគមន៍" ដែលហៅកាត់ថា APNRM&L (Angkor Participatory Natural Resource Management & Livelihoods) ។
- ដំណាក់កាលទី៣ (២០១៤ - ២០១៩)៖ គម្រោង "គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ និងបេតិកភណ្ឌអង្គរ" ដែលហៅកាត់ថា ACHA (Angkor Community Heritage and Economic Advancement)។

រីករាយថ្ងៃចុងសប្តាហ៍
ប្រាសាទព្រះគោ ៖ សំណង់ឥដ្ឋដ៏ប្រណីតដើមសម័យអង្គរ

ផ្សាយនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២២

ប្រាសាទចៅសាយទេវតា
បូជនីយដ្ឋានតូចច្រឡឹង ដែលមានចម្លាក់ក្បូរក្បាច់ល្អវិចិត្រ

ផ្សាយនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២២

ក្រុមការងារតម្រង់ទិស ប្រកាសបើកយុទ្ធនាការចុះវាស់វែង កំណត់និយាមកាក្បាលដី និងអត្តសញ្ញាណអ្នកកាន់កាប់ក្បាលដី និងសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២

នាព្រឹកថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដ៏ទៃទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដែលមាន **ឯកឧត្តម ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន បានប្រកាសបើកយុទ្ធនាការចុះវាស់វែង កំណត់និយាមកាក្បាលដី និងអត្តសញ្ញាណអ្នកកាន់កាប់ក្បាលដី និងសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ តទៅ។

យុទ្ធនាការចុះវាស់វែង កំណត់និយាមកាក្បាលដី និងអត្តសញ្ញាណអ្នកកាន់កាប់ក្បាលដី និងសំណង់ខុសច្បាប់ បានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមការងារតម្រង់ទិស **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា ព្រមទាំងមានការអញ្ជើញចូលរួមដោយរដ្ឋបាលខេត្តសៀមរាប ស្ថាប័នពាក់ព័ន្ធ ព្រមទាំងក្រុមការងារបច្ចេកទេសទាំង៣២ក្រុម មកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ប្រមាណជិត៧០០នាក់។

សូមបញ្ជាក់ថា កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ កន្លងទៅ ប្រមុខរាជរដ្ឋាភិបាល បានសម្រេចបង្កើតសមាសភាពក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លី ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងនៃអាជ្ញាធរជាតិអប្សរា ដែលមានសមាសភាពមកពីក្រសួងពាក់ព័ន្ធមួយចំនួនមាន ក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ក្រសួងផែនការ អាជ្ញាធរខេត្តសៀមរាប និងអាជ្ញាធរជាតិអប្សរាផង ដើម្បីអនុវត្តដោះស្រាយបញ្ហាសំណង់ និងដីធ្លី ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរានេះ ឱ្យមានប្រសិទ្ធិភាព និងស្ថេរភាព៕

សេចក្តីប្រកាសព័ត៌មាន ស្តីពីខ្លឹមសារនៃការបើកយុទ្ធនាការចុះវាស់វែង កំណត់និយាមកាក្បាលដី និងអត្តសញ្ញាណអ្នកកាន់កាប់ក្បាលដី និងសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃពុធ ៥រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ នៅសាលសន្និសីទអង្គរនៃអាជ្ញាធរជាតិអប្សរា ខេត្តសៀមរាប **ឯកឧត្តម ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមការងារតម្រង់ទិសដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរនិងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា រួមជាមួយ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាអនុប្រធានក្រុមការងារតម្រង់ទិស **ឯកឧត្តម ទៀ សីហា** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងជាអនុប្រធានក្រុមការងារតម្រង់ទិស និង **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានអញ្ជើញចូលរួមពិធីបើកយុទ្ធនាការចុះវាស់វែង កំណត់និយាមកាក្បាលដី និងអត្តសញ្ញាណអ្នកកាន់កាប់ដីនិងសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា។

យុទ្ធនាការនេះ មានគោលដៅការពារតំបន់រមណីយដ្ឋានអង្គរដែលបានចុះបញ្ជីក្នុងសម្បត្តិបេតិកភណ្ឌពិភពលោកឆ្នាំ១៩៩២ មានទំហំ៤០១គីឡូម៉ែត្រក្រាឡេ ជាតំបន់ដែលចាត់ទុកជាសម្បត្តិសាធារណៈរបស់រដ្ឋ ត្រូវរក្សាការពារដាច់ខាត មិនអាចកាត់ឆ្វៀលបានឡើយ។ កម្ពុជាក្នុងនាមរដ្ឋសមាជិក មានភារកិច្ចរក្សាការពារតំបន់រមណីយដ្ឋានអង្គរ ដែលជាមរតកកេរ្តិ៍ដូនតា ជាអត្តសញ្ញាណ និងដួងព្រលឹងរបស់ជាតិ ក៏ដូចជាតម្លៃជាសកលនៃសម្បត្តិបេតិកភណ្ឌពិភពលោក សម្រាប់មនុស្សជាតិទាំងមូល។

ក្នុងពេលថ្មីៗនេះ តាំងពីដើមឆ្នាំ២០២២ មានអ្នកឆ្លៀតឱកាសសាងសង់សំណង់ខុសច្បាប់រាប់រយករណីបន្ថែមពីលើករណីសំណង់ខុសច្បាប់ជាច្រើនទៀតដែលបានរំលោភបំពាន នាពេលកន្លងមក ក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ។ សំណង់ខុសច្បាប់អស់ទាំងនេះ ត្រូវធ្វើការរុះរើចេញជាបន្ទាន់ដោយផ្ទាល់ខ្លួន។ ទន្ទឹមនេះ រដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរជាតិអប្សរា បន្តចាត់វិធានការទប់ស្កាត់ការសាងសង់ រុះរើសំណង់ខុសច្បាប់ ហាមឃាត់ការទិញលក់ដីនិងផ្ទះគ្រប់ប្រភេទ និងមិនផ្តល់លិខិតគតិយុត្តផ្សេងៗ នៅក្នុងតំបន់រមណីយដ្ឋានអង្គរជាដាច់ខាត។

យុទ្ធនាការនេះ មានកម្លាំងសរុបចំនួន ៧៧៩ រូប ចែកចេញជា ៣២ ក្រុម ក្នុងនោះ មន្ត្រីជំនាញរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន ៤៣៩ រូប, មន្ត្រីរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចំនួន ២៣២ រូប និងមន្ត្រីរបស់រដ្ឋបាលខេត្តសៀមរាបចំនួន ១០៨រូប ដើម្បីចុះវាស់វែង កំណត់និយាមកាក្បាលដី

អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com ១/២

និងអត្តសញ្ញាណអ្នកកាន់កាប់ដីនិងសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរនិងតំបន់ដទៃទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា។ ឯកសារស្ថិតិប្រជាពលរដ្ឋស្ថិតក្នុងតំបន់ការពារទី១ និងការពារទី២ នៃរមណីយដ្ឋានអង្គរដែលរៀបចំដោយអាជ្ញាធរជាតិអប្សរានាឆ្នាំ២០០៤-២០០៥ នឹងត្រូវប្រើប្រាស់ជាឯកសារគោល ដើម្បីពិនិត្យការកាន់កាប់ដី និងសំណង់ស្របច្បាប់ ឬមិនស្របច្បាប់ក្នុងរមណីយដ្ឋានអង្គរ។

ក្រុមការងារតម្រង់ទិសពិនិត្យលទ្ធភាពផ្តល់ដីនៅតំបន់អភិវឌ្ឍន៍រុនតាឯក សម្រាប់ដោះស្រាយជាយថាហេតុជូនប្រជាពលរដ្ឋដែលគ្រប់លក្ខខណ្ឌក្នុងការទទួលបាននៅទីតាំងលំនៅថ្មី។ ចំពោះអ្នកបន្តទន្ទ្រានដីក្នុងតំបន់នេះ និងអ្នកមិនរុះរើសំណង់ខុសច្បាប់ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ក្រុមការងារតម្រង់ទិស សូមអំពាវនាវបងប្អូនប្រជាពលរដ្ឋនិងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ផ្តល់កិច្ចសហការជាមួយក្រុមការងារបច្ចេកទេសដែលចុះបំពេញភារកិច្ចនៅគ្រប់គោលដៅក្នុងតំបន់រមណីយដ្ឋានអង្គរ ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងទទួលបានជោគជ័យ។

ថ្ងៃពុធ ៥រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២

២/២

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា ដឹកនាំក្រុមការងារចុះពិនិត្យមើលការវាស់វែង និងកំណត់អត្តសញ្ញាណដីធ្លីក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២

នៅព្រឹកថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ នេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងរមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា បានដឹកនាំក្រុមការងារ ចុះពិនិត្យស្ថានភាពរស់នៅរបស់ប្រជាជន ការចុះវាស់វែងកំណត់និយាមការក្បាលដី និងកំណត់អត្តសញ្ញាណកាន់កាប់ដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងក្រុមការងារ បានចុះទៅតាមភូមិមួយចំនួន ដូចជានៅសង្កាត់គោកចក និងសង្កាត់ស្លក្រោមជាដើម ដែលស្ថិតនៅតំបន់១ និងតំបន់២នៃរមណីយដ្ឋានអង្គរ៕

សកម្មភាព ក្រុមការងារចុះវាស់វែង និងកំណត់អត្តសញ្ញាណដីធ្លីក្នុងសង្កាត់ទឹកវិល ក្រុងសៀមរាប

ផ្សាយនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២

នៅព្រឹកថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២នេះ ជាថ្ងៃដំបូងនៃយុទ្ធនាការ ចុះវាស់វែងកំណត់និយាមការក្បាលដី និង កំណត់អត្តសញ្ញាណកាន់កាប់ដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ។

ក្រុមការងារដែលមានសមាសភាពមកអញ្ជើញមកពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរភូមិឃុំ បានចុះវាស់វែងកំណត់និយាមការក្បាលដី និងកំណត់អត្តសញ្ញាណកាន់កាប់ដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ៕

ក្រុមការងារបច្ចេកទេសរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ កំពុងបន្តចុះពិនិត្យ វាស់វែង កំណត់និយាមកានិងអត្តសញ្ញាណកម្មក្បាលដី

ផ្សាយនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២

ក្រុមការងារបច្ចេកទេសទាំង៣២ក្រុមមកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ព្រមទាំងរដ្ឋបាលខេត្តសៀមរាប អាជ្ញាធរជាតិអប្សរា និងអាជ្ញាធរមូលដ្ឋាន កំពុងចុះពិនិត្យយ៉ាងសកម្ម ដើម្បីវាស់វែងកំណត់និយាមកាក្បាលដី អត្តសញ្ញាណដីធ្លី ក្នុងរមណីយដ្ឋានអង្គរ នៅតាមសង្កាត់ និងភូមិជាច្រើន ក្នុងក្រុងសៀមរាប នៅថ្ងៃទី១៩ សីហា ២០២២។

សកម្មភាពរបស់ក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់មួយចំនួនទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃអាជ្ញាធរជាតិអប្សរានេះ កំពុងចុះពិនិត្យយ៉ាងសកម្ម ដើម្បីវាស់វែងកំណត់និយាមកាក្បាលដី អត្តសញ្ញាណដីធ្លីក្នុងរមណីយដ្ឋានអង្គរ ដែលស្ថិតក្នុងតំបន់១ និងតំបន់២ ក្នុងរមណីយដ្ឋានអង្គរ នៅក្នុងភូមិសាស្ត្រទាំង៥សង្កាត់ មានសង្កាត់នគរធំ សង្កាត់គោកចក សង្កាត់ស្លក្រាម និងសង្កាត់ទឹកវិល ទូទាំងក្រុងសៀមរាប៕

រីករាយចុងសប្តាហ៍ ប្រាសាទមេបុណ្យខាងកើត អតីតអារាមហិណ្ឌូសាសនាសង់ក្នុងបារាយណ៍ដ៏ធំ នៅសតវត្សរ៍ទី១០

ផ្សាយនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២

សម្រស់ប្រាសាទបាយ័នក្រោមដំណក់ទឹកភ្លៀង

ផ្សាយនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២

សេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ស្ដីពី លទ្ធផលនៃយុទ្ធនាការចុះវាស់វែង កំណត់និយាមកាក្បាលដី និងអត្តសញ្ញាណអ្នកកាន់កាប់ក្បាលដី និងសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៣ សីហា ឆ្នាំ២០២២

ផ្សាយនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សេចក្ដីប្រកាសព័ត៌មាន

អនុវត្តតាមសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ២៦ សសរ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ ស្ដីពីការបង្កើតក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចាត់បញ្ជូនក្រុមការងារបច្ចេកទេសចំនួន ៦៨ ក្រុម មានមន្ត្រីជំនាញសរុបចំនួន ៧៨១ រូប ចុះសហការជាមួយមន្ត្រីរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចំនួន ៣៥២ រូប ដោយមានការសហការជាមួយមន្ត្រីមូលដ្ឋានថ្នាក់ភូមិ រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ចំណុះរដ្ឋបាលខេត្តសៀមរាប ដើម្បីចុះវាស់វែងកំណត់និយាមកាក្បាលដី និងអត្តសញ្ញាណអ្នកកាន់កាប់ដីនិងសំណង់ខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរ នឹងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា។

ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ក្រុមការងារបច្ចេកទេសបានសម្រេចលទ្ធផលដូចខាងក្រោម៖

- វាស់វែងក្បាលដីបានចំនួន ២០ ០៣១ ក្បាលដី ក្នុងនោះក្បាលដីមានសំណង់ចំនួន ១២ ៣១៥ ក្បាលដី ក្បាលដីគ្មានសំណង់ចំនួន ៦ ៧៣៧ ក្បាលដី ក្នុងទំហំសរុប ៤០ ១១៨ ហិកតានៃទីតាំងទាំងបីដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
- បំពេញសម្រង់ព័ត៌មានរបស់អ្នកសាងសង់ និងកាន់កាប់ដីបានចំនួន ១៧ ៣២២ គ្រួសារ
- ប្រជាពលរដ្ឋស្ម័គ្រចិត្តរុះរើតូបលក់ដូរសរុបចំនួន ៤៤ តូប ក្នុងនោះ ៣៤ តូប លក់វត្ថុអនុស្សាវរីយ៍ស្ថិតនៅលើខឿនជុំវិញស្រះស្រង់ ភូមិស្រះស្រង់ខាងត្បូង សង្កាត់នគរធំ និង ១០តូប ស្មើ ៧៩ ខ្ទះស្ថិតនៅភូមិទក្សិណត្បូង និងភូមិវាល សង្កាត់គោកចក
- ប្រជាពលរដ្ឋដែលបានតាំងទីលំនៅខុសច្បាប់សរុបចំនួន ៦៨៩ គ្រួសារ បានស្ម័គ្រចិត្តទៅរស់នៅតំបន់ភូមិធម្មជាតិរុនតាឯក ក្នុងនោះ ២៣៤គ្រួសារ ស្ថិតនៅភូមិទក្សិណត្បូង និង ៤៥៥គ្រួសារស្ថិតនៅភូមិត្រពាំងសេះ និងត្រូវចូលរួមចាប់ឆ្នោតទទួលយកដីឡូត៍នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០២២ ចាប់ពីម៉ោង ៨ និង ៣០ នាទីព្រឹក នៅសាលាខេត្តសៀមរាប។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១២រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២

អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

ការងារសម្អាតតាមដងផ្លូវនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២

ប្រាសាទនាគព័ន្ធ សាងសង់ក្នុងបារាយណ៍ដ៏ធំនៅចុងសតវត្សរ៍ទី១២

ផ្សាយនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២

សេចក្ដីជូនដំណឹង ស្ដីពីការដកហូតដើមឈើ និងកាត់ក្រីមែកឈើ មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ៥៧៦/២២ ជប.សអល

សេចក្ដីជូនដំណឹង
ស្ដីពី
ការកាត់ដកហូតដើមឈើនិងកាត់ក្រីមែកឈើ
មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើនៅតាមទីតាំងនានាដូចខាងក្រោម៖

- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន០៤ដើម (កាត់ដកហូតដើម៖ ទឹកដោះ០១ដើម ដើមត្នោត០១ដើម កាត់ក្រី០២ដើម៖ ដើមចាមរី០២ដើម ដើមឈើទាល០១ដើម ស្ថិតនៅបរិវេណប្រាសាទលលៃ។
- កាត់ដកហូតនិងកាត់ក្រីមែកឈើចំនួន១១ដើម (កាត់ដកហូត០២ដើម៖ ដើមសំពោចភ្លើង០១ដើម និងដើមបង្គួរដំរី០១ដើម កាត់ក្រីចំនួន០៩ដើមមាន៖ ដើមត្នោតចំនួន០៦ដើម ដើមល្វា០១ដើម ដើមចាមរី ០១ដើម ដើមសុភី០១ដើម) ស្ថិតនៅបរិវេណប្រាសាទភិមានអាកាស និងប្រាសាទព្រះបាលិល័យ្យ។
- កាត់ដកហូតដើមត្នោតចំនួន០២ដើម ស្ថិតនៅភូមិសណ្ដាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប ខាងលិចសាខាគយទឹកវិល។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន០៧ដើម (កាត់ដកហូត៖ ដើមឈើទាលងាប់០៣ដើម ដើមត្នោតងាប់០១ដើម ដើមដូងងាប់០១ដើម និងដើមចាមរីងាប់០១ដើម កាត់ក្រីដើមឈើទាល០១ដើម) ដែលស្ថិតនៅ Parvis មុខខាងលិចប្រាសាទអង្គរវត្ត និងវត្តអង្គរខាងជើង។
- កាត់ដកហូត និងកាត់ក្រីដើមត្នោតចំនួន០៤ដើម (កាត់ដកហូតចំនួន០២ដើម និងកាត់ក្រីចំនួន០២ដើម) ស្ថិតនៅភូមិរហាល សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន៣១ដើម (កាត់ដកហូតដើមឈើទាល០១ដើម កាត់ក្រីដើមឈើចំនួន៣០ដើមរួមមាន៖ ដើមឈើទាល១២ដើម ដើមដកពោធិ៍០១ដើម ដើមខ្នារ០១ដើម ដើមស្រឡៅ០៦ដើម ដើមខ្វាវ០៤ដើម ដើមចាមរី០៣ដើម ដើមខ្នុរព្រៃ០១ដើម ដើមស្វាយ០១ដើម ដើមខ្វាស់០១ដើម ស្ថិតនៅបរិវេណចំណតខាងកើតប្រាសាទព្រះពិធូរ និងតាមផ្លូវរហូតដល់ខ្លោងទ្វារដីឆ្នាំង។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន១៤ដើម (កាត់ដកហូតដើមត្នោតចំនួន០៥ដើម កាត់ក្រីដើមឈើចំនួន០៩ដើមរួមមាន៖ ដើមកន្ទ្រោក០២ដើម ដើមឈើទាល០៥ដើម ដើមគគីរ០១ដើម ដើមក្រសាំង០១ ដើម ដែលស្ថិតនៅបរិវេណប្រាសាទព្រះគោ និងប្រាសាទបាគង។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន០៩ដើម (កាត់ដកហូតដើមឈើទាលចំនួន០៣ដើម កាត់ក្រីដើមឈើទាលចំនួន០៦ដើម) ស្ថិតនៅបរិវេណសាលាបឋមសិក្សាគោកត្នោត ភូមិគោកត្នោត សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្ដើមអនុវត្តការងារខាងលើ ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ តទៅរហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៥ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
សៀមរាប ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប
អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែកញ្ញា

ក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា បើកកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព នៃការដោះស្រាយផលប៉ះពាល់ដីធ្លី និងសំណង់នៅក្នុងតំបន់ឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២

នៅព្រឹកថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២នេះ នាទីស្នាក់ការអាជ្ញាធរជាតិអប្សរា ក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា បានបើកកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារដែលបានកើតមានកន្លងមក ក្នុងពេលអនុវត្តន៍ការងារ ចុះវាស់វែង កំណត់និយាមកាក្បាលដី និងអត្តសញ្ញាណអ្នកកាន់កាប់ក្បាលដី និងសំណង់ខុសច្បាប់។

កិច្ចប្រជុំនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមការងារតម្រង់ទិស **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន **ឯកឧត្តម ស៊ុំ ម៉ាប់** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនិងជាអនុប្រធានអចិន្ត្រៃយ៍ ព្រមទាំងមានការអញ្ជើញចូលរួមដោយ រដ្ឋបាលខេត្តសៀមរាប ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា អង្គភាពនគរបាលការពារបេតិកភណ្ឌ ព្រមទាំងក្រុមការងារបច្ចេកទេស មកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈមួយចំនួនទៀតផងដែរ៕

រីករាយថ្ងៃចុងសប្តាហ៍
ទេសភាពស្រស់ត្រកាលប្រាសាទភ្នំបូក ដែលភ្ញៀវទេសចរមិនគួរមើលរំលង

ផ្សាយនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២២



ប្រាសាទបាពួន
សំណល់ប្រាសាទដ៏អស្ចារ្យ កសាងនៅដើមសតវត្សរ៍ទី១១ ក្នុងក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២២

លិខិតរំលែកមរណទុក្ខ របស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករទាំងអស់ នៃអាជ្ញាធរជាតិអប្សរា គោរពជូនលោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាព មហាឧបាសិកា ញឹម គេង ដែលបានទទួលមរណភាព កាលពីថ្ងៃអាទិត្យ ៩កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ១៣:៤០ នាទី ក្នុងជន្មាយុ ៩៤ ឆ្នាំ ដោយរោគាពាធ

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា

APSARA

លេខ៖......

សារលិខិតចូលរួមរំលែកមរណទុក្ខ

សូមគោរពជូន

លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

លោកជំទាវ កិត្តិសង្គហបណ្ឌិត ឧនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!

តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករទាំងអស់នៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ យើងខ្ញុំមានសេចក្ដីក្ដុកក្ដួល រន្ធត់តក់ស្លុត និងសោកស្ដាយឥតឧបមាចំពោះដំណឹងដ៏ក្រៀមក្រំនៃមរណភាពរបស់ **មហាឧបាសិកា ញឹម គេង** ត្រូវជាម្ដាយក្មេករបស់លោកជំទាវ កិត្តិសង្គហបណ្ឌិត ដែលបានទទួលមរណភាពនាថ្ងៃអាទិត្យ ៩កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ០១៖៤០នាទីរសៀល ក្នុងជន្មាយុ៩៤ឆ្នាំ ដោយជរាពាធ។

ក្នុងវេលាប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំរកទីបំផុតគ្មាននេះ យើងខ្ញុំសូមសម្ដែងនូការសោកស្ដាយ អាឡោះអាល័យជាទីបំផុតជាមួយលោកជំទាវ កិត្តិសង្គហបណ្ឌិត ព្រមទាំងកូនៗ និងចៅៗ ចំពោះការបាត់បង់ **មហាឧបាសិកា ញឹម គេង** ដែលត្រូវជាមាតា មាតាក្មេក និងជីដូន ជាទីគោរពស្រឡាញ់បំផុត ប្រកបដោយគុណធម៌ ព្រហ្មវិហារធម៌ ហើយដែលកន្លងមក **មហាឧបាសិកា** តែងផ្ដល់ការអប់រំណែនាំ និងដំបូន្មានល្អៗដល់កូន ចៅ និងក្រុមគ្រួសារជាទីស្រឡាញ់ឱ្យប្រព្រឹត្តតែអំពើល្អ និងកសាងនូវកុសលផលបុណ្យនានា ដើម្បីបុព្វហេតុនៃការរីកចម្រើន និងសុខដុមរមនាក្នុងសង្គម។

ក្នុងឱកាសដ៏សោកសង្រេង ប្រកបដោយសេចក្ដីសង្វេគក្រៀមក្រំនេះផងដែរ តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករទាំងអស់នៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ យើងខ្ញុំសូមចូលរួមរំលែកនូវមរណទុក្ខជាមួយ **លោកជំទាវ កិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** ព្រមទាំងក្រុមគ្រួសារ និងសូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ **មហាឧបាសិកា ញឹម គេង** សូមបានទៅកាន់ឋានបរមសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ កិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** ព្រមទាំងក្រុមគ្រួសារ មេត្តាទទួលនូវសេចក្ដីគោរព និងការរំលែកទុក្ខដ៏សែនក្រៀមក្រំបំផុតពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃចន្ទ ១០កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

សៀមរាប ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២

អគ្គនាយក

ហង់ ទៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារបេតិកភណ្ឌ និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

ក្រុមការងារព្រៃឈើ បានកាត់ក្រីសម្អាតមែកដើមចាន់ ដែលបាក់នៅចំនុចរោងទងខាងត្បូង ប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២

នៅព្រឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២នេះ ក្រុមការងារ នាយកដ្ឋានគ្រប់គ្រងព្រៃឈើទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា បានកាត់ក្រីសម្អាតមែកដើមចាន់ ដែលបានបាក់នៅចំនុចរោងទោងខាងត្បូង នៃប្រាសាទ តាព្រហ្ម។ ការងារកាត់ក្រីសម្អាតមែកដើមចាន់ ដែលបាន បាក់នេះ ក្នុងគោលបំណងធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណៈជន និងប្រាសាទ ជៀសវាងគ្រោះថ្នាក់ណាមួយ ជាយថាហេតុ។

សូមជម្រាបផងដែរថា កន្លងមកនេះអាជ្ញាធរជាតិអប្សរា តែងតែជូនដំណឹងដល់សាធារណៈជន ស្ដីពីការកាត់ដកហូត ដើមឈើ និងកាត់ក្រីមែកឈើ មានហានិភ័យខ្ពស់ នៅតាម បរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ ដើម្បីសុវត្ថិភាពសាធារណៈ និងលើកកម្ពស់សោភ័ណភាព នៅតាមដងផ្លូវនិងបរិវេណប្រាសាទនានា៕

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា អញ្ជើញចូលរួមពិធីប្រកាសតែងតាំងប្រធាន និងអនុប្រធាននាយកដ្ឋាននៃអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២

នារសៀលថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បានចូលរួមជាអធិបតីភាព ពិធីប្រកាសចូលកាន់តំណែងប្រធាន និងអនុប្រធាននាយកដ្ឋាន នៃអាជ្ញាធរជាតិអប្សរា។

មានប្រសាសន៍នាឱកាសនោះ **លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** បានបង្ហាញអារម្មណ៍ចូលរួមអបអរសាទរដល់តួនាទីថ្មីរបស់មន្ត្រីអាជ្ញាធរជាតិអប្សរា។ លោកជំទាវបានចាត់ទុកភារកិច្ចថ្មីនេះ ថាបានបង្ហាញយ៉ាងច្បាស់ចំពោះការខិតខំប្រឹងប្រែងក្នុងការងាររបស់មន្ត្រីគ្រប់រូប ក្នុងការបម្រើស្ថាប័ន។ តួនាទីជារឿងមួយ តែស្មារតី ការងារ និងក្តីស្រឡាញ់ចំពោះការងារឯណោះទេ ដែលប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ចាត់ទុកថាជាបុគ្គលិកលក្ខណៈរបស់មន្ត្រីគ្រប់រូប ដែលទើបទទួលភារកិច្ចថ្មីនៅពេលនេះ។

សម្រាប់ **លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** ស្ថាប័នមួយរីកចម្រើនទៅបាន មិនមែនដោយសារតែថ្នាក់ដឹកនាំ មន្ត្រីថ្នាក់លើទេ តែសុទ្ធសឹងកើតឡើងពីការចូលរួមពីបុគ្គលិក ឬពលករពីក្រោមទៅ ទាំងអ្នកជួសជុលប្រាសាទ សម្អាតបរិស្ថាន និងផ្នែកសណ្តាប់ធ្នាប់ជាដើម ដែលមានចំណែកជួយឱ្យស្ថាប័នឬអង្គភាពមានភាពរឹងមាំរហូតដល់សព្វថ្ងៃ។

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា ក៏បានលើកទឹកចិត្តដល់មន្ត្រីទាំងអស់ ពិសេសមន្ត្រីទើបទទួលបានតួនាទីថ្មីនៅពេលនេះ ឱ្យបន្តខិតខំប្រឹងប្រែងបន្តទៀត ដើម្បីអនាគតទៅថ្ងៃមុខ។ លោកជំទាវរដ្ឋមន្ត្រីបានចាត់ទុកតួនាទីថ្មីនេះ ថាជាអំណែកមួយបន្ថែមទៀត និងកោតសរសើរចំពោះការលះបង់ដើម្បីអង្គរ។ បន្ថែមពីនេះ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** ក៏អំពាវនាវឱ្យមន្ត្រីទាំងអស់ ធ្វើការដោយស្មារតីសាមគ្គីគ្នា គោរពគ្នា និងយោគយល់គ្នាទៅវិញទៅមក ដ្បិតថាគ្រប់គ្នាសុទ្ធតែមានបន្ទុករៀងៗខ្លួនដើម្បីបុព្វហេតុអង្គរ។ ភាពហ្មត់ចត់ និងច្បាស់លាស់នឹងការងារ ក៏ជាអ្វីដែ ល **រដ្ឋមន្ត្រី ភឿង សកុណា** ផ្តាំទៅមន្ត្រីគ្រប់រូបផងដែរ ដោយថាវាជាទុនសំខាន់ក្នុងការក្លាយខ្លួនជាថ្នាក់ដឹកនាំមួយរូបនាពេលអនាគត៕

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា អញ្ជើញចុះពិនិត្យការងាររៀបចំដីឡូត៍ នៅភូមិធម្មជាតិរុនតាឯក

ផ្សាយនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២

ព្រឹកថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២២ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា និងជាអនុប្រធានក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀតស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា បានអញ្ជើញចុះពិនិត្យការងាររៀបចំសម្អាតដីឡូត៍ សម្រាប់ប្រជាជាពលរដ្ឋដែលស្ម័គ្រចិត្តចាកចេញពីតំបន់រមណីយដ្ឋានអង្គរ ទៅកាន់ទីតាំងថ្មីស្ថិតនៅភូមិធម្មជាតិរុនតាឯក។

ក្នុងឱកាសនោះដែរ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** ជួបសំណេះសំណាល សួរសុខទុក្ខដល់លោកគ្រូ អ្នកគ្រូ ព្រមទាំងសិក្សានុស្សនៅសាលាបឋមសិក្សាហ៊ុន សែន រុនតាឯក ដែលមានទីតាំងស្ថិតនៅជាប់កន្លែងកំពុងរៀបចំសម្អាតដីឡូត៍ផង៕

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំកម្មវិធីពិសារអាហារពេលល្ងាច ក្នុងឱកាសសន្និសីទអន្តរជាតិស្តីពី ការការពារនិងការទប់ស្កាត់ ការចរាចរជួញដូរសម្បត្តិវប្បធម៌ខុសច្បាប់ «ទស្សនៈពីអាស៊ាន»

ផ្សាយនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២

នាល្ងាចថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២នេះ **លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធាន AMCA បានអញ្ជើញជាអធិបតីក្នុងពិធីពិសារអាហារពេលល្ងាច ក្នុងឱកាសសន្និសីទអន្តរជាតិ ស្តីពីការការពារ និងការទប់ស្កាត់ការជួញដូរចរាចរសម្បត្តិវប្បធម៌ខុសច្បាប់ «ទស្សនៈពីអាស៊ាន នៅបរិវេណប្រាសាទក្រវ៉ាន់ ស្ថិតក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលជាតំបន់បេតិកភណ្ឌពិភពលោក មានប្រាសាទបុរាណដ៏អស្ចារ្យ ជាច្រើនដូចជា អង្គរវត្ត បាយ័ន និងប្រាសាទតាព្រហ្មជាដើម»។

ពិធីនេះ ក៏មានការអញ្ជើញចូលរួមពី ឯកឧត្តម Ekkhaphab Phanthavong អគ្គលេខាធិការរងអាស៊ាន គណៈប្រតិភូអញ្ជើញមកពីគ្រប់ប្រទេសនិងរដ្ឋ ព្រមទាំងភ្ញៀវកិត្តិយសជាច្រើនទៀត។ក្នុងឱកាសនោះ **លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានAMCAមានប្រសាសន៍ថា ជាកិត្តិយសដ៏អស្ចារ្យ សម្រាប់ការរៀបចំអាហារពេលល្ងាចនាពេលនេះ ដើម្បីភាពជាមិត្តភាព សាមគ្គីភាព និងសមិទ្ធិផលនានារបស់យើង ព្រមទាំងរីករាយការប្រគំតន្ត្រី ការសម្តែងសិល្បៈទស្សនីយភាពផ្សេងៗ អមនឹងអាហារចម្រុះរសជាតិបែបខ្មែរ ដើម្បីទទួលស្វាគមន៍គណៈប្រតិភូ។

លោកជំទាវ បណ្ឌិតសភាចារ្យ មានប្រសាសន៍ទៀតថា តំបន់ឧទ្យានអង្គរនៃខេត្តសៀមរាប ជាតំបន់បេតិកភណ្ឌពិភពលោក ដែលមានប្រាង្គប្រាសាទបុរាណជាច្រើន ហើយប្រាសាទទាំងនេះ ធ្វើឱ្យភ្ញៀវទេសចរមកពីជុំវិញពិភពលោក មានការកោតស្ញប់ស្ញែងយ៉ាងខ្លាំង មិនត្រឹមតែពេលបច្ចុប្បន្ននេះប៉ុណ្ណោះទេ ថែមទាំងកាលពីអតីតកាលទៀតផង។ លោកជំទាវមានប្រសាសន៍ទៀតថា ជាថ្មីម្តងទៀត សូមថ្លែងអំណរគុណចំពោះវត្តមាន ហើយការបន្តការចូលរួម និងកិច្ចសហប្រតិបត្តិការក្នុងការអភិរក្ស និងកិច្ចការពារ បេតិកភណ្ឌវប្បធម៌៕

អាជ្ញាធរជាតិអប្សរា ពិភាក្សាការងារជាមួយភាគីអាមេរិក ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការបន្ថែមទៀតនាថ្ងៃអនាគត

ផ្សាយនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២

រសៀលថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាការងារជាមួយ កញ្ញា Anne Compton មកពីការិយាល័យកិច្ចការអប់រំ និងវប្បធម៌ នៃក្រសួងការបរទេសសហរដ្ឋអាមេរិក ដើម្បីពិភាក្សាអំពីលទ្ធភាពក្នុងការពង្រីកនូវកិច្ចសហការលើវិស័យវប្បធម៌ ជាពិសេសពាក់ព័ន្ធជាមួយនឹងការងារអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងរមណីយដ្ឋានអង្គរ៕

ព្រះវិហារបុរាណនៅវត្តប្រាសាទលលៃប្រែប្រួលសោភ័ណភាពដ៏ស្រស់ត្រកាល ក្រោយបញ្ចប់ការជួសជុល

ផ្សាយនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២

គម្រោងជួសជុល និងអភិរក្សព្រះវិហារបុរាណ នៅវត្តប្រាសាទលលៃ ដែលទទួលបានថវិកា និងបច្ចេកទេសទាំងស្រុងពីអាជ្ញាធរជាតិអប្សរា បានបញ្ចប់ជាស្ថាពរកាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២។

ក្រោមកិច្ចខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ពីសំណាក់មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា គឺបានជួសជុលព្រះវិហារបុរាណ ដែលមានសភាពចាស់ទ្រុឌទ្រោម ពុកផុយ ធ្លុះធ្លាយ ធ្លាក់បាក់ឱ្យល្អឡើងវិញ ដោយប្រើប្រាស់បច្ចេកទេស និងសម្ភារដូចដើមទាំងស្រុង ដើម្បីរក្សាបាននូវគុណតម្លៃផ្នែកប្រវត្តិសាស្ត្រ។

សូមបញ្ជាក់ថា ព្រះវិហារបុរាណនេះ មានទំហំបណ្តោយ ២៧,៥ម ទទឹង ១១,២ម និងកម្ពស់ ១៥,៥ម។ គោលបំណងនៃការជួសជុល និងអភិរក្សព្រះវិហារនេះ គឺដើម្បីថែរក្សាមត៌កវប្បធម៌ខ្មែរលើវិស័យព្រះពុទ្ធសាសនាដ៏រស់រវើកឱ្យនៅឋិតថេរបន្តទៅមុខទៀត នឹងដើម្បីបម្រើប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ ការសិក្សារៀនសូត្រផង និងដើម្បីទាក់ទាញអារម្មណ៍ភ្ញៀវទេសចរ ដែលមកទស្សនាទឹកដីបុរាណដ្ឋានមួយនេះផង៕

ប្រាសាទបក្សីចាំក្រុង កសាងនៅពាក់កណ្ដាលសតវត្សរ៍ទី១០ កន្លែងសម្រាប់ទេសចរដែលត្រូវការភាពស្ងប់ស្ងាត់

ផ្សាយនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២



អនុមោទនាពិធីបុណ្យភ្ជុំបិណ្ឌ-បិណ្ឌ១ ទេសភាពស្រស់បំព្រង នៃប្រាសាទលលៃ សំណង់ឥដ្ឋសាងសង់នៅចុងសតវត្សរ៍ទី៩

ផ្សាយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២

ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាអមដំណើរ ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមការងារតម្រង់ទិស ដើម្បីដោះស្រាយបញ្ហាសំណង់ខុសច្បាប់ និងដីធ្លី ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដទៃទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ចុះពិនិត្យមើលសកម្មភាពពលរដ្ឋភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ចាប់ឆ្នោតក្បាលដីឡូតិ៍នៅភូមិធម្មជាតិរុនតាឯក ដែលពិធីនេះធ្វើឡើងនៅបរិវេណរដ្ឋបាលខេត្តសៀមរាប នាព្រឹកថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២

ផ្សាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២

ប្រជាពលរដ្ឋរស់នៅភូមិធម្មជាតិរុនតាឯកមានជីវភាពធូរធារ

ផ្សាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២

ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចាកចេញពីតំបន់រមណីយដ្ឋានអង្គរទៅរស់នៅភូមិធម្មជាតិរុនតាឯកបានបញ្ជាក់ថាពួកគាត់មានជីវភាពរស់នៅប្រចាំថ្ងៃធូរធារ ដោយសារតែមានដីសម្រាប់ធ្វើកសិកម្ម និងប្រើប្រាស់តាមតម្រូវការ។

លោក រិន ស្រួច ជាអតីតអ្នករស់នៅក្នុងភូមិស្រះស្រង់ សង្កាត់នគរធំ ក្រុងសៀមរាប ថាកាលពីពេលដែលគាត់រស់នៅក្នុងរមណីយដ្ឋានអង្គរ គាត់មានដីលំនៅដ្ឋានទំហំតូចចង្អៀត មិនមានកម្មសិទ្ធិស្របច្បាប់ មិនអាចឱ្យលោកទាញយកផលប្រយោជន៍ពីដីឱ្យអស់លទ្ធភាពបាន ទើបគ្រួសារលោកស្ម័គ្រចិត្តដោះដូរជាមួយអាជ្ញាធរជាតិអប្សរាពីតំបន់ការពាររមណីយដ្ឋានអង្គរ ទៅរស់នៅភូមិធម្មជាតិរុនតាឯក។ លោកបន្តថា បច្ចុប្បន្នលោកបានរៀបចំផ្ទះធ្វើជាផ្ទះស្នាក់សម្រាប់ភ្ញៀវទេសចរ ដោយគិតជាថ្ងៃ និងជាក់ខែ ហើយលោកទទួលបានផលកម្រៃគួរសមក្នុងមួយខែៗ ពីផ្ទះស្នាក់ និងទិន្នផលចម្ការ។ លោក ស្រួច សប្បាយចិត្ត ព្រោះការរស់នៅក្នុងភូមិធម្មជាតិរុនតាឯកអាចឱ្យគាត់ចង់ធ្វើអ្វីក៏បានតាមសេចក្តីត្រូវការក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

លោកស្រី កី កិន្នរី ឱ្យដឹងថា បានស្ម័គ្រចិត្តផ្លាស់ទីលំនៅទៅភូមិធម្មជាតិរុនតាឯក រយៈពេល៥ឆ្នាំមកហើយ។ ចាប់តាំងពីរូបគាត់ទៅរស់នៅ លោកស្រីបានកែប្រែដីនោះ មានដាំដំណាំដូចជា ដូង ល្ហុង ម្នាស់ ក្រូចឆ្មារ និងចិញ្ចឹមសត្វគោ មាន់ ទា ក្ងានជាដើម។ សព្វថ្ងៃនេះ លោកស្រី កិន្នរី មានគោចំនួន១៣ក្បាល និងមាន់ ទា ក្ងានចំនួនជាង ១០០ក្បាល។

ជារៀងរាល់ថ្ងៃ លោកស្រី អាចរកកម្រៃបានពីការលក់ក្រូចឆ្មា លក់ពងទា ពងមាន់យ៉ាងហោចណាស់ក៏ទទួលបាន៣ម៉ឺនរៀលដែរក្នុង១ថ្ងៃ។ ដោយឡែក នៅរដូវក្ងានពងវិញ គឺគាត់អាចរកកម្រៃប្រចាំថ្ងៃបានច្រើនគួរសមដែរ តាមរយៈការលក់ពងក្ងានដែលធ្វើឱ្យជីវភាពធូរធារ។

ចំពោះមុខរបរបច្ចុប្បន្ន មានប្រជាពលរដ្ឋជាច្រើនគ្រួសារមួយចំនួនបានចូលបំពេញការងារជាមួយ អាជ្ញាធរជាតិអប្សរា ខ្លះប្រកបមុខរបរធ្វើផ្ទះស្នាក់សម្រាប់ទទួលភ្ញៀវទេសចរ និងខ្លះទៀតធ្វើកសិកម្មនៅលើដីកម្មសិទ្ធិរបស់ខ្លួនដែលជាហេតុបានចំណូលច្រើនផ្នែកក្នុងមួយខែៗ៕

អាជ្ញាធរជាតិអប្សរា និងស្ថានទូតបារាំងពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ

ផ្សាយនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២

នៅព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២នេះ **ឯកឧត្តម បណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានទទួលជួបពិភាក្សាការងារ ជាមួយលោក Pierre VINCENTទីប្រឹក្សាសហប្រតិបត្តិការ និងវប្បធម៌ នៃស្ថានទូតបារាំងប្រចាំកម្ពុជា និងជាសហប្រធានបច្ចេកទេសថ្មីរបស់គណៈកម្មាធិការ អាយស៊ីស៊ី-អង្គរ ដើម្បីសិក្សាស្វែងយល់ ពិភាក្សា និងផ្លាស់ប្តូរយោបល់ស្តីពី បេសកកម្ម និងសមិទ្ធផលដែលសម្រេចបានថ្មីៗរបស់អាជ្ញាធរជាតិអប្សរា កិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌ ICC-ANGKOR និងការងារជួសជុលប្រាសាទមេបុណ្យខាងលិច។

កិច្ចពិភាក្សានេះ ក៏បានផ្តោតសំខាន់លើលទ្ធភាពក្នុងការពង្រឹង និងពង្រីកនូវកិច្ចសហការទ្វេភាគី ជាពិសេសពាក់ព័ន្ធជាមួយនឹងការងារអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងរមណីយដ្ឋានអង្គរ៕

រដ្ឋមន្ត្រីពាណិជ្ជកម្ម និងនីហរណ៍នៃប្រទេសញ៉ូវហ្សឺឡែន បំពេញទស្សនកិច្ចលើគម្រោងសហប្រតិបត្តិការក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២

នារសៀលថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ **ឯកឧត្តម បណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បាន អមដំណើរឯកឧត្តម Phil Twyford រដ្ឋមន្ត្រីពាណិជ្ជកម្ម និងនីហរណ៍នៃប្រទេសញ៉ូវហ្សឺឡែន ពិនិត្យមើលសមិទ្ធផល សំខាន់ៗនៃគម្រោងសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិ អប្សរានៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលបានអនុវត្ត ចំនួនបីដំណាក់កាលកន្លងមក ចាប់ពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៩ និងគម្រោងនាពេលអនាគត (ដំណាក់កាល ទី៤) ដោយផ្តោតលើការគ្រប់គ្រងធនធានធម្មជាតិ និង សហគមន៍នៅក្នុងតំបន់អង្គរ។ គម្រោងសហប្រតិបត្តិការ ទ្វេភាគីនេះ មានសារប្រយោជន៍ខ្លាំង សម្រាប់ជួយឱ្យការ ថែរក្សាប្រព័ន្ធធារាសាស្ត្រសម័យបុរាណឱ្យគង់វង់ និងមាន ប្រសិទ្ធិភាពខ្ពស់ ក្នុងការគ្រប់គ្រងទឹកក្នុងតំបន់សៀមរាប-អង្គរ និងការទាញអត្ថប្រយោជន៍ពីធនធានធម្មជាតិដើម្បី អភិវឌ្ឍន៍សហគមន៍ និងការកសាងសមត្ថភាពនិងធនធាន មនុស្សជាដើម។

សូមរំលឹកផងដែរថា កន្លងមក ប្រទេសញ៉ូវហ្សឺឡែន បាន គាំទ្រអាជ្ញាធរជាតិអប្សរាអនុវត្តគម្រោងជាបន្តបន្ទាប់រួមមាន បីដំណាក់កាលៈ

- ដំណាក់កាលទី១ (២០០៩-២០១០) ជាគម្រោង សាកល្បងដែលមានឈ្មោះថា "កម្មវិធីគ្រប់គ្រងធនធាន ធម្មជាតិក្នុងតំបន់អង្គរ ដោយមានការចូលរួមពីសហគមន៍" ដែលហៅកាត់ថា APNRM&L (Angkor Participatory Natural Resource Management & Livelihoods)។
- ដំណាក់កាលទី២ (២០១១-២០១៣) គម្រោង "កម្មវិធី គ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់អង្គរ ដោយមានការ ចូលរួមពីសហគមន៍" ដែលហៅកាត់ថា APNRM&L (Angkor Participatory Natural Resource Management & Livelihoods)។
- ដំណាក់កាលទី៣ (២០១៤-២០១៩) គម្រោង "អភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ និងបេតិកភណ្ឌអង្គរ" ដែលហៅកាត់ថា ACHA (Angkor Community Heritage and Economic Advancement)៕

រីករាយថ្ងៃចុងសប្តាហ៍ ប្រាសាទបី កសាងនៅសតវត្សរ៍ទី១០ ស្ថិតក្បែរកសិន្ធុក្រុងអង្គរធំផ្នែកខាងត្បូង ដែលទេសចរមិនសូវបានស្គាល់

ផ្សាយនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២

ប្រាសាទក្រវ៉ាន់ សង់នៅដើមសតវត្សរ៍ទី១០ ដែលមានចម្លាក់លើជញ្ជាំងឥដ្ឋដ៏ល្អវិចិត្រ

ផ្សាយនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២



អាជ្ញាធរជាតិអប្សរារៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយវិស័យឯកជន និងស្ថាប័នពាក់ព័ន្ធ ស្តីពីការដាក់ឱ្យដំណើរការខ្សែទស្សនាចរណ៍ក្នុងបារាយណ៍ជយតដាកដោយជិះទូក និងកង់

ផ្សាយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២

ក្នុងក្របខ័ណ្ឌអនុវត្តគម្រោង «ដាក់ដំណើរការឡើងវិញនូវសហគមន៍ទេសចរណ៍បារាយណ៍ជយតដាក» ក្រោមជំនួយឧបត្ថម្ភពីអង្គការ GIZ សម្របសម្រួលដោយអង្គការយូណេស្កូ នៅថ្ងៃសុក្រ ទី១៦ ខែកញ្ញា ឆ្នាំ២០២២ **ឯកឧត្តម ឡុង កុសល** អគ្គនាយករង ទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធស្តីពី ការដាក់ដំណើរការខ្សែទស្សនាជិះទូកក្នុងបារាយ៍ជយតដាក (បារាយណ៍ខាងជើង ឬ បារាយណ៍នាគព័ន្ធ) និងខ្សែទស្សនាជិះកង់ របស់ «សហគមន៍ទេសចរណ៍បារាយណ៍ជយតដាក»។ សិក្ខាកាមចូលរួមមានចំនួន៣០នាក់ អញ្ជើញមកពីមន្ទីរទេសចរណ៍ មន្ទីរបរិស្ថាន អង្គភាពនគរបាលបេតិកភណ្ឌ អង្គភាពនគរបាលទេសចរណ៍ គ្រឹះស្ថានអង្គរ រដ្ឋបាលស្រុកអង្គរធំ សមាគមន៍ទីភ្នាក់ងារទេសចរណ៍កម្ពុជា ក្រុមហ៊ុនទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ សមាគមន៍មគ្គុទ្ទេសក៏ទេសចរ ក្លឹបទេសចរណ៍ខេត្តសៀមរាប និងតំណាងសហគមន៍ទេសចរណ៍ បារាយណ៍ជយតដាក។

ឯកឧត្តមអគ្គនាយករង ព្រមទាំងសិក្ខាកាមទាំងអស់ បានផ្តើមកម្មវិធីដោយការសាកល្បងខ្សែទស្សនាជិះកង់ចេញពីប្រាសាទតាកែវ ឆ្លងកាត់ និងទស្សនាប្រាសាទតានៃ ស្ពានយោលឆ្លងស្ទឹងសៀមរាប រានទស្សនាបារាយណ៍ខាងជើង ទ្វារទឹក និងជាទំនប់បង្ហៀរទឹកបារាយណ៍ខាងជើង ស្ថានីយបណ្តុះកូនឈើ របស់អាជ្ញាធរជាតិអប្សរានៅប្រាសាទព្រះខ័ន និងប្រាសាទព្រះខ័ន។ នៅពេលរសៀលនាថ្ងៃដដែល សិក្ខាកាម បានស្តាប់ពីបទបង្ហាញស្តីពីការរៀបចំសហគមន៍ និងការគ្រប់គ្រង ព្រមទាំងសេវាកម្មទេសចរណ៍ជិះទូក និងជិះកង់ដែលសហគមន៍ទេសចរណ៍បារាយណ៍ជយតដាកគ្រោងដាក់បំរើជូនភ្ញៀវទេសចរ និងបានជជែកពិភាក្សាផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកយ៉ាងផុសផុលស្តីពី«ការកំណត់តម្លៃសេវាកម្ម និងការចូលរួមរបស់អ្នកពាក់ព័ន្ធ ក្នុងការទ្រទ្រង់ដំណើរការ និងផ្សព្វផ្សាយពីសហគមន៍» ។

ខ្សែទស្សនាដោយជិះកង់គយគន់ទេសភាពធម្មជាតិ ស្រូបយកខ្យល់បរិសុទ្ធ ព្រមទាំងបានស្វែងយល់ពីប្រព័ន្ធធារាសាស្ត្រសម័យអង្គរ រួមទាំងខ្សែទស្សនាជិះទូកអុំ បែបបុរាណនៅក្នុងបារាយណ៍ជយតដាក សុទ្ធសឹងតែជាផលិតផល ទេសចរណ៍ថ្មីនៃអង្គរ ដែលមិនប៉ះពាល់ដល់បរិស្ថាន។

លទ្ធផលនៃកិច្ចពិគ្រោះយោបល់ ប្រកបដោយផ្លែផ្កានេះ នឹងត្រូវសរុបជូនថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និងថ្នាក់ដឹកនាំនៃសហគមន៍ទេសចរណ៍បារាយណ៍ជយតដាក ដើម្បីពិនិត្យ និងសម្រេច។

ភ្នាក់ងារទេសចរណ៍បានចូលរួមសហការជាមួយកម្លាំងនគរបាលទេសចរណ៍ និងភ្នាក់ងារសណ្តាប់ធ្នាប់ ប្រគល់សម្ភារជូនភ្ញៀវទេសចរ ដែលភ្លេចឬជ្រុះនៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២

ភ្នាក់ងារទេសចរណ៍ បានចូលរួមសហការជាមួយកម្លាំងនគរបាលទេសចរណ៍ និងភ្នាក់ងារសណ្តាប់ធ្នាប់ ប្រគល់កាបូបស្ពាយ និងសម្ភារមួយចំនួនដល់ភ្ញៀវទេសចរដែលបានភ្លេចឬជ្រុះនៅតាមតំបន់ប្រាសាទក្នុងរមណីយដ្ឋានអង្គរ។ សម្ភារដែលបានប្រគល់ជូនមានដូចជា ក្នុងកាបូបមានលុយ៤ម៉ឺនរៀល និងខ្សែដៃប្លាទីនមួយខ្សែ។

គួរបញ្ជាក់ថា ជារឿយៗភ្នាក់ងារទេសចរណ៍តែងតែរើសបាននូវសម្ភារឬរបស់របរមួយចំនួនដែលភ្ញៀវទេសចរបានជ្រុះឬភ្លេចនៅតាមប្រាសាទនានា។ នៅពេលបានឃើញរបស់ជ្រុះឬភ្លេច ភ្នាក់ងារទេសចរណ៍សហការជាមួយនគរបាលការពារបេតិកភណ្ឌ នគរបាលទេសចរណ៍ដើម្បីស្វែងរកម្ចាស់របស់របរទាំងនោះ និងតែងតែបានប្រគល់របស់របរទាំងនោះជូនទៅម្ចាស់ដើមវិញ៕

តើបោះបាយបិណ្ឌគឺកិច្ចពិធីសំខាន់ឬយ៉ាងណា? តើខ្មែរអាចធ្វើកិច្ចនេះនៅពេលណាខ្លះ?

ផ្សាយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២

បាយបិណ្ឌគេដឹងទូទៅថារៀបចំបោះឱ្យប្រេត។ តើយើងស្គាល់រូបប្រេតតាំងពីពេលណា? នៅពេលបច្ចុប្បន្ននេះ យើងស្គាល់ប្រេត នៅតាមរូបគំនូរក្នុងទីវត្តអារាម និងតាមជញ្ជាំងនៃព្រះវិហារព្រះពុទ្ធសាសនាប៉ុណ្ណោះ។ ប៉ុន្តែអ្នកស្រាវជ្រាវវប្បធម៌ខ្មែរនៅអាជ្ញាធរជាតិអប្សរា លោក គ្រូ **អាំង ជូលាន** បានប្រទះឃើញរូបភាពប្រេត នៅលើចម្លាក់មួយនៅប្រាសាទតានៃក្នុងតំបន់អង្គរ ហើយប្រហែលមានតែមួយគត់ដែលចាស់ជាងគេក្នុងសិល្បៈខ្មែរ។ អ្នកបុរាណវិទូ និងជាប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរា លោក **អ៊ឹម សុខរិទ្ធី** បានលើកបង្ហាញឱ្យឃើញថា យោងតាមគម្ពីរព្រះពុទ្ធសាសនាមហាយាន Kāraṇḍavyūha ដែលបានសរសេរនៅក្នុងតំបន់កាស្មៀនៃប្រទេសឥណ្ឌា តាំងពីអំឡុងសតវត្សរ៍ទី៥នៃគ្រីស្តរាជ និយាយពីរឿងរ៉ាវរបស់ព្រះអវលោកិតេស្វរ ដែលព្រះបាទជ័យវរ្ម័នទី៧ បានយកមកប្រតិបត្តិក្នុងរជ្ជកាលរបស់ព្រះអង្គរនៅចុងសតវត្សរ៍ទី១២ មានបង្ហាញរឿងព្រះអវលោកិតេស្វរសង្គ្រោះប្រេត។

តាំងតែពីជាង៩០០ឆ្នាំមុន អតីតព្រះមហាក្សត្រខ្មែរ ព្រះបាទជ័យវរ្ម័នទី៧ ទំនងជាប្រតិបត្តិគម្ពីរព្រះពុទ្ធសាសនាមហាយាន Kāraṇḍavyūha តាំងពីអំឡុងចុងសតវត្សរ៍ទី១២ និងដើមសតវត្សរ៍ទី១៣នៃគ្រីស្តសករាជ សម្រាប់ស្រោចស្រង់អ្នកស្លាប់ក្នុងចម្បាំងបង្ហូរឈាមដ៏ធំមួយ ដើម្បីរំដោះរាជធានីអង្គរចេញពីទ័ពចម្ប៉ា។ ដោយសារតែចម្បាំងនោះ ធ្វើឱ្យរាស្ត្រជាច្រើនបានស្លាប់ រួមទាំងព្រះញាតិវង្សផង រងទុក្ខវេទនា និរាសព្រាត់ប្រាស់គ្រួសារ ព្រមទាំងកងទ័ពរបស់ព្រះអង្គរជាច្រើនបានពលីជីវិត។ ព្រះអង្គមានព្រះទ័យជឿថា ព្រះញាតិវង្ស មន្ត្រី រាស្ត្រប្រជា និងកងទ័ពខ្លះ បានសុគត និងស្លាប់ទាំងនោះ មិនដឹងវិញ្ញាណក្ខ័ន្ធទៅដល់ទីណា ឬខ្លះដែលអាចនឹងទៅកើតជាប្រេត ទទួលរងទុក្ខទោសនៅឯឋានប្រេត។ មានតែព្រះអវលោកិតេស្វរទេ តាមទំនៀមក្នុងគម្ពីរ Kāraṇḍavyūha មានអំណាច និងលទ្ធភាពជួយសង្គ្រោះពួកប្រេតទាំងនោះ ឱ្យរួចផុតពីទុក្ខទោស និងឱ្យវិលមកកើតជាមនុស្សវិញបាន។

រឿងរ៉ាវ និងភស្តុតាងអំពីប្រេតនេះ បានឆ្លាក់រូបទុកនៅលើហោជាងថ្ម នៃខ្លោងទ្វារខាងកើតរបស់ប្រាសាទតានៃក្នុងទឹកដីខេត្តសៀមរាបបន្សល់ទុកមកដល់បច្ចុប្បន្ន។ លើសពីនេះទៀត នៅក្នុងជំនឿរបស់ព្រាហ្មណ៍សាសនា ដើម្បីសង្គ្រោះពួកប្រេតទាំងឡាយឱ្យអាចវិលមកកើតជាមនុស្សវិញបាននោះ មានកិច្ចពិធីមួយ គឺបោះបាយបិណ្ឌដែលបុព្វបុរសខ្មែរតែងតែធ្វើរហូតក្លាយទៅជាប្រពៃណីរបស់ខ្លួនមកដល់បច្ចុប្បន្ន។ លោក **អ៊ឹម សុខរិទ្ធី** បានឱ្យដឹងថា តាមសិលាចារិកថ្នល់បារាយណ៍ លេខសំគាល់ K279 គឺនិយាយអំពីពិធីបុណ្យមួយតាមព្រហ្មញ្ញសាសនា ដែលភាសាសំស្ក្រឹតហៅថា «ស្រាទ្ធ» គឺជាពិធីបោះបាយបិណ្ឌ ដើម្បីជួយស្រោចស្រង់ដល់ព្រលឹងអ្នកស្លាប់ដែលបានទៅកើតជាប្រេតហើយនោះ ឱ្យអាចវិលត្រឡប់មកកើតជាមនុស្សវិញ។

ការបោះបាយបិណ្ឌ មិនមែនក្នុងន័យបោះដើម្បីឱ្យពពួកប្រេតដែលកំពុងស្រេកឃ្លានទាំងនោះ បានទទួលទានចំអែតក្រពះទេ។ គឺបាយដែលគេពូតចេញពីអង្ករដំណើបដែលស្អិតចំនួន១៩ពំនូត ជាតំណាងឱ្យរូបកាយដែលអាចឱ្យព្រលឹងរបស់អ្នកស្លាប់ ដែលកើតទៅជាប្រេត អាចមកចាប់យករូបកាយបាន ហើយក៏អាចវិលមកកើតជាមនុស្សវិញបាន។ តាមទំនៀមខ្មែរជឿថាមនុស្សគ្រប់រូប គឺមានធាតុពីរសំខាន់គឺ៖ ទី១នាម(ព្រលឹង) ទី២គឺរូប(រាងកាយ)។ នៅពេលដែលមនុស្សស្លាប់ទៅនៅសល់តែនាមគឺព្រលឹង ចំណែកឯរូបវិញគឺបានរលាយបាត់ទៅហើយ។ ដោយសារហេតុផលនេះគេជឿថាដើម្បី ឱ្យអ្នកស្លាប់អាចវិលមកកើតជាមនុស្សវិញបានគឺទាល់តែធ្វើឱ្យនាមនិងរូបបានភ្ជាប់គ្នាឡើងវិញ។ ដូច្នេះហើយ បានជាបុព្វបុរសខ្មែរ ប្រារព្ធធ្វើពិធីបោះបាយបិណ្ឌនៅក្នុងពេលភ្ជុំបិណ្ឌនេះឡើង។

តើពិធីបោះបាយបិណ្ឌ ធ្វើបានតែនៅពេលភ្ជុំបិណ្ឌឬនៅពេលណាខ្លះទៀត? តាមអ្នកស្រាវជ្រាវសិលាចារិកសម័យបុរាណ បានរកឃើញថាពិធីបោះបាយបិណ្ឌ ដើម្បីជួយស្រោចស្រង់ ព្រលឹងអ្នកស្លាប់ ដែលបានទៅកើតជាប្រេត ឱ្យអាចវិលត្រឡប់មកកើតជាមនុស្សវិញនោះ មិនមែនអាចធ្វើបានតែក្នុងពេលបុណ្យភ្ជុំបិណ្ឌប៉ុណ្ណោះទេ។ ពិធីនេះគឺអាចធ្វើបាន៤ដងក្នុង១ឆ្នាំ គឺនៅពេលបុណ្យភ្ជុំបិណ្ឌ នៅពេលព្រឹត្តិការណ៍យប់ និងថ្ងៃស្មើគ្នា(សមរាត្រី)កើតឡើង២ដងក្នុង១ឆ្នាំ នៅពេលមានព្រឹត្តិការណ៍យប់វែងជាងថ្ងៃកើតឡើងម្តងក្នុង១ឆ្នាំ និងនៅពេលដែលមានព្រឹត្តិការណ៍ថ្ងៃវែងជាងយប់កើតឡើងម្តងក្នុង១ឆ្នាំ។

នៅស្រុកឥណ្ឌា តាមជំនឿព្រហ្មញ្ញសាសនា ការបោះបាយបិណ្ឌដើម្បីជួយស្រោចស្រង់ ព្រលឹងអ្នកស្លាប់ ដែលបានទៅកើតជាប្រេត ឱ្យអាចវិលត្រឡប់មកកើតជាមនុស្សវិញនោះគឺគេធ្វើឡើងទៅតាមគ្រួសារតូចៗប៉ុណ្ណោះ។ ប៉ុន្តែទំនៀមនេះត្រូវបានព្រះមហាក្សត្រខ្មែរសម័យបុរាណ យកមកធ្វើជាទម្រង់ពិធីធំ និងទូលំទូលាយរបស់ខ្មែរ សម្រាប់ញាតិសន្តានច្រើនជំនាន់ សាច់សារលោហិត មនុស្សចាស់ ក្មេងៗ អ្នកពុំមានទីពំនាក់ ជាពិសេសគឺដឹងគុណដល់អ្នកស្នេហាជាតិទាំងឡាយដែលបានស្លាប់ដោយសារការធ្វើចម្បាំងការពារទឹកដី ប្រទេសជាតិ ក៏ទទួលបានការឧទ្ទិសនេះផង ហើយបន្តបន្ទាប់មកទៀត កិច្ចពិធីនេះបានក្លាយទៅជាពិធីបុណ្យធំដុំរហូតដល់ក្លាយជាបុណ្យជាតិ និងប្រពៃណីដ៏ធំជាងគេតែម្តង៕

ព្រឹត្តិការណ៍សមរាត្រី Autumnal Equinox នឹងឈានមកដល់នៅថ្ងៃស្អែក ទី២២ ខែកញ្ញាឆ្នាំ២០២២

ផ្សាយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២

Autumnal Equinox នឹងឈានមកដល់នៅថ្ងៃស្អែក ទី២២ ខែកញ្ញាឆ្នាំ២០២២ នេះហើយ។ លោក **អ៊ឹម សុខរិទ្ធី** បុរាណវិទូ និងជាប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ បានឱ្យដឹងថា នាវេលាម៉ោង ៦កន្លះព្រឹកថ្ងៃទី២២ ខែកញ្ញា ព្រះអាទិត្យនឹងរះចំកំពូលកណ្តាលនៃប្រាសាទអង្គរវត្ត គឺជាវេលាពេលថ្ងៃ និងរយៈពេលយប់មានស្មើគ្នា ដែលជាព្រឹត្តិការណ៍ដ៏កម្រនេះ តែងតែកើតឡើង២ដងតែប៉ុណ្ណោះក្នុងមួយឆ្នាំ នៅក្នុងខែកញ្ញា និងខែមីនា។ ប៉ុន្តែអាកាសធាតុមិនអំណោយផលក្នុងសប្តាហ៍នេះ ប្រហែលជាយើងមិនអាចបានឃើញព្រឹត្តការណ៍នេះដូចរាល់ឆ្នាំទេ។

លើសពីនេះទៅទៀត ព្រឹត្តិការណ៍សមរាត្រីនាខែកញ្ញានេះ ត្រូវចំវេលាដែលខ្មែរកំពុងបោះបាយបិណ្ឌ ហើយគាប់ជួននឹងសេចក្តីមានចែងក្នុងសិលាចារឹកថ្នល់បារាយណ៍ K279 នាចុងសតវត្សរ៍ទី៩បានអនុញ្ញាតឲ្យបោះបាយបិណ្ឌនៅថ្ងៃសមរាត្រីដែរ៕

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ នាំយកទេយ្យទានប្រគេនព្រះមហាវិមលធម្ម ពិន សែម សិរីសុវណ្ណោ ព្រះរាជាគណៈថ្នាក់ទោ គណៈមហានិកាយ ព្រះឧត្តមទីប្រឹក្សាគណៈសង្ឃនាយក សមាជិកថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះគ្រូចៅអធិការវត្តរាជបូណ៌ ក្រុងសៀមរាប

ផ្សាយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២

នៅព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២នេះ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អមដំណើរដោយ**ឯកឧត្តម បណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងអគ្គនាយករងបានអញ្ជើញក្រាបថ្វាយបង្គំ និងប្រគេនទេយ្យទានមួយចំនួន**ថ្វាយព្រះមហាវិមលធម្ម ពិន សែម សិរីសុវណ្ណោ** ព្រះរាជាគណៈថ្នាក់ទោ គណៈមហានិកាយ ព្រះឧត្តមទីប្រឹក្សាគណៈសង្ឃនាយក សមាជិកថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះគ្រូចៅអធិការវត្តរាជបូណ៌ ក្រុងសៀមរាប ក្នុងឱកាសពិធីកាន់បិណ្ឌវេនទី១១ ដែលជាបុណ្យដ៏ធំមួយនៃប្រពៃណីទំនៀមទំលាប់របស់ប្រជាពលរដ្ឋខ្មែរ។

សូមជម្រាបថា បុណ្យភ្ជុំបិណ្ឌ ដែលជាបុណ្យមួយដ៏ធំនៃប្រពៃណីទំនៀមទំលាប់របស់ប្រជាពលរដ្ឋខ្មែរ ដែលកាន់សាសនាព្រះពុទ្ធ គោរពប្រតិបត្តិតាំងពីដូនតា តរៀងមក ។ ម៉្យាងទៀតពិធីកាន់វេនបិណ្ឌនេះ ពុទ្ធសាសនិកខ្មែរយើងបានប្រារព្ធបដិបត្តិធ្វើឡើងចាប់ពីថ្ងៃ១រោជ ខែភទ្របទ ដល់ថ្ងៃ១៤រោច ខែ ភទ្របទ រហូតដល់ ថ្ងៃបុណ្យភ្ជុំធំ ត្រូវថ្ងៃ១៥រោច ខែភទ្របទ ដែលបងប្អូនជាមន្ត្រីរាជការអ្នកមុខអ្នកការ ពុទ្ធបរិស័ទ ប្រជាពលរដ្ឋជិតឆ្ងាយបានមកជួបជុំគ្នានាំយកនូវចង្ហាន់ ចំណីអាហារ ទៀនធូប បច្ច័យទៅប្រគេនដល់ព្រះសង្ឃគង់នៅចាំព្រះវស្សា តាមទីវត្តអារាមនានា ក្នុងព្រះរាជាណាចក្រកម្ពុជា៕



អបអរសាទរ ទិវាទេសចរណ៍ពិភពលោក លើកទី៤២ ក្រោមប្រធានបទ "ការគិតគូរឡើងវិញពីវិស័យទេសចរណ៍"

ផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២



អាជ្ញាធរជាតិអប្សរា ធ្វើកំណាយខឿនតម្កល់លិង្គនៅលើភ្នំបូក ដើម្បីឈានទៅរកការជួសជុលសំណង់បុរាណនោះឡើងវិញ

ផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

ក្រុមការងារនាយកដ្ឋានអភិរក្សប្រាសាទនិងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា កំពុងកំណាយស្រាវជ្រាវ ខឿនតម្កល់លិង្គទំហំធំនៅលើភ្នំបូក និងមានតែមួយគត់នៅតំបន់អង្គរ ដែលរងការខូចខាត ក្នុងគោលបំណងជួសជុលលើកតម្លៃខឿនតម្កល់លិង្គឱ្យលេចរូបរាងល្អប្រសើរឡើងវិញ។បច្ចុប្បន្ននេះក្រុមការងារ កំពុងធ្វើកំណាយស្រាវជ្រាវសិក្សាពីរចនាសម្ពន្ធ មុននឹងឈានទៅដល់រៀបចំផែនការជួសជុលលើកតម្លៃបុរាណដ្ឋានឡើងវិញ។

លោក ហួរ សុធន បុរាណវិទូនៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ការធ្វើកំណាយបានចាប់ផ្តើមតាំងពីដើមខែសីហា ឆ្នាំ២០២២ ហើយគម្រោងសិក្សាស្រាវជ្រាវនឹងបញ្ចប់ទៅវិញនៅចុងខែកញ្ញា ឆ្នាំ២០២២ខាងមុខ។ លោក **ហួរ សុធន** ឱ្យដឹងទៀតថា សំណង់បុរាណតម្កល់លិង្គនៅលើភ្នំបូកនេះធ្វើពីថ្មបាយក្រៀមប្រវែងបណ្តោយ១៩ និងទទឹង២០ម៉ែត្រ និងកម្ពស់៣,៥ម៉ែត្រ ហើយនៅលើខឿនថ្មបាយក្រៀមនេះមានជើងទម្រធ្វើពីថ្មភក់មានប្រវែង៥.២ម៉ែត្រ បួនជ្រុងស្មើ សម្រាប់តម្កល់លិង្គ ដែលមានទំហំមុខកាត់ជាង១ម៉ែត្រ និងប្រវែង៤.២ម៉ែត្រ។ ជើងទម្រលិង្គ ដែលធ្វើពីថ្មភក់នោះស្ទើរតែ៩០ភាគរយរងការខូចខាត រីឯលិង្គក៏រងខូចខាតយ៉ាងខ្លាំងតាំងពីផ្នែកគល់ រហូតដល់ចុង គឺបែកបាក់ជាច្រើនបំណែក។ លោក ហួរ សុធន សន្និដ្ឋានថា ការខូចខាតដ៏ធ្ងន់ធ្ងរនេះ អាចបណ្តាលមកពីការបំផ្ទុះដោយគ្រាប់រំសេវ ពីព្រោះយើងប្រទះឃើញបំណែកតូចៗ យ៉ាងច្រើននៅពាសពេញទាំងក្នុងដី និងលើដី។ ដោយឡែក ខឿនថ្មបាយក្រៀម បានរងការខូចខាតដោយកត្តាអាយុកាលធម្មជាតិ ដោយការពុកផុយ ក្រៀកហែក រលុះថ្មធ្លាក់មកក្រោមនៅតាមជ្រុងខ្លះ ជាមួយគ្នានេះនៅលើខឿននោះមានដើមឈើដុះច្រើន ឬសឈើបានចាក់ជ្រែកចូលប្រលោះថ្ម បង្កើតជាចន្លោះដែលជាលក្ខណៈងាយស្រួលដល់ការហូរជ្រោះនៃទឹកភ្លៀង ដំបូកកណ្តៀរបង្កឱ្យមានការបាក់ស្រុតដោយផ្នែក និងកង្វះការថែទាំពីមុនមក។

ពាក់ព័ន្ធនិងសំណង់បុរាណតម្កល់លិង្គនៅលើភ្នំបូកនេះ មិនមានសិលាចារឹក ឬឯកសារណាបញ្ជាក់ពីកាលបរិច្ឆេទនៃការសាងសង់ឡើយ ប៉ុន្តែតាមការពិនិត្យមើលលើខ្សែក្បាច់មាននៅតាមជើងទម្រតម្កល់លិង្គ គេអាចសន្និដ្ឋានបានថាវាប្រហែលជាស្ថិតនៅអំឡុងសតវត្សរ៍ទី១០ ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី១៕

អគ្គនាយកអាជ្ញាធរជាតិអប្សរា និងមន្ត្រីជំនាញ បានចុះពិនិត្យស្ថានភាពដី និងរចនាសម្ព័ន្ធនៅប្រាសាទអង្គរវត្តក្រោយពេលមានភ្លៀងធ្លាក់ខ្លាំង

ផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

នៅព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២នេះ **ឯកឧត្តម បណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរដោយអគ្គនាយករង អ្នកជំនាញជាតិ និងអន្តរជាតិ បានអញ្ជើញចុះពិនិត្យបរិវេណ ប្រាសាទអង្គរវត្ត ក្រោយពេលមានភ្លៀងធ្លាក់ខ្លាំង ដើម្បីពិនិត្យមើលស្ថានភាពដី ថ្មប្រាសាទ ប្រព័ន្ធរំដោះទឹក និងរចនាសម្ពន្ធមួយចំនួនទៀតដើម្បីការពារចៀសវាងមានបញ្ហាប្រឈមណាមួយកើតឡើង៕

មន្ត្រីជាន់ខ្ពស់របស់អង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ បំពេញទស្សនៈកិច្ចនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២

ក្នុងអំឡុងពេលបំពេញបេសកកម្មនៅប្រទេសកម្ពុជា នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២២ **ឯកឧត្តម Stephen Mathias** ឧបការីឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិ និងជានាយកទទួលបន្ទុក ការិយាល័យកិច្ចការច្បាប់ និង **លោកជំទាវ Lynn Goldman Mathias** ដែលជាភរិយា បានឆ្លៀតពេលមកទស្សនៈកិច្ចស្វែងយល់អំពីការគ្រប់គ្រងរមណីយដ្ឋានអង្គរ ដោយមាន **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរផងដែរ។

ក្នុងដំណើរទស្សនៈកិច្ចនោះ គណៈប្រតិភូបានទៅទស្សនាប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទតាព្រហ្ម ប្រាសាទនាគព័ន្ធ សួនរុក្ខជាតិអង្គរជាដើម៕

សូមអញ្ជើញទស្សនាទិដ្ឋភាពស្រស់ត្រកាល នៃប្រាសាទបេងមាលាក្រោយពេលភ្លៀងធ្លាក់

ផ្សាយនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២



ទិដ្ឋភាពថ្ងៃរៀបលិចដ៏ស្រស់ស្អាតអមដោយទេសភាពផ្ទៃដីព្រៃលិចទឹកដាច់កន្ទុយភ្នែក នៃបឹងទន្លេសាបនៅភ្នំក្រោម

ផ្សាយនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២



បុណ្យភ្ជុំបិណ្ឌមានទេសចរជាង៤ពាន់នាក់ចូលទស្សនាសួនរុក្ខជាតិអង្គរ

ផ្សាយនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២

រយៈពេល៣ថ្ងៃ គឺពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ នៃពិធីបុណ្យភ្ជុំបិណ្ឌ មានទេសចរជាតិ និងអន្តរជាតិសរុប ៤ ៣៥០នាក់ ចូលទស្សនាសួនរុក្ខជាតិអង្គរ។ សួនរុក្ខជាតិអង្គរ បានទាក់ទាញទេសចរជាច្រើន ពិសេសនារដូវបុណ្យទានផ្សេងៗ ក្រោយបើកដំណើរការនៅថ្ងៃទី ១៩ ខែឧសភា មក។

សួនរុក្ខជាតិអង្គរ បង្កើតឡើងដោយអាជ្ញាធរជាតិអប្សរា ដោយចែកជា៥ផ្នែកធំៗ រួមមាន សួនឱសថ និងគ្រឿងទេស សួនផ្កាស្មៅ និងផ្កាចម្រុះ សួនអំបូរត្នោតសួនលំនៅដ្ឋានខ្មែរ និងសួនព្រៃឈើ/សត្វព្រៃអង្គរ ដែលសរុបមានរុក្ខជាតិប្រមាណ ៥០០ប្រភេទ។សាធារណជនបន្តចូលទស្សនាដោយសេរី និងឥតបង់ថ្លៃ៕

ក្រុមការងារអាជ្ញាធរជាតិអប្សរា កំពុងរំដោះទឹកចេញពីប្រាសាទដើម្បីបញ្ចៀសពីការជន់លិច

ផ្សាយនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២

នាយដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា បាននិងកំពុងខិតខំរំដោះទឹកតាមទ្វារទឹក និងតំបន់ប្រាសាទមួយចំនួន បង្ការកុំឱ្យជន់លិចប្រាសាទ។

ឥទ្ធិពលនៃព្យុះ ណូរុ ពីប្រទេសហ្វីលីពីន បណ្តាលឱ្យកម្ពុជារងសម្ពាធទាប និងមានភ្លៀងធ្លាក់ជាបន្តបន្ទាប់ចាប់ពីពាក់កណ្តាលខែ កញ្ញា មក។ ការណ៍នេះ ធ្វើឱ្យមានភ្លៀងធ្លាក់ជាច្រើនដង និងបណ្តាលឱ្យជន់លិចស្រុកមួយចំនួនក្នុងខេត្តសៀមរាប។ នៅរមណីយដ្ឋានអង្គរ ទឹកភ្លៀងច្រើនសន្ធឹកត្រូវបានប្រមូលទុក និងខ្លះត្រូវបានរំដោះចេញផងដែរ ដោយសារបរិមាណហួសកម្រិត។

តាមរបាយការណ៍សង្ខេប ពីនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា ក្រុមការងារបានរំដោះទឹក នៅប្រាសាទមួយចំនួនដូចជា ប្រាសាទអង្គរវត្ត ព្រះខ័ន តាព្រហ្ម និងបាយ័ន្តជាដើម។ល។ បញ្ចៀសទឹកតាមប្រព័ន្ធប្រឡាយបុរាណទៅតាមស្ទឹងនានា ដូចជាស្ទឹងសៀមរាប ស្ទឹងរលួស ស្ទឹងពួក និងស្ទឹងព្រះស្រុក ដើម្បីកុំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់តំបន់ប្រាសាទ និងក្រុងសៀមរាប។

ក្រៅពីការងារខាងលើនេះ ក្រុមការងារក៏បានប្រមូលទឹកដើម្បីបំពេញក្នុងប្រព័ន្ធគ្រប់គ្រងបុរាណ ដើម្បីធានាដល់តុល្យភាពនៃការប្រើប្រាស់ទឹកក្នុងតំបន់អង្គរ មានដូចជាបារាយណ៍ខាងលិច បារាយណ៍ខាងជើង កសិន្ធុអង្គរធំ កសិន្ធុអង្គរវត្ត ស្រះស្រង់ រួមនិងកសិន្ធុព្រះខ័នជាដើម។ល។

ដីជ្រាយ ភ្លៀងខ្យល់ខ្លាំង ដើមឈើដួលរលំ សូមមានការប្រុងប្រយ័ត្នខ្ពស់

ផ្សាយនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២

ក្នុងស្ថានភាពអាកាសធាតុទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំពុងស្ថិតក្នុងរដូវវស្សាដែលមានភ្លៀងធ្លាក់ជាប្រចាំច្រើន ព្រមទាំងសម្ពាធទាបដែលរងឥទ្ធិពលពីខ្យល់ព្យុះផ្សេងៗធ្វើឱ្យមានភ្លៀងធ្លាក់លើសពីធម្មតា និងមានខ្យល់ដែលមានកម្លាំងល្បឿនខ្លាំង។ ចំពោះរមណីយដ្ឋានអង្គរក៏ទទួលបានទឹកភ្លៀងក្នុងកំរិតខ្ពស់បណ្តាលឱ្យដីមានភាពទន់ជ្រាយ និង រងទទួលនូវខ្យល់កន្ត្រាក់បក់បោកយ៉ាងខ្លាំងបណ្តាលឱ្យមានដើមឈើមួយចំនួនបានដួលរលំជាបន្តបន្ទាប់ ព្រមទាំងបង្កផលប៉ះពាល់ដល់ប្រាង្គប្រាសាទ សុវត្ថិភាពរបស់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរទាំងឡាយដែលឆ្លងកាត់ និងចូលទៅទស្សនាក្នុងរមណីយដ្ឋានអង្គរ។

ស្ថិតក្នុងស្ថានភាពប្រឈម អាជ្ញាធរជាតិអប្សរាសូមក្រើនរំលឹកដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរឱ្យមានការប្រុងប្រយ័ត្នខ្ពស់ ក្នុងដំណើរចូលទៅកម្សាន្តក្នុងរមណីយដ្ឋានអង្គរ ជាពិសេស ពេលមានភ្លៀងធ្លាក់ខ្លាំងត្រូវនៅឱ្យឆ្ងាយពីដើមឈើធំៗ កុំជ្រក ឬចតយានយន្តក្រោមដើមឈើដើម្បីជៀសវាងពីគ្រោះថ្នាក់ជាយថាហេតុណាមួយ៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែតុលា

ប្រាសាទភិមានអាកាស កសាងនៅពាក់កណ្តាលសតវត្សរ៍ទី១០ ដែលត្រូវចាត់ទុកថាជាទីបូជា នៃព្រះរាជវាំង ក្នុងក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២

ក្រុមប្រាសាទព្រះពិធូរ មានប្រាសាទផ្សេងៗគ្នាចំនួន៥ ដែលមានប្រាសាទ១ សម្រាប់ព្រះពុទ្ធសាសនា និងប្រាសាទ៤ផ្សេងទៀតសម្រាប់ព្រហ្មញ្ញសាសនា ស្ថិតក្នុងបរិវេណក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០២២



ទិដ្ឋភាពដ៏អស្ចារ្យនៅប្រាសាទអង្គរវត្ត នាព្រឹកព្រលឹម ០៣ តុលា ២០២២

ផ្សាយនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២

ក្រុមការងារអាជ្ញាធរជាតិអប្សរា តាមដានជាប្រចាំនៅតាមទ្វារទឹកសំខាន់ៗ ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២

ក្រុមការងារនៃនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ របស់អាជ្ញាធរជាតិអប្សរា កំពុងធ្វើការជាប់ជាប្រចាំ ទាំងយប់ទាំងថ្ងៃ នៅតាមទ្វារទឹកសំខាន់ៗ ដើម្បីបញ្ចៀសទឹកមិនឱ្យជន់លិចតំបន់រមណីយដ្ឋានអង្គរ និងក្រុងសៀមរាប។ បើទោះបីបរិមាណទឹកមានច្រើនក៏ដោយ តែក្រុមការងារអាជ្ញាធរជាតិអប្សរា អាចបញ្ចៀសទឹកទៅតាមប្រព័ន្ធធារាសាស្ត្រដែលមានភាពខ្វាត់ខ្វែង និងប្រសិទ្ធភាពខ្ពស់៕

ប្រទះឃើញបំណែកចម្លាក់ក្បាលនាគក្នុងរចនាបថបាយ័ន កប់ក្នុងដីចំនួន១

ផ្សាយនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២

ថ្មីៗនេះ មានការប្រទះឃើញដោយចៃដន្យនូវក្បាលនាគចំនួន១ធ្វើពីថ្មភក់ស្ថិតក្នុងរចនាបថបាយ័ន នៅពេលដើមស្រឡៅធំមួយដើមបានដួលរលំ បណ្តាលឱ្យបំណែកក្បាលនាគដែលកប់ក្នុងដីជាយូរឆ្នាំហើយ ត្រូវបានផុសឡើងតាមឫសឈើ នៅក្នុងបរិវេណវត្តទេពប្រណម្យ អតីតរាជធានីអង្គរធំ។

លោក ឈូក សុម៉ាឡា ប្រធានក្រុមចុះបញ្ជីវត្ថុសិល្បៈ នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា បំណែកក្បាលនាគនេះ បានកប់ក្នុងដីជម្រៅប្រមាណកន្លះម៉ែត្រ ហើយជាក់ស្តែង ដើមស្រឡៅដែលដុះពីលើមិនមានឫសកែវធំៗ ទើបពេលភ្លៀងជោគជាំដីជ្រាយ ធ្វើឱ្យដួលរលំ និងផុសក្បាលនាគដែលឫសឈើដុះចាក់ស្រេះមកជាមួយតែម្តង។ លោក សុម៉ាឡា បន្តថា បំណែកក្បាលនាគនេះ មានត្រឹមតែកនាគមកក្បាលខាងលើដែលមាន បណ្តោយ១.២ម៉ែត្រ ទទឹង១ម៉ែត្រ និងកម្រាស់ ០.៣ម៉ែត្រ បំណែកសត្វគ្រុឌជិះលើក្បាលនាគ ស្ថានភាពមុខនាគខាងមុខមានការខូចខាតច្រើនដោយអន្លើរ ដោយបាក់បែកមុខនាគ និងជុំវិញសងខាង។ រីឯសត្វគ្រុឌវិញ ត្រូវបានបាក់ច្រមុះ និងដៃផ្នែកនៅខាងលើ រួមទាំងផ្នែកខ្លះនៃក្បាល។

លោក ឈូក សុម៉ាឡា សន្និដ្ឋានថា បំណែកក្បាលនាគនេះ អាចយកចេញពីប្រាសាទបាយ័ន តែមិនដឹងថា យកមកទីតាំងនេះក្នុងគោលបំណងអ្វី និងពេលណានោះទេ។ បន្ថែមទៀតថា រូបចម្លាក់បែបនេះច្រើនឃើញនៅរចនាបថបាយ័ន ក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ ទ្រង់បានយកនាគ និងគ្រុឌដែលជាសត្រូវនឹងគ្នាមកបញ្ចូលក្នុងសិល្បៈតែមួយ។ អាចជាព្រះអង្គចង់បង្ហាញពីទស្សនៈបង្រួបបង្រួមសាសនា រវាងព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ទើបព្រះអង្គឱ្យស្ថាបត្យករបញ្ចូលនាគ និងគ្រុឌនៅជាមួយគ្នា ហើយដាក់បង្ហាញលើសំណង់នានារបស់ទ្រង់។

ដើម្បីរក្សាសុវត្ថិភាពនូវបំណែកក្បាលនាគនេះ ទើបអាជ្ញាធរជាតិអប្សរា សហការជាមួយនគរបាលការពារបេតិកភណ្ឌ ព្រមទាំងភ្នាក់ងារទេសចរណ៍ ធ្វើកំណត់ហេតុប្រគល់ទទួលបំណែកចម្លាក់ខាងលើ យកទៅរក្សាទុកនៅសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ ដើម្បីចុះបញ្ជីទុកជាឯកសារ លាងសម្អាត រក្សាទុកទៅតាមបច្ចេកទេស និងស្វែងរកទិន្នន័យផ្សេងទៀតផងទាក់ទងនឹងបំណែកក្បាលនាគនេះ ងាយស្រួលយកទៅដាក់នៅទីតាំងដើមវិញ បើមានការជួសជុលនៅទីតាំងដែលបានបាត់បង់នោះ៕

ក្រុមការងារសម្អាតបរិស្ថានបន្តការងារជាប្រចាំដើម្បីសោភ័ណភាពបរិស្ថានក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

ក្រុមការងារសម្អាតបរិស្ថានក្នុងរមណីយដ្ឋានអង្គរ បានបន្តការងារជាប្រចាំ ទាំងការងារសម្អាតលើកដី ប្រាសាទ និងក្នុងទឹក ដើម្បីធ្វើយ៉ាងណាឱ្យរមណីយដ្ឋានអង្គរមានសោភ័ណភាព និងអនាម័យស្អាតជានិច្ច។ នេះជាការរួមចំណែកមួយដ៏សំខាន់ ដើម្បីឱ្យរមណីយដ្ឋានអង្គរ ក្លាយជាគោលដៅទេសចរណ៍ដ៏សំខាន់ និងទាក់ទាញសម្រាប់ភ្ញៀវទេសចរ៕

ក្រុមការងារសណ្តាប់ធ្នាប់ បន្តការងារយ៉ាងសកម្ម ដើម្បីរៀបចំ និងសម្រួលការចតយានយន្តរបស់ភ្ញៀវទេសចរ

ផ្សាយនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា បានខិតខំកែប្រែទីតាំងជាច្រើនកន្លែង ធ្វើយ៉ាងណារៀបចំសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ សាធារណៈ ការលក់ដូររបស់បងប្អូនអាជីវករ ជាពិសេស រៀបចំឱ្យមានចំណតចតយានយន្តរបស់អ្នកទេសចរដែល មានបំណងចូលទស្សនានៅតាមប្រាសាទ ឬរមណីយដ្ឋាន នានា ក្នុងតំបន់រមណីយដ្ឋានអង្គរ។

លោក សោម ហ៊ិត់ អនុប្រធានប្រចាំការ សណ្តាប់ធ្នាប់ នៅមុខប្រាសាទអង្គរវត្ត បានឱ្យដឹងថា នៅខាងមុខ ប្រាសាទអង្គរ មានទីតាំងចំណតសម្រាប់ចតយានយន្ត គ្រប់ប្រភេទយ៉ាងធំទូលាយ និងអនុញ្ញាតឱ្យភ្ញៀវទេសចរ ចូលចតក្នុងចំណតទាំងនោះ ដោយមិនតម្រូវឱ្យបង់ ថវិកាឡើយ ។ លោកបន្តថា ក្រុមការងារសណ្តាប់ធ្នាប់ ប្រចាំការតាមគោលដៅនីមួយៗ បានយកចិត្តទុកដាក់ យ៉ាងខ្លាំងក្នុងការជួយសម្រួលចរាចរណ៍ ជាពិសេស នៅតាម ដងផ្លូវដោយជំរុញណែនាំឱ្យម្ចាស់យានយន្តដែលចតគ្មាន របៀបរៀបរយ នៅតាមដងផ្លូវ ត្រូវចូលមកចតនៅក្នុង ចំណតជាដើម។ លោកបន្តថា ទោះបីពេលខ្លះក្រុមការងារ លោក ត្រូវប្រឈមមុខ និងការប្រមាថមាក់ងាយពីសំណាក់ ជនមួយចំនួន ក្រោយពួកគាត់បានណែនាំឱ្យយកយាន ជំនិះទៅរក្សាទុកក្នុងទីតាំងចំណតឱ្យបានត្រឹមត្រូវក្តី។

លោក សុខ សីហា អ្នកដឹកភ្ញៀវទេសចរមួយរូបនៅខាងមុខ ប្រាសាទអង្គរវត្ត បានឱ្យដឹងថា បច្ចុប្បន្ននេះ អាជ្ញាធរជាតិ អប្សរា បានរៀបចំសណ្តាប់ធ្នាប់ និងចំណតយានយន្ត បានយ៉ាងស្រស់ស្អាត ដើម្បីទាក់ទាញភ្ញៀវទេសចរចូលមក ទស្សនាប្រាសាទអង្គរវត្ត។ ចំណែកឥរិយាបទនៃការចត យានជំនិះរបស់ភ្ញៀវទេសចរវិញ ក៏បានចូលរួមយ៉ាងសកម្ម តាមការណែនាំរបស់អាជ្ញាធរជាតិអប្សរាដែរ។

ដើម្បីឱ្យសណ្តាប់ធ្នាប់សាធារណៈ នៅតំបន់រមណីយដ្ឋាន អង្គរ មានរបៀបរៀបរយ មិនកកស្ទះ មានសោភ័ណភាព ស្រស់ស្អាត ស័ក្តិសមជាសម្បត្តិបេតិកភណ្ឌពិភពលោក ចាំបាច់ណាស់ត្រូវមានការចូលរួមពីសំណាក់ភ្ញៀវទេសចរ គ្រប់រូបមិនអាចខ្វះបានឡើយ៕



ខ្លោងទ្វារតាកាវ នឹងក្លាយទៅជាគោលដៅទេសចរណ៍ថ្មីមួយទៀត បន្ទាប់ពីការជួសជុលរួចរាល់

ផ្សាយនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២

ខ្លោងទ្វារតាកាវ ស្ថិតនៅទិសខាងលិចនៃក្រុងអង្គរធំ ដែលធ្លាប់តែមានភាពទ្រុឌទ្រោមដោយសារអាយុកាល អាកាសធាតុ សង្គ្រាម កង្វះការថែទាំ ជំរីទាំង៤ជ្រុងបានរងនូវការខូចខាតជាខ្លាំងដោយសារដើមឈើ និងឬសឈើដុះចាក់ចូលរចនាសម្ពន្ធ បណ្តាលឱ្យរចនាសម្ពន្ធរបស់ខ្លោងទ្វារមួយភាគធំ ពិសេស កំពូលខ្លោងទ្វារដែលមានមុខព្រហ្មទាំងបួនទិស រួមទាំងសំណង់ជាប់សងខាងនៃខ្លោងទ្វារ ថ្មបានក្រៀករំកិលចេញពីទីតាំងដើមដោយអន្លើ ថ្មមួយចំនួនបានជ្រុះធ្លាក់មកក្រោមផង ដែលទាមទារឱ្យមានការទល់ទ្រ បណ្តោះអាសន្នជាចាំបាច់ និងបានប្រើខ្សែកាបរឹតផង អស់រយៈពេលជាង១០ឆ្នាំ នៅតែមានហានិភ័យខ្ពស់ដោយសារឈើទ្រនល់ពុកផុយ កាបធូររលុង ឬសឈើដុះឬសជ្រែកហែកកាន់តែធំឡើង ឥឡូវបានវិលត្រឡប់ទៅរកភាពល្អស្អាត រឹងមាំ និងមានសោភ័ណភាពពេញលេញវិញហើយ បន្ទាប់ពីក្រុមអ្នកជំនាញបានចំណាយអស់រយៈពេលប្រមាណជិត២ឆ្នាំដើម្បីជួសជុល។

បច្ចុប្បន្ននេះ ខ្លោងទ្វារតាកាវទាំងមូលបានសង្គ្រោះឱ្យរួចផុតពីហានិភ័យផ្សេងៗ ដោយអាជ្ញាធរជាតិអប្សរា ក្រោមជំនួយឧបត្ថម្ភពីវិស័យឯកជន តាមរយៈ**លោកជំទាវឧកញ៉ា នាងវិសាខា អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភកិត្តិបណ្ឌិត សៀង ចាន់ហេង** (អគ្គនាយិកាក្រុមហ៊ុន ហេង អភិវឌ្ឍន៍) ធ្វើការជួសជុល ដើម្បីលើកតម្លៃឱ្យខ្លោងទ្វារនេះ នៅឈររឹងមាំ ជាខ្លោងទ្វារការពារក្រុងអង្គរធំ។ កំពូលខ្លោងទ្វារដែលមានព្រះភ័ក្ត្រទាំងបួនទិស ដែលធ្លាប់តែបាត់បង់ផ្នែកខ្លះជាយូរមកហើយ ត្រូវបានជួសជុលទៅតាមលក្ខណៈដើមឡើងវិញ ដូចជា បបូរមាត់ ក្តោងច្រមុះ ស្លឹកត្រចៀក ថ្ពាល់ និងផ្នែកផ្សេងៗបានរៀបបញ្ចូលទីតាំងដើមវិញ ធ្វើឱ្យព្រះភ័ក្ត្រញញឹមរស់រវើកឡើងវិញ ហើយរូបជំរីនៅតាមជ្រុងទាំងបួន បានលេចរូបរាងឈរឡើងវិញ ហាក់កំពុងជួយទប់លំនឹងរចនាសម្ពន្ធខ្លោងទ្វារទាំងមូលផង។

ក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមជួសជុលខ្លោងទ្វារតាកាវ ភាគខាងលិចនៃក្រុងអង្គរធំនេះ តាំងតែពីចុងខែកុម្ភៈ ឆ្នាំ២០២១ ហើយរហូតមកដល់អំឡុងខែតុលា ឆ្នាំ២០២២នេះ គឺបានសម្រេចប្រមាណ៩៧ភាគរយហើយ ដោយនៅសេសសល់តែការកែសម្រួលថ្មភក់ថ្មី ដែលបានជំនួសថ្មចាស់ដែលបាត់បង់ឬខូចគុណភាព។ បច្ចុប្បន្ន ក្រុមការងារកំពុងមមាញឹកក្នុងការរុះរើរន្ទារចេញជាបណ្តើរៗ ហើយនឹងបញ្ចប់នាពេលឆាប់ៗខាងមុខ។

ខ្លោងទ្វារតាកាវ គឺជាខ្លោងទ្វារមួយក្នុងចំណោមខ្លោងទ្វារចេញចូលទាំង៥ នៃក្រុងអង្គរធំ ដែលស្ថិតនៅទិសខាងលិចនៃប្រាសាទបាយ័ន។ ក្រោយពីបញ្ចប់ការជួសជុលទាំងស្រុងខ្លោងទ្វារនេះ នឹងបង្កើនភាពទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យទៅទស្សនា និងផ្តិតយករូបភាពមួយផ្នែកទៀតនៃទិសដៅទេសចរណ៍ថ្មី ៕

សកម្មភាពក្រុមភ្នាក់ងារទេសចរណ៍នៅប្រាសាទអង្គរវត្ត ចូលរួមជួយបោសសម្អាតដើម្បីអនាម័យល្អនៅកំពូលរួតបាកាណ

ផ្សាយនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២



ប្រាសាទតាកែវ ស្ថាបត្យកម្មសំណង់បុរាណដ៏ធំ សាងសង់នៅចុងសតវត្សទី១០ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥

ផ្សាយនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២២



ប្រាសាទតាណៃ បុរាណដ្ឋានកសាងនាចុងស.វ.ទី១២ សម្រាប់ទេសចរ ដែលចូលចិត្តធម្មជាតិ និងដំណើរកម្សាន្តបែបផ្សងព្រេង

ផ្សាយនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២២



អាជ្ញាធរជាតិអប្សរាកំពុងជួសជុលប្រាសាទខ្នារផ្ទោល ស្ថិតនៅក្នុងឃុំស្រែណូយស្រុកវ៉ារិន ខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២

ប្រាសាទខ្នារផ្ទោល ជាប្រាសាទសង់អំពីឥដ្ឋ និងថ្មបាយក្រៀម ដែលមានចំនួន២ប៉ម ដោយប៉មនីមួយៗ មានទំហំទទឹង ៤ម៉ែត្រ បណ្តោយ៦ម៉ែត្រ និងកម្ពស់៦ម៉ែត្រ ឈរទន្ទឹមគ្នា ជើង ត្បូងនៅលើរចនាសម្ពន្ធបុរាណមានកសិន្ធុទឹកពទ្ធ័ជុំវិញ។ ប្រាសាទនេះ បច្ចុប្បន្នស្ថិតនៅដាច់ស្រយាលចម្ងាយប្រមាណ៧០គីឡូម៉ែត្រ ភាគខាងជើងឈៀងខាងលិច ពីទីរួមខេត្តសៀមរាប និងឆ្ងាយពីទីប្រជុំជននៃស្រុកវ៉ារិន ហើយកន្លងមក ការថែទាំ និងអភិរក្សពុំទាន់បានអនុវត្តគ្រប់ជ្រុងជ្រោយនៅឡើយ។ ហេតុដូច្នេះហើយ បច្ចុប្បន្នគេសង្កេតឃើញថា រចនាសម្ពន្ធរបស់ប៉មថ្ម និងប៉មឥដ្ឋទាំងមូលរងការខូចខាតធ្ងន់ធ្ងរ ដោយសាររុក្ខជាតិតូចធំជាច្រើនដុះលើប៉មប្រាសាទ និងមានបញ្ហាទទួលនូវជម្រាបទឹកជាប្រចាំបណ្តាលឱ្យរចនាសម្ពន្ធប្រាសាទរងនូវការខូចទ្រង់ទ្រាយដោយផ្នែក។

លោក តាន់ សុផល អនុប្រធាននាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរាមានប្រសាសន៍ថា សំណង់ប្រាសាទខ្នារផ្ទោលនេះ ជាមរតកបេតិកភណ្ឌជាតិ មានតម្លៃខ្លាំង ដែលត្រូវយកចិត្តទុកដាក់ថែរក្សា និងការពារកម្រិតខ្ពស់ ព្រោះវាកំពុងស្ថិតនៅរូបរាងច្បាស់លាស់ដែលអាចឱ្យភ្ញៀវទេសចរទស្សនា និងស្វែងយល់បានច្បាស់អំពីសំណង់ស្ថាបត្យកម្មខ្មែរ និងប្រវត្តិនានាទាក់ទងទៅនឹងសិល្បៈ នៃការសាងសង់ប្រាសាទនេះឡើងនាសម័យអតីតកាល។

កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២នេះ គឺមួយផ្នែកត្រង់រចនាសម្ពន្ធរបស់ខ្លោងទ្វារខាងកើតនៃប៉មខាងត្បូង រួមមាន ផ្តែរ សសរពេជ្របានរលុះចេញពីទីតាំងដើម ដោយសារកត្តាធម្មជាតិ។ ចំណែក ស្រទាប់ឥដ្ឋដែលសេសសល់ស្ថិតនៅខាងលើផ្តែរ ក៏កំពុងប្រឈមនឹងបន្តការលុះនាពេលបន្ទាប់ខាងមុខ។ ដូចនេះ អាជ្ញាធរជាតិអប្សរា បានខិតខំប្រឹងប្រែងរកវិធីទប់ស្កាត់ និងជួយសង្គ្រោះបន្ទាន់ដោយប្រើប្រាស់បច្ចេកទេសទល់ទ្រូបណ្តោះអាសន្ននៅត្រង់ខ្លោងទ្វារខាងកើតគឺក្នុងបំណងកាត់បន្ថយរាល់ហានិភ័យទាំងនោះ និងអាចមានពេលវេលាគ្រប់គ្រាន់សម្រាប់សិក្សាលម្អិតអំពីកម្រិតខូចខាតទាំងមូល រួមទាំងរៀបចំកម្មវិធីអភិរក្ស និងជួសជុលសម្រាប់រយៈពេលវែងក្នុងឆ្នាំ២០២៣ ឬឆ្នាំ២០២៤។

បច្ចុប្បន្នក្រុមអ្នកបច្ចេកទេសខ្មែរ នៃអាជ្ញាធរជាតិអប្សរាកំពុងប្រតិបត្តិផ្នែកអភិរក្សប្រាសាទនេះឡើងវិញ ក្នុងដំណាក់កាលទី២ បន្ទាប់ពីធ្វើការទល់ទ្រូបឋមរួចរាល់កន្លងមក ក្នុងនោះកិច្ចការសង្គ្រោះបន្ទាន់ គឺនឹងរៀបចំជួសជុលសសរពេជ្រដែលបាក់បែកទាំងសងខាង ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ដំឡើងថ្មផ្តែរដាក់នៅត្រង់ ទីតាំងដើមវិញក្នុងស្ថានភាពមានសុវត្ថិភាពគ្រប់គ្រាន់ រួមទាំងជួសជុលជញ្ជាំងឥដ្ឋ និងសសរផ្អោបទាំងពីរនៅខ្លោងទ្វារខាងកើតនៃប៉មខាងត្បូង។

សកម្មភាពក្រុមការងារសម្អាតបរិស្ថានបន្តការងារជាប្រចាំដើម្បីសោភ័ណភាពបរិស្ថាន ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២

ក្រុមភ្នាក់ងារសណ្ដាប់ធ្នាប់ នៃនាយកដ្ឋានសណ្ដាប់ធ្នាប់ ចូលរួមជីករណ្ដៅ ដើម្បីដាំកូនឈើឡើងវិញនៅបរិវេណខាងមុខប្រាសាទភ្នំបាខែង ក្រោយទីតាំងនោះត្រូវបានរៀបចំដោយរើបង្គោលឈើចេញ ហើយកន្លែងផែកសំបុត្រ បានរើចូលទៅកន្លែងថ្មីក្នុងចំណតមុខប្រាសាទនេះ។ ទីតាំងនេះត្រូវបានទំនេរ ហើយនាយកដ្ឋានជំនាញអាជ្ញាធរជាតិអប្សរា រៀបចំយកកូនឈើជាង១០០ដើម ដើម្បីដាំបំពេញបន្ថែមនៅកន្លែងចន្លោះនោះ។៕

ផ្សាយនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរាគ្រោងបិទផ្ទៃមុខអប្សរា ដែលរបេះឡើងវិញពេលអាកាសធាតុអំណោយផល

ផ្សាយនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា តាមរយៈនាយកដ្ឋានជំនាញគ្រោងបិទផ្ទៃមុខអប្សរាដែលរបេះចេញពីរូបរាងឡើងវិញ នៅពេលអាកាសធាតុអំណោយផល ជារួមនៅពេលដែលទីតាំងថ្មដែលរបេះនោះស្ងួតល្អវិញ។

លោក សោម ប៊ុនធឿន អនុប្រធានភ្នាក់ងារទេសចរណ៍ប្រចាំប្រាសាទតាព្រហ្ម បានរាយការណ៍ថា ផ្ទៃមុខអប្សរាដែលបាត់នោះ ពុំមានអ្នកណាជាប់ ឬលួចយកនោះទេ។ លោករំឭកថា កាលពីព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ភ្នាក់ងារទេសចរណ៍បានប្រទះឃើញផ្ទៃមុខអប្សរា ដែលមានទីតាំងនៅជិតដើមគ្រាង ដែលទេសចរចូលចិត្តផ្តិតរូបភាព ដោយសារមានឫសឈើធំតោងលើរោងទងប្រាសាទនោះ របេះចេញពីទីតាំងដើម និងបានរាយការណ៍ទៅផ្នែកពាក់ព័ន្ធ ពិសេសផ្នែកអភិរក្ស ដើម្បីមកពិនិត្យ។

អនុប្រធានភ្នាក់ងារទេសចរណ៍ដែលប្រចាំការដោយផ្ទាល់នៅប្រាសាទតាព្រហ្ម រំឭកទៀតថា ក្រោយអ្នកជំនាញត្រួតពិនិត្យរួចឃើញថា រូបខាងលើគឺបានជ្រុះធ្លាក់ដោយសារអាយុកាល និងធម្មជាតិ ពុំមែនជាសកម្មភាពរបស់មនុស្សលួចជាប់ឡើយ។

លោកស្រី នេត ស៊ីម៉ន មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា ដែលប្រចាំការនៅប្រាសាទតាព្រហ្ម លើកឡើងថា លោកស្រីបានទទួលព័ត៌មាន ពីករណីខាងលើ ពីក្រុមភ្នាក់ងារទេសចរណ៍ និងបានចុះទៅពិនិត្យជាមួយផ្នែកពាក់ព័ន្ធដូចជានគរបាលបេតិកភណ្ឌជាដើម។ តាមការវាយតម្លៃផ្ទៃមុខអប្សរានោះ គឺរបេះមកដោយខ្លួនឯង ដោយមានស្នាមប្រេះយូរហើយ តែគេមើលមិនឃើញ។

លោកស្រីបន្ថែមថា តាមការសង្កេតផ្ទៃថ្មដែលជាប់ជញ្ជាំងគឺមានកូនឫសឈើដើមគ្រាងចាក់ចូល ហើយមានស្នាមប្រេះស្រាប់ផងនោះ ទើបឫសឈើវាបានផ្ទាត់រូបមុខអប្សរានោះឱ្យជ្រុះធ្លាក់។ យ៉ាងណាលោកស្រី នេត ស៊ីម៉ន បញ្ជាក់ថា ជាសំណាងល្អផ្ទាំងមុខអប្សរាបានជ្រុះទើរឬសឈើ មិនដូច្នោះទេ អាចឱ្យបែកដោយងាយ។

មន្ត្រីរូបនេះបញ្ជាក់ទៀតថា បច្ចុប្បន្នផ្ទៃមុខដែលជ្រុះនោះត្រូវបានរក្សាទុកនៅទីមានសុវត្ថិភាព និងរង់ចាំពេលវេលាអំណោយផល អាកាសធាតុល្អឡើងវិញ នោះក្រុមការងារភាគីឥណ្ឌា ដែលសហការជួសជុលប្រាសាទតាព្រហ្ម នឹងយកមកបិទឡើងវិញ៕

លិខិតអបអរសាទរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលទទួលបានយុត្តិធម៌ និងភាពស្អាតស្អំពីតុលាការយុត្តិធម៌ ទីក្រុងប៉ារីស ប្រទេសបារាំង ក្នុងសំណុំរឿងបរិហារកេរ្តិ៍ ប្តឹងជនជាប់ចោទ សម រង្ស៊ី។

ផ្សាយនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
A P S A R A

លេខ៖ ៦៩០/ឥប.អលម
២២

លិខិតអបអរសាទរ

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់!

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករនៃអាជ្ញាធរជាតិអប្សរា សូមសម្តែងនូវអំណរសាទរ និងសេចក្តីសោមនស្សរីករាយក្រៃលែង ក្នុងឱកាសដែលសភាទី១៧ នៃតុលាការយុត្តិធម៌ទីក្រុងប៉ារីស បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសំអាងហេតុនៃសាលក្រម ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ ផ្តល់យុត្តិធម៌ និងភាពស្អាតស្អំជូន **សម្តេចតេជោ** ជាទីគោរពដ៏ខ្ពង់ខ្ពស់ និងរកឃើញការពិតថា ជនជាប់ចោទ **សម រង្ស៊ី** បានប្រព្រឹត្តអំពើបរិហារកេរ្តិ៍ចំពោះ **សម្តេចតេជោ**។

សាលក្រមរបស់តុលាការបារាំងនេះ បានបង្ហាញយ៉ាងច្បាស់នូវភាពជោគជ័យរបស់ **សម្តេចតេជោ** ដោយទទួលបាននូវការសម្រេចមួយសមស្របតាមបំណងប្រាថ្នារបស់ **សម្តេចតេជោ** ដែលចង់បាននូវយុត្តិធម៌ និងភាពស្អាតស្អំនេះ និងទាត់ចោលការថ្លែងមួលបង្កាច់នាពេលកន្លងមករបស់ជនជាប់ចោទ**សម រង្ស៊ី**។ ចំពោះបុគ្គល **សម រង្ស៊ី** វិញ ត្រូវរងភាពបរាជ័យយ៉ាងធ្ងន់ធ្ងរ ដោយតុលាការបានគូសបញ្ជាក់ថាពាក្យពេចន៍ទាំងឡាយរបស់បុគ្គលនេះ គឺជាការចោទប្រកាន់ដោយគ្មានភ័ស្តុតាង និងជាការបរិហាកេរ្តិ៍ ហើយបុគ្គល **សម រង្ស៊ី** ត្រូវបង់ខាតចំពោះរាល់ការចំណាយទាំងអស់។

យើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមតាមថែរក្សា **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បុត្រា បុត្រី ចៅប្រុស ចៅស្រីជាទីស្រឡាញ់របស់ **សម្តេចទាំងទ្វេ** សូមបានប្រកបដោយសុខភាពល្អបរិបូណ៌ កម្លាំងកាយចិត្តមាំមួន និងពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ៕

ថ្ងៃ ពុធ ២រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សៀមរាប ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២
អគ្គនាយក

ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

1/1

ភ្ញៀវទេសចរបង្ហាញអារម្មណ៍សប្បាយរីករាយក្រោយពេលបានឆ្លងកាត់ស្ពានថ្មី ចូលទស្សនាប្រាសាទនាគព័ន្ធ

ផ្សាយនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

ស្ពានថ្មីនៅប្រាសាទនាគព័ន្ធ បានចាប់ផ្ដើមបើកឱ្យភ្ញៀវទេសចរធ្វើដំណើរឆ្លងកាត់ ចូលទៅទស្សនាប្រាសាទនាគព័ន្ធ ជាពិសេសទស្សនាទិដ្ឋភាពដ៏ស្រស់ស្អាតនៅលើផ្ទៃទឹក នៃបារាយណ៍ជ័យតដាក ឬនាគព័ន្ធ (បារាយណ៍ខាងជើង)។

លោក វិចិត្រ ប្រជាពលរដ្ឋមកពីខេត្តបន្ទាយមានជ័យ បានឱ្យដឹងថា នេះជាលើកទី១ហើយ ដែលរូបលោកបាននាំក្រុមគ្រួសារ ចូលមកទស្សនាប្រាសាទនាគព័ន្ធ ដោយសារធ្វើដំណើរឆ្លងកាត់ បានឃើញស្ពានថ្មីមួយ ទើបតែសាងសង់រួចរាល់ មានរូបរាងស្រស់ស្អាត ទើបចាប់ចិត្តចង់ចូលទស្សនាទិដ្ឋភាពនៅទីនេះ។ លោកបន្តថា នៅពេលបានឆ្លងកាត់លើស្ពានថ្មីនេះ ពិតជាមិនខកបំណងឡើយ ព្រោះមានទេសភាពស្រស់ស្អាត ផ្ទៃទឹកខៀវស្រងាត់ ព្រមជាមួយសត្វស្លាបហោះហើរឆ្លងកាត់ព្រោងព្រៀតជាទីចាប់អារម្មណ៍សម្រាប់អ្នកទេសចរ។

ចំណែកលោក សេង គុណ ប្រជាពលរដ្ឋមកពីស្រុកប្រាសាទបាគង បានបង្ហាញថា ក្រោយទទួលបានព័ត៌មានអំពីការជួសជុលស្ពានថ្មី នៅមុខប្រាសាទនាគព័ន្ធបានរួចរាល់ ហើយអនុញ្ញាតឱ្យភ្ញៀវទេសចរឆ្លងកាត់ហើយនោះ លោកក៏បានសម្រេចចិត្តមកទស្សនាប្រាសាទនាគព័ន្ធ។

ក្នុងនោះលោកសង្កេតឃើញ ស្ពានថ្មីនេះមានភាពរឹងមាំស្រស់ស្អាត និងធំទូលាយជាងមុន។ លោកក៏រំពឹងថា និងមានភ្ញៀវទេសចរមកទស្សនា ប្រាសាទនាគព័ន្ធនេះកាន់តែច្រើនថែមទៀត។

លោក សេង គុណា ក៏បានថ្លែងអំណរគុណដល់អាជ្ញាធរជាតិអប្សរា ដែលបានយកចិត្តទុកដាក់ក្នុងការស្ថាបនាស្ពានថ្មីនេះ ក៏ដូចជាការអភិវឌ្ឍរមណីយដ្ឋានអង្គរ ឱ្យកាន់តែមានភាពស្រស់ស្អាត សាកសមជាសម្បត្តិបេតិកភណ្ឌពិភពលោក។

គួររំឭកថា បារាយណ៍ជ័យតដាក ឬនាគព័ន្ធ (បារាយណ៍ខាងជើង) ស្ថាបនាឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ អស់រយៈកាលជិតមួយពាន់ឆ្នាំមកហើយ បារាយណ៍នេះមានបណ្តោយ៣៦០០ម៉ែត្រ និង ទទឹង៩៣០ម៉ែត្រ ។ ដោយសារភាពរីងស្ងួត អស់កាលជាយូរឆ្នាំមកហើយ

នៅក្នុងឆ្នាំ២០០៥ អាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមការងារជួសជុលប្រព័ន្ធធារាសាស្ត្របុរាណឡើងវិញ មានទំនប់ និងប្រឡាយបង្ហូរទឹក ដើម្បីអាចរក្សាទឹកក្នុងបារាយណ៍បាន ហើយនៅក្នុងឆ្នាំ២០០៧ អាជ្ញាធរជាតិអប្សរា ក៏បានបង្ហូរទឹកចូលមក ធ្វើឱ្យបារាយណ៍ជ័យតដាក

មានជីវិតសារជាថ្មីម្តងទៀត។ បច្ចុប្បន្នបារាយណ៍នេះបានដើរតួយ៉ាងសំខាន់ ដើម្បីផ្គត់ផ្គង់ទឹកសម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម និងដល់មនុស្ស ក្នុងរាជធានីអង្គរធំ នាគព័ន្ធ និងនៅប្រាសាទព្រះខ័ន៕

អាជ្ញាធរជាតិអប្សរាស្តារកំណកដី សម្អាតស្មៅនៅតាមប្រព័ន្ធរំដោះទឹក នៅមុខបរិវេណប្រាសាទសួរព្រ័ត្រ

ផ្សាយនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

ក្រុមនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និង ហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា បានស្តារកំណកដី សម្អាតស្មៅ និង រុក្ខជាតិដុះក្នុងទឹក នៅតាមប្រព័ន្ធរំដោះទឹកនៅមុខប្រាសាទ សួរព្រ័ត្រ និងព្រះលានជល់ដំរីនៃបរិវេណក្រុងអង្គរធំ។

ការសម្អាតនេះ ធ្វើឡើងដើម្បីសម្រួលដល់លំហូរចរន្តទឹក ឱ្យកាន់តែលឿនជាងមុន បញ្ចៀសការដក់ទឹកនៅតាម បរិវេណមុខប្រាសាទសួរព្រ័ត្រ ឬប្រាសាទនាង១២ និង តំបន់ជុំវិញ៕

អាជ្ញាធរជាតិអប្សរា បន្តស្តារកំណកដី សម្អាតប្រព័ន្ធលូរំដោះទឹក ក្នុងបរិវេណប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២

ក្រុមនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ពន្ធនៃអាជ្ញាធរជាតិអប្សរា បានស្តារកំណកដី សម្អាតស្មៅ និងរុក្ខជាតិដុះតូចៗដែលដុះនៅតាមប្រព័ន្ធប្រលាយរំដោះទឹកនៅក្នុងបរិវេណប្រាសាទអង្គរវត្ត ដើម្បីសម្រួលដល់លំហូរទឹកភ្លៀង ហូរបានលឿន និងរំដោះទឹកការពារកុំឱ្យដក់នៅតាមបរិវេណប្រាសាទអង្គរវត្ត ដែលបណ្តាលឱ្យជ្រាយដី ជៀសវាងការដួលរលំដើមឈើ និងបញ្ចៀសហានិភ័យផ្សេងៗ៕



ខ្លោងទ្វារខាងកើតនៃអគារព្រះឥសូរក្នុងប្រាសាទព្រះខ័ន គ្រោងនឹងបើកឱ្យភ្ញៀវទេសចរឆ្លងកាត់ឡើងវិញក្រោយបញ្ចប់ការងារជួសជុល

ផ្សាយនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២

ខ្លោងទ្វារអគារព្រះឥសូរដែលស្ថិតនៅជ្រុងឥសាននៃប្រាង្គកណ្តាលរបស់ប្រាសាទព្រះខ័ន គ្រោងនឹងបើកឱ្យភ្ញៀវទេសចរដើរឆ្លងកាត់ឡើងវិញ បន្ទាប់ពីបានផ្អាកដំណើរការមួយរយៈពេល ដើម្បីធ្វើការងារជួសជុល។

លោកជា សារិទ្ធិ បុរាណវិទូ និងជាប្រធានការដ្ឋានជួសជុលខ្លោងទ្វារអគារព្រះឥសូរ នៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា ក្រុមអ្នកជំនាញបានចាប់ផ្តើមដំណើរការជួសជុលខ្លោងទ្វារនេះ តាំងពីអំឡុងដើមខែវិច្ឆិកា ឆ្នាំ២០២១ មកដល់បច្ចុប្បន្ននេះក្រុមការងារបានបញ្ចប់ការជួសជុល។ លោកបន្តថា ការជួសជុលចាប់ផ្តើមពីការសិក្សាស្រាវជ្រាវឯកសារពាក់ព័ន្ធកិច្ចការអភិរក្សកន្លងមក ធ្វើសម្រង់ប្លង់ចុះបញ្ជីថ្ម ស្វែងរកថ្ម រៀបផ្គុំថ្មសាកល្បង វាស់ស្ទង់ សិក្សាវាយតម្លៃស្ថានភាពសំណង់ដែលរងការខូចខាត ធ្វើវិភាគ ហើយកំណត់នូវវិធីសាស្ត្រដើម្បីជួសជុល។ បន្ទាប់មក រៀបចំរបាយការណ៍ ដាក់ឆ្លងគណកម្មាធិការសម្របសម្រួលបច្ចេកទេសអង្គរ (ICC-Angkor)។ ក្រោយទទួលបានអនុសាសន៍ពីអ្នកជំនាញការ Ad hoc នៃអង្គការយូណេស្កូ ក្រុមការងារចាប់ផ្តើមរុះរើត្រង់ផ្នែករងការខូចខាត ហើយប្រឈមនឹងដួលរលំ។ ធ្វើកំណាយសិក្សាពិនិត្យស្ថានភាពគ្រឹះ ហើយជួសជុលពង្រឹងគ្រឹះនិងជើងតាង។

លោកបន្តទៀតថា អគារនេះមានសសរចំនួន២៤ ហើយស្រុតស្ទើរតែទាំងអស់ ចំណែករចនាសម្ព័ន្ធសំណង់ទ្រេតខ្លាំង ប្រឈមនឹងដួលរលំ។ កិច្ចការបន្ត គឺជួសជុលពង្រឹងគ្រឹះនិងជើងតាង (ដូរថ្មដែលពុកផុយ ជំនួសដោយថ្មបាយក្រៀមថ្មី ចំពោះថ្មដែលមានគុណភាពល្អរក្សាទុកដដែល) បន្ទាប់មករៀបផ្គុំសសរ ធ្នឹម និងដំបូល។

លោកបន្តទៀតថា ក្រោយពីការងារជួសជុលរួច អាជ្ញាធរជាតិអប្សរារំពឹងថា នឹងបើកវង់ទស្សនាឱ្យបានទូលំទូលាយជាងមុន ព្រោះពេលកន្លងមកអគារនេះត្រូវបិទមិនឱ្យភ្ញៀវឆ្លងកាត់។លោកបានបញ្ជាក់បន្ថែមថា សំណង់ខ្លោងទ្វារអគារព្រះឥសូរមានលក្ខណៈខុសប្លែកពីសំណង់ផ្សេងៗនៅក្នុងប្រាសាទព្រះខ័ន មានច្រកចេញបើកចំហរគ្រប់ទិសគ្មានជញ្ជាំង ហើយមានដំបូលគ្របពីលើសសរចំនួន២៤ដើម។

សូមជម្រាបដែរថា រចនាសម្ព័ន្ធខ្លោងទ្វារខាងកើតនៃអគារព្រះឥសូរធ្លាប់បានរៀបចំទល់ទ្រ ដោយការទល់ទ្រនល់និងធ្នឹមអំពីបេតុងនៅឆ្នាំ១៩២៨ ដោយក្រុមអភិរក្សអង្គរនៃសាលាបារាំងចុងបូព៌ា និងនៅឆ្នាំ២០០២ អាជ្ញាធរជាតិអប្សរាបានសិក្សា និងធ្វើការទល់ទ្រ នូវរចនាសម្ព័ន្ធដែលប្រឈមនិងដួលរលំ៕

ទិដ្ឋភាពថ្ងៃរៀបលិចនៅស្រះស្រង់ ទីកន្លែងមួយផ្សេងទៀតក្នុងរមណីយដ្ឋានអង្គរ ដែលទេសចរអាចថតយករូបភាពថ្ងៃលិចដ៏ស្រស់ស្អាត

ផ្សាយនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២



ក្រុមការងារសម្អាតបរិស្ថានយកចិត្តទុកដាក់សម្អាតបរិស្ថានក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២

ក្រុមការងារសម្អាតបរិស្ថានក្នុងរមណីយដ្ឋានអង្គរ បានយកចិត្តទុកដាក់លើការងារសម្អាតបរិស្ថានទាំងនៅតាមប្រាសាទ លើដី និងក្នុងទឹកជាប្រចាំ ដើម្បីលើកសម្រស់សោភ័ណភាព និងតម្លៃរមណីយដ្ឋាន។ សកម្មភាពនេះជាការរួមចំណែកមួយដ៏សំខាន់ ក្នុងការលើកតម្លៃអង្គរដែលមានប្រាសាទ ព្រៃឈើ ស្មៅ កសិន្ធុទឹក ផ្លូវផង រក្សាបាននូវសោភ័ណភាព និងអនាម័យស្អាតជានិច្ច គយគន់មិនជិនណាយ ហើយរមណីយដ្ឋានអង្គរ ក្លាយជាគោលដៅទេសចរណ៍ដ៏សំខាន់ និងទាក់ទាញភ្ញៀវទេសចរ។

សូមភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលរួមថែរក្សាបរិស្ថាននៅក្នុងតំបន់រមណីយដ្ឋានអង្គរទាំងអស់ ដាក់សំរាមក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ ដើម្បីឱ្យក្រុមការងារងាយស្រួលក្នុងការគ្រប់គ្រង និងប្រមូលយកទៅកន្លែងស្តុកសំរាមតាមបច្ចេកទេស៕

ផ្ទៃមុខអប្សរាដែលរបេះត្រូវបានយកបិទភ្ជាប់ឡើងវិញ

ផ្សាយនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២

នារសៀលថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរា និងស្ថាប័នឥណ្ឌា ដែលសហប្រតិបត្តិការជួសជុលប្រាសាទតាព្រហ្ម បានយកផ្ទៃមុខអប្សរា ដែលរបេះជ្រុះធ្លាក់ពីរូបរាង មកបិទភ្ជាប់ឡើងវិញ ក្រោយស្ថានភាពថ្មមានសភាពស្ងួត។ សូមបញ្ជាក់ថា ផ្ទៃមុខអប្សរា នៅចំណុចដើមគ្រាង បានរបេះធ្លាក់នៅព្រឹកថ្ងៃទី៣០ ខែកញ្ញា ដោយមិនមានការបែកបាក់អ្វីទេ ដោយសារធ្លាក់ទើរនឹងឫសឈើ និងត្រូវបានក្រុមភ្នាក់ងារទេសចរណ៍របស់អាជ្ញាធរជាតិអប្សរា រាយការណ៍ទៅក្រុមជំនាញ និងបាននាំទៅរក្សាទុក៕

សូមថ្វាយមហាព្រះរាជកុសល ខួបគម្រប់ ១០ឆ្នាំ នៃការយាងសោយព្រះទិវង្គតរបស់ព្រះករុណា សម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ (១៥ តុលា ឆ្នាំ២០១២ - ១៥ តុលា ឆ្នាំ២០២២) នាថ្ងៃសៅរ៍ ៥រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២។

ផ្សាយនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២



អាជ្ញាធរជាតិអប្សរាចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ ថ្វាយព្រះរាជកុសលព្រះបរមរតនកោដ្ឋគម្រប់ខួបសោយទិវង្គត១០ព្រះវស្សា

ផ្សាយនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២

នៅព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២ **ឯកឧត្តម ជុំ សុភមករា** អគ្គនាយករង តំណាង **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរដោយប្រធាននាយកដ្ឋាន និងមន្ត្រីបុគ្គលិក បានចូលរួមគោរពព្រះវិញ្ញាណក្ខន្ធថ្វាយព្រះរាជកុសលព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ គម្រប់ខួបសោយទិវង្គត ១០ព្រះវស្សា នៅព្រះរាជដំណាក់ ខេត្តសៀមរាប។

ក្នុងឱកាសដ៏ក្រៀមក្រំនេះ តាំងនាមឱ្យថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា សូមសម្តែងព្រះរាជមរណទុក្ខយ៉ាងក្រៀមក្រំបំផុត ចំពោះការយាងចូលទិវង្គតរបស់សម្តេចតា សម្តេចតាទួត ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ និងបង្រួបបង្រួមជាតិខ្មែរ ព្រះបរមរតនកោដ្ឋ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៃប្រជានុរាស្ត្រ ទូទាំងព្រះនគរ មហាទុក្ខសោកនៃប្រជាជាតិកម្ពុជា ១៥ តុលា ២០១២ ថ្ងៃដែលប្រជាជាតិកម្ពុជា មិនអាចបំភ្លេចបាន។

អាជ្ញាធរជាតិអប្សរា ចងចាំជានិច្ចនូវរាល់ស្នាព្រះហស្ត ព្រះរាជបូជនីយកិច្ច និងគុណូបការៈដ៏ធំធេងរបស់ព្រះអង្គ ដែលបានលះបង់ព្រះកាយពល ព្រះបញ្ញាញាណ ដើម្បីបូរណភាពទឹកដីកម្ពុជា ក៏ដូចជាព្រះរាជកិច្ចដាក់បញ្ចូលតំបន់អង្គរជាបេតិកភណ្ឌពិភពលោករហូតដល់សព្វថ្ងៃនេះ៕

សកម្មភាពក្រុមការងារសម្អាតស្មៅ និងកូនរុក្ខជាតិតូចៗនៅប្រាសាទព្រះខ័ន

ផ្សាយនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២



រីករាយចុងសប្តាហ៍ ទិដ្ឋភាពដ៏ស្រស់ស្អាតនៅខ្លោងទ្វារដីឆ្នាំង(ខាងជើង)នៃក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២



តៀវទេសចរបន្ថាញអារម្មណ៍សប្បាយរីករាយក្រោយពេលបានឆ្លងកាត់ស្ពានថ្មី ចូលទស្សនាប្រាសាទនាគព័ន្ធ

ផ្សាយនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

ខឿនកំពង់ទឹកដែលស្ថិតនៅខាងកើតប្រាសាទព្រះខ័ន គឺជារចនាសម្ព័ន្ធមួយក្នុងចំណោមរចនាសម្ព័ន្ធផ្សេងៗ នៃប្រាសាទនេះ កសាងឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ចន្លោះចុងសតវត្សទី១២ ដល់សតវត្សទី១៣ ជាព្រះពន្លាជ័យ ឬកន្លែងសម្រាប់ព្រះរាជា ធ្វើដំណើរតាមទូកទៅកាន់ក្រុមប្រាសាទនាគព័ន្ធ នៅលើកូនកោះកណ្តាលបារាយជ័យតដាក។ លក្ខណៈសំណង់បែបនេះឃើញមាននៅស្រះស្រង់ នៅលើខ្នងទំនប់ខាងលិចនៃបារាយណ៍យសោធដាកសព្វថ្ងៃហៅបារាយខាងកើត និងនៅខាងកើតប្រាសាទបន្ទាយឆ្មា។ ដោយពិនិត្យឃើញរចនាសម្ព័ន្ធរបស់កំពង់ទឹករងសភាពខូចខាតទ្រុឌទ្រោមខ្លាំង ទើបឆ្នាំ២០២២នេះ អាជ្ញាធរជាតិអប្សរា ចាប់ផ្តើមសិក្សាអំពីគម្រោងជួសជុលពង្រឹងរចនាសម្ព័ន្ធកំពង់ទឹក ដែលនៅសល់ឡើងវិញ ដើម្បីថែរក្សានូវរូបរាងសំណង់ឲ្យបានគង់វង់។

លោកជា សារិទ្ធិ បុរាណវិទូ និងជាប្រធានគម្រោងជួសជុលកំពង់ទឹកនៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថាគម្រោងនេះចែកជាពីរដំណាក់កាល ហើយដំណាក់កាលទី១ ចាប់ផ្តើមនៅខែមករា ឆ្នាំ២០២២ រហូតដល់បច្ចុប្បន្នបានបញ្ចប់ការងារជួសជុលរួចរាល់។ លោកបន្តថាមូលហេតុដែលនាំឱ្យមានការជួសជុល ដោយសារខឿនកំពង់ទឹកមានការខូចខាត និងបាត់ថ្មអស់ច្រើន ដោយកត្តាអាយុកាលនៃសំណង់ ឫសឈើចាក់បំប៉ើងថ្ម ទឹកភ្លៀងហូរច្រោះដី នាំឱ្យខឿនជុំវិញស្រុតចុះ និងផ្នែកខ្លះរអិលធ្លាក់ចូលក្នុងទឹកជាដើម។ មុនពេលដំណើរការជួសជុលក្រុមការងារបានធ្វើកំណាយស្រាវជ្រាវ ហើយរកឃើញថ្មមួយចំនួនត្រឡប់មកវិញ និងបានយកថ្មទាំងនោះរៀបចំទៅក្នុងទីតាំងដើមវិញ។

លោកបានបន្តថា ក្រោយពេលជួសជុលកំពង់ទឹកនេះ នឹងមានភាពល្អប្រសើរ ហើយរឹងមាំ ដែលរក្សាបាននូវតម្លៃដើមនៃសំណង់បុរាណ ធ្វើឱ្យភ្ញៀវទេសចរអាចស្គាល់ថាព្រះពន្លាជ័យ (កំពង់ទឹក)។ ជាពិសេសផ្តល់ភាពងាយស្រួលដល់ភ្ញៀវទេសចរ អាចធ្វើដំណើរឆ្លងកាត់ទៅទស្សនាប្រាសាទព្រះខ័នផ្នែកខាងកើត និងអាចទស្សនាទិដ្ឋភាពប្រាសាទនាគព័ន្ធ លើកោះកណ្តាលបារាយជ័យតដាកសព្វថ្ងៃហៅថាឬបារាយខាងជើង។

សូមជម្រាបថា សំណង់កំពង់ទឹកខាងកើតប្រាសាទព្រះខ័នសាងសង់នៅលើខ្នងទំនប់ខាងលិច នៃបារាយខាងជើង រចនាសម្ពន្ធនៃកំពង់ទឹកនេះ ផ្នែកខាងកើតរាងកាកបាទមានជណ្តើរបីទិស ផ្នែកកណ្តាលមានខឿនធំបណ្តោយពីខាងលិចខាងកើតប្រវែង២០ម៉ែត្រ ទទឹងខាងជើងខាងត្បូងប្រវែង២០ម៉ែត្រ។ ទីតាំងនេះធ្លាប់មានការធ្វើកំណាយសម្អាតក្នុងសម័យបារាំងនាឆ្នាំ១៩២៨ បន្ទាប់មកក្នុងឆ្នាំ២០០៦ អង្គការមូលនិធិប្រាសាទពិភពលោកបានសិក្សាស្រាវជ្រាវធ្វើកំណាយសម្អាតជុំវិញខឿនដើម្បីសិក្សាប្លង់ស្ថាបត្យកម្មនៃកំពង់ទឹក និងឆ្នាំ២០២២នេះ អាជ្ញាធរជាតិអប្សរាបានធ្វើការងារជួសជុលពង្រឹងឡើងវិញ៕

ក្រុមការងារទប់ស្កាត់ហានិភ័យ នៃអាជ្ញាធរជាតិអប្សរា កំពុងជួយសង្គ្រោះបន្ទាន់ផ្នែកខ្លះនៃថែវនៅរួតទី១របស់ប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២

ដោយសារកត្តាធម្មជាតិ ភ្លៀង ខ្យល់ កម្ដៅថ្ងៃ រុក្ខជាតិ និង អាយុកាល ធ្វើឱ្យផ្នែកខ្លះនៃរចនាសម្ពន្ធប្រាសាទរងការគំរាមកំហែងខូចខាតដោយអន្លើ។ ដើម្បីទប់ស្កាត់នូវហានិភ័យទាំងនោះ និងទប់ស្កាត់ការខូចខាតជាបន្តទៀត ទើបក្រុមការងារទប់ស្កាត់ហានិភ័យនៃអាជ្ញាធរជាតិអប្សរា ធ្វើការងារទល់ទ្រុបណ្ដោះអាសន្នជាបន្ទាន់ ដើម្បីអភិរក្សសំណង់បុរាណទាំងនោះបានទាន់ពេលវេលា។

ក្នុងកិច្ចការនេះ ក្រុមការងារទប់ស្កាត់ហានិភ័យរបស់នាយកដ្ឋានគ្រប់គ្រងទឹកព្រៃឈើ និងហេដ្ឋារចនាសម្ពន្ធនៃអាជ្ញាធរជាតិអប្សរា បានសិក្សាផែនទីហានិភ័យ ដើម្បីកំណត់ឱ្យដឹងថា ទីតាំងដែលចាំបាច់អន្តរាគមន៍ភ្លាមៗ ទប់ស្កាត់រាល់បញ្ហាណាមួយដែលអាចកើតមានឡើងដោយយថាហេតុ។ ក្នុងការងារទល់ទ្រជាបន្ទាន់មួយនៅថែវនៅរួតទី១ ផ្នែកខាងត្បូងនៃប្រាសាទអង្គរវត្ត ប្រវែង ១០០ម៉ែត្រនិងទទឹង៥ម៉ែត្រ កម្ពស់៧ម៉ែត្រ ជាទីតាំងដំបូងនៅក្នុងផែនទីហានិភ័យ ដើម្បីធានាដល់រចនាសម្ពន្ធមួយចំនួនកុំឱ្យឈានដល់ការខូចខាត។ បន្ទាប់មកក្រុមការងារនឹងបន្តបំពេញការងារជាបន្តបន្ទាប់ទៅតាមទិសដៅដែលបានកំណត់នៅក្នុងផែនទីហានិភ័យ។

លោក សុខ សូសិលា អនុប្រធាននាយកដ្ឋានគ្រប់គ្រងទឹកព្រៃឈើនិងហេដ្ឋារចនាសម្ពន្ធ នៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា ក្នុងរយៈពេល២-៣សប្តាហ៍ចុងក្រោយនេះភ្លៀងបានធ្លាក់ខ្លាំង ហើយទឹកហូរបាចសាចចូលសព្វផ្នែកទាំងអស់នៃថែវ នៅរួតទី១ផ្នែកខាងត្បូងនៃប្រាសាទអង្គរវត្ត បណ្ដាលឱ្យប៉ះពាល់គ្រឹះ បង្កឱ្យផ្នែកខ្លះនៃថែវរំកិល ជញ្ជាំងហើប និងធ្នឹមចាប់ផ្ដើមញែកចេញពីគ្នា។

ដោយសារតែបញ្ហានេះ ក្រុមការងារទប់ស្កាត់ហានីភ័យក៏បានយកឈើ និងរន្ទាដែកមួយចំនួន ធ្វើការទល់ទ្រជាបន្ទាន់ ដើម្បីជួយសង្គ្រោះជាបណ្ដោះអាសន្ននៅមុនពេលដែលឈានទៅដល់ការសុំអនុសាសន៍ ពីគណៈកម្មាធិការ អាយ ស៊ី ស៊ី អង្គរ ថាតើត្រូវធ្វើយ៉ាងណាបន្តទៀតនោះ។

ការទល់ទ្រមួយផ្នែកនៃថែវ នៅរួតទី១ភាគខាងត្បូង របស់ប្រាសាទអង្គរវត្តប្រវែង១០០ម៉ែត្រ និងទទឹង៥ម៉ែត្រនេះ គឺជាគម្រោងបន្ទាន់ដំបូងគេ ដែលក្រុមការងារបានអនុវត្តន៍។ នៅពេលខាងមុខ ក្រុមការងារទប់ស្កាត់ហានិភ័យ មានគម្រោងនឹងធ្វើការងារពង្រឹងធ្នឹម សសរ និងដំបូលនៃថែវរបស់ប្រាសាទអង្គរវត្ត ចំនួន៣៨ទីតាំងបន្ថែមទៀត៕

សេចក្ដីជូនដំណឹង ស្ដីពីការផ្អាកការចូលគោរពបូជា នៅទីសក្ការៈព្រះអង្គចេក និងព្រះអង្គចម នៅខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

លេខ ៖ ២៧ ស.ជ.ណ.

សេចក្ដីជូនដំណឹង

ស្ដីពី

ការផ្អាកការចូលគោរពបូជានៅទីសក្ការៈព្រះអង្គចេក និងព្រះអង្គចម នៅខេត្តសៀមរាប

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានកិត្តិយសសូមជម្រាបជូនដំណឹងចំពោះភ្ញៀវទេសចរជាតិ អន្តរជាតិ និងសាធារណៈជនទូទៅមេត្តាជ្រាបថា ទីសក្ការៈបូជាចំពោះព្រះអង្គចេក និងព្រះអង្គចមនៅខេត្តសៀមរាប នឹងត្រូវបិទទ្វារមិនដំណើរការមួយរយៈពេល ចាប់ពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២នេះតទៅ ដើម្បីអនុញ្ញាតឲ្យក្រុមការងារជំនាញរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ធ្វើការជួសជុលបល្ល័ង្កបដិមាព្រះអង្គចេក និងព្រះអង្គចម។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នឹងជូនដំណឹងនៃការបើកឲ្យដំណើរការឡើងវិញនាពេលការជួសជុលត្រូវបានបញ្ចប់។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមភ្ញៀវទេសចរជាតិ អន្តរជាតិ និងសាធារណៈជនទូទៅមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ៧ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២

ទូរស័ព្ទ / ទូរសារ: 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

គម្រោងជួសជុលខ្លោងទ្វារខាងកើតប្រាសាទតាព្រហ្មសម្រេចបាន៣៥ភាគរយហើយ

ផ្សាយនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២

គិតត្រឹមពាក់កណ្តាលខែ តុលានេះ គម្រោងជួសជុលខ្លោងទ្វារខាងកើតប្រាសាទតាព្រហ្មសម្រេចបាន៣៥ភាគរយហើយ ដោយបច្ចុប្បន្នក្រុមការងារកំពុងជួសជុលថ្ម និងដំឡើងកាំថ្មនៅផ្នែកខាងជើង ក្រោយផ្នែកខាងត្បូង និងដំបូល ជួសជុលបានប្រមាណ៥០ភាគរយ។

លោកស្រី នេត ស៊ីម៉ន មន្ត្រីបុរាណវិទ្យា នៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យាបង្ការ លើកឡើងថា ការងារជួសជុលខ្លោងទ្វារខាងកើត ប្រាសាទតាព្រហ្ម មានការវិវត្តន៍ច្រើន ទោះមានការរាំងស្ទះខ្លះៗដោយសារភ្លៀងក្តី។ បច្ចុប្បន្នការងារសម្រេចបាន៣៥ភាគរយហើយ ដែលគ្រោងនឹងបញ្ចប់នៅឆ្នាំ២០២៣។

រំឭកទៅពេលមុន ស្ថានភាពខ្លោងទ្វារខាងកើតនេះមានសភាពទ្រុឌទ្រោមខ្លាំង ដែលតួខ្លោងទ្វារនេះបានទ្រេត និងមានហានិភ័យខ្ពស់ដល់ភ្ញៀវទេសចរ។ ដោយមើលឃើញដូច្នេះហើយ ទើបអាជ្ញាធរជាតិអប្សរា ដោយមានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នឥណ្ឌា និងមានការយល់ព្រមពីគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ បានចាប់ផ្តើមជួសជុលខ្លោងទ្វារនេះវិញនៅដើមឆ្នាំ២០២២។

ចំពោះដំណើរការជួសជុល លោកស្រី នេត ស៊ីម៉ន ពន្យល់ថា គឺត្រូវរើថ្មទាំងអស់ ដើម្បីជួសជុលពង្រឹងគ្រឹះ និងរៀបថ្មឡើងវិញ។ ស្ថានភាពថ្មមួយចំនួនតូចមានភាពពុកផុយ និងខ្លះបានបាត់ ដែលតម្រូវឱ្យប្រើប្រាស់ថ្មថ្មី តែក្នុងកម្រិតតិចតួចប៉ុណ្ណោះ៕

លិខិតថ្កោលទោស របស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំនៃអាជ្ញាធរជាតិអប្សរា សូមថ្កោលទោសដាច់អហង្ការ និងប្រឆាំងដាច់ខាត ចំពោះសេចក្ដីថ្លែងការណ៍របស់ ទណ្ឌិត សម រង្ស៊ី មេក្រុមឧទ្ទាមក្បត់ជាតិ៣ជំនាន់

ផ្សាយនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ៖.....✓.........

លិខិតថ្កោលទោស

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំនៃអាជ្ញាធរជាតិអប្សរា សូមថ្កោលទោសដាច់អហង្ការ និងប្រឆាំងដាច់ខាតចំពោះសេចក្ដីថ្លែងការណ៍របស់ ទណ្ឌិត សម រង្ស៊ី មេក្រុមឧទ្ទាម ជាពូជក្បត់ជាតិ៣ជំនាន់ តាមរយៈវីដេអូឃ្លីបនាពេលថ្មីៗនេះ ដែលបានញុះញង់ឱ្យកងកម្លាំងប្រដាប់អាវុធធ្វើការបះបោរ និងបានប្រមាថដោយអសីលធម៌ចំពោះ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ដែលជាស្ថាបនិកសន្តិភាព និងជាទីគោរពស្រឡាញ់របស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

ការចិញ្ចឹមចិត្តផ្ដួលរំលំរាជរដ្ឋាភិបាលស្របច្បាប់នៅឆ្នាំ២០២៣ បានស្ដែងឱ្យឃើញនូវចេតនាបំផុសបំផុលចង់ធ្វើបដិវត្តន៍ពណ៌ បង្កចលាចលក្នុងសង្គម ដើម្បីបំពេញមហិច្ឆតាបំផ្លិចបំផ្លាញសន្តិភាព ដែលរកបានដោយលំបាក ព្រមទាំងនាំប្រទេសកម្ពុជាឆ្ពោះទៅរកសង្គ្រាមសាជាថ្មី។

យើងខ្ញុំទាំងអស់គ្នា សូមប្ដេជ្ញាការពារដាច់ខាតនូវរដ្ឋធម្មនុញ្ញ ការពាររាជរដ្ឋាភិបាលស្របច្បាប់ដែលកើតចេញពីការបោះឆ្នោត ការពារ**សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ពិសេសការពារឱ្យបាននូវសន្តិភាពទោះក្នុងតម្លៃណាក៏ដោយ ព្រមទាំងគាំទ្រ **ឯកឧត្ដម បណ្ឌិត ហ៊ុន ម៉ាណែត** ជាបេក្ខភាពនាយករដ្ឋមន្ត្រីបន្តវេននាពេលអនាគត។

ថ្ងៃសុក្រ ៨ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សៀមរាប ថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២២
អគ្គនាយក

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរជាតិសម្រាប់ការពារតំបន់ និងរៀបចំដែនដីអង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

អាជ្ញាធរជាតិអប្សរាជួបពិភាក្សាជាមួយតំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ពាក់ព័ន្ធការសិក្សាលទ្ធភាពគម្រោងជួសជុលខឿនរួតបាកាណនៃប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២

នៅរសៀលថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា **ឯកឧត្តម បណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមវត្តមានចូលរួមដោយឯកឧត្តម អគ្គនាយករង និងប្រធាននាយកដ្ឋានជំនាញពាក់ព័ន្ធបានជួបពិភាក្សាការងារជាមួយទីភ្នាក់ងារ សហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ដឹកនាំដោយ លោក TAHK Kyungbaek ដែលបានអញ្ជើញមកបំពេញបេសកកម្មនៅរមណីយដ្ឋានអង្គរ ខេត្តសៀមរាប ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២២ ដើម្បីសិក្សាលទ្ធភាពគម្រោងជួសជុលខឿនរួតបាកាណ នៃប្រាសាទអង្គរវត្តនាពេលអនាគត។

ក្នុងកិច្ចជំនួបពិភាក្សានេះ ក៏មានការចូលរួមពីអ្នកជំនាញរបស់ស្ថាប័នមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ (KCHF) ដែលបាននឹងកំពុងអនុវត្តគម្រោងជួលជុលប្រាសាទជម និងព្រះលានជល់ដំរី ក្នុងបរិវេណរាជធានីអង្គរធំផងដែរ៕

ភ្ញៀវទេសចរ ចូលមកទស្សនារមណីយដ្ឋានអង្គរ ចាប់ផ្ដើមមានកំណើនឡើងវិញជាបន្តបន្ទាប់

ផ្សាយនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២

សកម្មភាពភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ជាបន្តបន្ទាប់ បានចាប់ផ្ដើមចូលមកទស្សនាតំបន់រមណីយដ្ឋានអង្គរ។ នេះជាសញ្ញាមួយបញ្ជាក់ថា កំណើននៃភ្ញៀវទេសចរ នឹងវិលត្រឡប់មករកស្ថានភាពល្អប្រសើឡើងវិញ បន្ទាប់ពីស្ងប់ស្ងាត់ភ្ញៀវទេសចរ រយៈពេលប្រមាណជាង២ឆ្នាំកន្លងមកនេះ ដោយសារការរាតត្បាតជាសកលនៃជំងឺកូវីដ១៩។

ជាក់ស្ដែង នៅពេលព្រឹកព្រលឹមស្រាងៗ ភ្ញៀវទេសចរចម្រុះជាតិសាសន៍ជាច្រើន បានចូលមករង់ចាំទស្សនាទិដ្ឋភាពថ្ងៃរះដ៏ស្រស់ស្អាត នៅបរិវេណប្រាសាទអង្គរវត្ត៕

ដំណឹងជ្រើសរើសបុគ្គលិក

ផ្សាយនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ: ៩៧០៤/សប.៧៨០៧/២២

ថ្ងៃ ពុធ ៩ រោច ខែ អស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
សៀមរាប ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២២

ដំណឹងជ្រើសរើសបុគ្គលិក

អាជ្ញាធរជាតិអប្សរា "អាជ្ញាធរជាតិដើម្បីការពារមណ្ឌលបេតិកភណ្ឌ និងរៀបចំតំបន់អង្គរ" (www.apsaraauthority.gov.kh) សូមជូនដំណឹងដល់សិស្ស និស្សិត និងសាធារណជន ឱ្យបានជ្រាបថា អាជ្ញាធរជាតិអប្សរា នឹងធ្វើការជ្រើសរើសបុគ្គលិកចំនួន០៧រូប ជំនួសបុគ្គលិកដែលបានឈប់ពីការងារ ឱ្យបម្រើការងារនៅនាយកដ្ឋានសណ្ដាប់ធ្នាប់ (បរិញ្ញាបត្រនីតិសាស្ត្រចំនួន ០២រូប បរិញ្ញាបត្រព័ត៌មានវិទ្យាចំនួន ០១រូប និងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំនួន ០៤រូប)។ លក្ខខណ្ឌនៃការជ្រើសរើសមានដូចខាងក្រោម៖

១- កម្រិតសញ្ញាបត្រ

- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រនីតិសាស្ត្រ ព័ត៌មានវិទ្យា និងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ស្របទៅតាមលក្ខខណ្ឌជ្រើសរើសតាមផ្នែកនីមួយៗ

២- លក្ខខណ្ឌនៃការជ្រើសរើស មានដូចតទៅ:

- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី១៨-៣៥ឆ្នាំ
- បើមានបទពិសោធន៍តាមផ្នែកពាក់ព័ន្ធ និងចំណេះដឹងភាសាបរទេសត្រូវបានលើកទឹកចិត្ត
- មានសុខភាពល្អ
- មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី និងសិទ្ធិជាពលរដ្ឋ
- បេក្ខជនដែលមានលំនៅដ្ឋានក្នុងឧទ្យានអង្គរត្រូវបានផ្ដល់អាទិភាព

៣- សំណុំឯកសារដែលត្រូវមាន

- ជីវប្រវត្តិរូបសង្ខេបមានបិទរូបថតទំហំ (៤x៦) ០១ច្បាប់
- អត្តសញ្ញាណប័ណ្ណ និងសៀវភៅស្នាក់នៅ ច្បាប់ថតចម្លង ០១ច្បាប់
- សំបុត្រកំណើត ច្បាប់ថតចម្លង ០១ច្បាប់
- លិខិតបញ្ជាក់កិរិយាមាយាទ ០១ច្បាប់
- លិខិតធានាអះអាងមិនមែនជាមន្ត្រី ០១ច្បាប់

៤- ទីកន្លែងទទួលពាក្យ៖ នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នៃទីស្នាក់ការអាជ្ញាធរជាតិអប្សរា ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២។**

៥- ការសម្ភាសបេក្ខជន៖ បញ្ជីសម្រាំងបេក្ខជនដែលត្រូវឆ្លងកាត់ការប្រលង និងសម្ភាសជ្រើសរើសនឹងត្រូវបិទផ្សាយនៅស្នាក់ការអាជ្ញាធរជាតិអប្សរាខេត្តសៀមរាប ឬជូនដំណឹងតាមរយៈទូរស័ព្ទផ្ទាល់ទៅបេក្ខជន។

៦- ព័ត៌មានចាំបាច់៖ សូមទំនាក់ទំនងមកលេខទូរស័ព្ទ **០១២ ៧៦ ៨៤ ៤៥ /០៩២ ៨៧ ២៥ ៨៨**

អាជ្ញាធរជាតិអប្សរា
ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារមណ្ឌលបេតិកភណ្ឌ និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

1/1

ប្រទះឃើញបំណែកព្រះកេសអសុរាមួយ នៅប៉ែកខាងកើតខ្លោងទ្វារទន្លេអុំ

ផ្សាយនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២

ក្រុមមន្រ្តីនៃអាជ្ញាធរជាតិអប្សរា បានប្រទះឃើញបំណែកព្រះកេសអសុរា ធ្វើពីថ្មបុរាណចំនួនមួយកាលពីរសៀលថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ក្រោយចុះរៀបចំសណ្តាប់ធ្នាប់ទីតាំងអតីតតូបលក់ដូររបស់អាជីវករនៅមុខខ្លោងទ្វារចូលក្រុងអង្គរធំនាប៉ែកខាងកើតនៃស្ពានទន្លេអុំ ឱ្យល្អប្រសើរឡើងវិញ។

ប្រធានក្រុមការងារចុះបញ្ជីវត្ថុសិល្បៈ របស់នាយកដ្ឋានអភិរក្សប្រាសាទនិងបុរាណវិទ្យានៃ អាជ្ញាធរជាតិអប្សរា លោក ឈូក សុម៉ាឡា ឱ្យដឹងថា ទីតាំងដែលរកឃើញបំណែកព្រះកេសអសុរានេះ គឺជាអតីតកន្លែងតូបលក់ដូរវត្ថុអនុស្សាវរីយ៍របស់អាជីវករដែលស្ថិតនៅផ្នែកខាងកើតនៃខ្លោងទ្វារទន្លេអុំ។ ក្រោយពីផ្លាស់ប្តូរតូបលក់ដូរទៅទីតាំងចំណតថ្មី មុខភ្នំបាខែង ក្រុមការងារក៏បានចុះទៅសម្អាតទីតាំងចាស់នោះ ឱ្យមានសណ្តាប់ធ្នាប់ល្អប្រសើរឡើងវិញ ហើយក៏បានប្រទះឃើញបំណែកព្រះកេសអសុរាទាញព្រ័ត្រនេះ។

ព្រះកេសអសុរាតែមួយដែលមានកម្ពស់៦០សង់ទីម៉ែត្រ ទទឹង៦៥សង់ម៉ែត្រ និងកម្រាស់៥៩សង់ទីម៉ែត្រ។ ព្រះកេសអសុរាធ្វើពីថ្មភក់ ដែលគេប្រទះឃើញនេះ គឺស្ថិតក្នុងរចនាបថបាយ័ន នៃរាជព្រះបាទជ័យវរ្ម័នទី៧ ដូចគ្នានឹងអសុរាទាញព្រ័ត្រ នៅតាមខ្លោងទ្វារទាំង៤ផ្សេងទៀតនៃក្រុងអង្គរធំដែរ។ បច្ចុប្បន្ន ព្រះកេសអសុរានេះ ក្រុមការងារបានសហការជាមួយនគរបាលការពារបេតិកភណ្ឌ និងភ្នាក់ងារសណ្តាប់ធ្នាប់ ព្រមទាំងភ្នាក់ងារទេសចរណ៍ យកទៅរក្សាទុកនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ដើម្បីលាងសម្អាត និងជួសជុលតាមបច្ចេកទេសឱ្យបានត្រឹមត្រូវ ហើយក្រុមការងារក៏នឹងសិក្សាដើម្បីស្វែងរកដងខ្លួនដើមនៃចម្លាក់នោះ មុននឹងយកទៅផ្គុំឡើងវិញ។

មន្រ្តីអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា តាមការអះអាងរបស់អ្នកភូមិ កន្លែងដែលគេប្រទះឃើញព្រះកេសអសុរានេះ គឺធ្លាប់ជាការដ្ឋានជួសជុលខ្លោងទ្វារទន្លេអុំ កាលពីសម័យបារាំង។ បច្ចុប្បន្នតាមការពិនិត្យនៅទីតាំងនោះជាក់ស្តែងឃើញថាមាននៅសេសសល់បំណែកដៃ ជើង ដងខ្លួននាគ ព្រមទាំងចម្លាក់ទេវតា និងអសុរាទាញព្រ័ត្រជាច្រើនបំណែកទៀតដែលនៅរប៉ាត់រប៉ាយពេញក្នុងបរិវេណនោះ។

សិស្សានុសិស្សចំនួន១៨២នាក់ នៃសាលាបឋមសិក្សាក្របីរៀល បានមកទស្សនកិច្ចសិក្សានៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២

នៅព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២នេះ សិស្សានុសិស្សចំនួន១៨២នាក់ ក្នុងនោះមានសិស្សថ្នាក់ទី៥ ចំនួន២ថ្នាក់ និងសិស្សថ្នាក់ទី៦ ចំនួន២ថ្នាក់ នៃសាលាបឋមសិក្សាក្របីរៀល ស្ថិតក្នុងសង្កាត់ក្របីរៀល ក្រុងសៀមរាប បានមកទស្សនកិច្ចសិក្សា អំពីកិច្ចការងារអភិរក្សប្រាសាទអង្គរវត្ត។

នេះជាលើកទី១ហើយដែលសិស្សានុសិស្សមកពីសាលាបឋមសិក្សាក្របីរៀល បានចូលមកទស្សនកិច្ចសិក្សានៅតំបន់រមណីយដ្ឋានអង្គរ បន្ទាប់ពីអាជ្ញាធរជាតិអប្សរាសហការណ៍ជាមួយអាជ្ញាធរក្នុងតំបន់ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី អប់រំបេតិកភណ្ឌ កាលពីខែឧសភា ឆ្នាំ២០២២នេះ។

សូមជម្រាបផងដែរថា ដើម្បីបណ្តុះគំនិតយុវជនជំនាន់ក្រោយឱ្យបានយល់ដឹងអំពី ការថែរក្សាបេតិកភណ្ឌ ចាប់តាំងពីឆ្នាំ២០០៧មក ក៏មានវគ្គបណ្តុះបណ្តាលមួយដល់សិស្សានុសិស្សរស់នៅតំបន់បេតិកភណ្ឌ មានក្នុងខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ សៀមរាប ព្រះវិហារ និងខេត្តកំពង់ធំ៕

ផ្ទាំងទស្សនីយភាពដ៏ស្រស់ស្អាត នៃប្រាសាទព្រះខ័ននារដូវបៃតងនេះ ដែលភ្ញៀវទេសចរទាំងអស់អាចទៅទស្សនា រឺថតរូបទុកជាអនុស្សាវរីយ៍ ជាមួយក្បាច់ចម្លាក់ល្អឯក និងស្លាបត្បូងកម្ពស់សំណង់ដ៏អស្ចារ្យ

ផ្សាយនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២២

ប្រាសាទបន្ទាយស្រី សំណាក់ថ្មឆ្លាក់ពណ៌ផ្កាឈូកដ៏វិចិត្រ ដែលទេសចរ កម្រមើលរំលងការទស្សនាក្នុងបុរាណដ្ឋានមួយនេះ

ផ្សាយនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២២



ពលរដ្ឋខ្មែរ រស់នៅប្រទេសកាណាដា បរិច្ចាគថវិកាជួយជួសជុលចម្លាក់ទេវតាទាញព្រ័ត្រតួទី៨ នៅខ្លោងទ្វារតាកាវ

ផ្សាយនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២

ពលរដ្ឋខ្មែរមួយគ្រួសារ ដែលកំពុងរស់នៅឯប្រទេសកាណាដា បានស្ម័គ្រចិត្តរួមគ្នាបរិច្ចាគថវិកាមួយចំនួនដើម្បីជួយដល់ដំណើរការជួសជុល រូបចម្លាក់ថ្មទេវតាទាញព្រ័ត្រចំនួនមួយ នៅខ្លោងទ្វារតាកាវនៃក្រុងអង្គរធំ ជាមួយអាជ្ញាធរជាតិអប្សរា ដោយសារតែទឹកចិត្តស្រឡាញ់ មានបំណងចង់ចូលរួមអភិរក្សប្រាង្គប្រាសាទបុរាណ និងជាសម្បត្តិបេតិកភណ្ឌ ដែលជាស្នាដៃដ៏មានតម្លៃរបស់បុព្វបុរសខ្មែរឱ្យស្ថិតនៅគង់វង្សជាបន្តទៀតសម្រាប់កូនខ្មែរជំនាន់ក្រោយ។

ស្ថាបត្យករ និងជាក្រុមការងារបច្ចេកទេសជួសជុលខ្លោងទ្វារតាកាវ កញ្ញា ម៉េង សុវណ្ណលីលីន បានសម្តែងការត្រេកអរ និងថ្លែងអំណរគុណ ចំពោះពលរដ្ឋខ្មែរ ដែលកំពុងរស់នៅប្រទេសកាណាដា បានជួយឧបត្ថម្ភចំពោះដំណើរការជួសជុលអភិរក្សនៅខ្លោងទ្វារតាកាវនេះ។ បច្ចុប្បន្ន ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា កំពុងបន្តជួសជុលរូបចម្លាក់ទេវតាទាញព្រ័ត្រតួទី៨តាមរយៈជំនួយថវិកាពីសប្បុរសជនខ្មែរ នៅប្រទេសកាណាដានេះ។ ប៉ុន្តែការងារជួសជុលរូបទេវតាទាញព្រ័ត្រនេះ មិនអាចធ្វើបន្តត្រឹមតែតួទី៨ប៉ុណ្ណោះទេ គឺចាំបាច់ទាមទារឱ្យមានការជួសជុលតួទី៩ ស្របពេលជាមួយគ្នា ពីព្រោះតែរចនាសម្ពន្ធខ្លួននាគទី៨ និងទី៩ មានទំនាក់ទំនងនិងគ្នា។

គម្រោងជួសជុលខ្លោងទ្វារតាកាវមានពីរផ្នែក គឺដំណាក់កាលទី១ ក្រុមការងារបានជួសជុលពង្រឹងតួខ្លោងទ្វារ និងដំណាក់កាលទី២ គឺជួសជុលចម្លាក់ទេវតានិងចម្លាក់អសុរាទាញព្រ័ត្រនៅអមសងខាងស្ពានហាលបានចំនួន៧តួរួចហើយ។

សូមជម្រាបថា ស្ពានហាលខ្លោងទ្វារតាកាវ របស់ក្រុងអង្គរធំ មានអាយុកាលច្រើនរយឆ្នាំមកហើយ មកដល់សព្វថ្ងៃទទួលរងការគំរាមកំហែងពីអាកាសធាតុ សង្គ្រាម កង្វះការថែទាំ និងការដុះដាលនៃដើមឈើធំៗ បណ្តាលឱ្យរូបចម្លាក់បង្កាន់ដៃយក្ស និងទេវតាជាច្រើនបានដួលរលំ។ ដោយសារភាពទ្រុឌទ្រោមខ្លាំងនេះ បច្ចុប្បន្នខ្លោងទ្វារតាកាវបានបិទជាបណ្តោះអាសន្ន មិនឱ្យអ្នកដំណើរឆ្លងកាត់ទេ ទីមួយគឺដើម្បីសុវត្ថិភាពអ្នកដំណើរនិងទី២ដោយសារតែក្រុមអ្នកជំនាញ កំពុងបន្តអនុវត្តដំណើរការជួសជុលឱ្យប្រសើរឡើងវិញ៕

អាជ្ញាធរជាតិអប្សរា ចាប់ផ្តើមជួសជុលប្រាំងកសិន្ធុអង្គរវត្ត ប៉ែកខាងត្បូងប្រវែង២៥ម៉ែត្របន្ថែមទៀត

ផ្សាយនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២

ក្រុមការងារនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា បាននិងកំពុងចាប់ផ្តើមគម្រោងជួសជុលប្រាំងកសិន្ធុអង្គរវត្ត ប៉ែកខាងត្បូងស្ពានហាលប្រវែងសរុប២៥ម៉ែត្របន្ថែមទៀត ខណៈដែលស្ថានភាពទីតាំងមានសភាពទ្រុឌទ្រោម និងស្រុតខ្លាំង។

អ្នកស្រី ស៊ឹម ដានី មន្ត្រីបច្ចេកទេសផ្នែកអភិរក្ស និងជួសជុលប្រាំងកសិន្ធុអង្គរវត្តប៉ែកខាងត្បូងស្ពានហាល លើកឡើងថា នេះជាគម្រោងដំណាក់កាលទី៣ ដែលបានចាប់ផ្តើមពីខែ សីហាមក។ ការងារទាំងនេះគឺផ្តោតលើការពង្រឹងគ្រឹះ និងចំណុចដែលមានហានិភ័យខ្លាំងនូវប្រាំងកសិន្ធុដោយសារស្ថានភាពមានការស្រុតខ្លាំង។

ចំពោះដំណើរការជួសជុល អ្នកស្រី ស៊ឹម ដានី ពន្យល់ថា ក្រុមការងារកំពុងរើថ្មរំកិលទៅទីតាំងផ្សេង ដើម្បីងាយស្រួលជួសជុល និងរៀបចំបុកបង្ហាប់ដីឱ្យមានសភាពរឹងមាំនៅផ្នែកគ្រឹះ មុននឹងរៀបចំដំឡើងថ្មឡើងវិញ។ អ្នកជំនាញពន្យល់ថា ស្ថានភាពប្រាំងកសិន្ធុនេះមានសភាពស្រុតខ្លាំងដោយសារបេតុង ដែលប្រើនៅជំនាន់បារាំងនាអំឡុងឆ្នាំ ១៩៦២ អស់គុណភាព ដូច្នេះតម្រូវឱ្យរើចេញ និងជំនួសដោយបាយអរដែលជាបច្ចេកទេសបុរាណវិញ៕

ញត្តិថ្កោលទោស របស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំ នៃអាជ្ញាធរជាតិអប្សរា សូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទង្វើ របស់ ទណ្ឌិត សម រង្ស៊ី មេក្រុមឧទ្ទាមក្បត់ជាតិ៣ជំនាន់ ដែលបានប្រមាថយ៉ាងធ្ងន់ធ្ងរ បំផុតចំពោះអង្គព្រះមហាក្សត្រ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជាជនខ្មែរ

ផ្សាយនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

ញត្តិថ្កោលទោសទណ្ឌិត សម រង្ស៊ី
ជនក្បត់ជាតិ៣ជំនាន់

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំនៃអាជ្ញាធរជាតិអប្សរា សូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការ ចំពោះ ទណ្ឌិត សម រង្ស៊ី មេក្រុមឧទ្ទាម ជាជនក្បត់ជាតិ៣ជំនាន់ ដែលជាថ្មីម្តងទៀតបានចោទប្រកាន់ និងប្រមាថយ៉ាងធ្ងន់ធ្ងរបំផុតចំពោះអង្គព្រះមហាក្សត្រជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជារាស្ត្រខ្មែរ ដើម្បីបម្រើប្រយោជន៍ និងមហិច្ឆតាជញ្ជ្រៀមអំណាចនយោបាយរបស់បុគ្គលខ្លួន និងបក្សពួកខ្លួន។ ទង្វើដ៏សែនថោកទាបបែបនេះ ប្រជាពលរដ្ឋកម្ពុជាទាំងមូលមិនអាចអត់ឱនឱ្យជាដាច់ខាត។

អំពើដែល ទណ្ឌិត សម រង្ស៊ី បានប្រព្រឹត្ត និងកំពុងផ្សព្វផ្សាយតាមរយៈបណ្តាញទំនាក់ទំនងសង្គម ជាបទល្មើសជាក់ស្តែងបង្កវិទ្ធង្សនា ញុះញង់បង្កើតចលាចល អសន្តិសុខក្នុងសង្គម ដែលអាចនាំឱ្យប្រទេសជាតិទាំងមូលឈានដល់ភាពកលិយុគច្របូកច្របល់។

យើងខ្ញុំទាំងអស់គ្នា សូមស្នើអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការផ្លូវច្បាប់ ឱ្យបានតឹងរឹងជាទីបំផុតចំពោះទណ្ឌិតរូបនេះ រួមទាំងបក្សពួក និងរាល់អង្គការនយោបាយពាក់ព័ន្ធ ដែលបាននិងកំពុងរួមគំនិតបំផ្លាញសុខសន្តិភាពនៅកម្ពុជា។ យើងខ្ញុំទាំងអស់គ្នា សូមប្រកាសគាំទ្រយ៉ាងមុតមាំ និងសូមគោរពជង្គ្រៃតាមអង្គព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជារាស្ត្រទូទាំងនគរ។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នា សូមប្តេជ្ញាចូលរួមការពារជាដាច់ខាតនូវរដ្ឋធម្មនុញ្ញ និងរាជរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងសូមអំពាវនាវដល់ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ចាត់វិធានការជាបន្ទាន់ចំពោះទណ្ឌិតរូបនេះ តាមផ្លូវច្បាប់ឱ្យសមតាមទម្ងន់ទោសរបស់បុគ្គលនេះ។

ថ្ងៃ អង្គារ ១ កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សៀមរាប ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរជាតិអប្សរាសូមអរគុណ និងស្វាគមន៍
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

1/1

សូមថ្វាយព្រះពរព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដ៏មហាមង្គលថ្ងៃថ្លៃ នៃព្រះរាជពិធីបុណ្យខួបលើកទី១៨ នៃការយាងគ្រងព្រះបរមរាជសម្បត្តិ របស់ព្រះករុណាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២

ភ្នាក់ងារទេសចរណ៍ សហការជាមួយកម្លាំងនគរបាលទេសចរណ៍ និងនគរបាលការពារបេតិកភណ្ឌ ប្រគល់ទូរស័ព្ទមួយគ្រឿងម៉ាក Iphone XR ពណ៌ខ្មៅ ដែលភ្ញៀវទេសចរជ្រុះនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២

នៅវេលាម៉ោង ១២:៤៩នាទី ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ នេះ ភ្នាក់ងារទេសចរណ៍ សហការជាមួយកម្លាំងនគរបាលទេសចរណ៍ និង នគរបាលការពារបេតិកភណ្ឌ បានប្រគល់ទូរស័ព្ទមួយគ្រឿងម៉ាក Iphone XR ពណ៌ខ្មៅជូនភ្ញៀវទេសចរ ឈ្មោះ Gaud Eleanor អាយុ ១៥ឆ្នាំ ជនជាតិបារាំង ដែលគាត់បានជ្រុះ នៅចំណុចវាលស្មៅស្រះទឹកខាងត្បូងនៃប្រាសាទអង្គរវត្ត។

គួរបញ្ជាក់ថា ជារឿយៗភ្នាក់ងារទេសចរណ៍តែងតែរើសបាននូវសម្ភារឬរបស់របរមួយចំនួនដែលភ្ញៀវទេសចរបានជ្រុះ ឬភ្លេចនៅតាមប្រាសាទនានា។ នៅពេលបានឃើញរបស់ជ្រុះ ឬភ្លេច ភ្នាក់ងារទេសចរណ៍សហការជាមួយនគរបាលការពារបេតិកភណ្ឌ នគរបាលទេសចរណ៍ដើម្បីស្វែងរកម្ចាស់របស់របរទាំងនោះ និងតែងតែបានប្រគល់របស់របរទាំងនោះជូនទៅម្ចាស់ដើមវិញ៕

ប្រាំងកសិន្ធុផ្នែកខាងជើងស្ពានហាល របស់ប្រាសាទអង្គរវត្តប្រវែង២០ម៉ែត្រទៀត នឹងបញ្ចប់ការជួសជុលនៅខែវិច្ឆិកា ឆ្នាំ២០២២

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២

ក្រុមការងាររបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា ឱ្យដឹងថា គម្រោងជួសជុលប្រាំងកសិន្ធុផ្នែកខាងជើងស្ពានហាលនៃប្រាសាទអង្គរវត្ត ប្រវែង២០ម៉ែត្រថ្មីទៀតអាចនឹងបញ្ចប់នៅមុនការគ្រោងទុក។ ក្រុមការងារអះអាងបែបនេះ បន្ទាប់ពីការងាររៀបកាំជណ្ដើរថ្មបាយក្រៀមថ្មីបានរួចរាល់ ហើយការងាររៀបឡើងវិញនូវកាំជណ្ដើរថ្មភក់បុរាណរៀបត្រូវតាមលំដើម មានដំណើរការឆាប់រហ័ស ដែលមកដល់ពេលនេះ នៅសល់តែកាំជណ្ដើរថ្មភក់ផ្នែកខាងលើប្រហែល ២ទៅ៣ជុំទៀតប៉ុណ្ណោះ ដែលនឹងត្រូវធ្វើបង្ហើយឆាប់ៗនេះ។

បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទនិងបុរាណវិទ្យារបស់អាជ្ញាធរជាតិអប្សរា និងជាប្រធានការដ្ឋានជួសជុលប្រាំងកសិន្ធុអង្គរវត្តជ្រុងខាងជើង អ្នកស្រី នង ប៉ូរ៉ាវី មានប្រសាសន៍ថា ការងារជួសជុលប្រាំងកសិន្ធុផ្នែកខាងជើងស្ពានហាលនៃប្រាសាទអង្គរវត្ត អាចនឹងបញ្ចប់នៅអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ ដោយសារតែការរៀបកាំជណ្ដើរថ្មភក់បុរាណត្រូវតាមលំនាំដើមមានដំណើរការរលូនល្អ មិនរើផ្ដុំច្រើនលើកច្រើនសារ។ អ្នកស្រី នង ប៉ូរ៉ាវី ឱ្យដឹងទៀតថា បច្ចុប្បន្ននេះ ការងារជួសជុលប្រាំងកសិន្ធុផ្នែកខាងជើងស្ពានហាលនៃប្រាសាទអង្គរវត្ត ដែលនៅសេសសល់ប្រហែល ១០ភាគរយប៉ុណ្ណោះ ដូចជាការសម្អាត និងបំពេញថ្មភក់ថ្មីជំនួសថ្មភក់ចាស់ដែលបាត់បង់ ដើម្បីឱ្យកាំជណ្ដើរមានលំនឹងឡើងវិញ។

គម្រោងជួសជុលប្រាំងកសិន្ធុផ្នែកខាងជើងស្ពានហាលនៃប្រាសាទអង្គរវត្ត បានចាប់ផ្ដើមឡើងតាំងពីអំឡុងខែមីនា ឆ្នាំ២០២២មក ដែលហួត មកដល់ពេលនេះ មានរយៈពេលប្រមាណ៧ខែមកហើយ។

ចាប់តាំងពីឆ្នាំ២០១៣ រហូតមកដល់ឆ្នាំ២០២២ អាជ្ញាធរជាតិអប្សរាបានអនុវត្តគម្រោងជួសជុលប្រាំងកសិន្ធុអង្គរវត្តជ្រុងខាងជើងចំនួន៧ដំណាក់កាលរួចមកហើយ បើគិតជាប្រវែងសរុបចំនួនប្រមាណ១៤៣ម៉ែត្រ៕

ចម្លាក់តោចំនួន២ នឹងយកទៅដាក់នៅកំពង់ទឹកផ្នែកខាងជើងស្ពានហាល មុខប្រាសាទអង្គរវត្តឡើងវិញ ក្រោយពេលបញ្ចប់ការជួសជុល

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២

ចម្លាក់តោចំនួន២ មានទម្ងន់ប្រមាណជាង៣តោន កម្ពស់ជាង២ម៉ែត្រ ដែលយកពីកំពង់ទឹករបស់ស្ពានហាលផ្នែកខាងជើងនៃស្ពានហាលចូលប្រាសាទអង្គរវត្តតាំងពីឆ្នាំ១៩៩៧ យកមករក្សាទុកនៅអភិរក្សដ្ឋានអង្គរ កំពុងត្រូវបានជួសជុលពង្រឹងឡើងវិញ បានប្រមាណ៩៥ភាគរយហើយ ដោយក្រុមអភិរក្សថ្មរបស់អាជ្ញាធរជាតិអប្សរា។ ក្រោយពីបញ្ចប់ការងារជួសជុលរួចរាល់ អាជ្ញាធរជាតិអប្សរាត្រៀមនឹងយកចម្លាក់តោទាំងគូទៅដាក់ទីតាំងដើមឡើងវិញ នៅកំពង់ទឹកផ្នែកខាងជើងនៃស្ពានហាលមុខប្រាសាទអង្គរវត្ត នៅដើមខែវិច្ឆិកា ឆ្នាំ២០២២ខាងមុខនេះ ក្រោយពីឃ្លាតចាកឆ្ងាយពីទីតាំងដើមប្រមាណ២៥ឆ្នាំ រក្សាបាននូវទម្រង់ដើមលើកតម្លៃ និងបង្កើនសោភ័ណភាពកំពង់ទឹកស្ពានហាលរបស់ប្រាសាទអង្គរឡើងវិញ ក្រោយពីទីតាំងស្ពានហាលនេះជិតបញ្ចប់ការជួសជុល។

លោក ឡុង ណារី ប្រធានក្រុមការងារអភិរក្សថ្មនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា មានប្រសាសន៍ថា ក្រុមការងាររបស់លោកចាប់ផ្តើមជួសជុលចម្លាក់ទាំងនេះពីខែមេសា ឆ្នាំ២០២២ រហូតដល់ពេលនេះរយៈពេល៦ខែ។ ដំបូង ក្រុមការងារបានរៀបចំធ្វើឯកសារ និងប្រមូលបំណែកតូចធំរបស់ចម្លាក់ដើមមកផ្គុំគ្នា។ មកដល់ពេលនេះ ចម្លាក់តោទាំងគូ មានភាពរឹងមាំឡើងវិញហើយ ដោយបានបំពេញនូវកន្លែងខូចខាតនឹងបានបង់ថ្មមួយចំនួនដូចជាជើងទម្រ ជើង ដងខ្លួន និងផ្នែកផ្សេងៗរបស់តោដែលចាំបាច់សម្រាប់ធានាភាពយូរអង្វែងរបស់តោ ជៀសវាងការខូចខាតបន្តទៀត។

លោក ណារី បានលើកឡើងថា ចម្លាក់តោថ្មនេះ មុនការជួសជុលមានសភាពទ្រុឌទ្រោមបែកបាក់រូបរាងជាអន្លើរនៅផ្នែកជើងទម្រ ជើង ទ្រូង និងផ្នែកខាងក្រោយជាដើម។ នៅសម័យបារាំង ចម្លាក់តោនេះ ត្រូវបានជួសជុលដោយប្រើស៊ីម៉ង់ត៍ និងដែកបិទភ្ជាប់ដើម្បីឱ្យមានលំនឹងអាចឈរបានប៉ុណ្ណោះ ប៉ុន្តែក្រោយមក វាក៏បានបែកបាក់ជាបន្តបន្ទាប់តាមអាយុកាលស៊ីម៉ងត៍។

លោកបញ្ជាក់ថា ក្នុងការជួសជុល ក្រុមការងារក៏បានប្រើបច្ចេកទេសជួសជុលសមស្រប ទៅតាមបទដ្ឋានដែលអាចធានាបាននូវលក្ខណៈដើម និងសុវត្ថិភាពយូរអង្វែងនៃចម្លាក់។ រីឯបច្ចេកទេស និងការជួសជុលក៏ត្រូវបានទទួលស្គាល់ដោយអ្នកជំនាញការអាដហុក៕

អាជ្ញាធរជាតិអប្សរាទទួលជួបសំណេះសំណាលការងារ ជាមួយលោកនាយកសាលាបារាំងចុងបូព៌ា (EFEO) នៅទីក្រុងប៉ារីស ប្រទេសបារាំង

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២

នៅរសៀលថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបសំណេះសំណាល និងពិភាក្សាការងារជាមួយលោក Nicolas Fiévé នាយកថ្មី នៃសាលាបារាំងចុងបូព៌ានៅទីក្រុងប៉ារីស បន្ទាប់ពីលោកត្រូវបានតែងតាំងក្នុងមុខតំណែងនេះ នាខែមេសា ឆ្នាំ២០២២ កន្លងទៅ។





ទិដ្ឋភាពដ៏ស្រស់ស្អាត នៃប្រាសាទតាសោម អមជាមួយធម្មជាតិស្រស់បំព្រង កំពុងរង់ចាំស្វាគមន៍ទេសចរមកកម្សាន្ត

ផ្សាយនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២

សកម្មភាពក្រុមឆ្លាក់ទារទេសចរណ៍ បន្តចូលរួមជួយសម្អាតកូនរុក្ខជាតិតូចៗ ដើម្បីបរិស្ថានល្អនៅប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២

ប្រាសាទធម្មនន្ទ ប្ញូជនីយដ្ឋានតូចច្រឡឹង កសាងនៅដើមសតវត្សរ៍ទី១២

ផ្សាយនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែវិច្ឆិកា

បន្ទាប់ពីការជួសជុល តួប៉មចំនួន៩ក្នុងចំណោមតួប៉មចំនួន១២ នៃប្រាសាទមេបុណ្យខាងលិចបានបង្ហាញខ្លួនជាថ្មី

ផ្សាយនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា សហការជាមួយនិងស្ថានទូតបារាំង ក្នុងការជួសជុលប្រាសាទបុរាណមេបុណ្យខាងលិច បាន ជួសជុលតួប៉មចំនួន៩ ក្នុងចំណោមតួប៉មទាំងអស់ ចំនួន១២ឱ្យលេចចេញរូបរាងឡើងវិញ បន្ទាប់ពីបានរួមគ្នា ធ្វើការជួសជុលអស់រយៈពេល៣ឆ្នាំមកនេះ។



ភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទតាព្រហ្ម សហការជាមួយក្រុមការងារផែណ្ណា ជួសជុលជណ្តើរឈើនៅចំណុចរោងទងទី៣នៃប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២

នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ ភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទតាព្រហ្ម បានសហការជាមួយក្រុមការងារផែណ្ណា លើការងារជួសជុលជណ្តើរឈើនៅរោងទងទី៣ ក្បែរច្រកទ្វារខាងកើត ចំណុចឡើងទស្សនាទេសភាពនៃប្រាសាទតាព្រហ្ម ដែលមានសភាពទ្រុឌទ្រោម។

ការងារជួសជុលនេះ ធ្វើឡើងដើម្បីរក្សាបាននូវសុវត្ថិភាពនៅទីតាំងគយគន់ទេសភាព និងកន្លែងផ្តិតយករូបភាពដ៏សំខាន់មួយនៅប្រាសាទតាព្រហ្ម។ ជាពិសេសលើកសោភ័ណភាព បង្កលក្ខណៈងាយស្រួល និងជៀសវាងការបង្កជាគ្រោះដោយយថាហេតុណាមួយដល់ភ្ញៀវទេសចរ៕

អ្នកសម្អាតបរិស្ថានស្នើឱ្យភ្ញៀវទេសចរចូលរួមទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ពេលមកលេងប្រាសាទ

ផ្សាយនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២

ទោះបីបច្ចុប្បន្នការយល់ដឹងពីបញ្ហាសំរាមរបស់ប្រជាពលរដ្ឋ ក៏ដូចជាភ្ញៀវទេសចរមានភាពល្អប្រសើរក៏ពិតមែន តែក៏នៅមានករណីមួយចំនួនតូច មិនទាន់ល្អនៅឡើយ ដែលទាមទារឱ្យមានការចូលរួមជាចាំបាច់ ដើម្បីគ្រប់គ្រងសំរាម ក៏ដូចជាបញ្ហាបរិស្ថាននៅតំបន់ប្រាសាទនៃរមណីយដ្ឋានអង្គរ។

អ្នកស្រី កុ ចត់ ភ្នាក់ងារសម្អាតបរិស្ថាននៅមុខប្រាសាទអង្គរវត្តបានលើកឡើងថា សំរាមដែលមានច្រើនសព្វថ្ងៃនេះ គឺស្លឹកឈើដែលទាមទារឱ្យបោសសម្អាតជាប្រចាំថ្ងៃ។ ក្រៅពីសំរាមប្រភេទនេះ ក៏មានសំរាមប្លាស្ទិក និងស្បោងមួយចំនួនតូច ដែលភ្ញៀវទុកដាក់មិនបានល្អនៅតាមធុងសំរាមដែរ ដោយអ្នកស្រីស្នើឱ្យភ្ញៀវទេសចរដែលមកលេងរមណីយដ្ឋានអង្គរ សហការចូលរួមដើម្បីបរិស្ថានស្អាតទាំងអស់គ្នា។

កំពុងកាត់ស្មៅមុខកសិន្ធុអង្គរវត្តមុខប្រាសាទអង្គរវត្ត ភ្នាក់ងារសម្អាតបរិស្ថានមួយរូបទៀត គឺអ្នកស្រី យន់ ចន្ទី ក៏លើកឡើងពីករណីសំរាមប្លាស្ទិកដែលភ្ញៀវទេសចរទុកដាក់មិនបានល្អផងដែរ។ សំរាមប្លាស្ទិកភាគច្រើនមានចានស្នោ និងបំពង់បឺតដែលមានចោលតាមដងផ្លូវ និងក្រៅធុងសំរាម ហើយពេលខ្លះត្រូវឆ្កែហែកពេញសួនច្បារក៏មាន។ ភ្នាក់ងាររូបនេះ ទទូចឱ្យភ្ញៀវទេសចរដែលមកដើរកម្សាន្តក្នុងតំបន់ប្រាសាទ នៃរមណីយដ្ឋានអង្គរ គួរមានឥរិយាបថល្អ ចូលរួមថែរក្សាបរិស្ថានទាំងអស់គ្នា ដើម្បីជាចំណែកទាក់ទាញទេសចរកាន់តែច្រើនបន្ថែមទៀត មកលេងខេត្តសៀមរាប។

យ៉ាងណាមិញ ភ្នាក់ងារទេសចរណ៍ក៏សង្កេតពីឥរិយាបថដ៏ល្អរបស់ភ្ញៀវទេសចរភាគច្រើន ដែលបានចូលរួមសហការទុកដាក់សំរាមបានត្រឹមត្រូវ និងមានការចូលរួមពីអ្នកលក់ផងដែរ ដែលតែងវេចខ្ចប់បានល្អក្រោយទទួលទានរួច។ បច្ចុប្បន្នមិនមានការលក់ដូរតាមវាលស្មៅទៀតទេ គឺច្រើននៅតាមរោងអង្គុយហូបអាហារ ដែលប្រការនេះធ្វើឱ្យការគ្រប់គ្រងសំរាមនៅតាមប្រាសាទកាន់តែប្រសើរឡើង៕

អាជ្ញាធរជាតិអប្សរាទទួលជួបសំណេះសំណាលការងារ ជាមួយ ឯកអគ្គរដ្ឋទូតអ៊ីស្រាអែល ប្រចាំប្រទេសកម្ពុជា

ផ្សាយនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២

នៅព្រឹកថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបសំណេះសំណាល និងពិភាក្សាការងារជាមួយលោកជំទាវ Orna Sagiv ឯកអគ្គរដ្ឋទូតអ៊ីស្រាអែលប្រចាំប្រទេសកម្ពុជា ដើម្បីពិនិត្យលទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការជាមួយគ្នានាពេលអនាគត។

សិស្សសាលាបឋមសិក្សាក្របីរៀលចំនួន១៨២នាក់ ចុះទស្សនកិច្ចសិក្សានៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ

ផ្សាយនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២

ក្រោមកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និង អង្គការមរតកវប្បធម៌ខ្មែរ នាព្រឹកថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២ សិស្សានុសិស្សសាលាបឋមសិក្សាក្របីរៀល ដែលមាន ទីតាំងនៅសង្កាត់ក្របីរៀល ក្រុងសៀមរាបចំនួន១៨២នាក់ ដែលក្នុងនោះមានសិស្សថ្នាក់ទី៥ ចំនួន២ថ្នាក់ និងសិស្ស ថ្នាក់ទី៦ ចំនួន២ថ្នាក់ ដែលសិក្សាស្តីពីការអប់រំបេតិកភណ្ឌ បានចុះទស្សនកិច្ចសិក្សានៅសារមន្ទីរព្រះនរោត្តមសីហនុអង្គរ ដើម្បីស្វែងយល់នូវភាពជាក់ស្តែងនៃកិច្ចការពារ ថែរក្សា អភិរក្ស ការងារគ្រប់គ្រង និងអភិវឌ្ឍប្រកបដោយចីរភាព សម្រាប់តំបន់អង្គរ។

លោក អ៊ុន មុណីនីតា ជាគ្រូបង្គោលក្នុងកម្មវិធីអប់រំ បេតិកភណ្ឌ បានឱ្យដឹងថា ក្រោយពីសិស្សានុសិស្ស បាន យល់ដឹងពីមូលដ្ឋានអំពីបេតិកភណ្ឌវប្បធម៌ និងអរូបីនៅក្នុង សាលាកន្លងមកហើយ ក្រុមការងារគ្រូបង្គោលរបស់ អាជ្ញាធរជាតិអប្សរា និងអង្គការមរតកវប្បធម៌ខ្មែរ បាន រៀបចំសិស្សានុសិស្សបឋមសិក្សានៃសាលាក្របីរៀល ចំនួន១៨២នាក់ មកធ្វើទស្សនកិច្ចសិក្សាតាមរមណីយដ្ឋាន វប្បធម៌-ប្រវត្តិសាស្ត្រអង្គរ និងសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ។

លោក អ៊ុន មុណីនីតា គោលបំណងចុះទស្សនកិច្ចសិក្សា នៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ក្នុងគោលបំណង ឱ្យសិស្សបានយល់ដឹងពីតួនាទីសំខាន់ៗ ទី១ ជាកន្លែង ប្រមូលរក្សាទុកវត្ថុសិល្បៈបុរាណ ទី២ ជាកន្លែងជួសជុល ថែរក្សា និងការពារវត្ថុសិល្បៈបុរាណ ទី៣ ជាកន្លែង តាំងបង្ហាញវត្ថុសិល្បៈបុរាណ និងទី៤ ជាថ្នាលបណ្តុះ បណ្តាលបន្តជំនាន់។

លោក អ៊ុន មុណីនីតា បានថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ នៃអាជ្ញាធរជាតិអប្សរា ដែលបានយកចិត្តទុកដួចផ្តើមដាក់លើ គម្រោងការអប់រំបេតិកភណ្ឌនេះ និងមានផ្តល់ជាមធ្យោបាយ ដឹកជញ្ជូនសិស្ស អាហារសម្រន់ដល់កុមារដើម្បីឱ្យកម្មវិធី អប់រំបេតិកភណ្ឌនៅបន្តបានមកដល់សព្វថ្ងៃនេះ៕

សេចក្តីប្រកាសព័ត៌មាន

ផ្សាយនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ៖ ៧៥៦០/អប.ផរអក
/២២

សេចក្តីប្រកាសព័ត៌មាន

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា៖ នៅរសៀលថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង១៣និង៤០នាទី ក្រុមការងារសំអាតបរិស្ថាន អនាម័យនៃអាជ្ញាធរជាតិអប្សរា បានប្រទះឃើញត្រីអារ៉ាប៉ៃម៉ា (Arapaima) ប្រវែង២.១៥ម៉ែត្រ ទទឹង០.៤០ម៉ែត្រ ដែលជាប្រភេទត្រីទឹកសាប មានប្រភពមកពីតំបន់អាម៉ាហ្សូននៅអាមេរិចខាងត្បូង បានស្លាប់នៅក្នុងកសិន្ធុប្រាសាទអង្គរវត្ត។ ក្រុមការងារបានស្រង់យកត្រីនោះមកលើច្រាំង ជូនអ្នកជំនាញខាងជលផលពិនិត្យ និងបានកប់នៅផ្នែកខាងជើងនៃកសិន្ធុប្រាសាទអង្គរវត្ត។ តាមសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញផ្នែកជលផល ត្រីនេះស្លាប់ដោយធម្មជាតិ ព្រោះពុំមានស្លាកស្នាមរបួសនៃមង ឬប្រការអ្វីផ្សេងទៀតឡើយ។ ត្រីស្លាប់នេះ ជាប្រភេទត្រីដែលស៊ីត្រីតូចជាងខ្លួនជាអាហារ ហើយត្រូវបានមហាជនលួចយកព្រលែងក្នុងកសិន្ធុប្រាសាទអង្គរវត្ត។ ពាក់ព័ន្ធនឹងករណីនេះ នាពេលកន្លងមក អាជ្ញាធរជាតិអប្សរាធ្លាប់បានចេញសេចក្តីប្រកាសណែនាំ ហាមឃាត់ការព្រលែងត្រីក្នុងកសិន្ធុ ដែលពុំមែនជាប្រភេទត្រីក្នុងស្រុក ពីព្រោះសកម្មភាពនេះ អាចនាំឱ្យមានការបាត់បង់ពូជត្រីធម្មជាតិក្នុងស្រុកផងដែរ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សៀមរាប ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា APSARA

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

អញ្ជើញទស្សនាទេសភាពស្អាតៗនៅប្រាសាទតាព្រហ្ម នារដូវរំហើយនេះ

ផ្សាយនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២២



ប្រាសាទបាយ័ន ជាបេះដូងនៃរាជធានីអង្គរធំ

ផ្សាយនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២





ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ អញ្ជើញមកទស្សនាប្រាសាទអង្គរវត្តថ្ងៃនេះ

ផ្សាយនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២

ទិដ្ឋភាពភ្ញៀវទេសចរ អញ្ជើញមកទស្សនាប្រាសាទនាគព័ន្ធ

ផ្សាយនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២២

អបអរសាទរ ខួបលើកទី៦៩ នៃថ្ងៃបុណ្យឯករាជ្យជាតិ

ផ្សាយនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២២

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា និងឯកឧត្តម លី ខឺឈាង នាយករដ្ឋមន្ត្រីចិន អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ និងប្រគល់ទទួលគម្រោងជួសជុលប្រាសាទតាកែវ

ផ្សាយនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២

នៅព្រឹកថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២ **ឯកឧត្តម ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**ឯកឧត្តម លី ខឺឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ និងប្រគល់ទទួលគម្រោងជួសជុលប្រាសាទតាកែវ។ គម្រោងជួសជុលប្រាសាទតាកែវ ជាគម្រោងសហប្រតិបត្តិការអន្តរជាតិរវាងកម្ពុជានិងចិន អនុវត្តដោយក្រុមការងារនៃរដ្ឋាភិបាលចិនសម្រាប់ការអភិរក្សអង្គរហៅកាត់ថា CSA ដែលបានចាប់ផ្តើមពីឆ្នាំ២០១១ និងបញ្ចប់នៅឆ្នាំ២០១៨។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា មានប្រសាសន៍ថា សាធារណរដ្ឋប្រជាមានិតចិន តាមរយៈគោលនយោបាយ និងកិច្ចសហប្រតិបត្តិការទ្វេភាគីនានា នឹងបន្តចូលរួមកាន់តែសកម្មក្នុងកិច្ចការអភិរក្ស និងការពារបេតិកភណ្ឌវប្បធម៌ឱ្យបានកាន់តែខ្លាំងក្លា ដូចដែលភាគីមិត្តបាននិងកំពុងធ្វើក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា និងការគាំទ្រភាពជាដៃគូអាស៊ាន-ចិន ក្នុងក្របខណ្ឌអាស៊ានតាំងពីដើមរៀងមក។ ការជួយរបស់ចិនសម្រាប់កិច្ចការអភិរក្សប្រាសាទមានតាំងពីឆ្នាំ ១៩៩៣ មក ជាក់ស្តែងគម្រោងជួសជុលប្រាសាទតាកែវ បានចាប់ផ្តើមពីឆ្នាំ ២០១១ រហូតដល់ឆ្នាំ២០១៨ និងបន្តជួសជុលប្រាសាទដទៃទៀតក្នុងរមណីយដ្ឋានអង្គរ។

ឯកឧត្តម ក៏មិនភ្លេចថ្លែងអំណរគុណដល់មិត្តចិន ដែលបានផ្តល់វ៉ាក់សាំងកូវីដ១៩ សម្រាប់ចាក់ជូនប្រជាជនកម្ពុជា ដែលបានអនុញ្ញាតឱ្យកម្ពុជាអាចគ្រប់គ្រងវិបត្តិធ្ងន់ធ្ងរ និងជាសាកលបានយ៉ាងឆាប់រហ័ស និងអាចចាប់ផ្តើមបើកប្រទេសឡើងវិញ ស្តារបានជាបន្តបន្ទាប់នូវសេដ្ឋកិច្ច សង្គម ប្រកបដោយបរិយាប័ន្ន។

ឯកឧត្តម លី ខឺឈាង នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន បានបង្ហាញស្មារតីស្មោះស្ម័គ្រចំពោះចំណងមិត្តភាពដ៏ជ្រាលជ្រៅរវាងកម្ពុជា-ចិន។ ឯកឧត្តមមានប្រសាសន៍ថា កិច្ចសហប្រតិបត្តិការកម្ពុជា-ចិនមានជាង ១ពាន់ឆ្នាំមកហើយ តាមរយៈកំណត់ហេតុ និងសៀវភៅប្រវត្តិសាស្ត្រជាច្រើននិយាយរឿងរ៉ាវនៃអារ្យធម៌ប្រទេសទាំងពីរ។ ហើយគម្រោងជួសជុលប្រាសាទតាកែវ ធ្វើឡើងក្នុងក្របខណ្ឌអង្គការយូណេស្កូដែលបានជួយកម្ពុជាក្នុងការអភិរក្សមរតកវប្បធម៌របស់ខ្លួន។

ឯកឧត្តមនាយករដ្ឋមន្ត្រី មានសុទិដ្ឋិនិយមថា គម្រោងជួសជុលនេះនឹងផ្តល់ផលប្រយោជន៍ច្រើនដល់កម្ពុជា ក៏ដូចជាកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ និងការផ្លាស់ប្តូរនៃអារ្យធម៌បណ្តាប្រទេសនៅក្នុងពិភពលោក។ ចិនគាំទ្រ នឹងបន្តកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសកម្ពុជាក្នុងការអភិរក្សប្រាសាទ និងជួយជំរុញផ្លាស់ប្តូរសេដ្ឋកិច្ច និងវប្បធម៌ ដើម្បីជំរុញការផ្សារភ្ជាប់គ្នារវាងប្រជាជននិងប្រជាជន។ ឯកឧត្តមនាយករដ្ឋមន្ត្រីសង្ឃឹមថា កិច្ចសហប្រតិបត្តិកម្ពុជា-ចិន នឹងរួមចំណែកយ៉ាងសំខាន់ និងធ្វើឱ្យប្រជាជននិងប្រជាជន ស្វែងយល់ពីអារ្យធម៌ពីគ្នាថែមមួយកម្រិតទៀត៕

សេចក្ដីជូនដំណឹង ស្ដីពីការកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ: ៧៥៩៧/វប.សវ៦៣
២២

សេចក្ដីជូនដំណឹង
ស្ដីពី
ការកាត់ដកហូតដើមឈើនិងកាត់ក្រីមែកឈើ
មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជា ដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរានឹងកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ នៅតាមទីតាំងនានាដូចខាងក្រោម៖

- កាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើចំនួន១៥ដើម ដែលមានហានិភ័យស្ថិតនៅបរិវេណប្រាសាទបន្ទាយស្រី (កាត់ដកហូតចំនួន០៩ដើម ដើមចន្ទគិរី២ដើម ដើមស្វាយ២ដើម ដើមស្រល១ដើម ដើមទំពាំង០១ដើម ដើមក្រវៅ ១ដើម ដើមថ្កូវ១ដើម ដើមឈើទាល១ដើម កាត់ក្រីដើមឈើចំនួន៦ដើម ដើមអង្កាញ់៥ដើម ដើមពង្រ១ដើម) ។
- កាត់ដកហូត និងកាត់ក្រីមែកឈើចំនួន៧ដើម (កាត់ដកហូតឈើទាលរស់ចំនួន៥ដើម កាត់ក្រីមែឈើរស់ ចំនួន២ ដើម ដើមឈើទាល១ដើម ដើមជ្រៃ១ដើម)។
- កាត់ដកហូតដើមឈើទាលចំនួន០១ដើម ដែលមានហានិភ័យនៅប្រាសាទអង្គរវត្ត។
- កាត់ដកហូតដើមឈើចំនួន០៦ដើម (មានដើមអំពិលរស់១ដើម ដើមគររស់១ដើម ដើមស្វាយងាប់១ដើម ដើមអង្កាញ់ងាប់១ដើម ដើមឈើទាលរស់១ដើម ដើមចន្ទគិរីរស់១ដើម)។
- កាត់ដកហូតដើមឈើចំនួន០២ដើម ដែលមានហានិភ័យនៅតាមផ្លូវក្រៅកំពែងខាងត្បូងប្រាសាទតាព្រហ្ម (ដើមស្រលចំនួន១ដើម ដើមឈើទាលចំនួន០១ដើម)
- កាត់ដកហូតដើមឈើទាលចំនួន១ដើម ដែលមានហានិភ័យ ស្ថិតនៅផ្លូវចូលខាងកើតប្រាសាទបន្ទាយក្តី។
- កាត់ដកហូតដើមឈើចំនួន០២ដើម ដែលមានហានិភ័យនៅប្រាសាទវត្តអធ្វារ (ដើមពង្រចំនួន០១ដើម ដើមឈើទាល ចំនួន០១ដើម)។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន១៨ដើម ដែលមានហានិភ័យចាប់ពីផ្សារភូមិភាគ រហូតដល់រង្វង់មូលតាគុះ (កាត់ដកហូតដើមឈើចំនួន៨ដើមមាន ដើមអាកាស្យា៤ដើម ដើមឈើទាល១ដើម ដើមត្រសេក២ដើម ដើមស្រល១ដើម កាត់ក្រីមែកឈើចំនួន១០ដើមមាន ដើមច័ន្ទគិរី២ដើម ដើមត្រសេក៥ដើម ដើមអាកាស្យា២ដើម ដើមប្រេងខ្យល់១ដើម)

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្ដើមអនុវត្តការងារខាងលើចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២ តទៅ រហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមមន្ទីរស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៣ រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ពស២៥៦៦
សៀមរាប ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

អគ្គនាយកអាជ្ញាធរជាតិអប្សរាទទួលជួបពិភាក្សាការងារជាមួយអគ្គនាយកCACH

ផ្សាយនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២

ឯកឧត្ដម បណ្ឌិត ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឱ្យលោក Li Lausan អគ្គនាយកនៃបណ្ឌិតសភាបេតិកភណ្ឌវប្បធម៌ចិន(CACH)ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា។

កិច្ចជំនួបពិភាក្សានេះ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងការងារបច្ចេកទេសមួយចំនួន សម្រាប់អនុវត្តគម្រោងជួសជុលប្រាសាទជាបន្តបន្ទាប់ទៀតក្នុងតំបន់រមណីយ-ដ្ឋានអង្គរ៕

ការងារសម្អាតបរិស្ថានក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២២

ក្រុមការងារសម្អាតបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា តែងតែបង្កើនការយកចិត្តទុកដាក់លើការថែទាំ សម្អាតបរិស្ថានស្អាតជាប្រចាំ មាននៅក្នុងទឹក លើគោក តាមដងផ្លូវ បរិវេណក្នុងក្រៅប្រាសាទ តាមគោលដៅរបស់ខ្លួននៅក្នុងរមណីយ-ដ្ឋានអង្គរ ដើម្បីរក្សាបាននូវសោភ័ណភាព អនាម័យ និងតម្លៃរបស់សម្បត្តិបេតិកភណ្ឌពិភពលោក៕

ខ្លោងទ្វារជ័យ ប្រើសម្រាប់ចេញចូលក្រុងអង្គរធំ ដោយព្រះមហាក្សត្រ និងកងទ័ពបន្ទាប់ពីបានទទួលនូវជោគជ័យលើខ្មាំងសត្រូវ

ផ្សាយនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២២

ប្រាសាទវត្តអធ្វា ទីសក្ការៈបូជា សាងសង់នៅចុងសតវត្សរ៍ទី១២ ក្នុងរចនាបថអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២

ឯកឧត្តមអនុប្រធានាធិបតីនៃសាធារណៈរដ្ឋឥណ្ឌា និងលោកជំទាវបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អញ្ជើញសម្ពោធសាលរបាំប្រាសាទតាព្រហ្ម ក្រោយពីបញ្ចប់ការជួសជុល

ផ្សាយនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២

នៅរសៀលថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២ នៅសាលរបាំប្រាសាទតាព្រហ្មដែលបានជួសជុលដោយអ្នកជំនាញមកពីប្រទេសឥណ្ឌា ក្រោមកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិអប្សរាត្រូវបានសម្ពោធបញ្ចប់ការជួសជុល និងដាក់ឱ្យចូលទស្សនាជាសាធារណៈ ចាប់ពីពេលនេះតទៅ។

អញ្ជើញចូលរួមជាអធិបតីក្នុងព្រឹត្តិការណ៍នេះមាន **ឯកឧត្តម JAGDEEP Dhankar** អនុប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌា **ឯកឧត្តម S. JAISHANKAR** រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋឥណ្ឌា និង**លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនៃព្រះរាជាណាចក្រកម្ពុជា។

សូមបញ្ជាក់ថា មុនមានការជួសជុលសាលរបាំប្រាសាទតាព្រហ្មនេះត្រូវបានដួលរលំជាគំនរថ្ម ហើយដំបូលត្រូវជ្រុះធ្លាក់ស្ទើរទាំងស្រុង ចំណែកសសរដួលរាបដល់ដីគ្មានសល់។ ក្រុមការងារបានចាប់ផ្តើមជួសជុលចាប់តាំងពីឆ្នាំ២០១០ និងបានបញ្ចប់ដោយជោគជ័យនៅឆ្នាំ២០២២៕

អាជ្ញាធរជាតិអប្សរា បិតបំពេញបាយអរនៅតាមជង្ហុក និងចន្លោះថ្មភក់កម្រាលស្ពានហាលមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២

ក្រុមការងារនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា បំពេញការងារបិតបាយអ តាមជង្ហុកដក់ទឹក និងចន្លោះថ្មភក់ដែលបាត់ ឬខូចផ្នែកខ្លះនៃកម្រាលស្ពានហាលប្រាសាទអង្គរវត្តឱ្យប្រសើរឡើង បំណងបញ្ចៀសហានិភ័យផ្សេងៗ ពិសេសលើកតម្លៃ ព្រមទាំងសោភ័ណភាពកម្រាលស្ពានហាល ស្របពេលការងារជួសជុលស្ពានហាលប្រាសាទអង្គរវត្ត ជិតរួចរាល់។ បិតបំពេញបាយអនេះ បញ្ចៀសកុំឱ្យទឹកដក់ធ្វើឱ្យដុះស្លែ បញ្ចៀសទឹកមិនឱ្យហូរចូលគ្រឹះនាំឱ្យខូចគ្រឹះរបស់ស្ពានហាល ជៀសវាងគ្រោះថ្នាក់កើតឡើងជាយថាហេតុផ្សេងៗពេលភ្ញៀវទេសចរដើរឆ្លងកាត់។

មន្ត្រីបច្ចេកទេសអភិរក្ស និងជួសជុលថ្ម (ITALIA) នៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា លោក មុំ សុផុន លើកឡើងថា កម្រាលស្ពានហាលធ្វើពីថ្មភក់ នៅផ្ទៃផ្នែកខាងលើមិននៅល្អពេញលេញ១០០ភាគរយដូចដើមនោះ ជ្រុងខ្លះនៃថ្មភក់ពុកផុយ បាក់បែក ខូចខាតដោយអន្លើរៗ បណ្តាលឱ្យមានជង្ហុកខ្លះៗ អាចធ្វើឱ្យក្រឡាច់ឬជំពប់ជើងដួលពេលភ្ញៀវទេសចរដើរឆ្លងកាត់។ លោក សុផុន បន្តថា ការងារនេះធ្វើឡើងតាមដំណាក់កាលៗ និងបានចាប់ផ្តើមតាំងពីដើមខែកញ្ញា គ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២២ ខាងមុខ។ ដំណាក់កាលទី១សម្រេចបានប្រវែងទទឹង៦ម៉ែត្រ បណ្តោយ១០ម៉ែត្រ និងនៅដំណាក់កាលទី២នេះ កំពុងបន្តប្រវែងទទឹង៦ម៉ែត្រ និងបណ្តោយ១០ម៉ែត្រជាបន្តទៀត។

លោក មុំ សុផុន បានឱ្យដឹងទៀតថា វត្ថុធាតុដើមសម្រាប់ផលិតបាយអរួមមានខ្សាច់ ម្សៅថ្មភក់ ម្សៅឥដ្ឋ កំបោរ និងទឹកជាដើម ជាវត្ថុធាតុដើមអាចរកបាននៅក្នុងស្រុក និងមិនធ្វើឱ្យប៉ះពាល់ខូចខាតដល់សាច់ថ្មឡើយ។ ក្រុមអ្នកជំនាញរំពឹងថា ក្រោយបំពេញនៅតាមជង្ហុកនៅស្ពានហាលផ្លូវចូលប្រាសាទអង្គរវត្តរួចរាល់ភ្ញៀវទេសចរអាចដើរឆ្លងកាត់ដោយមានសុវត្ថិភាព ដែលនេះ ក៏ជាផ្នែកមួយដ៏សំខាន់ស័ក្តិសមនិងតម្លៃរបស់ប្រាសាទអង្គរវត្តផង៕

អាជ្ញាធរជាតិអប្សរាទទួលជួបសម្តែងការគួរសមជាមួយសាកលវិទ្យាល័យសូហ្វីយ៉ា និងអ្នកជំនាញផ្នែកបេតិកភណ្ឌពីបណ្តាប្រទេសក្នុងតំបន់អាស៊ាន

ផ្សាយនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២

នៅព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា បានទទួលជួបសម្តែងការគួរសមជាមួយលោកសាស្ត្រាចារ្យបណ្ឌិត យ៉ូស៊ីអាគី អ៊ីស៊ីសាវ៉ា (Prof. Ishizawa Yoshiaki) ប្រធានមជ្ឈមណ្ឌលអាស៊ីសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្ស នៃសាកលវិទ្យាល័យសូហ្វីយ៉ា និងអ្នកជំនាញផ្នែកបេតិកភណ្ឌពីបណ្តាប្រទេសក្នុងតំបន់អាស៊ាន ដែលបានមកចូលរួមក្នុងសន្និសីទអន្តរជាតិស្តីពីការអប់រំបេតិកភណ្ឌវប្បធម៌អាស៊ាន ឆ្នាំ២០២២ ប្រារព្ធធ្វើឡើងចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ក្រោមកិច្ចសហការរវាងសាកលវិទ្យាល័យសូហ្វីយ៉ា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

អាជ្ញាធរជាតិអប្សរាបិទវគ្គបណ្តុះបណ្តាលស្តីពី ការអប់រំបេតិកភណ្ឌ ដល់សិស្សានុសិស្សសាលាបឋមសិក្សាក្របីរៀល

ផ្សាយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២

បន្ទាប់ពីដំណើរការបង្រៀនអស់រយៈពេល៧ខែកន្លងមក នៅព្រឹកថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២នេះ សិស្សានុសិស្ស ចំនួន១៨២នាក់ នៃសាលាបឋមសិក្សាក្របីរៀល បានបញ្ចប់ ដោយជោគជ័យនូវវគ្គបណ្តុះបណ្តាលស្តីពី ការអប់រំ បេតិកភណ្ឌ។

លោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាលនិងផ្សព្វផ្សាយ នៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ ក្នុងឱកាសនោះថា គម្រោងអប់រំបេតិកភណ្ឌសម្រាប់កុមារ ដែលរួមសហការដោយអាជ្ញាធរជាតិអប្សរា និងអង្គការមរតក វប្បធម៌ខ្មែរ នៅសាលាបឋមសិក្សាក្របីរៀលនេះ បានផ្តល់ ឱកាសឱ្យកុមារដែលកើត រស់នៅ និងសិក្សា ក្នុងតំបន់ បេតិកភណ្ឌបានដឹងថា ខ្លួនកំពុងរស់នៅក្នុងតំបន់ដែល ពិសេសជាងគេ ហើយទទួលមរតកដ៏ធំធេងពីបុព្វបុរស ដែលត្រូវបន្តថែរក្សា និងការពារបេតិកភណ្ឌជាតិរបស់ខ្លួន។

លោកបន្តថា បន្ទាប់ពីទទួលបានជោគជ័យលើវគ្គបណ្តុះ បណ្តាលនេះ គោលដៅបន្តអាជ្ញាធរជាតិអប្សរា នឹងឈានទៅ បន្តបើកវគ្គបណ្តុះបណ្តាលឡើងវិញ នៅសាលាបឋមសិក្សា និងវិទ្យាល័យក្នុងស្រុកប្រាសាទបាគង។ បន្ថែមពីនេះ អាជ្ញាធរជាតិអប្សរាកំពុងតែសហការជាមួយមជ្ឈមណ្ឌល ជាតិយុវជនកម្ពុជា ខេត្តសៀមរាប បណ្តុះបណ្តាលគ្រូបង្គោល ដើម្បីបន្តទៅបណ្តុះបណ្តាលសិស្សានុសិស្សនៅតាមសាលា រៀនរបស់ខ្លួន។

សូមជម្រាបផងដែរថា កម្មវិធីអប់រំបេតិកភណ្ឌ សម្រាប់ សិស្សានុសិស្សក្នុងសាលាបឋមសិក្សាក្របីរៀល មានរយៈ ពេល៧ខែ ដោយចាប់ផ្តើមពីខែឧសភា ដល់ខែវិច្ឆិកា ឆ្នាំ២០២២ មានសិស្សចូលរៀនសរុបចំនួន១៨២នាក់ មកពីថ្នាក់ទី៥ ចំនួន២ថ្នាក់ និងថ្នាក់ទី៦ ចំនួន២ថ្នាក់ រួម ទាំងគ្រូទទួលបន្ទុកចំនួន៤នាក់។ ដោយបង្រៀនក្នុងថ្នាក់ ពេលព្រឹករយៈពេល២ម៉ោង និងរសៀល២ម៉ោង នៅរៀងរាល់ ថ្ងៃព្រហស្បតិ៍ សរុបបង្រៀនក្នុងថ្នាក់បានចំនួន៤៨ម៉ោង និងបង្រៀនតាមរមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ និង សារមន្ទីរ បានចំនួន១២ម៉ោង៕

ព្រះលានស្តេចគម្លង់ ព្រះពន្លាសាងសង់នៅចុងសតវត្សទី១២ ដែលទេសចរអាចមកទស្សនាចម្លាក់ក្បូរក្បាច់ ដ៏អស្ចារ្យជាច្រើន

ផ្សាយនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២២

ស្រះស្រង់ កន្លែងទេសចរនិយមមកកម្សាន្តស្រូបយកខ្យល់អាកាសបរិសុទ្ធ អមដោយទេសភាពស្រស់បំព្រង

ផ្សាយនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២២



បាយអ គឺជាសារធាតុសំខាន់មួយ សម្រាប់ការពារមិនឱ្យទឹកជ្រាបចូលគ្រឹះប្រាសាទ និងខូចខាតរចនាសម្ពន្ធសំណង់បុរាណ

ផ្សាយនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២

រាល់ការជួសជុលសំណង់បុរាណ ដូចជាប្រាសាទកសាងពីថ្មភក់ សំណង់ឥដ្ឋ ឬក៏ថ្មបាយក្រៀមនោះទេ ក្រៅតែពីការធ្វើកំណាយស្រាវជ្រាវ ការពង្រឹងគ្រឹះឡើងវិញ ការស្វែងរកថ្មមកផ្គុំដាក់នៅទីតាំងដើម បំពេញថ្មថ្មីនៅតាមកន្លែងបាត់បង់ ឬខូចខាតដែលចាំបាច់នោះ ការបិទបាយអនៅតាមចន្លោះប្រហោងថ្មដែលខូចខាតឬបាត់បង់ និងនៅតាមមុខតំណក៏ជាកត្តាសំខាន់ដូចគ្នា ដើម្បីការពារការទឹកកុំឱ្យជ្រាបចូលបានតទៅទៀត។

ក្រុមអ្នកជំនាញផ្នែកអភិរក្សសំណង់បុរាណឱ្យដឹងថា រាល់សំណង់បុរាណទាំងឡាយ កាលណាទឹកហូរចូលគឺវាអាចបណ្តាលឱ្យគ្រឹះរបស់សំណង់ធាប់ចុះខ្សោយ និងឈានដល់ការខូចខាត។ ដោយសារតែមើលឃើញកត្តាសំខាន់នៃការទប់ស្កាត់ទឹកមិនឱ្យជ្រាបចូលរចនាសម្ពន្ធនៃសំណង់នេះហើយ បានជានៅពេលជួសជុលឡើងវិញនូវសំណង់បុរាណនីមួយៗ អ្នកជួសជុលតែងយកចិត្តទុកដាក់បំផុត ទៅលើថ្មមួយចំនួន និងកន្លែងខ្លះ ដែលមិនល្អពេញលេញ១០០ភាគរយនោះ គឺតម្រូវឱ្យបិទបាយអរនៅតាមចន្លោះប្រហោងនៅតាមទីតាំងដែលមានបញ្ហាជាចាំបាច់។ក្រុមអ្នកបច្ចេកទេសឱ្យដឹងថា បិទផ្និតបាយអនៅតាមមុខតំណនៃសំណង់ ដើម្បីការពារហានិភ័យទាំងអស់ ដែលអាចកើតឡើង។

កម្មករជំនាញម្នាក់ ដែលមានបទពិសោធន៍ប្រមាណ៧ឆ្នាំ ហើយ លោក ទក ធុល អាយុ៦១ឆ្នាំមានប្រសាសន៍ថា វត្ថុធាតុដែលអាចយកមកផលិតជាបាយអបាន គឺត្រូវយកម្សៅថ្មបាយក្រៀម ម្សៅឥដ្ឋ កំបោរ និងខ្សាច់លាយជាមួយទឹកទៅតាមសមាសធាតុជាក់ស្តែង។នៅពេលបិទឬបៀកវាដើម្បីឱ្យជាប់រឹងមាំគឺត្រូវដាក់ល្បាយកំបោរបាយអជុំគ្រើមៗជាមុន បន្ទាប់មកទើបបៀកកំបោរបាយអម៉ដ្ឋពីលើម្តងបន្តិចៗសង្កត់ឱ្យហាប់ណែនពេញចន្លោះប្រហោងនោះ ទើបមានគុណភាពមិនងាយទឹកជ្រាបចូល ព្រមទាំងមើលទៅមិនទើសទាស់ភ្នែក ព្រមទាំងលើកសោភណ័ភាពសំណង់មួយកម្រិតទៀតផង។

លោក បញ្ជាក់ទៀតថាលោកធ្លាប់មានបទពិសោធន៍ធ្វើការងារជួសជុលប្រាសាទជាមួយបារាំងជាច្រើនឆ្នាំលើផ្នែកដាប់ឆ្លាក់ក្បាច់ និងលោកទទួលបានចំណេះដឹងផ្នែកផលិតកំបោរបាយអ និងបិទបាយអនេះនៅប្រាំងកសិន្ធុខាងជើងស្ពានហាលនៃប្រាសាទអង្គរវត្ត បន្តពីអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរាប្រមាណជា៧ឆ្នាំមកហើយ៕

គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និមន្តមកទស្សនកិច្ចវត្តអារាមព្រះពុទ្ធសាសនានៅក្នុងបរិវេណរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២

ចាប់ពីថ្ងៃទី២០ ដល់ ២១ ខែវិច្ឆិកា ឆ្នាំ២០២២ សម្តេចព្រះពុទ្ធជ័យមុនីបណ្ឌិត ឃឹម សន ព្រះតំណាងគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូនិមន្តមកបំពេញទស្សនកិច្ចតាមវត្តអារាមព្រះពុទ្ធសាសនាមួយចំនួន នៅក្នុងបរិវេណរមណីយដ្ឋានអង្គរ។

ឯកឧត្តមបណ្ឌិត ហង់ ពៅ អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា បានដឹកនាំក្រុមការងារចូលក្រាបថ្វាយបង្គំ ធ្វើបទបង្ហាញ និងអមព្រះដំណើរនិមន្តទស្សនកិច្ចនៅតាមវត្តអារាមមួយចំនួនដូចជា វត្តអធ្វា វត្តអង្គរខាងត្បូង វត្តអង្គរខាងជើង វត្តកងជុំ វត្តឥន្ទទេព វត្តលលៃ ជាដើម ក្នុងគោលបំណងពិនិត្យ និងស្វែងយល់ពីការរៀបចំវត្ត បញ្ហាប្រឈមនៃសំណង់មិនរៀបរយក្នុងវត្តអារាម បទពិសោធន៍ និងគម្រូល្អ នៃការអភិរក្សជួសជុលវត្តបុរាណ និងការចូលរួមលើកតម្លៃវត្តអារាមនៅក្នុងបរិវេណរមណីយដ្ឋានអង្គរបេតកភណ្ឌពិភពលោក។

បាយអ គឺជាសារធាតុសំខាន់មួយ សម្រាប់ការពារមិនឱ្យទឹកជ្រាបចូលគ្រឹះប្រាសាទ និងខូចខាតរចនាសម្ពន្ធសំណង់បុរាណ

ផ្សាយនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា និងស្ថានទូតបារាំងដែលជាសហប្រធាននៃគណៈកម្មការដឹកនាំបច្ចេកទេសគម្រោងជួសជុលប្រាសាទមេបុណ្យខាងលិច នៅព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ នាប្រាសាទមេបុណ្យខាងលិច។

គោលបំណងនៃកិច្ចប្រជុំគឺដើម្បីតាមដានពិនិត្យលើវឌ្ឍនភាពការងារនាពេលកន្លងមក និងសម្រេចកំណត់ទិសដៅជាបន្តទៀតអំពីផែនការសកម្មភាពដើម្បីជួសជុល អភិរក្សប្រាសាទមេបុណ្យខាងលិច នៅឆ្នាំ២០២៤ ខាងមុខ។

សូមបញ្ជាក់ថា កិច្ចប្រជុំនេះបានប្រព្រឹត្តទៅដោយមានការចូលរួមពី **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា លោក Pierre Vincent ទីប្រឹក្សាវប្បធម៌ និងសហប្រតិបត្តិការនៃស្ថានទូតបារាំង ក្នុងនាមជាសហប្រធាននៃក្រុមការងារបច្ចេកទេសដឹកនាំគម្រោងជួសជុលប្រាសាទមេបុណ្យខាងលិច **លោក ជំទាវ ចៅស៊ុន គិរិយា** ទីប្រឹក្សាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រុមអ្នកបច្ចេកទេសមួយចំនួនទៀត៕

ប្រាសាទ ព្រះឥន្ទ្រកោសីយ៍ សំណង់ឥដ្ឋ កសាងនៅចុងសតវត្សទី១០ ដែលលាក់ខ្លួនក្នុងទីអារាមយ៉ាងស្ងប់ស្ងាត់

ផ្សាយនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២

ប្រាសាទប្រី កសាងនៅចុងសតវត្សទី១២ ដែលទេសចរមិនសូវបានស្គាល់

ផ្សាយនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២២

សាលាឆាន់បុរាណនៅវត្តរាជបូណ៌បញ្ចប់ការជួសជុលជាស្ថាពរ

ផ្សាយនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២

គម្រោងជួសជុល និងអភិរក្សសាលាឆាន់បុរាណនៅវត្តរាជបូណ៌ ដែលទទួលបានថវិកា និងបច្ចេកទេសទាំងស្រុងពីអាជ្ញាធរជាតិអប្សរា បានបញ្ចប់ជាស្ថាពរនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២។

ក្រោមកិច្ចខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ពីសំណាក់មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា គឺបានជួសជុលសាលាឆាន់បុរាណ ដែលមានសភាពចាស់ទ្រុឌទ្រោម ពុកផុយ ធ្លុះធ្លាយ ធ្លាក់បាក់ឱ្យល្អឡើងវិញ ដោយប្រើប្រាស់បច្ចេកទេស និងសម្ភារដូចដើមទាំងស្រុង ដើម្បីរក្សាបាននូវគុណតម្លៃផ្នែកប្រវត្តិសាស្ត្រ។ គោលបំណងនៃការជួសជុល និងអភិរក្សសាលាឆាន់នេះ គឺដើម្បីថែរក្សាមត៌កវប្បធម៌ខ្មែរលើវិស័យព្រះពុទ្ធសាសនាដ៏រស់រវើកឱ្យនៅឋិតថេរបន្តទៅមុខទៀត នឹងដើម្បីបម្រើប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ ការសិក្សារៀនសូត្រផង និងដើម្បីទាក់ទាញអារម្មណ៍ភ្ញៀវទេសចរដែលមកទស្សនាទឹកដីបុរាណដ្ឋានមួយនេះផង។

សូមបញ្ជាក់ថា ដំណាក់កាលទី១ គឺជួសជុលផ្នែកដំបូល មានដូចជា គ្រឿងបង្គំដំបូល ហោជាង ក្បឿងស្រការលិញ ក្បាច់រងស្បូវ ព្រំដំបូល បៃរកា នាគចែង នាគដងក្តារ ព្រំខ្នងដំបូល និងជហ្វាជាដើម។ ដំណាក់កាលទី២ ផ្តោតលើការជួសជុលផ្នែកតួអគារ រួមមាន ជួសជុលជញ្ជាំង កាំជណ្តើរ ក្បាច់តាមខឿនជើងជញ្ជាំង និងសម្អាតការ៉ូបាត សសរពិដាន៕



អាជ្ញាធរជាតិអប្សរាទទួលជួបសម្ដែងការគួរសមជាមួយប្រធានទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ ប្រចាំប្រទេសកម្ពុជា

ផ្សាយនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២

នៅរសៀលថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា **ឯកឧត្ដម ឃិត ចាន់ដារដ្ឋ** អគ្គនាយកស្ដីទីនៃអាជ្ញាធរជាតិអប្សរា បានទទួលជួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយលោកស្រី **Sandrine BOUCHER** ប្រធានថ្មី នៃទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ ប្រចាំប្រទេសកម្ពុជា ដើម្បីពិនិត្យលទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការបន្ថែមទៀត រវាងស្ថាប័នទាំងពីរនាពេលខាងមុខ។

អាជ្ញាធរជាតិអប្សរាចែកអំណោយសប្បុរសធម៌ដែលជាជំនួយរបស់មូលនិធិចិន សម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ (CFCHC) ជូនសិស្សានុសិស្សក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២

នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ លោកភ័ន ផល្លា ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិកនៃអាជ្ញាធរជាតិអប្សរា តំណាង **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានចុះចែកអំណោយសប្បុរសធម៌ដែលជាជំនួយរបស់មូលនិធិចិនសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ (CFCHC) ជូនសិស្សានុសិស្សនៅសាលាបឋមសិក្សាល្បើក ស្ថិតក្នុងភូមិល្បើក ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប សម្រាប់កម្មវិធីពេលព្រឹក និងនៅសាលាបឋមសិក្សាខ្នាត ស្ថិតក្នុងភូមិខ្នាត ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាបសម្រាប់កម្មវិធីពេលរសៀល ក្នុងនោះសាលាបឋមសិក្សាល្បើក មានសិស្សចំនួន ២៩៨ នាក់ និងសាលាបឋមសិក្សាខ្នាត មានចំនួន ៣៥៩ នាក់ សរុបចំនួន ៦៥៧ នាក់។ អាជ្ញាធរជាតិអប្សរានឹងបន្តចែកអំណោយសប្បុរសធម៌នេះតាមកម្មវិធីដែលបានគ្រោងទុកជូនសាលាមួយចំនួនទៀតក្នុងរមណីយដ្ឋានអង្គរ នៅថ្ងៃទី៣០ ខែវិច្ឆិកា និងថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២។

កម្មវិធីចែកអំណោយសប្បុរសធម៌នេះ ក៏មានការចូលរួមផងដែរ ពីសំណាក់លោកស្រី ជា សំនៀង មេឃុំដូនកែវ លោកឡឹក ឡូន មេឃុំខ្នាត លោកស៊ឹម ប៊ុនធឿន អនុប្រធាននាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ លោកនាយកសាលាបឋមសិក្សាល្បើក លោកនាយកសាលាបឋមសិក្សាខ្នាត លោកមេភូមិល្បើក លោកមេភូមិខ្នាត និងមន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាពាក់ព័ន្ធមួយចំនួនទៀតផងដែរ។

សូមបញ្ជាក់ជូនថាមូលនិធិចិនសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ (CFCHC) បាលផ្តល់ជំនួយមនុស្សធម៌ជូនអាជ្ញាធរជាតិអប្សរាចំនួន ២០០០ឃីត ដើម្បីចែកជូនប្រជាពលរដ្ឋ និងសិស្សានុសិស្សក្នុងរមណីយដ្ឋានអង្គរចំនួន២០០០គ្រួសារ ក្នុងនោះរួមមានសម្ភារសិក្សា និងសម្ភារការពារជំងឺឆ្លងកូវីដ-១៩។

អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលស្តីពី ការកសាងសមត្ថភាពភ្នាក់ងារសណ្តាប់ធ្នាប់ និងអភិរក្សព្រៃឈើ ក្នុងការប្រើប្រាស់កម្មវិធី Carry Map

ផ្សាយនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២

នៅរសៀលថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២នេះ នៅនាយកដ្ឋានសណ្តាប់ធ្នាប់ បានបើកវគ្គបណ្តុះបណ្តាលមួយ ស្តីពីការកសាងសមត្ថភាពភ្នាក់ងារសណ្តាប់ធ្នាប់ និងអភិរក្សព្រៃឈើ ចំនួន៦២នាក់ អំពីរបៀបប្រើប្រាស់កម្មវិធី **Carry Map** ក្នុងការបំពេញការងារ កំណត់ និងស្វែងរកអត្តសញ្ញាណអ្នកប្រើប្រាស់ក្បាលដី និងកំណត់តំបន់ការពារព្រៃឈើ នៅក្នុងតំបន់ឧទ្យានអង្គរ ឱ្យកាន់តែមានប្រសិទ្ធភាព៕



ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែធ្នូ

ខ្លោងទ្វារទន្លេអុំ ជាទីទាក់ទាញអ្នកទេសចរគ្រប់រូប ដែលមិនអាចរំលងបាន

ផ្សាយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២

ខ្លោងទ្វារទន្លេអុំទិសខាងត្បូង គឺជាខ្លោងទ្វារមួយក្នុងចំណោមខ្លោងទ្វារទាំង៥នៃច្រកចេញចូលសំខាន់របស់ក្រុងអង្គរធំ ដែលជាផ្លូវទស្សនារមណីយដ្ឋានអង្គរក្នុងវង់តូចនិងវង់ធំផង។ កំពូលខ្លោងទ្វារ ដែលមានរូបព្រហ្មមុខបួនខ្ពស់ត្រដែតញញឹមពព្រាយ អមដោយចម្លាក់ទេវតានិងអសុរៈទាញព្រ័ត្រយ៉ាងស្វាហាប់ ម្ខាងៗមានចំនួន៥៤ នៅអមកំពែងក្រុងព័ទ្ធជុំវិញដោយកសិន្ធុទឹកនេះមានសោភ័ណល្អឯក ទាក់ចិត្តទេសចរជាតិ និងអន្តរជាតិឱ្យចាប់អារម្មណ៍យ៉ាងខ្លាំង គឺនៅពេលគេធ្វើដំណើរមកដល់ទីនោះ មិនអាចហួសរំលងទេ ដោយគេតែងតែចុះមកទស្សនាស្វែងយល់ និងថតយករូបភាពមិនដែលខាន។

ប្រធានក្រុមភ្នាក់ងារទេសចរ ប្រចាំគោលដៅខ្លោងទ្វារទន្លេអុំ លោក ខឿន កុសល ឱ្យដឹងថា ក្រោយពីចំនួនភ្ញៀវទេសចរបានកើនឡើងវិញនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ខ្លោងទ្វារទន្លេអុំមានភាពមមាញឹកខ្លាំង។ ក្នុងមួយថ្ងៃៗយ៉ាងហោចណាស់ក៏មានភ្ញៀវទេសចរលើសពី១ពាន់នាក់។ លោក កុសល បន្តថា ដោយសារខ្លោងទ្វារទន្លេអុំជាច្រកចេញចូលសំខាន់នៃក្រុងអង្គរធំ និងជាផ្លូវសម្រាប់ទៅទស្សនារមណីយដ្ឋានអង្គរ វង់តូច និងវង់ធំផងនោះ ចរាចរណ៍មានការមមាញឹកខ្លាំងជារៀងរាល់ថ្ងៃ។ ប៉ុន្តែក្រុមការងារបានសហការណ៍ជាមួយភ្នាក់ងារសណ្តាប់ធ្នាប់ សម្រួលចរាចរណ៍ និងរក្សាសណ្តាប់ធ្នាប់នៅទីនោះ ឱ្យមានភាពប្រសើរដោយធ្វើយ៉ាងណាជៀសវាងការកកស្ទះ សម្រួលឱ្យលំហូរទស្សនារបស់ភ្ញៀវបានរលូន មិនរំខានដល់ការទស្សនារបស់ទេសចរឡើយ។

អាជ្ញាធរជាតិអប្សរា ក៏សំណូមពរដល់ភ្ញៀវទេសចរ ដែលបានមកទស្សនារមណីយដ្ឋានអង្គរទាំងឡាយ សូមចូលរួមគោរពនូវក្រមប្រតិបត្តិអង្គរទាំងអស់គ្នា ដោយកុំស្លៀកពាក់សម្លៀកបំពាក់ខើចខ្លីពេក ដែលមិនស័ក្តិសមនឹងទីតាំងនៃបូជនីយដ្ឋាន ពិសេសប្រាង្គប្រាសាទ។ មួយវិញទៀត សូមក្រុមហ៊ុនដឹកអ្នកដំណើរ ម៉ូតូកង់បី មេត្តាចតយានជំនិះទៅតាមកន្លែងដែលអាជ្ញាធរជាតិអប្សរាបានរៀបចំជូន ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងលើកតម្លៃរមណីយដ្ឋានអង្គររបស់យើងទាំងអស់គ្នា៕

អាជ្ញាធរជាតិអប្សរាបិទបញ្ចប់កម្មវិធីចែកអំណោយសប្បុរសធម៌ ដែលជាជំនួយរបស់មូលនិធិចិនសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ (CFCHC) ជូនសិស្សានុសិស្សក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២

នៅថ្ងៃទ០១ ខែធ្នូ ឆ្នាំ២០២២ លោក ភ័ន ផល្លា ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិកនៃអាជ្ញាធរជាតិអប្សរា តំណាង **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានបន្តចុះចែកអំណោយសប្បុរសធម៌ដែលជាជំនួយរបស់មូលនិធិចិនសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ (CFCHC) ជូនសិស្សានុសិស្សនៅសាលាបឋមសិក្សាបាគង ស្ថិតក្នុងភូមិថ្នល់ត្រង់ ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាបសម្រាប់កម្មវិធីពេលព្រឹក និងនៅសាលាបឋមសិក្សាតាឯក ស្ថិតក្នុងភូមិតាឯក ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាបសម្រាប់កម្មវិធីពេលរសៀល ក្នុងនោះសាលាបឋមសិក្សាបាគងមានសិស្សចំនួន ៥៧៦នាក់ និងសាលាបឋមសិក្សាតាឯកមានសិស្សចំនួន ២៤០នាក់ សរុបចំនួន ៨១៦ នាក់។

កម្មវិធីចែកអំណោយសប្បុរសធម៌នេះ មានការចូលរួមផងដែរ ពីសំណាក់លោក នឹម សុវណ្ណ អភិបាលរងស្រុកប្រាសាទបាគង លោកមេឃុំបាគង លោកមេឃុំរុនតាឯក លោកនាយកសាលាបឋមសិក្សាបាគង លោកនាយកសាលាបឋមសិក្សាតាឯក លោកមេភូមិថ្នល់ត្រង់ លោកមេភូមិតាឯក ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាមួយចំនួនទៀត។ ដោយឡែក នៅរសៀលថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ លោកស្រី Mengxi Yuan តំណាងម្ចាស់ជំនួយនៃមូលនិធិចិនសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ (CFCHC) ក៏បានមានវត្តមានចូលរួមផងដែរ ក្នុងកម្មវិធីបិទបញ្ចប់ការចែកអំណោយសប្បុរសធម៌របស់មូលនិធិចិនសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ ជូនសិស្សានុសិស្សក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលបានរៀបចំដោយអាជ្ញាធរជាតិអប្សរា ។

សូមបញ្ជាក់ជូនថា អាជ្ញាធរជាតិអប្សរាបានរៀបចំផែនការចំនួន៣ថ្ងៃ គិតចាប់ពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ដើម្បីចែកអំណោយសប្បុរសធម៌ដែលទទួលបានពីមូលនិធិចិនសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ (CFCHC) ចំនួន២០០០ឃីត នៅសាលាបឋមសិក្សាចំនួន០៦ ដែលស្ថិតក្នុងតំបន់រមណីយដ្ឋានអង្គរ ក្នុងនោះរួមមាន សាលាបឋមសិក្សាល្បើកចំនួន ២៩៨ឃីត សាលាបឋមសិក្សាខ្នាតចំនួន៣៥៩ឃីត សាលាបឋមសិក្សាលាងដៃចំនួន ៣៧៥ឃីត សាលាបឋមសិក្សាគោកត្រើលចំនួន ១៥២ឃីត សាលាបឋមសិក្សាបាគងចំនួន ៥៧៦ឃីត និងសាលាបឋមសិក្សាតាឯកចំនួន ២៤០ឃីត។

អាជ្ញាធរជាតិអប្សរា ធ្វើពិធីបួងសួង ប្រុងពលី បើកការដ្ឋានជួសជុលចម្លាក់សត្វមករ

ផ្សាយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២

ពិធីបួងសួងសុំសេចក្តីសុខរៀបចំដោយអាជ្ញាធរជាតិអប្សរាសហការជាមួយវិស័យឯកជន ប្រព្រឹត្តទៅតាមទំនៀមបុរាណ ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម ឃិត ចាន់ដារដ្ឋ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា តំណាង**ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយក **លោកជំទាវ ឧកញ៉ាកិត្តិបណ្ឌិត សៀង ចាន់ហេង** អគ្គនាយកក្រុមហ៊ុនហេងអភិវឌ្ឍន៍ ព្រមទាំងអាជ្ញាធរមូលដ្ឋាន មន្ត្រី បុគ្គលិកនៃអាជ្ញាធរជាតិអប្សរា បានអញ្ជើញអុជធូប ថ្វាយគ្រឿងសក្ការៈ និងបួងសួង ពិធីប្រុងពលីបើកការដ្ឋានជួសជុលចម្លាក់សត្វមករ ស្ថិតនៅភូមិទឹកលិច ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២។

ការរៀបចំពិធីបួងសួង ប្រុងពលីដើម្បីសុំការអនុញ្ញាតពីម្ចាស់ទឹកម្ចាស់ដី វត្ថុស័ក្តិសិទ្ធិដែលថែរក្សាការជួសជុលចម្លាក់សត្វ មករ នៅទំនប់ទឹកមុជ ខាងត្បូងឈាងខាងកើតជួរភ្នំគូលែន ឱ្យរួចផុតពីហានិភ័យទុកជាកេរតំណែលសម្រាប់កូនចៅជំនាន់ក្រោយ៕

សេចក្តីជូនដំណឹង ស្តីពីការរៀបចំព្រឹត្តិការណ៍ រត់ពាក់កណ្តាលម៉ារ៉ាតុនអន្តរជាតិ នៅបរិវេណមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៤៣៣/អស.៥៤៧/២២

សេចក្តីជូនដំណឹង
ស្តីពី
ការរៀបចំព្រឹត្តិការណ៍ រត់ពាក់កណ្តាលម៉ារ៉ាតុនអន្តរជាតិ នៅបរិវេណមុខប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថាគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សហការជាមួយរដ្ឋបាលខេត្តសៀមរាប មន្ទីរ-អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរជាតិអប្សរា នឹងរៀបចំព្រឹត្តការណ៍ទិវារត់ប្រណាំងពាក់កណ្តាលម៉ារ៉ាតុនអន្តរជាតិលើកទី២៧ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២២ នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប លើវិញ្ញាសារត់ប្រណាំងចំនួន០៤ប្រភេទ ដូចខាងក្រោម៖

- ចម្ងាយ២១គីឡូម៉ែត្រ មានអ្នកចូលរួម ១,៧៥០នាក់ ចាប់ផ្តើមរត់ ម៉ោង៥ និង៤៥នាទី
- ចម្ងាយ១០គីឡូម៉ែត្រ មានអ្នកចូលរួម ៣,៤២០នាក់ ចាប់ផ្តើមរត់ ម៉ោង៦ និង០០នាទី
- ចម្ងាយ០៥គីឡូម៉ែត្រ មានអ្នកចូលរួម ១,៤០០នាក់ ចាប់ផ្តើមរត់ ម៉ោង៦ និង១៥នាទី
- ចម្ងាយ០៣គីឡូម៉ែត្រ មានអ្នកចូលរួម ៥០០នាក់ ចាប់ផ្តើមរត់ ម៉ោង៥ និង៣០នាទី

កម្មវិធីដែលមានភ្ញៀវចូលរួមប្រមាណ ៧,០០០នាក់នេះ (ភ្ញៀវអន្តរជាតិ ១,៧០០នាក់ មកពី៦៥ប្រទេសផ្សេងគ្នា) រួមបញ្ចូលផងដែរកីឡាករជាជនពិការ គ្រោងនឹងបញ្ចប់នៅម៉ោង៩ និង០០នាទីព្រឹក។ ក្នុងន័យដើម្បីជៀសវាងការកកស្ទះចរាចរណ៍ និងផលប៉ះពាល់ដល់ការទស្សនានានា អាជ្ញាធរជាតិអប្សរាស្នើសាធារណជនទាំងអស់ ជាពិសេសភ្ញៀវទេសចរជាតិ-អន្តរជាតិ មេត្តាជៀសវាងការធ្វើដំណើរទស្សនារមណីយដ្ឋាន ក្នុងចន្លោះពេលវេលាបញ្ជាក់ជូនខាងលើនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ ក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរ ជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការដោយក្តីអនុគ្រោះ។

ថ្ងៃ.សុក្រ.៩.កើត...... ខែ.មិគសិរ... ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
សៀមរាប ថ្ងៃទី...០២... ខែ...ធ្នូ... ឆ្នាំ២០២២
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

1/2

ទិដ្ឋភាពថ្ងៃបាក់រសៀល នៅប្រាសាទអង្គរវត្ត ជាទស្សនីយភាពដ៏អស្ចារ្យមួយផ្សេងទៀតនាឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២២

ទិដ្ឋភាពខ្លោងទ្វារទន្លេអុំ ច្រកចេញចូលសំខាន់នៃក្រុងអង្គរធំ ដែលទាក់ចិត្តទេសចរគ្រប់រូប

ផ្សាយនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២២

ព្រឹត្តិការណ៍រត់ពាក់កណ្ដាលម៉ារ៉ាតុងអន្តរជាតិឆ្នាំ២០២២ លើកទី២៧ ប្រព្រឹត្តទៅនៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២២

ព្រឹត្តការណ៍រត់ពាក់កណ្ដាលម៉ារ៉ាតុងអន្តរជាតិឆ្នាំ២០២២ លើកទី២៧ បានចាប់ផ្ដើមសាជាថ្មីនៅលើទឹកដីអង្គរ នាព្រឹកថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២២ ដែលមានអ្នកចូលរួមជាជនជាតិខ្មែរ និងបរទេសជាច្រើនប្រមាណជិត៨ពាន់នាក់មកពី៦៩ប្រទេសជុំវិញពិភពលោក។ អញ្ជើញចូលរួម ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា លោក សេង សុធារ៉ា ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ តំណាង**ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា **ឯកឧត្តម អ៊ឹង គឹមលាង** អភិបាលរងខេត្តសៀមរាប និងអាជ្ញាធរពាក់ព័ន្ធមួយចំនួនទៀត។

សូមបញ្ជាក់ដែរថា ការរត់ប្រណាំងពាក់កណ្ដាលម៉ារ៉ាតុងអន្តរជាតិនេះ ត្រូវបានរៀបចំធ្វើជារៀងរាល់ឆ្នាំនៅខេត្តសៀមរាប ក្នុងគោលបំណងសំខាន់ ក្រៅពីការបំផុសកីឡានេះដល់ប្រជាពលរដ្ឋលេងកីឡាដើម្បីសុខភាព និងរួមចំណែកវិស័យទេសចរណ៍ រួមទាំងផ្សព្វផ្សាយតំបន់បេតិកភណ្ឌពិភពលោក មានប្រាង្គប្រាសាទនៃតំបន់អង្គរ ក៏ដើម្បីផ្សារភ្ជាប់មនុស្សធម៌ដោយការស្វែងរកមូលនិធិកាកបាទក្រហម មន្ទីរពេទ្យគន្ធបុប្ផា អង្គការសប្បុរសជាតិ និងអន្តរជាតិនានានៅកម្ពុជា។ ម្យ៉ាងទៀត ក៏ដើម្បីផ្សព្វផ្សាយព្រឹត្តិការណ៍ប្រវត្តិសាស្ត្រស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេមនៅកម្ពុជា ឆ្នាំ២០២៣ខាងមុខ៕

សូមកុំបោះចោលសំរាមនៅតាមដងផ្លូវក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២២

ព្រឹត្តិការណ៍រត់ប្រណាំងអន្តរជាតិ ពាក់កណ្តាលម៉ារ៉ាតុងអង្គរ ដែលបានប្រព្រឹត្តិទៅនៅព្រឹកថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២២នេះ គឺជាព្រឹត្តិការណ៍កីឡារត់ដើម្បីសុខភាព ដើម្បីសាមគ្គីភាព ហើយការរៀបចំព្រឹត្តិការណ៍កីឡានេះ មានភាពល្អប្រសើ និងទទួលបានការចូលរួមយ៉ាងច្រើនកុះករពីសំណាក់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

សំរាមប្លាស្ទិកជាច្រើនក៏ត្រូវបានបោះចោលនៅតាមដងផ្លូវនានា ដោយសំណល់ប្លាស្ទិកទាំងនោះ អាចបង្កផលប៉ះពាល់ទៅដល់អនាម័យបរិស្ថាន នៅក្នុងតំបន់អង្គរទាំងមូល។ដើម្បីចូលរួមថែរក្សាអនាម័យ បរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរ៕

សេចក្តីជូនដំណឹង ស្តីពីការកាត់ដកហូតដើមឈើ និងកាត់ត្រីមែកឈើមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ៤៣៦/ អប.ស២៣
២២

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើ និងកាត់ត្រីមែកឈើ
មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ និងកាត់ត្រីមែកឈើ នៅតាមទីតាំងនានាដូចខាងក្រោម៖

- កាត់ដកហូតដើមឈើចំនួន១៥ដើម (ត្រសេក២ដើម ឈើទាល៣ដើម អាកាស្យា៧ដើម អង្គាញ់១ដើម គគីរ១ដើម និងស្រឡៅ០១ដើម) និងកាត់ត្រីមែកឈើចំនួន៣ដើម (ចាន់គីរី២ដើម និងឈើទាល១ដើម) ដែលមានហានិភ័យ ស្ថិតនៅបរិវេណសួនរុក្ខជាតិអង្គរ។
- កាត់ដកហូតដើមឈើចំនួន៤ដើម(ត្រសេក១ដើម ស្រឡៅ២ដើម ស្រឡៅ១ដើម និងត្រាច១ដើម ដែលមានហានិភ័យ ស្ថិតនៅប្រាសាទបេងមាលា។
- កាត់ដកហូតដើមឈើចំនួន១០ដើម (ឈើទាល៨ដើម និងត្រសេក២ដើម) និងកាត់ត្រីមែកឈើ ចំនួន១៨ដើម (ឈើទាល១៦ដើម និងចាន់២ដើម) ដែលមានហានិភ័យ ស្ថិតនៅសងខាងបង្អាន់ដៃ នាគខ្លោងទ្វារជ័យ។
- កាត់ដកហូតដើមឈើចំនួន១០ដើម (អង្គោល១ដើម លៀង១ដើម ក្រឡាញ់១ដើម ស្វាយ២ដើម ខ្នុរ១ដើម ច្រេស១ដើម និងអាកាស្យា៣ដើម) និងកាត់ត្រីមែកឈើចំនួន១៥ដើម (អំពិល១ដើម ស្រឡៅ១ដើម បេង១ដើម រំដួល១ដើម លៀង១ដើម ស្វាយ១ដើម ដកឿ២ដើម ស្តុល២ដើម ក្រឡាញ់១ដើម និងស្វាយ១ដើម) ដែលមានហានិភ័យ ស្ថិតនៅបរិវេណប្រាសាទចៅស្រីវិបុល។
- កាត់ដកហូតដើមឈើចំនួន១១ដើម (សិរមាន់២ដើម ផ្ចឹក១ដើម ស្វាយគគីត១ដើម អង្គាញ់១ដើម ក្របៅគោក៣ដើម ពញ្ញា២ដើម និងស្រឡៅ១ដើម) និងកាត់ត្រីមែកឈើចំនួន១០ដើម (ក្របៅគោក៤ ដើម ដកឿ១ដើម ក្រឡាញ់៣ដើម ក្របេង១ដើម និងខ្ទិត១ដើម) ដែលមានហានិភ័យ ស្ថិតនៅបរិវេណប្រាសាទបន្ទាយឡុង។
- កាត់ដកហូតដើមឈើចំនួន៧ដើម (សិរមាន់២ដើម ស្វាយ១ដើម និងកកោះ១ដើម) និងកាត់ត្រីមែកឈើចំនួន៦ដើម(ក្របេង២ដើម លៀប២ដើម និងត្រាច១ដើម) ដែលមានហានិភ័យ ស្ថិតនៅបរិវេណប្រាសាទបន្ទាយអំពិល។
- កាត់ដកហូតដើមស្រឡៅ១ដើម ដែលមានហានិភ័យ ស្ថិតនៅខាងលិចប្រាសាទភិមានអាកាស។
- កាត់ដកហូតដើមឈើទាលចំនួន២ដើម ដែលមានហានិភ័យ ស្ថិតនៅផ្លូវចូលខាងកើតប្រាសាទតាកែវ។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារខាងលើចាប់ពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២ តទៅ រហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១២កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ពស២៥៦៦
សៀមរាប ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០២២
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប
អាជ្ញាធរដើម្បីការពារតំបន់រមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

ព្រឹត្តិការណ៍រំលឹកគុណអង្គររយៈពេល៣ថ្ងៃ នឹងចាប់ផ្ដើមពីថ្ងៃទី១៤ រហូតដល់ថ្ងៃទី១៦ ក្នុងខែធ្នូ ឆ្នាំ២០២២

ផ្សាយនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២

ឯកឧត្តម ឡុង កុសល អគ្គនាយករងអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា តាមការគ្រោងទុកពិធីរំលឹកគុណអង្គរចំនួន៣ថ្ងៃ ចាប់ពីថ្ងៃទី១៤ដល់ទី១៦ ខែធ្នូ ឆ្នាំ២០២២ ដែលមានកម្មវិធីសាសនា ស្តង់ពិព័ណ៌ និងការសម្តែងសិល្បៈបុរាណនៅពេលរាត្រី។

ដោយចាប់ផ្តើមនៅព្រឹកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ពិធីបួងសួងព្រឹត្តិការណ៍រំលឹកគុណអង្គរ នៅបរិវេណមុខប្រាសាទអង្គរវត្ត នឹងប្រព្រឹត្តទៅក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ថ្នាក់ដឹកនាំខេត្តសៀមរាប ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ភ្ញៀវទេសចរជាតិនិងភ្ញៀវអន្តរជាតិ។ នៅព្រឹកថ្ងៃនោះដែរ បន្ទាប់ពីកម្មវិធីបួងសួង ក៏មានពិធីរាប់បាតព្រះសង្ឃចំនួន ១៣០អង្គផងដែរ។

ឯកឧត្តម ឡុង កុសល បានឱ្យដឹងទៀតថា នៅថ្ងៃបន្តបន្ទាប់ក៏មាននូវទស្សនីយភាពជាច្រើនដូចជា កម្មវិធីបែបសាសនាសំខាន់ៗ ការតាំងពិព័ណ៌បង្ហាញសមិទ្ធផលការងាររយៈពេល៣០ឆ្នាំកន្លងមករបស់អាជ្ញាធរជាតិអប្សរា ស្នាដៃសិល្បៈជាច្រើនដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌអរូបីនៃអង្គការយូណេស្កូ ការសម្តែងអាយ៉ៃឆ្លើយឆ្លងដោយលោក ព្រហ្ម ម៉ាញ ព្រមទាំងការចាក់បញ្ចាំងភាពយន្តអំពីអង្គរជាដើម។ រាល់កម្មវិធីសាសនា សិល្បៈទស្សនីយភាពទាំងអស់នឹងបើកជាសាធារណៈចូលទស្សនាដោយពុំមានបង់ប្រាក់នោះទេ។ អាស្រ័យដូចនេះ សូមបងប្អូនសាធារណជនអញ្ជើញចូលរួមឲ្យបានច្រើនកុះករ។

សូមជម្រាបដែរថា នេះជាឆ្នាំទីពីរហើយ ដែលអាជ្ញាធរជាតិអប្សរាបានរៀបព្រឹត្តិការណ៍រំលឹកគុណអង្គរនេះ។ ព្រឹត្តិការណ៍នេះ រៀបចំឡើងក្នុងគោលបំណងដើម្បីរំលឹកគុណអង្គព្រះមហាក្សត្រគ្រប់ព្រះអង្គ និងបុព្វការីជនដែលលោកបានកសាង និងថែរក្សាប្រាសាទទាំងអស់នៅក្នុងរមណីយដ្ឋានអង្គរ ដោយបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ជាតិមាតុភូមិតាំងពីដើមរហូតដល់សព្វថ្ងៃ៕

អាយស៊ីស៊ី-អង្គរ នឹងបើកកិច្ចប្រជុំបច្ចេកទេសលើក៣៦ និងកិច្ចប្រជុំពេញអង្គលើកទី២៩នៅពាក់កណ្តាលខែធ្នូខាងមុខនេះ

ផ្សាយនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២

គណៈកម្មាធិការអន្តរជាតិ ដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរហៅកាត់ថា (អាយស៊ីស៊ី-អង្គរ) នឹងបើកកិច្ចប្រជុំបច្ចេកទេសលើកទី៣៦ និងកិច្ចប្រជុំពេញអង្គលើកទី២៩ របស់ខ្លួននៅថ្ងៃទី១៥ ដល់១៦ ខែធ្នូ ឆ្នាំ២០២២ នាសណ្ឋាគារសូហ្វីតែល អង្គរ ភូគីត្រា ខេត្តសៀមរាប។

កិច្ចប្រជុំទាំងពីរនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា ក្នុងនាមតំណាងរាជរដ្ឋាភិបាលកម្ពុជា រួមនឹងសហប្រធានគណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ ដែលមានឯកឧត្តម ឯកអគ្គរដ្ឋទូតប្រទេសបារាំងប្រចាំប្រទេសកម្ពុជា និងឯកឧត្តម ឯកអគ្គរដ្ឋទូតប្រទេសជប៉ុនប្រចាំប្រទេសកម្ពុជា។

របៀបវារៈនៃកិច្ចប្រជុំទាំងពីរអង្គនេះ នឹងផ្តោតទៅលើចំណុចសំខាន់ៗមួយចំនួនដូចជា៖ តាមដានការអនុវត្តអនុសាសន៍កិច្ចប្រជុំកន្លងមក អំពីកិច្ចការអភិរក្សជួសជុល និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងរមណីយដ្ឋានអង្គរ របាយការណ៍សកម្មភាពស្តីអំពីការងារអភិរក្ស និងកិច្ចការស្រាវជ្រាវបុរាណវិទ្យា។

សូមបញ្ជាក់ថា អាយស៊ីស៊ី-អង្គរ រៀបចំកិច្ចប្រជុំរបស់ខ្លួនពីរដងក្នុង១ឆ្នាំ ម្តងជាមួយសមាជិក គឺកិច្ចប្រជុំពេញអង្គ និងម្តងទៀត គឺកិច្ចប្រជុំបច្ចេកទេស៕

ក្រុមអ្នកជំនាញការអាដហុក នៃអាយស៊ីស៊ី-អង្គរ ចុះពិនិត្យតាមការដ្ឋានជួសជុលប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២

ក្រុមអ្នកជំនាញការចំពោះកិច្ចអាដហុកនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ (ICC-Angkor) ដោយមានការចូលរួមពីលេខាធិការដ្ឋានអាយស៊ីស៊ី-អង្គរ ថ្នាក់ដឹកនាំ និងមន្ត្រីអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យការងារជួសជុលការដ្ឋានមួយចំនួនក្នុងរមណីយដ្ឋានអង្គរ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២។

ការចុះពិនិត្យផ្លាស់ប្តូរយោបល់នេះ គឺជាសកម្មភាពចាប់ផ្តើមមុននឹងដំណើរការនៃកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ ទាំងគម្រោងរបស់អាជ្ញាធរជាតិអប្សរា និងគម្រោងដៃគូអន្តរជាតិ ដើម្បីអ្នកជំនាញផ្តល់អនុសាសន៍ចំណុចដែលត្រឹមត្រូវ ឬចំណុចត្រូវកែលម្អឱ្យការងារទាំងនោះដំណើរការល្អ និងស្របតាមលក្ខខណ្ឌនៃធម្មនុញ្ញអង្គរ ដើម្បីអនុវត្តក្នុងការដ្ឋានរបស់ខ្លួនបានរលូន និងល្អប្រសើរថែមទៀត៕

ក្រុមអ្នកជំនាញអាដហុក នៃអាយស៊ីស៊ី-អង្គរ បន្តចុះពិនិត្យការងារអភិរក្សប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២

នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២នេះ ក្រុមអ្នកជំនាញការចំពោះកិច្ចអាដហុកនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថាអាយស៊ីស៊ី-អង្គរ(ICC-Angkor) ដោយមានការចូលរួមពីលេខាធិការដ្ឋានអាយស៊ីស៊ី-អង្គរ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញជាច្រើនរូបទៀត បានបន្តចុះពិនិត្យការងារជួសជុល និងអភិរក្សដែលកំពុងអនុវត្តតាមប្រាសាទមួយចំនួនដូចជា ប្រាសាទបន្ទាយសំរែ ប្រាសាទព្រះគោ ប្រាសាទចៅសាយទេវតា និងប្រាសាទតាព្រហ្ម៕

ប្រាសាទបន្ទាយធំ កសាងនៅចុងសតវត្សរ៍ទី១២ ដែលនៅមិនឆ្ងាយពីក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២

ក្រុមអ្នកជំនាញអាដហុក នៃអាយស៊ីស៊ី-អង្គរ បន្តសកម្មភាពចុះពិនិត្យការងារអភិរក្សប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២

នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២នេះ ក្រុមអ្នកជំនាញការចំពោះកិច្ចអាដហុកនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថាអាយស៊ីស៊ី-អង្គរ(ICC-Angkor) ដោយមានការចូលរួមពីលេខាធិការដ្ឋានអាយស៊ីស៊ី-អង្គរ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងថ្នាក់ដឹកនាំ និងមន្រ្តីជំនាញជាច្រើនរូបទៀត បានបន្តចុះពិនិត្យការងារជួសជុល និងអភិរក្សដែលកំពុងអនុវត្ត តាមប្រាសាទមួយចំនួនដូចជា អតីតព្រះបរមរាជវាំងនៃក្រុងអង្គរធំ ព្រះលានជល់ដំរី ប្រាសាទជម (ក្រុមព្រះពិធូ) ច្រកខាងកើតប្រាសាទអង្គរវត្ត ប្រាសាទបន្ទាយប្រី និងសារមន្ទីរព្រះនរោត្តមសីហនុអង្គរ៕

ប្រាសាទទ សំណង់ថ្មបាយក្រៀម សាងសង់នៅចុងសតវត្សរ៍១២ ដែលពុំសូវប្រទះឃើញមាននៅក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២២

អ្នកជំនាញការចំពោះកិច្ច នៃអាយស៊ីស៊ី-អង្គរ ចុះពិនិត្យការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច

ផ្សាយនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២

ព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ អ្នកជំនាញការចំពោះកិច្ចនៃការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់គណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថាអាយស៊ីស៊ី-អង្គរ (ICC-Angkor) អមដំណើរដោយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អគ្គនាយករងទីប្រឹក្សា និងក្រុមការងារពាក់ព័ន្ធ បានអញ្ជើញចុះពិនិត្យការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច។

ការចុះពិនិត្យនេះ ក្នុងគោលបំណងពិនិត្យតាមដានការងារជួសជុល និងវឌ្ឍនភាពគម្រោងជួសជុលប្រាសាទមេបុណ្យខាងលិច ក៏ដូចជាពិនិត្យលទ្ធភាពរៀបចំផែនការអភិវឌ្ឍន៍ទិសដៅទេសចរណ៍នៅប្រាសាទមេបុណ្យខាងលិចនេះបានល្អប្រសើរ៕

អ្នកជំនាញការចំពោះកិច្ច នៃអាយស៊ីស៊ី-អង្គរ ចុះពិនិត្យទីតាំងដែលពលរដ្ឋស្ម័គ្រចិត្តផ្លាស់ប្តូរទៅភូមិរុនតាឯក និងអភិវឌ្ឍន៍ពាក់ស្នែង

ផ្សាយនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២

ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២២ អ្នកជំនាញការចំពោះកិច្ចនៃការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់គណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថាអាយស៊ីស៊ី-អង្គរ (ICC-Angkor) អមដំណើរដោយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អគ្គនាយករង ក្រុមការងារពាក់ព័ន្ធ បានអញ្ជើញចុះពិនិត្យទីតាំងមួយចំនួនដែលពលរដ្ឋបានស្ម័គ្រចិត្ត ផ្លាស់ប្តូរទីលំនៅពីតំបន់រមណីយដ្ឋានអង្គរទៅរស់នៅតំបន់ភូមិធម្មជាតិរុនតាឯក និងតំបន់អភិវឌ្ឍន៍ពាក់ស្នែង។

នាពេលនោះដែរ ក្រុមអ្នកជំនាញការចំពោះកិច្ច នៃអាយស៊ីស៊ី-អង្គ បានជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋ និងបានស្វែងយល់ពីទិដ្ឋភាពជាក់ស្តែងនៃការរស់នៅមិនសមស្របរបស់ប្រជាពលរដ្ឋ និងបានចុះទៅពិនិត្យផ្ទាល់នូវទិដ្ឋភាពជាក់ស្តែងនៅតំបន់ភូមិធម្មជាតិរុនតាឯក និងតំបន់អភិវឌ្ឍន៍ពាក់ស្នែងដែរ៕

ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ខាងមុខនេះ ជាថ្ងៃបើកព្រឹត្តការណ៍រំលឹកគុណអង្គរ

ផ្សាយនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២

ព្រឹត្តិការណ៍រំលឹកគុណអង្គរ ដែលអាជ្ញាធរជាតិអប្សរា នឹងរៀបចំឡើង ចំនួន៣ថ្ងៃបានខិតចូលមកដល់ហើយគឺចាប់ពីថ្ងៃទី១៤ រហូតដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ខាងមុខ នៅបរិវេណប្រាសាទអង្គរវត្ត។

ឯកឧត្តម ឡុង កុសល អគ្គនាយករងនិងជាអ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា នៅព្រឹកព្រលឹមថ្ងៃទី១៤ ខែធ្នូ ខាងមុខនេះ មានពិធីបួងសួងបែបសាសនាបើកព្រឹត្តិការណ៍រំលឹកគុណអង្គរ នាបរិវេណមុខប្រាសាទអង្គរវត្តកម្មវិធីនេះនឹងប្រព្រឹត្តទៅក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ថ្នាក់ដឹកនាំខេត្តសៀមរាប ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ភ្ញៀវទេសចរជាតិនិងភ្ញៀវអន្តរជាតិ។ បន្ទាប់ពីនោះ វេលាម៉ោង១០ព្រឹក មានពិធីរាប់បាត្រព្រះសង្ឃចំនួន១៣០អង្គផងដែរ ក្នុងន័យនេះ ពុទ្ធបរិស័ទ មានបំណងចូលរួមក្នុងពិធីខាងលើ សូមអញ្ជើញចូលរួមឱ្យបានច្រើនកុះករ។

ឯកឧត្តម ឡុង កុសល អគ្គនាយករងមានប្រសាសន៍បន្តថា នៅពេលល្ងាចចាប់ពីវេលាម៉ោង៥តទៅ នៅបរិវេណខាងក្រោយប្រាសាទអង្គរវត្ត ក៏មានពិធីសម្តែងទស្សនីយភាពសិល្បៈជាច្រើនទម្រង់ «រាត្រីចងចាំ» ជូនទស្សនិកជនបានទស្សនា។

ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរា សូមអញ្ជើញសាធារណៈជនទាំងអស់ ចូលរួមឱ្យបានច្រើនកុះករ ក្នុងកម្មវិធីដែលបានប្រារព្ធធ្វើឡើងនេះ។សូមជម្រាបដែរថា ក្នុងរយៈពេល៣ថ្ងៃនៃព្រឹត្តិការណ៍រំលឹកគុណអង្គរ អាជ្ញាធរជាតិអប្សរា ក៏មានរៀបចំកម្មវិធីផ្សេងៗគ្នាជាច្រើន ហើយអាជ្ញាធរជាតិអប្សរា នឹងជូនដំណឹងជាបន្តបន្ទាប់ ពីពេលវេលានិងកម្មវិធីទាំងនោះ ដើម្បីជូនភ្ញៀវទេសចរជាតិ និ ងអន្តរជាតិជ្រាប និងបានចូលរួមទស្សនា៕

អាជ្ញាធរជាតិអប្សរា និងសិស្សានុសិស្ស ចំនួនជិត១ពាន់នាក់ ធ្វើព្យុះហយាត្រាដង្ហែក្បួនមុនព្រឹត្តិការណ៍រំលឹកគុណអង្គរ

ផ្សាយនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២

មុនពេលព្រឹត្តិការណ៍រំលឹកគុណអង្គរឈានចូលមកដល់មួយថ្ងៃ នៅព្រឹកថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២នេះ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរដោយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា រួមសិស្សានុសិស្ស សរុបចំនួនជិត១ពាន់នាក់ បានធ្វើព្យុះហយាត្រាដង្ហែក្បួន ដើម្បីឱ្យសាធារណជន ក៏ដូចជា ប្រជាពលរដ្ឋខ្មែរ ភ្ញៀវទេសចរជាតិ អន្តរជាតិ មានការរំលឹកគុណដល់ប្រាសាទអង្គរ ជាបេតិកភណ្ឌពិភពលោកមិនអាចកាត់ថ្លៃបាន ដែលបុព្វបុរសខ្មែរបានបន្សល់ទុកឱ្យកូនខ្មែរជំនាន់ក្រោយ។

ឯកឧត្តមបណ្ឌិត ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា ព្យុះហយាត្រាដែលមានមនុស្សចូលរួមជិតមួយ១ពាន់នេះ ធ្វើឡើងជាលើកទី១ នៃពិធីបុណ្យរំលឹកគុណអង្គរ ហើយជាសារមួយបង្ហាញថា កូនខ្មែរគ្រប់រូបបានតបស្នងសងគុណដល់បុព្វបុរសក៏ដូចជាអតីតព្រះមហាក្សត្រខ្មែរ ដែលបានកសាងប្រាសាទអង្គរទុកឱ្យកូនខ្មែរជំនាន់ក្រោយបានស្គាល់។ ព្រោះថា ប្រាសាទអង្គរជាបេតិកភណ្ឌរស់រវើកដែលមិនអាចកាត់ថ្លៃបាន។ ឯកឧត្តមបន្តថា សម័យបច្ចេកវិទ្យាទំនើបនេះ ប្រទេសនៅលើពិភពលោកក៏អាចចម្លង ឬកសាងប្រាសាទថ្មីធំៗបានដែរ ប៉ុន្តែការសាងសង់ថ្មី គឺគ្មានតម្លៃ និងគ្មានន័យដូចប្រាសាទរបស់កម្ពុជាបានឡើយ ព្រោះប្រាសាទនេះ មានអាយុកាលជាច្រើនពាន់ឆ្នាំមកហើយ ហើយក៏ជាដួងព្រលឹង និងអត្តសញ្ញាណជាតិរបស់ខ្មែរ។ ឯកឧត្តមបន្តថា វប្បធម៌ អរិយធម៌ ដែលជាដួងព្រលឹងរបស់ខ្មែរមានច្រើនមហិមា មានអាយុរាប់រយឆ្នាំ ឬរាប់ពាន់ឆ្នាំមកហើយ ដូចនេះ កូនខ្មែរគ្រប់រូបត្រូវដឹងគុណអង្គរ ដែលពាក្យមានន័យទូលំទូលាយបំផុត សម្រាប់មនុស្សជំនាន់ក្រោយ ត្រូវចូលរួមការអភិរក្ស និងអភិវឌ្ឍឱ្យបានគង់វង្ស។

សូមជម្រាបផងដែរថា ពិធីដង្ហែក្បួននេះ ចាប់ផ្តើមឡើងចេញពីខាងមុខប្រាសាទអង្គរ ឆ្ពោះទៅកាន់ខ្លោងទ្វារក្រុងអង្គរធំ ឬខ្លោងទ្វារទន្លេអុំ ដោយមានកាន់នូវបដា ជាភាសាខ្មែរផង និងភាសាបរទេសផង ដែលរំលេចដោយអត្ថន័យដ៏ជ្រាលជ្រៅរបស់ប្រាសាទអង្គរ ដូចជា អង្គរជាដួងប្រលឹង និងជាអត្តសញ្ញាណជាតិ អបអរសាទរពិធីបុណ្យរំលឹកគុណអង្គរ វប្បធម៌ជាមូលដ្ឋានគ្រឹះនៃសន្តិភាព និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាដើម៕

អាជ្ញាធរជាតិអប្សរា បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ជាមួយសាកលវិទ្យាល័យឯកជនចំនួន២ កិច្ចការអភិរក្សសំណង់បុរាណ

ផ្សាយនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២

ពិធីចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា (MOU)ជាមួយនិងសាកលវិទ្យាល័យបៀលប្រាយ(Build Bright)និងសាកលវិទ្យាល័យអង្គរ(Angkor University) ប្រចាំខេត្តសៀមរាប នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ នៅឯមុខប្រាសាទបន្ទាយសំរ៉ែ ក្នុងបំណងបើកឱកាសឱ្យក្រុមនិស្សិតផ្នែកស្ថាបត្យកម្មនៃសកលវិទ្យាល័យទាំងពីរនេះ អាចយល់ដឹងអំពីសំណង់បុរាណ ព្រមទាំងអាចសិក្សាយកបទពិសោធន៍លើកិច្ចការអភិរក្សថ្មជាមួយក្រុមអ្នកជំនាញនៃអង្គការអាល្លឺម៉ង់ ដែលកំពុងតែបំពេញការងារនៅឯប្រាសាទសំរ៉ែនោះផងដែរ។

ឯកឧត្តម គឹម សុធិន អគ្គនាយករង នៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា ការណ៍ដែលនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា សម្រេចចិត្តចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយសាកលវិទ្យាល័យBuild Bright និងសាកលវិទ្យាល័យអង្គរពេលនេះ ដោយសារតែអ្នកជំនាញនៃអង្គការអាល្លឺម៉ង់GIZដែលជាក្រុមឯកទេសខាងអភិរក្សថ្ម នៅតាមប្រាសាទនានាជាយូរមកហើយនោះ បានលើកឡើងថា ពេលបច្ចុប្បន្នធនធានមនុស្សខ្មែរដែលចេះជួសជុលនិងព្យាបាលថ្មប្រាសាទបុរាណគឺនៅមានចំនួនតិចតួចនៅឡើយ។

ឯកឧត្តម គឹម សុធិន រំពឹងថា នេះគឺជាឱកាសមួយដ៏ល្អសម្រាប់សាកលវិទ្យាល័យឯកជនទាំងពីរ ក្នុងការចូលរួមបណ្តុះបណ្តាលនិស្សិត ឱ្យល់ដឹងលើសំណង់បុរាណ ដើម្បីរួមចំណែកជួយអភិរក្សនិងថែរក្សាមត៌កដូន ឱ្យបានគង់វង្សយូរអង្វែងតទៅទៀត។

ព្រឹទ្ធបុរសរងនៃសាកលវិទ្យាល័យអង្គរ និងប្រធានក្រុមគ្រូបង្រៀនវិស្វកម្ម ស្ថាបត្យកម្ម លោក ពិន សុមុនី និងលោក ឈួន ភារុន នាយកសាខាសាកលវិទ្យាល័យបៀប្រាយសៀមរាប បានបង្ហាញនូវសុទិដ្ឋិនិយម ដែលអាជ្ញាធរជាតិអប្សរាបានអនុញ្ញាតិឱ្យក្រុមនិស្សិតមកពីសកលវិទ្យាល័យទាំងពីរបានចូលរួមសិក្សាយល់ដឹងពីជំនាញអភិរក្សថ្មនៃសំណង់បុរាណនេះ។ ថ្នាក់ដឹកនាំនៃសាកលវិទ្យាល័យទាំងពីរ បានរំពឹងយ៉ាងមុតមាំថា តាមរយៈអាជ្ញាធរជាតិអប្សរាជាស្ថាប័នជំនាញមួយ ដែលគ្រប់គ្រងតំបន់រមណីយដ្ឋានអង្គរជាសម្បត្តិបេតិកភណ្ឌលោកដ៏ល្បីល្បាញផងនោះ និងអ្នកជំនាញអ្នកជំនាញរបស់អង្គការអាល្លឺម៉ង់GIZ នឹងជួយបណ្តុះបណ្តាលដល់និស្សិតមកពីសាកលវិទ្យាល័យរបស់លោកឱ្យមានសមត្ថភាពពេញលេញ ដើម្បីរួមចំណែកអភិរក្សសំណង់ និងប្រាសាទបុរាណនានាពេលអនាគត៕

អាជ្ញាធរជាតិអប្សរា ប្រារព្ធពិធីបើកព្រឹត្តិការណ៍«រំលឹកគុណអង្គរ»

ផ្សាយនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរា ធ្វើពិធីបួងសួងប្រារព្ធបើកព្រឹត្តិការណ៍រំលឹកគុណអង្គរ និងរាប់បាត្រព្រះសង្ឃចំនួន១៣០អង្គ នៅមុខប្រាសាទអង្គរវត្ត នាព្រឹកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ នេះ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់**លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចជាតំណាងដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងឯកឧត្តម លោកជំទាវ និងភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ដ៏ច្រើនកុះករ។

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា បានមានប្រសាសន៍ ព្រឹត្តិការណ៍រំលឹកគុណអង្គរនេះ ប្រារព្ធធ្វើឡើងក្នុងគោលបំណង ដើម្បីអបអរសាទរខួបទី៣០ឆ្នាំនៃការចុះរមណីយដ្ឋានអង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២-ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ក៏ដូចជាដើម្បីរំលឹកគុណដល់បុព្វការីជនគ្រប់ជំនាន់ ព្រះមហាក្សត្រជំនាន់មុនគ្រប់ព្រះអង្គ ដែលបានកសាងប្រាង្គប្រាសាទនានា ព្រមទាំងបានបន្សល់ទុកនូវសម្បត្តិបេតិកភណ្ឌសិល្បៈ និងវប្បធម៌ជាច្រើនទៀត ដែលជាគុណប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចដល់ប្រជាជនកម្ពុជា នាពេលកន្លងមក បច្ចុប្បន្ន នឹងទៅអនាគត។

សូមបញ្ជាក់ថា ក្នុងរយៈពេល៣ថ្ងៃនៃការប្រារព្ធព្រឹត្តិការណ៍រំលឹកគុណអង្គរ(គឺថ្ងៃទី១៤ ដល់១៦ ខែធ្នូឆ្នាំ២០២២) ក្រៅពីការប្រារព្ធពិធីសាសនា អាជ្ញាធរជាតិអប្សរានៅបានរៀបចំកម្មវិធីសំខាន់ៗមួយចំនួនទៀត ដូចជា ស្តង់ពិព័រណ៍ស្តីពីសមិទ្ធផលរយៈពេល៣០ឆ្នាំ របស់អាជ្ញាធរជាតិអប្សរា ក្នុងកិច្ចអភិរក្ស និងអភិវឌ្ឍដោយចីរភាពរមណីយដ្ឋានអង្គរ រៀបចំការទស្សនានៅតាមការដ្ឋាន និងសារមន្ទីររបស់អាជ្ញាធរជាតិអប្សរា ជូនភ្ញៀវទេសចរ និងសាធារណជនចូលរួមដោយសេរី ដើម្បីសិក្សាស្វែងយល់ពីកិច្ចការអភិរក្ស និងកិច្ចការរៀបចំតំបន់រមណីយដ្ឋានអង្គររបស់អាជ្ញាធរជាតិអប្សរា និងពេលរាត្រីមានការសម្តែងសិល្បៈជូនសាធារណជនទស្សនាកម្សាន្តផងដែរ៕

ថ្ងៃទី២ នៃព្រឹត្តិការណ៍រំលឹកគុណអង្គរ នឹងមានពិព័រណ៍ស្តីពីសមិទ្ធផលការងារ របស់អាជ្ញាធរជាតិអប្សរា ការតាំងបញ្ចាំងសិល្បៈនិងការសម្តែងសិល្បៈអាយ៉ៃឆ្លើយឆ្លងជូនទស្សនា

ផ្សាយនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២

ឯកឧត្តម ឡុង កុសល អគ្គនាយករងនិងជាអ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា បន្ទាប់ពីពិធីបើកព្រឹត្តិការណ៍រំលឹកគុណអង្គរ នៅព្រឹកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ មក ទទួលបានការនិមន្ត និងអញ្ជើញចូលរួមពីថ្នាក់ដឹកនាំសំខាន់ៗជាច្រើនរូប និងភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ។ ក្នុងនោះកម្មវិធីសំខាន់ៗជាច្រើនទៀតដែលនឹងបង្ហាញជូនសាធារណៈទស្សនា សម្រាប់ថ្ងៃទី១៥ ខែធ្នូ ជាថ្ងៃទី២ នៃព្រឹត្តិការណ៍រំលឹកគុណអង្គរ មានដូចជា៖ ចាប់ពីម៉ោង០៨៖០០ព្រឹក ដល់ម៉ោង១៧៖០០ល្ងាច មានពិព័រណ៍ផលិតផល សកម្មភាពសិល្បៈចម្រុះ និងសមិទ្ធផលសំខាន់ៗរបស់អាជ្ញាធរជាតិអប្សរា ការទស្សនាសារមន្ទីរ ការចុះទស្សនាតាមការដ្ឋាននានាក្នុងរមណីយដ្ឋានអង្គរ និងសកម្មភាពផ្សេងៗ មាន៖ពិព័រណ៍សៀវភៅប្រវត្តិសាស្ត្រខ្មែរនិងបរទេស បទបង្ហាញនានាដោយបុរាណវិទូអាជ្ញាធរជាតិអប្សរា និងក្រសួងវប្បធម៌។ល។ ដោយពិធីនេះប្រារព្ធនៅទីតាំងបរិវេណមុខប្រាសាទអង្គរវត្ត និងការដ្ឋាននានាក្នុងតំបន់រមណីយដ្ឋានអង្គរ។

ឯកឧត្តមបន្តទៀតថា នៅពេលល្ងាចចាប់ពីម៉ោង១៨៖០០ ដល់ម៉ោង២២៖០០យប់ មានកម្មវិធីអាយ៉ៃឆ្លើយឆ្លងសម្តែងដោយលោក កិត្តិឧទេសបណ្ឌិត ព្រហ្ម ម៉ាញ និងការបញ្ចាំងភាពយន្តឯកសារអំពីអង្គរ ដែលមានទីតាំងនៅបរិវេណព្រះលានជល់ដំរី នៃក្រុងអង្គរធំ។

ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរា សូមនិមន្ត ព្រះតេជគុណ និងអញ្ជើញសាធារណៈជនទាំងអស់ ចូលរួមឱ្យបានច្រើនកុះករក្នុងកម្មវិធីដែលបានប្រារព្ធធ្វើឡើងនេះ។

សូមជម្រាបដែរថា ក្នុងរយៈពេល៣ថ្ងៃ នៃព្រឹត្តិការណ៍រំលឹកគុណអង្គរ អាជ្ញាធរជាតិអប្សរា ក៏មានរៀបចំកម្មវិធីផ្សេងៗគ្នាជាច្រើន ហើយអាជ្ញាធរជាតិអប្សរានឹងជូនដំណឹងជាបន្តបន្ទាប់ពីពេលវេលានិងកម្មវិធីទាំងនោះ ដើម្បីជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិជ្រាប និងបានចូលរួមទស្សនា៕

លិខិតគោរពជូនពរ
របស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករនិងឆ្មាំនៃអាជ្ញាធរជាតិអប្សរា គោរពជូនសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា ក្នុងឱកាសដ៏សែនមហានក្ខត្តឫក្សចម្រើនជន្មាយុគម្រប់ ៦៨ឆ្នាំ ឈានចូល ៦៩ឆ្នាំ

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ: ៤៥៥៤/២២ អ.ជ.អ

លិខិតគោរពជូនពរ

សូមគោរពជូន

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា

ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងឱកាសដ៏មហានក្ខត្តឫក្សចម្រើនជន្មាយុគម្រប់ ៦៨ឆ្នាំ ឈានចូល ៦៩ឆ្នាំរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ប្រធានកាកបាទក្រហមកម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ៧កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការបុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ យើងខ្ញុំសូមឆ្លៀតឱកាសបួងសួងដល់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះអង្គតាមជួយបីបាច់ថែរក្សា ប្រោះព្រំសព្វសាធុការពរជ័យ សិរីមង្គលគ្រប់ប្រការជូនចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាទីគោរពដ៏ខ្ពង់ខ្ពស់ សូមមានជន្មាយុយឺនយូរ សុខភាពល្អបរិបូរណ៍ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីបន្តបំពេញបេសកកម្មមនុស្សធម៌ជាប្រវត្តិសាស្ត្រ ទទួលបានជោគជ័យដ៏ត្រចះត្រចង់ថ្មីៗថែមទៀត បន្តចូលរួមចំណែកយ៉ាងធំធេងជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ដែលនាំមកជូនប្រទេសជាតិ និងប្រជាជននូវសុខសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យ។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាពុំអាចបំភ្លេចបាននូវគុណូបការៈ ការលះបង់និងពលិកម្មគ្រប់បែបយ៉ាងរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដើម្បីបុព្វហេតុជាតិមាតុភូមិ ដោយយកអស់កម្លាំងកាយចិត្ត ពុំចេះនឿយហត់ក្នុងការបំពេញនូវបេសកកម្មបម្រើប្រជាពលរដ្ឋទូទាំងប្រទេស ប្រកបដោយទឹកចិត្តសប្បុរសប្រពៃថ្លៃថ្លាគ្រប់ពេលវេលា។

ឆ្លៀតក្នុងឱកាសដ៏បវរមហាប្រសើរនេះដែរ យើងខ្ញុំទាំងអស់គ្នាសូមលើកហត្ថប្រណាមដោយក្តីគោរព និងសូមគោរពជូនពរចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និង**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ព្រមទាំង **បុត្រាបុត្រី ចៅប្រុស ចៅស្រី** សូមប្រកបបាននូវព្រះពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ប្រធានកាកបាទក្រហមកម្ពុជា មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ៧ ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សៀមរាប ថ្ងៃទី ៩ ខែធ្នូ ឆ្នាំ២០២២

អគ្គនាយក

ហង់ ពៅ

APSARA National Authority
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 578

1/1

គណៈកម្មាធិការសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ បើកធ្វើកិច្ចប្រជុំបច្ចេកទេសលើកទី៣៦ នៅខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២

គណៈកម្មាធិការអន្តរជាតិ ដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរហៅកាត់ថា (អាយស៊ីស៊ី-អង្គរ)និងសំបូរព្រៃគុក បានបើកកិច្ចប្រជុំបច្ចេកទេសលើកទី៣៦ របស់ខ្លួននៅព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ នៅខេត្តសៀមរាប។

កិច្ចប្រជុំបច្ចេកទេសនេះ ស្ថិតក្រោមអធិបតីភាព **លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ដោយមានបារាំង និងជប៉ុនជាសហប្រធាន។ សហប្រធាននៃកិច្ចប្រជុំពេលនេះ មានលោក TANINAI Ichitomo អនុប្រធានបេសកកម្មនៃស្ថានទូតជប៉ុនប្រចាំកម្ពុជា លោក Pierri VINCENT ទីប្រឹក្សាកិច្ចសហប្រតិបត្តិការវប្បធម៌ស្ថានទូតបារាំងប្រចាំកម្ពុជា និងមានការចូលរួមពីលោក Sardar Umar ALAM តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា។

កិច្ចប្រជុំបច្ចេកទេសថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ នេះ គណៈកម្មាធិការអន្តរជាតិ ដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា (អាយស៊ីស៊ី-អង្គរ) បានពិភាក្សា និងពិនិត្យតាមដានលើការអនុវត្តអនុសាសន៍ ដែលបានអនុម័តនៅក្នុងសម័យប្រជុំបច្ចេកទេសទី៣៥ និងកិច្ចប្រជុំពេញអង្គទី២៨ នៅខែមីនា ឆ្នាំ ២០២២ កន្លងមក ព្រមទាំង ពិនិត្យរបាយការណ៍សកម្មភាពក្រុមបច្ចេកទេស ការជួសជុល និងការអភិរក្ស។

ចំពោះរបាយការណ៍ដែលបានពិនិត្យក្នុងកិច្ចប្រជុំនេះបានឆ្លុះបញ្ចាំងចំពោះកម្មសភាពរបស់គណកម្មាធិការចំពោះកិច្ច (AdHoc)ដែលបានចុះតាមការដ្ឋាន ចាប់តាំងពីថ្ងៃទី០៦ រហូតដល់ថ្ងៃទី១២ ខែធ្នូ ២០២២ ហើយរបាយការណ៍នានានឹងដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃស្អែក ទី១៦ ខែធ្នូ ឆ្នាំ២០២២។

អាជ្ញាធរជាតិអប្សរា រៀបចំស្តង់ពិព័រណ៍សមិទ្ធផលការងារ ក្នុងព្រឹត្តិការណ៍រំលឹកគុណអង្គរឆ្នាំ២០២២

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២

ក្នុងព្រឹត្តិការណ៍ រំលឹកគុណអង្គរ ដែលបានប្រារព្ធឡើងថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២នេះ អាជ្ញាធរជាតិអប្សរា បានរៀបចំជាស្តង់ពិព័រណ៍សមិទ្ធផលការងារនៅមុខប្រាសាទអង្គរវត្ត។

ការតាំងពិព័រណ៍មិនអចិន្ត្រៃយ៍នេះ បានដាក់តាំងបង្ហាញពីសមិទ្ធផលដ៏ធំធេងរយៈពេល៣០ឆ្នាំ ដែលអាជ្ញាធរជាតិអប្សរាសម្រេចបាន លើការងារសំខាន់ៗមួយចំនួនក្នុងកិច្ចអភិរក្ស និងអភិវឌ្ឍន៍ដោយចីរភាពរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរដូចជា៖ កិច្ចការអភិរក្សប្រាសាទបុរាណ ការងារស្រាវជ្រាវផ្នែកបុរាណវិទ្យា និងបណ្តុះបណ្តាលធនធានមនុស្ស កិច្ចសហប្រតិបត្តិការជាមួយដៃគូរអន្តរជាតិនៅតំបន់អង្គរ ការងារអភិវឌ្ឍន៍វិស័យទេសចរណ៍អង្គរ និងវប្បធម៌ ការងារគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ពន្ធ ការងារគ្រប់គ្រងដីធ្លីក្នុងឧទ្យាន និងបេតិកភណ្ឌក្រុង ការងារអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក និងកិច្ចគាំពារនិងអភិរក្សបុរាណដ្ឋានផ្សេងទៀតក្នុងខេត្តសៀមរាបជាដើម។

ពិព័រណ៍ដែលមានរយៈពេល៣ថ្ងៃគឺ(ពីថ្ងៃទី១៤ ដល់១៦ ខែធ្នូឆ្នាំ២០២២)នេះគឺបានបើកចំហទទួលឱ្យសិស្សនិស្សិត អ្នកស្រាវជ្រាវ ភ្ញៀវទេសចរជាតិ-អន្តរជាតិ ដែលមានបំណងស្វែងយល់អំពីកិច្ចការអភិរក្ស និងកិច្ចការរៀបចំតំបន់រមណីយដ្ឋានអង្គររបស់អាជ្ញាធរជាតិអប្សរា អាចចូលទស្សនាបានដោយសេរី៕

គណៈកម្មាធិការសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ បើកកិច្ចប្រជុំពេញអង្គ លើកទី២៩ នៅខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២

គណៈកម្មាធិការអន្តរជាតិ ដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា (អាយស៊ីស៊ី-អង្គរ) និងសំបូរព្រៃគុក បានបើកកិច្ចប្រជុំពេញអង្គលើកទី២៩ នៅព្រឹកថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ នៅខេត្តសៀមរាប ក្រោមអធិបតីភាពរបស់**លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ព្រមទាំងសហប្រធាននៃកិច្ចប្រជុំ **ឯកឧត្តម MIKAMI Masahiro** ឯកអគ្គរាជទូតជប៉ុន និង **ឯកឧត្តម Jacques PELLET** ឯកអគ្គរដ្ឋទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា។

កិច្ចប្រជុំពេញអង្គលើកទី២៩នៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ នាពេលនេះនឹងពិនិត្យ ពិភាក្សាទៅលើរបាយការណ៍សកម្មភាពនានារបស់អាជ្ញាធរជាតិអប្សរា និងអាជ្ញាធរជាតិសំបូរព្រៃគុក ការអភិរក្សជួសជុល ការស្រាវជ្រាវបុរាណវិទ្យា និងការបណ្តុះបណ្តាលធនធានមនុស្ស និងការងារសង្គ្រោះបន្ទាន់ទៅលើប្រាសាទ និងបុរាណដ្ឋាននានាជាដើម។ ក្នុងនោះដែរក៏មានការចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាចំនួន២៖ ១)រវាងអាជ្ញាធរជាតិអប្សរា និងសហជីពអង្គរ សង្កាត់គ្រប់គ្រងទឹកនៃជ្រលងប៊ីយ៉ែវ្រ SIAVB (បារាំង) ២) អាជ្ញាធរជាតិអប្សរា និងស្ថាប័នJASA ជប៉ុន។

បន្ថែមពីលើនេះ នារសៀលថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នឹងផ្តល់កិត្តិយសដ៏ឧត្តុងឧត្តមអញ្ជើញចូលរួមជាអធិបតីក្នុងការបំពាក់គ្រឿងឥស្សរិយស ជូនដល់អ្នកជំនាញជាតិនិងអន្តរជាតិដែលបានចូលរួមចំណែកក្នុងកិច្ចអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គររយៈពេល៣០ឆ្នាំមកនេះ៕

អាជ្ញាធរជាតិអប្សរា ធ្វើពិធីបួងសួងលើប្រាសាទភ្នំបាខែង

ផ្សាយនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២

ព្រឹកថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ អាជ្ញាធរជាតិអប្សរាសហការជាមួយវិស័យឯកជន បានរៀបចំពិធីបួងសួងលើប្រាសាទភ្នំបាខែង តាមទំនៀមបែបពុទ្ធសាសនា និងព្រហ្មញ្ញសាសនា។ អញ្ជើញចូលរួមនាពេលនោះមាន**ឯកឧត្តម ឃិត ចាន់ដារដ្ឋ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា **លោកជំទាវឧកញ៉ាមហាឧបាសិកាកិត្តិបណ្ឌិត សៀង ចាន់ហេង** អគ្គនាយិកាក្រុមហ៊ុន ហេងអភិវឌ្ឍន៍ព្រះសង្ឃ យាយជី តាជី និងមន្ត្រីអ្នកមុខ អ្នកការជាច្រើនរូបទៀត។

ពិធីបួងសួងនេះ រៀបចំឡើងក្នុងគោលបំណងរំលឹកគុណ និងឧទ្ទិសកុសលដល់អតីតព្រះមហាក្សត្រគ្រប់ព្រះអង្គ បុព្វការីជន ដែលបានកសាង និងថែរក្សាប្រាសាទបុរាណទាំងអស់នៅក្នុងរមណីយដ្ឋានអង្គរទុកឱ្យកូនខ្មែរជំនាន់ក្រោយ ព្រមទាំងសុំសេចក្តីសុខ សន្តិភាព ជូនប្រជាពលរដ្ឋ និងជាតិមាតុភូមិកម្ពុជាទាំងមូល៕

អាជ្ញាធរជាតិអប្សរាចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាចំនួន២ ជាមួយបារាំង និងជប៉ុន

ផ្សាយនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២

កិច្ចប្រជុំពេញអង្គលើកទី២៩របស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរនិងសំបូរព្រៃគុក បានធ្វើពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាចំនួន២ ក្នុងន័យពង្រឹងកិច្ចអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរស្របតាមផែនការ និងសកម្មភាពដែលបានកំណត់ គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុកបានធ្វើជាសាក្សីនៃការចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាទាំង២ ដែលមានដូចជា៖

១- គម្រោងអភិរក្ស និងជួសជុលប្រាសាទបាយ័ន ជាមូលនិធិផ្តល់ដោយរាជរដ្ឋាភិបាលជប៉ុនតាមរយៈអង្គការយូណេស្កូ មានការអញ្ជើញចុះហត្ថលេខាជាពីរផ្នែកដោយ៖

- **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនិងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា និង **ឯកឧត្តម** MIKAMI Masahiro ស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា

- **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និង លោក Sardar Umar ALAM តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា

២- គម្រោងប្រព័ន្ធជំនួយស្វ័យប្រវត្តិក្នុងការគ្រប់គ្រងទឹកក្នុងតំបន់សៀមរាប-អង្គរ (SDGERA) មានការអញ្ជើញចុះហត្ថលេខាដោយ៖

- **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និង លោក Francisque Vigouroux ប្រធានសហជីពអន្តរសង្កាត់គ្រប់គ្រងទឹកនៃជ្រលងប៊ីយ៉ែវ SIAVB (បារាំង)៕

ពលរដ្ឋជាច្រើនបង្ហាញអារម្មណ៍រីករាយ ពេលបានទស្សនាការរៀបចំព្រឹត្តិការណ៍រំលឹកគុណអង្គរ

ផ្សាយនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២

ព្រឹត្តិការណ៍រំលឹកគុណអង្គរ រយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី១៤ ដល់ទី១៦ ខែធ្នូ ឆ្នាំ២០២២បានប្រព្រឹត្តទៅយ៉ាងឱឡារិកអធិកអធម។

ក្រៅតែពីការរៀបចំ ឱ្យមានការសម្តែងសិល្បៈអរូបី បង្ហាញក្បាច់គុនល្បុកតោ្គ អាយ៉ៃឆ្លើយឆ្លង សិល្បៈល្ខោនស្រមោលស្បែកធំ និងរបាំជាច្រើន មកអាជ្ញាធរជាតិអប្សរា ក៏បានរៀបចំស្តង់ពិព័រណ៍ សមិទ្ធផលការងារដ៏ធំធេងរយៈពេល៣០ឆ្នាំ លើការងារសំខាន់ៗមួយចំនួនក្នុងកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ដោយចិរភាពនៃរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរនៅមុខប្រាសាទអង្គរវត្ត សម្រាប់ឱ្យពលរដ្ឋ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ បានចូលរួមកំសាន្តដោយសេរី និងស្វែងយល់ដែរ។

អ្នកស្រី សូ វីឡែន ដែលបានមកទស្សនាសិល្បៈល្ខោនស្រមោលស្បែកធំ នៅអតីតអង្គភាពនគរបាលការពារបេតិកភណ្ឌ មុខបរិវេណប្រាសាទអង្គរវត្ត នារាត្រីចុងក្រោយនៃព្រឹត្តិការណ៍រំលឹកគុណអង្គរបានបង្ហាញអារម្មណ៍ថា នេះជាលើកទី១ហើយ ដែលបានមើលសិល្បៈស្រមោលស្បែកធំដោយផ្ទាល់។ គ្រួសាររបស់អ្នកស្រី បានមកមើលទាំងអស់គ្នា មានកូនៗ និងស្វាមីមកជាមួយផង។ អ្នកស្រីមានចិត្តរំភើប និងអរគុណអាជ្ញាធរជាតិអប្សរាដែលបានរៀបចំព្រឹត្តិការណ៍នេះឡើងឱ្យមហាជនបានទស្សនា។

លោក លី ហួរ ជាអ្នករស់នៅក្នុងឃុំកំពង់ក្តី ស្រុកជីក្រែង ហើយបានមកទស្សនាការសំដែងសិល្បៈដែរនោះ បង្ហាញអារម្មណ៍ថាសិល្បៈស្រមោលស្បែកធំ ពិតជាអស្ចារ្យ។ ការបានមើលផ្ទាល់ លោកចាប់អារម្មណ៍ខ្លាំងជាងគេ គឺភ្នក់ភ្លើងដុត ឆេះសន្ធោរសន្ធៅហាក់ដូចជាស្ថិតនៅក្នុងសម័យបុរាណកាល។ ព្រឹត្តិការណ៍រំលឹកគុណអង្គរ មានសារៈសំខាន់ជាច្រើន ពីព្រោះ អង្គរវត្តជាសម្បត្តិមហាសាលរបស់កម្ពុជា ព្រមទាំងផ្សារភ្ជាប់ ការផ្សារភ្ជាប់គ្នារវាងវប្បធម៌អរូបី និងរូបបីរបស់ខ្មែរយើង ព្រោះការបង្ហាញអំពីវប្បធម៌ជាច្រើន អាចនឹងធ្វើឱ្យកូនខ្មែរបានឃើញ បានស្គាល់ចងចាំ ព្រមទាំងចាប់ចិត្តស្រឡាញ់ ហើយបណ្តុះគំនិតនាំគ្នាថែរក្សានិងអភិរក្សបន្តវេន ឱ្យបានគង់វង្សជាយូរអង្វែងតទៅទៀត៕

ប្រាសាទបន្ទាយសំរ៉ែ ទីសក្ការៈបូជា សាងសង់នៅពាក់កណ្តាលសតវត្សរ៍ទី១២ ក្នុងរចនាប័ទ្មអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២២



ប្រាសាទសួរព្រ័ត ឬខ្លះហៅថាប្រាសាទនាង១២ ជាសំណង់ថ្មបាយក្រៀម សាងសង់នៅចុងសតវត្សរ៍ទី១២ ក្នុងក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២២

លិខិតជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៣

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ: ៨៩៣/២២ រប.លឧ៣

សារលិខិតជូនពរ

ជូនចំពោះ
ឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំ
មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា
ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៣

នៅក្នុងឱកាសដ៏នក្ខត្តឫក្សប្រពៃថ្លៃថ្លា ពោពេញដោយសុខសន្តិភាព បរិយាកាសសប្បាយរីករាយ និងឆ្លៀតក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល ដែលនឹងឈានចូលមកដល់នៅថ្ងៃអាទិត្យ ១០កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០១ ខែមករា គ.ស.២០២៣ នាពេលខាងមុខនេះ ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរអស់ ពីដួងចិត្តចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ចូលរួមចំណែកបំពេញភារកិច្ចជូនជាតិ ក្នុងបុព្វហេតុការពារ អភិរក្ស និងអភិវឌ្ឍតំបន់រមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោកឱ្យទទួលបានលទ្ធផលជាផ្លែផ្កាដ៏ល្អប្រសើរ។

ក្នុងឱកាសដ៏មហាប្រពៃថ្លៃថ្លានេះ ខ្ញុំសូមប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខគ្រប់ប្រការ និងសូមទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក តាមជួយអភិបាលប្រោះព្រំសព្វសាធុការពរជ័យគ្រប់ប្រការជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា សូមសមប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ៕

ថ្ងៃព្រហស្បតិ៍ ៧កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សៀមរាប ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០២២

អគ្គនាយក

ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

សារលិខិតជូនពរ

ឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំ
មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា
ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល
ដែលនឹងឈានមកដល់នៅថ្ងៃអាទិត្យ ១០កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០១ ខែមករា គ.ស.២០២៣

ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរអស់ពីដួងចិត្តចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការចូលរួមចំណែកបំពេញភារកិច្ចជូនជាតិ ក្នុងបុព្វហេតុការពារ អភិរក្ស និងអភិវឌ្ឍតំបន់រមណីយដ្ឋានអង្គរបេតិកភណ្ឌពិភពលោក ឱ្យទទួលបានលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈ ។

សូមឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា បានសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមជូនពរពី
ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា

លិខិតជូនពរ លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៣

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ១៧៤/២២ រជ.លអ៣

សារលិខិតជូនពរ

សូមគោរពជូន
លោកជំទាវបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកលដែលនឹងឈានមកដល់នៅថ្ងៃអាទិត្យ ១០កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០១ ខែមករា គ.ស.២០២៣ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំនៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ ខ្ញុំបាទសូមគោរពជូនពរបវរមហាប្រសើរជូនចំពោះ **លោកជំទាវ បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ សូមមានសុខភាពល្អបរិបូណ៌ កម្លាំងពលំមាំមួន ប្រាជ្ញាឈ្លាសវៃ ជន្មាយុយឺនយូរ ដើម្បីបន្តរួមចំណែកជាមួយរាជរដ្ឋាភិបាលដឹកនាំប្រទេសកម្ពុជា ជាពិសេសក្នុងវិស័យវប្បធម៌ឈានឆ្ពោះទៅរកសុខសន្តិភាព និងការអភិវឌ្ឍរីកចម្រើនរុងរឿងជានិរន្តរ៍។

យើងខ្ញុំទាំងអស់គ្នា សូមគោរពកោតសរសើរ និងចងចាំជានិច្ចចំពោះការដឹកនាំរបស់ **លោកជំទាវ បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ដែលបានយកអស់កម្លាំងកាយចិត្ត មិនខ្លាចនឿយហត់ ប្រកបដោយភាពឈ្លាសវៃ ធ្វើឱ្យវិស័យវប្បធម៌ជាតិយើងបានរីកចម្រើនថ្កុំថ្កើងជាលំដាប់លើឆាកអន្តរជាតិ។

ជាថ្មីម្តងទៀតឆ្លៀតក្នុងឱកាសដ៏វិសេសថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមគោរពជូនពរ **លោកជំទាវ បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** សូមមានសុខភាពល្អបរិបូណ៌ កម្លាំងពលំមាំមួន ប្រាជ្ញាភ្លឺថ្លា ជន្មាយុយឺនយូរ ឈ្នះអស់មារសត្រូវគ្រប់ទិសទី និងទទួលបានជោគជ័យថ្មីៗបន្ថែមទៀត ក្នុងបុព្វហេតុជាតិ មាតុភូមិ ប្រជាពលរដ្ឋ ជាពិសេសវិស័យវប្បធម៌ប្រកបដោយការអភិវឌ្ឍ និងរីកចម្រើនជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **លោកជំទាវបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** ព្រមទាំងក្រុមគ្រួសារ ជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន និងសុភមង្គល ព្រមទាំងសូមបានសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សៀមរាប ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០២២
អគ្គនាយក
ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារមណ្ឌលអង្គរ និងរៀបចំដែនដីតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province



សារលិខិតជូនពរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៣

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខៈ ៤៩២/ ២២ /ជប.សជ៣

សារលិខិតជូនពរ

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងឱកាសដ៏សែនមហានក្ខត្តឫក្សថ្លៃថ្លានៃថ្ងៃចូលឆ្នាំថ្មី ឆ្នាំសកល ដែលនឹងឈានមកដល់នៅថ្ងៃអាទិត្យ ១០កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០១ ខែមករា គ.ស.២០២៣ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំនៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ ខ្ញុំបាទសូមសម្តែងនូវមនោសញ្ចេតនារីករាយឥតឧបមា និងសេចក្តីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត ព្រមទាំងសូមគោរពជូនពរ បវរមហាប្រសើរជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ សូមមានជន្មាយុយឺនយូរ សុខមាលភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា ដើម្បីដឹកនាំរាជរដ្ឋាភិបាល និងប្រទេសជាតិទទួលបានជោគជ័យដ៏ត្រចះត្រចង់ថ្មីៗបន្ថែមទៀត ជាពិសេសវឌ្ឍនភាព និងកិត្យានុភាពល្បីរន្ទឺលើឆាកអន្តរជាតិ។

យើងខ្ញុំទាំងអស់គ្នា សូមគោរពកោតសរសើរយ៉ាងស្មោះអស់ពីចិត្តចំពោះគំរូវីរភាពដ៏អង់អាចក្លាហាន ការលះបង់ និងពលិកម្មគ្រប់បែបយ៉ាង យកអស់កម្លាំងកាយចិត្តដឹកនាំនាវាកម្ពុជាប្រកបដោយគតិបណ្ឌិត និងដោយពុំចេះនឿយហត់ក្នុងការបំពេញនូវបេសកកម្មជាប្រវត្តិសាស្ត្រ ដើម្បីជាតិមាតុភូមិ និងប្រជាជន ជាពិសេសការផ្សះផ្សាបង្រួបបង្រួមជាតិ នាំមកនូវឯកភាពជាតិ ស្ថិរភាពនយោបាយ និងការអភិវឌ្ឍលើគ្រប់វិស័យ។

ជាថ្មីម្តងទៀតតាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំនៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ ខ្ញុំបាទសូមសម្តែងនូវកតញ្ញុតាធម៌ សូមលំឱនកាយបួងសួង ដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតារក្សាព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សា អភិបាលប្រោះព្រំសព្វសាធុការពរ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ព្រមទាំងក្រុមគ្រួសារ សូមបានប្រកប ដោយពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សៀមរាប ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០២២

អគ្គនាយក

ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារមរតកវប្បធម៌ និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

សារលិខិតថ្វាយព្រះពរ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៣

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ៖ ៨៩១/រប.សជា/២២

សារលិខិតថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសដ៏នក្ខត្តឫក្សថ្លៃថ្លានៃឱកាសចូលឆ្នាំថ្មី ឆ្នាំសកលដែលនឹងឈានមកដល់នៅថ្ងៃអាទិត្យ ១០កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០១ ខែមករា គ.ស.២០២៣ខាងមុខនេះ ទូលព្រះបង្គំ តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងផ្ទៃនៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមទូលព្រះបង្គំ ខ្ញុំសូមព្រះបរមរាជានុញ្ញាតលំឱនកាយវាចាចិត្ត សម្តែងថ្វាយនូវកតញ្ញុតាកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះមហាករុណាទិគុណ និងព្រះព្រហ្មវិហារធម៌របស់**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ក្នុងព្រះបរមនាមជាអង្គព្រះមហាក្សត្រ ប្រកបដោយទសពិធរាជធម៌ និងព្រះរាជតម្រិះគតិបណ្ឌិតដ៏ឈ្លាសវៃ ដែលព្រះអង្គតែងតែយកព្រះទ័យទុកដាក់អស់ពីកម្លាំងព្រះកាយពល និងព្រះបញ្ញាញាណបំពេញព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តម បម្រើមាតុភូមិ និងប្រជានុរាស្ត្រជាទីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់ព្រះអង្គ នៅគ្រប់កាលៈទេសៈ។ ទន្ទឹមនឹងនេះទូលព្រះបង្គំ សូមក្រាបបង្គំអភិវន្ទសម្តែងថ្វាយ ព្រះសព្ទសាធុការពរជ័យ បវរសួស្តី សិរីវិឡូនា វិបុលសុខ មហាប្រសើរគ្រប់យ៉ាង ថ្វាយចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចម៉ែ** សូមព្រះអង្គទាំងទ្វេទ្រង់ប្រកបដោយព្រះកាយពលរឹងមាំខ្លាំងក្លា ព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះបញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ ព្រះជន្មាយុ យឺនយូរជាងរយព្រះវស្សា ចាកផុតពីព្រះរោគាព្យាធិនានា ដើម្បីព្រះអង្គទ្រង់គង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ ជាម្លប់ត្រជាក់ត្រជុំ សម្បូរសប្បាយ ថ្កុំថ្កើងរុងរឿងរបស់ប្រជានុរាស្ត្ររបស់ព្រះអង្គ និងមាតុភូមិអង្គជាទីស្នេហា។

ជាថ្មីម្តងទៀត ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមអភិវន្ទលើកហត្ថប្រណម្យបួងសួងដល់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ បុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសឫទ្ធិបារមីនៃដួងព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ សូមព្រះអង្គតាមជួយបីបាច់ថែរក្សា អភិបាលប្រោះព្រំ ព្រះសព្ទសាធុការពរជ័យគ្រប់ប្រការ ថ្វាយចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចម៉ែ** សូមព្រះអង្គទាំងទ្វេទ្រង់ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ប្រជានុរាស្ត្រខ្មែរ ជានិច្ចនិរន្តរ៍។

សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តា ទទួលនូវគារវកិច្ចកក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាប្រោស។

ថ្ងៃព្រហស្បតិ៍ ៧កើតខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សូមក្រាបបង្គំទូលថ្វាយ... ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០២២
អគ្គនាយកអាជ្ញាធរជាតិអប្សរា
ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារមរតកវប្បធម៌ និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

ប្រាសាទភ្នំបាខែង កសាងនៅចុងសតវត្សរ៍ទី៩ ជាគោលដៅទស្សនាថ្ងៃលិចដ៏ទាក់ទាញនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

ថ្ងៃចុងក្រោយនៃឆ្នាំ២០២២ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនាប្រាសាទអង្គរវត្តយ៉ាងច្រើនកុះករ

ផ្សាយនៅថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០២២

នៅព្រឹកថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលជាថ្ងៃចុងក្រោយនៃឆ្នាំចាស់ ត្រៀមផ្លាស់ចូលឆ្នាំ២០២៣ មានភ្ញៀវទេសចរជាតិ និងអន្តរជាតិចម្រុះជាតិសាសន៍បានចូលមកទស្សនាប្រាសាទអង្គរវត្តជាច្រើនពាន់នាក់។ ការមកទស្សនាកម្សាន្តរមណីយដ្ឋានអង្គរ សូមភ្ញៀវទេសចរជាតិ និងអន្តរជាតិប្រកបដោយសុខសុវត្ថិភាពក្នុងការដំណើរ គោរពក្រមប្រតិបត្តិអង្គរ រក្សាសណ្តាប់ធ្នាប់ល្អ មានអធ្យាស្រ័យគ្នាទៅវិញទៅមក កុំធ្វេសប្រហែសទ្រព្យសម្បត្តិដែលមានតម្លៃ និងប្រកាន់ខ្ជាប់នូវឥរិយាបថចូលរួមថែរក្សាបរិស្ថានលើកតម្លៃរមណីយដ្ឋានអង្គរទាំងអស់គ្នា៕

កិច្ចការពារបេតិកភណ្ឌវប្បធម៌ជាភារកិច្ច
របស់កូនខ្មែរគ្រប់ៗរូប

ទីស្នាក់ការអាជ្ញាធរជាតិអប្សរា

មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

មជ្ឈមណ្ឌលសេវាកម្មត្រូវបានបង្កើតឡើងដើម្បីកែលម្អការផ្តល់សេវាសាធារណៈតាមយន្តការប្រកចេញ-ចូលតែមួយដោយគ្មានធ្វើប្រតិភូកម្មអំណាចក្នុងគោលដៅបម្រើប្រជាជនឱ្យបានប្រសើរជាងមុនតាមរយៈការប្រមូលផ្តុំសេវាកម្មរដ្ឋបាលឱ្យនៅកន្លែងតែមួយ និងកំណត់យ៉ាងច្បាស់លាស់នូវគុណភាព នីតិវិធី ពេលវេលាប្រគល់ឯកសារ និងថ្លៃសេវា។

ទីតាំងមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

១- ស្នាក់ការកណ្តាលអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគងខេត្តសៀមរាប
២- ភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប (តាមបណ្តោយផ្លូវហ្សាលដីហ្គោលឆ្ពោះទៅប្រាសាទអង្គរវត្ត)
៣- ប្រកចេញ-ចូលតែមួយរបស់រដ្ឋបាលក្រុងសៀមរាប
៤- ប្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកពួក
៥- ប្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកអង្គរធំ
៦- ប្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកបន្ទាយស្រី
៧- ប្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកប្រាសាទបាគង
៨- និងតាមរយៈក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំក្រុង-ស្រុកទាំង៥ (ចំពោះការស្នើសុំជួសជុលតូចតាច)

លេខទំនាក់ទំនង

សារអេឡិចត្រូនិច
sca_apsara@yahoo.com
លេខទូរស័ព្ទ
+៨៥៥ ៦៣ ៧៦ ៥៥ ៧៧

ម៉ោងបំពេញការងារ

ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ
ពេលព្រឹក ៖ ម៉ោង ៨:០០ព្រឹក - ម៉ោង ១២:០០ថ្ងៃត្រង់
ពេលរសៀល ៖ ម៉ោង ១៣:០០រសៀល - ម៉ោង ១៦:០០រសៀល

ផលិតដោយនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ
ឆ្នាំ២០២៣